# ព្រះសមណគោតម

មហាសាស្ដាចារ្យនៃមនុស្សនិងទេវតា



ឌឹង ផាន់សុផុន

ភាគទី ១

ពិនិត្យនិងកែសំរួលដោយ

ព្រះមហា ហុកសាវណ្ណ និងបណ្ឌិត គុលផេង



ឌឹង ផាន់សុផុន

សៀវភៅ "ព្រះសមណគោតម" ទាំង៣ភាគនេះបញ្ជាក់ដូចៈ

- អរិយមគ្គទេសក៍នៃមនុស្សនិងទេវតា។
- ធម្មាធិបតេយ្យនិយម។
- ឱសថទិព្វសំរាប់ព្យាបាលមនុស្សពុលនិងវត្ថុលោកិយ។
- ឱសថទិព្វសំរាប់ព្យាបាលជម្ងឺផ្លូវចិត្ត។
- ធម៌ប្រោសមនុស្សមានចិត្តលោភៈ ទោសៈ និងមោហៈ។
- សីលធម៌សំរាប់អប់រំខ្លួន គ្រួសារ និង សង្គម។
- ធម៌នាំអោយចំរើនខ្លួន : សីល សមាធិ និងបញ្ញា។
- ធម៌នាំអោយកើតព្រហ្មវិហារធម៌គឺ : សេចក្ដីមេត្តា ករុណា មុទិតា និង ឧបេក្ខា។

**រក្សាសិទ្ធិគ្រប់យ៉ាង**

ALL RIGHT RESERVED



**បោះពុម្ពលើកទី១**

**ថ្ងៃចន្ទ ទី៦ វិច្ឆិកា ១៩៩៥ ចំនួន៣០០០ក្បាល**

FRIST EDITION

ON NOVENBER 6, 1995 3.000 COPIES

**បោះពុម្ពនៅសហរដ្ឋអាមេរិក**

PRINTED IN THE UNITED STATES OF AMERICA


# មាតិការឿង

ជំពូក ... ទំព័រ


០១. ព្រះពោធិសត្វចាប់បដិសន្ធិ ........ ០៥

០២. ព្រះសិទ្ធត្ថកុមារ ........ ០៨

០៣. រង្វាន់ជំរីស ........ ១៩

០៤. ខ្សែព្រះសុវង ........ ២២

០៥. គន្លងនៃមេត្តាធម៌ ........ ២៤

០៦. រាហុលប្រសូត ........ ៣១

០៧. សេះកណ្ឋកៈ ........ ៣៣

០៨. ព្រះសិទ្ធត្ថយាងចេញសាងព្រះផ្នួស ........ ៣៩

០៩. ព្រះសិទ្ធត្ថធ្វើទុក្ករកិរិយា ........ ៤៧

១០. ព្រះពោធិសត្វបានត្រាស់ដឹង ........ ៥៤

១១. ព្រះពុទ្ធសោយវិមុត្តិសុខ៧សប្តាហ៍ ........ ៧៤

១២. ព្រះពុទ្ធប្រោសបញ្ចវគ្គីយភិក្ខុ ........ ៨៤

១៣. យសកុលបុត្តបព្វជ្ជា ........ ៩៥

១៤. ព្រះត្រៃសរណគមន៍ ........ ១០៦

១៥. មាណព៣០រូបសាងបព្វជ្ជា ........ ១១៣

១៦. ឧរវេលកស្សបៈបព្វជ្ជា ........ ១១៦

១៧. ធម៌ទាំងអស់ជារបស់ក្តៅ ........ ១២៦

១៨. ព្រះពុទ្ធប្រោសព្រះបាទពិម្ពិសារ ........ ១៣៦

១៩. អគ្គសាវកបព្វជ្ជា ........ ១៤២

# អារម្ភកថា

ចំពោះលោកអ្នកអានជាទីមេត្រី!

ជាអភ័ព្វណាស់ ដែលពួកទមិឡអន្យតិរ្ថិយបានរំលាយជាតិបំបាត់សាសនា អោយវិនាសសាបសូន្យ ដែលប្រៀបបានទៅនឹងសត្វកង្កែប ដែលរបស់នៅក្នុងស្រះមានផ្ការឈូកដ៏ក្រអូបឈ្ងុយឈ្ងប់ ហើយមិនបានដឹងក្លិន មិនបានក្រេបជញ្ជក់ទឹកដមនៃផ្កាឈូនោះ បែរជានាំគ្នាប្រមាទមើលងាយនឹងកាច់បំផ្លាញចោល ហើយទទួលយកលាមកថាជាផ្កាទៅវិញ។

ជាការពិបាកណាស់ ដែលយើងចង់រក្សានូវអ្វីដែលយើងមាន ដូចជា៖ សាសនា សិល្បៈ ទំនៀមទំលាប់ វប្បធម៌ជាដើម ប៉ុន្តែជាការងាយបំផុតបើយើងបោះបង់វាចោល។

ខ្មែរយើងនៅមានវាសនាគោរពបូជាព្រះពុទ្ធសាសនា យ៉ាងហោចណាស់ក៏ ២៥០០ ឆ្នាំតទៅមុខទៀតដែរ និងពុទ្ធវាចាស់រាំងក្នុងសៀវភៅ "ព្រះសមណគោតម" ទាំង៣ភាគ នេះបង្ហាញអោយឃើញនូវសភាពពិតនៃជីវិតនិងចិត្តរបស់មនុស្សលោក។ ដូច្នេះ យើងគួរតែនាំគ្នាភ្ញាក់រលឹក និងបដិបត្តិធម៌វិន័យអោយបានត្រឹមត្រូវសារឡើងវិញ។

ខ្ញុំព្រះករុណា ខ្ញុំបានបានចងក្រងសៀវភៅ "ព្រះសមណគោតម" នេះជា៣ភាគគឺ៖

*ភាគទី១ ពីជំពូកទី១ (ព្រះពោធិសត្វចាប់បតិសន្ធិ) ដល់ទី១៩ (អគ្គសាវកបព្វជ្ជា)។

*ភាគទី២ ពីជំពូកទី២០ (វត្តវេឡុវ័ននៃព្រះបាទពិម្ពិសារ) ដល់ទី៤៨ (រឿងនាងបដាចារ)។

*ភាគទី៣ ពីជំពូកទី ៤៩(ទុតិយាសាវិកាឧប្បលវណ្ណា)ដល់ទី៨០(លិទ្ធិព្រះពុទ្ធសាសនា)។

ដើម្បីអោយបានយល់ច្បាស់ ក្នុងការអានសៀវភៅ "ព្រះសមណគោតម" នេះសូមមេត្តាអាននូវ៖ សេចក្តីយោង ព្រះញាតិវង្សានុវង្សនៃព្រះពុទ្ធ និងប្រវត្តិសាស្រ្តភូមិសាស្រ្តនៃប្រទេសឥណ្ឌានិងនេប៉ាល់ នៅផ្នែកខាងចុងនៃសៀវភៅនីមួយៗ។

សូមព្រះពុទ្ធសាសនាប្រតិស្ថានក្នុងដូងចិត្តខ្មែរនិងវប្បធម៌ខ្មែរជាយូរអង្វែង ដើម្បីអោយខ្មែរគ្រប់រូបនិងគ្រប់ជំនាន់មានសីលធម៌សំរាប់អប់រំខ្លួន គ្រួសារ និងសង្គមជាតិ។

ធ្វើនៅក្រុងសាន់តាអាណា សហរដ្ឋអាមេរិក ថ្ងៃចន្ទទី ៦ វិច្ឆិកា ព.ស ២៥៣៨។

គ.ស 1995

ឆឹង ផាន់សុផុន



# កថាមុខ

នមត្ថុ រតនត្តយស្ស

សូមនមស្ការថ្វាយបង្គំដោយគោរពចំពោះព្រះរតនត្រ័យ

**សម្ពុទ្ធាទ្យានុភាវេន សោត្ថិ វោ ហោតុ សព្វទា**

អានុភាពពុទ្ធរ័ត្នកំចាត់ទុក្ខ ឲ្យកើតសុខសិរិសក្តិមានលក្ខដ្ឋាន
អានុភាពធម្មរ័ត្នកំចាត់បាន នូវសេចក្តីរំខានក្សាន្តចាកភ័យ
អានុភាពសង្ឃរ័ត្នបំបាត់រោគ អស់សោកវិយោគទុក្ខចង្រៃ
អានុភាគត្រៃរ័ត្នវិសេសថ្លៃ ឲ្យសុខសួស្តីសព្វៗកាល។

(ស្រង់ពីគោលពុទ្ធសាសន៍ រៀបរៀងដោយ ព្រះឧត្តមវិជ្ជា ទូក ទឹម)

ជកិត្តិយសមួយដ៏ប្រពៃណាស់ ដែលខ្ញុំព្រះករុណា ខ្ញុំបាទមានវាសនាជាអ្នកបានអានទីមួយ ជាមួយព្រះមហាភិក្ខុ ហុក សាវណ្ណ នូវសៀវភៅ "ព្រះសមណគោតម" ដែលនិពន្ធដោយលោក ឆឹង ផាន់សុផុន។ ក្នុងការរចនានិពន្ធរឿងព្រះសមណគោរមនេះ លោក ឆឹង ផាន់សុផុន បានធ្វើការសិក្សាស្រាវជ្រាវដ៏ហ្មត់ចត់ តាមប្រភពបីដ៏សំខាន់ៗ។ ប្រភពទីមួយគឺ "ពុទ្ធប្រវត្តិ" តាមការបកស្រាយនៃព្រះត្រៃបិដក និងការសិក្សាផ្នែកហីនយាន។ ប្រភពទីពីរគឺ "ពុទ្ធប្រវត្តិ" តាមការសិក្សាផ្នែកមហាយាន។ ប្រភពទីបីគឺ "ពុទ្ធប្រវត្តិ" តាមការសិក្សាផ្នែកព្រះពុទ្ធសាសនាដោយអ្នកប្រាជ្ញខាងបច្ឆិមប្រទេស។ លោកឆឹង ផាន់សុផុនបានយកប្រភពនីមួយៗមកធ្វើការសិក្សានិងវិភាគ ហើយរចនាបញ្ចូលគ្នា ដើម្បីបង្ហាញនូវពុទ្ធប្រវត្តិដ៏ជាក់ស្តែងផង នូវមេធម៌សំខាន់ៗរបស់ព្រះសម្មាសម្ពុទ្ធមហាសាស្តាចារ្យនៃយើងផង។

ក្នុងរឿងព្រះសមណគោតមនេះ អ្នកនិពន្ធពុំបានយកអច្ឆិរិយភាព (ភាពអស្ចារ្យ) របស់ព្រះអង្គមកអធិប្បាយវែកញែកឡើយ។ ផ្ទុយទៅវិញអ្នកនិពន្ធយកអរិយបញ្ញា និង សតិដ៏ខ្លាំងក្លារបស់ព្រះអង្គមកបកស្រាយធ្វើជាខ្សែប្រព័ន្ធនៃរឿង ក៏ប៉ុន្តែអ្នកនិពន្ធបានទុកចំណុចខ្លះជូនអ្នកអានសម្រាប់យកមកធ្វើការត្រិះរិះពិចារណា និង វិនិច្ឆ័យដោយខ្លួនឯង។

ក្នុងការជួយកែសម្រួលអត្ថបទនៃសៀវភៅនេះ ខ្ញុំមានសំណាងបានពិគ្រោះ ជាមួយព្រះមហាភិក្ខុ ហុក សាវណ្ណ នូវមាតិកាធម៌សំខាន់ៗខ្លះ ដែលនាំឲ្យខ្ញុំព្រះករុណា ខ្ញុំបាទបានយល់ និងបានក្រេបអត្ថរសនៃព្រះពុទ្ធសាសនា ជាច្រើនថែមទៀត។ សៀវភៅនេះអាចចាត់

ទុកជាក្បួនខ្នាតផ្នែកព្រះពុទ្ធសាសនាមួយដ៏សំខាន់ សំរាប់ធ្វើការសិក្សា និងអនុវត្តន៍ ដើម្បីអប់រំកាយ វាចា ចិត្ត ឲ្យបានប្រសើរចាំជីវិត។

ទោះបីជាមានការខ្វះខាត ឬឆ្គាំឆ្គងខ្លះ ខាងផ្នែកអក្ខរាវិរុទ្ធក្តី ផ្នែកឃ្លាប្រយោគក្តី សៀវភៅនេះជាវិភាគទានមួយដ៏ប្រសើរខ្ពង់ខ្ពស់របស់អ្នកនិពន្ធក្នុងការខំប្រឹងប្រែងរក្សាព្រះពុទ្ធសាសនាឲ្យបានគង់វង្សនៅក្នុងសង្គមខ្មែរយើងតទៅអនាគត។ នៅពេលជួយកែសម្រួលអត្ថបទនេះ ខ្ញុំព្រះករុណា ខ្ញុំបាទនឹកឃើញនូវចំណាររបស់សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោមួយប្រយោគថា៖

"ធម្មតាកាងារអ្វីទាំងអស់ក្នុងលោក តែងតែមានភ្លាំងភ្លាតខ្លះបើមិនច្រើន ក៏តិចតួចពុំខាន, នេះជាទម្លាប់នៃការងាររបស់បុថុជ្ជន, ព្រោះត្រូវជាគូគ្នានឹងខុស ប៉ុន្តែបើមានត្រូវច្រើន មានខុសតែបន្តិចបន្តួច ក៏គង់អាចប្រើការកើត គ្រាន់បើជាងគ្មានសោះទៅដែរ។"

ខ្ញុំមានការគោរព និងកោតសរសើរដោយសុទ្ធចិត្តចំពោះការប្រឹងប្រែងចងក្រងរឿងព្រះសមណគោតមនេះឡើងដោយលោក ឆឹង ផាន់សុផុន។ នេះជាការព្យាយាមមួយដ៏មុះមុតក្នុងការសាងកុសលធម៌។ ការសរសេរមួយបន្ទាត់ម្តង មួយបន្ទាត់ម្ត អាចកើតជាសៀវភៅមួយបាន។ យកផ្កាមួយទងម្តងៗ មកក្រងបន្តគ្នាក៏អាចបង្កើតជាកម្រងផ្កាដ៏ល្អប្រណិតបាន។ យ៉ាងណាមិញ ការសាងអំពើល្អ (ឬកុសលធម៌) បន្តិចម្តងៗក៏គង់ឲ្យយើងសំអាតចិត្តឲ្យបរិសុទ្ធផូផង់បាន ដូចព្រះសម្ពុទ្ធទ្រង់បានបង្ហាញយើងតាមមាគ៌ាជីវិតនៃព្រះពោធិសត្វរាប់សែនជាតិ មុននឹងព្រះអង្គបានត្រាស់។

សៀវភៅ "ព្រះសមណគោតម" ទាំងបីភាគនេះ មានសារសំខានបីយ៉ាងដូចតទៅនេះ៖

១. ចំពោះពុទ្ធសាសនិកជនទូទៅ សៀវភៅនេះ ជាគម្ពីរបង្ហាញភាពពិស្តារនៃប្រវត្តិរបស់ព្រះអគ្គមហាបុរសដ៏កំពូលនៃលោក និងធម៌ប្រចាំជីវិត។

២. ចំពោះអ្នកសិក្សាស្រាវជ្រាវផ្នែកសាសនា និងចិត្តសាស្ត្រ សៀវភៅនេះ ជាមូលដ្ឋាននៃចិត្តសាស្ត្រផង ជាគោលចារិកនៃការសិក្សាផ្លូវចិត្តរបស់មនុស្សលោកទូទៅផង។

៣. ចំពោះអ្នកដឹងនាំសង្គមជាតិ សៀវភៅនេះអាចាត់ទុកជាក្បួនមគ្គុទេសឆ្ពោះទៅរកសុភមង្គលវិបុលសុខ ដោយយកគុណធម៌ និងគតិធម៌មានព្រហ្មវិហារធម៌ និងទសពិធរាជធម៌ជាដើមជាគន្លង។



សូមអានិសង្សដែលកើតមានឡើងដោយការចងក្រងសៀវភៅ "ព្រះសមណគោតម" នេះមានដល់អ្នកនិពន្ធ ក្រុមគ្រួសារ និងញាតិមិត្រ ដែលគាំទ្រក្នុងការបោះពុម្ពសៀវភៅនេះ ព្រមទាំងលោក អ្នកអានទាំងឡាយ សូមបានជួបប្រទះនូវសុខោទ័យគ្រប់ៗជាតិលុះសម្រេចព្រះនិព្វាន។

ដោយឥទ្ធិពលនៃឧសបារមីរបស់ព្រះសម្មាសម្ពុទ្ធបរមសាស្តាចារ្យដ៏កំពូលនៃលោក សូមសេចក្តីសុខចូលមានដល់សព្វសត្វ ជាពិសេសដល់ប្រជាពលរដ្ឋខ្មែរដែលកំពុងឆ្លងកាត់ទុក្ខវេទនាដោយផលវិបាកនៃសង្គ្រាម។

ធ្វើនៅក្រុង Austin, Texas ថ្ងៃទី៣ កើតខែស្រាព

ឆ្នាំកុរសម្ពស័ក ព.ស ២៥៣៩/គ.ស ១៩៩៥

បណ្ឌិត កុល ផេង

## ជំពូកទី១

# ព្រះពោធិសត្វចាប់បដិសន្ធិ

ប្រមាណជា៨០ឆ្នាំមុនពុទ្ធសករាជឬ ៦២៣ឆ្នាំ មុនគ្រឹស្តសករាជមានព្រះពុទ្ធមួយព្រះអង្គបានកើតឡើងក្នុងលោក។ កាលនៅគ្រហស្ថមានព្រះមានថា "សិទ្ធត្ថ គោតម" (សិទ្ធត្ថ ជានាមខ្លួននិង គោតមជានាមត្រកូល)។ ក្រោយមកក៏បានក្លាយជាព្រះមួយព្រះអង្គព្រះនាមថា "ព្រះពុទ្ធ" ដែលមានមនុស្សយ៉ាងតិចក៏ ៨កោដិនាក់ក្នុងពិភពលោកគោរពបូជានិងចាត់ទុកព្រះអង្គជាព្រះមហាសាស្តាចារ្យដ៏កំពូល។ ព្រះអង្គបានកើតក្នុងត្រកូលស្តេចដែលមានព្រះវរបិតាព្រះនាម សុទ្ធោទន៍និងព្រះមាតាព្រះនាម សិរិមហាមាយា (ឬមហាមាយាទេវី) នៅក្នុងសាក្យរាជត្រកូល នាទីក្រុងកបិលពស្តុ សព្វថ្ងៃស្ថិតនៅក្នុងតំបន់មួយជាប់ ប្រទេសនេប៉ាល់ ភូមិភាគខាងជើងនៃ ប្រទេសឥណ្ឌា។

នៅថ្ងៃព្រហស្បតិ៍ ១៥កើត ពេញបូណ៌មី ខែអាសាធ ឆ្នាំរកា (មុន ព.ស ៨០ឆ្នាំនិង ១០ខែ) ជាថ្ងៃដែលព្រះអង្គមកចាប់បដិសន្ធិក្នុងផ្ទៃព្រះមាតា។ រយៈ៧ថ្ងៃមុនថ្ងៃពេញបូណ៌មីនេះ មានមហាជនជាច្រើនក្នុងទីក្រុងកបិលពស្តុ នាំគ្នាលេងមហោស្រពយ៉ាងសប្បាយរីករាយ។ ព្រះនាងសិរិមហាមាយាទ្រង់ព្រះកាយដោយគ្រឿងក្រអូបនិងលាប (សុគន្ធវិលេបនៈ) ហើយក្រសាលអស់កាលទាំង៧ថ្ងៃ។ នៅថ្ងៃពេញបូណ៌មីវេលាព្រឹក ព្រះនាងទេវីបានធ្វើបរិច្ចាកទានជាទ្រព្យអស់ចំនួន៤សែនកហាមណៈដល់ប្រជាពលរដ្ឋ។ លុះដល់ពេលរាត្រី ព្រះនាងសមាទានឧបោសថសីល រួចហើយក៏ឡើងទៅផ្ទំលើសិរីសយនា(គ្រែ) ក្នុងព្រះទែនបន្ទំ។ អស់រយៈ២០ឆ្នាំកន្លងមកហើយដែលព្រះមហាក្សត្រនិងព្រះអគ្គមហេសីពុំដែលមានរាជបុត្រមួយសោះ។ ទើបតែក្នុងទិវានេះ ព្រះនាងបានសុបិននិមិត្តឃើញថាមានចាតុម្មហារាជបួនអង្គមកលើកត្រកងព្រះនាងទាំងសិរីសយនានាំទៅកាន់ព្រៃហេមពាន្ត រួចក៏តម្កល់ទុកលើផ្ទាំងមនោសិលាដ៏ធំខាងក្រោមដើមរាំងធំមួយ។ ពេលនោះទេពធីតាទាំងឡាយរបស់ចាតុម្មហារាជទាំងបួនក៏បានអញ្ជើញព្រះនាងទេវីទៅស្រង់ទឹកនៅក្នុងស្រះអនោត្តដើម្បីជំរះព្រះកាយថ្វាយព្រះនាងនិងបានលាបនូវគ្រឿងគុន្ធវិលេបនៈទៀតផង។ នៅជិតស្រះនោះមានភ្នំមួយដែលមាន សុវណ្ណវិមាន (ប្រាសាទមាស) សង់នៅលើកំពូល។ ទេពធីតាទាំងឡាយបានយាងព្រះនាងទៅផ្ទំនៅក្នុងប្រាសាទមាសនោះដោយ



យកព្រះសិរ (ក្បាល) ទៅទិសខាងកើត។ មានសុវណ្ណគិរី (ភ្នំមាស) មួយទៀតនៅជិតទីនោះដែរដែលមាន សេតហត្ថី (ដំរីស) ស្រស់ឆើតឆាយមួយ មានភ្លុក៦ សម្បុរសក្បុសដូចជាភ្នំព្រឹលមានប្រមោយកាន់ជាប់នូវសេកបទុមជាតិ (ផ្កាឈូកក្រហម) ហោះចុះមកអំពីភ្នំមាសនោះដោយមានក្រុមអ្នកភ្លេងនិងអ្នកចម្រៀងប្រគំបទថ្វាយព្រះពរ ហែហមយ៉ាងគគ្រឹកគគ្រេងតាមកជាមួយផង។ ពេលចុះមកជិតដល់ ដំរីសនោះក៏ដើរសន្សឹមៗតម្រង់ទៅកាន់ព្រះនាងទេវីដែលកំពុងតែផ្ទំនៅក្នុងប្រាសាទមាសនោះ។ ដំរីសបានដើរប្រទក្សិណបីជុំមុននឹងដាក់ផ្កាឈូកក្រហមនោះចូលទៅក្នុងព្រះគភ៌របស់ព្រះនាង។ ដំរីសក៏ហាក់ដូចជាដើរចូលទៅក្នុងឧទរប្រទេស (គភ៌) ខាងស្តាំរបស់ព្រះនាងទេវីដែរ។ ក្នុងគ្រានោះឯង ព្រះនាងហាក់ដូចជាមានភាពសុខស្រួលក្នុងព្រះចិន្តា កើតមានសេចក្តីរីករាយយ៉ាងខ្លាំង។ ព្រះនាងមិនចាប់អារម្មណ៍ថាមានការពិបាក ភិតភ័យ ឬក៏ឈឺចុកចាប់អ្វីសោះឡើយ។ បន្ទាប់ពីនោះមក ព្រះនាងទេវីក៏តើនឡើងដោយមានព្រះហឫទ័យសោមនស្សរីករាយនៅក្នុងបរមសុខ។ ពេលយាងចុះអំពីព្រះទែនបន្ទំមក ព្រះនាងនៅតែឮសូរសម្លេងតូរ្យតន្ត្រីនៃសុបិនខ្ទរមិនដាច់សូរក្នុងព្រះសោតា។ ដោយមិនចង់សម្ងំលាក់ទុករឿងនេះទុកដល់ថ្ងៃស្អែកឡើយ ព្រះនាងបានយាងទៅបង្គំគាល់សួរព្រះបាទសុទ្ធោទន៍ជាព្រះស្វាមីនូវរឿងសុបិននិមិត្តដ៏ចម្លែកអស្ចារ្យនោះភ្លាម។ ព្រះរាជាទ្រង់កោតស្ញប់ស្ញែងនូវរឿងសុបិនដ៏ចម្លែកនេះណាស់។

លុះព្រឹកស្អែកឡើង ព្រះរាជាទ្រង់ត្រាស់បញ្ជាអោយរាជបុរសទៅអញ្ជើញអស់ពួកព្រាហ្មណ៍មកគន់គូរកាត់សប្តិនោះថាតើមានន័យយ៉ាងណាដែរ។ ពួកព្រាហ្មណ៍សោតក៏ទូលនូវទំនាយតាមប្រការដូចតទៅថា "បពិត្រព្រះសម្មតិទេព! ព្រះអង្គម្ចាស់ក្សត្រីយ៍នឹងប្រសូតបានបុត្រាមួយព្រះអង្គ ដែលនឹងក្លាយជាអ្នកដឹកនាំព្រះរាជាណាចក្រដ៏ឆ្នើមហើយព្រះរាជកុមារនឹងមានវាសនាធ្វើជាព្រះអធិរាជដែលមានឥទ្ធានុភាពខ្លាំងពូកែអាចដឹកនាំសត្វលោកគ្រប់ទិសទាំងបួនយ៉ាងល្បីល្បាញ ឬក៏នឹងក្លាយជាមហាសាស្តាចារ្យដ៏កំពូលដែលនឹងអាចដឹកនាំសព្វសត្វ ទាំងក្នុងឋានសួគ៌និងទាំងក្នុងឋានមនុស្សអោយគោរពប្រតិបត្តិតាមព្រហ្មចរិយធម៌។ បពិត្រមហារាជ! នគររបស់យើងរង់ចាំអ្នកមានបុណ្យបែប

នេះ កើតឡើងជាយូរយាណាស់មកហើយ។

ព្រះបាទសុទ្ធោទន៍ទ្រង់ញញឹមតបព្រាហ្មណ៍វិញ ដើម្បីបង្ហាញនូវការយល់ព្រម។

បន្ទាប់អំពីបានប្រឹក្សាប្តូរព្រះយោបល់ នឹងព្រះអគ្គមហេសីរួចមក ព្រះរាជាក៏ទ្រង់បញ្ជាអោយកែរើយករបស់ទ្រព្យចេញអំពីឃ្លាំង យកទៅចែកជាទានដល់ប្រជាពលរដ្ឋនៅក្នុងនគរដឹងដឹងថាព្រះមហាក្សត្រនិព្រះអគ្គមហេសីនឹងប្រសូតបានបុត្រមួយព្រះអង្គនៅក្នុងពេលអនាគតដ៏ខ្លីខាងមុខ។

ព្រះនាងសិរិមហាមាយាជាស្ត្រីប្រកបដោយគុណធម៌ដ៏ធំធេង។ ព្រះនាងមានព្រះទ័យស្រឡាញ់រាប់អានដល់មនុស្សសត្វទាំងអស់ ដោយមិនប្រកាន់ឡើយ។

---

ជំពូកទី ២

# ព្រះសិទ្ធត្ថកុមារ

តាំងអំពីថ្ងៃដែលព្រះបរមពោធិសត្វចាប់បដិសន្ធិមកទល់នឹងថ្ងៃព្រះអង្គប្រសូតគំរប់មួយទសមាសគត់ (១០ខែ) មានទេវបុត្របួនអង្គ ដែលមានព្រះហស្តកាន់ព្រះខ័នឃ្លាំចាំរក្សានិងការពារនូវសេចក្តីអន្តរាយ មិនអោយកើតមានដល់ព្រះទារកនិងព្រះវរមាតាឡើយ។

តាមទំនៀមទំលាប់ជនជាតិឥណ្ឌានាសម័យនោះ ដល់ពេលសំរាលបុត្រម្តងៗស្ត្រីឥណ្ឌាតែងតែត្រឡប់សំរាលបុត្រនៅខាងផ្ទះមាតាបិតាខ្លួនវិញ។ ចំពោះព្រះនាងសិរិមាយាក៏ដូច្នោះដែរ ពេលព្រះគភ៌បរិបូណ៌គំរប់១០ខែហើយ ព្រះនាងក៏មានប្រាថ្នាយាងទៅកាន់វេទហានគរ ដែលជាជាតិភូមិរបស់ព្រះនាង ទើបទៅក្រាបបង្គំទូលព្រះភស្តាដើម្បីសុំរាជានុញ្ញាត។ ព្រះរាជាយល់សព្វហេតុការណ៍ទើបទ្រង់អនុញ្ញាតនិងទ្រង់ត្រាស់បញ្ជាអោយរាជអាមាត្យរៀបចំក្បួនរទេះគោនិងរទេះសេះ ដើម្បីនឹងដង្ហែព្រះអគ្គមហេសីទៅកាន់ នគរវេទហៈ។

លុះដល់ថ្ងៃសុក្រ១៥កើតពេញបូណ៌មី ខែពិសាខ ឆ្នាំច (មុន ព.ស ៨០ឆ្នាំគត់) ព្រះនាងមហាមាយាទេវីចូលទៅថ្វាយបង្គំលាព្រះភស្តា ហើយក៏យាងព្រះដំណើរចេញ



ទៅកាន់ស្រុកកំណើតជាមួយអស់ពួកសេនាភីលាងដែលជាបរិពារ។ នៅក្នុងព្រះរាជដំណើរ ព្រះនាងបានឈប់សំរាកព្រះកាយនៅពាក់កណ្តាលផ្លូវក្នុងឧទ្យានមួយឈ្មោះលុម្ពិនី ដែលស្ថិតនៅចំព្រំដែននៃនគរទាំងពីរគឺ កបិលពស្តុនិង វេទហៈ(សព្វថ្ងៃហៅថារុម្មិនដេ ក្នុងខេត្តប៉ាជារិយ៉ា នៃប្រទេស នេប៉ាល់)។ ព្រៃលុម្ពិនីមានខ្យល់ត្រជាក់បក់ស្រួលណាស់ រុក្ខជាតិនិងវល្លិជាតិលូតលាស់ខៀវស្រងាត់គួរអោយគយគន់។ បុប្ផាជាតិរីកស្គុសស្គាយ និងចោលក្លិនសុគន្ធពិដោរក្រអូបសាយ។ មានម្រឹគីម្រឹគារត់ចុះឡើង និងបក្សាបក្សីតូចធំប្រចិកប្រលែងគ្នាលេងយ៉ាងអឺងកងគ្មៀវក្ងា។ ភាពដ៏សែនមនោរម្យនេះហើយ ដែលធ្វើអោយអ្នកដំណើរទាំងឡាយ ចូលឈប់សំរាកយកកម្លាំងនៅទីលុម្ពិនីនេះ មុននឹងបន្តដំណើរទៅមុខទៀត។ ព្រះនាងសិរិមហាមាយាមានព្រះហឫទ័យចង់ចូលទៅប្រពាតក្នុងព្រៃម្តុំនោះ។ ពួករាជអាមាត្យក៏យាងព្រះនាងចូលទៅ។ ពេលយាងទៅដល់ក្រោមដើមរាំងភ្នំមួយ (ឬដើមសាលព្រឹក្ស) ព្រះនាងទ្រង់ឈោងព្រះហស្តខាងស្តាំចាប់មែករាំងភ្នំនោះដើម្បីទប់អង្គប្រាណ។ ស្រីស្នំទាំងឡាយបានយល់ហេតុថាព្រះនាងនឹងសំរាលបុត្រក្នុងពេលឥឡូវនេះហើយក៏នាំគ្នាយកព្រះសន្ទិយា (រាំងនន) ទៅបិទបាំងនៅក្រោមដើមរាំងភ្នំនោះ។ ព្រះនាងនៅឈរប្រតោងមែករាំងភ្នំរហូតដល់ព្រះពោធិសត្វទ្រង់ប្រសូតចាកព្រះឧទរ ក្នុងវេលាថ្ងៃជិតត្រង់។ ព្រះទារកមានព្រះរូបឆោមល្អបរិសុទ្ធ មានសុខភាពបរិបូណ៌និងគ្រប់លក្ខណៈ ក្នុងថ្ងៃសុក្រ១៥កើតពេញបូណ៌មី ខែពិសាខ ឆ្នាំច ត្រូវនឹងថ្ងៃទី ៨ មេសា។ ព្រះទារកត្រូវបានស្រីស្នំទាំងឡាយយកទៅស្រង់វារី (ទឹក) ដើម្បីជុសលាងមន្ទិលគភ៌និងរុំដណ្តប់ដោយសំពត់សូត្រពណ៌លឿង។

តាមប្រភពមហាជនដែលបានឃើញការប្រសូតនេះផ្ទាល់ភ្នែកបាននិយាយថា៖ ពេលព្រះនាងយាងទៅដល់ក្រោមដើមរាំងភ្នំក្នុងសួនសុម្ពិនី ក៏មានព្រះទ័យចង់ឈោងចាប់មែករាំងភ្នំនោះ។ ប៉ុន្តែព្រះនាងឈោងចាប់ពុំដល់ ក៏ស្រាប់តែមែករាំងនោះទោរទន់ចុះមកក្រោមដោយឯកឯង ដើម្បីអោយព្រះនាងចាប់។ រួចមកព្រះនាងក៏ប្រឈ្មួនព្រះឧទរ (ឈឺពោះសំរាលបុត្រ)។ ព្រះពោធិសត្វទ្រង់ប្រសូតមកដោយស្រួល និងមានទឹកក្តៅទឹកត្រជាក់ហូរធ្លាក់ចុះដោយឯកឯងមកលាងមន្ទិលគភ៌។ ទ្រង់ប្រសូត្រមកភ្លាមមានពួកសុទ្ធាវាសមហាព្រហ្មទាំង៤ បានយកផ្ទាំងសំពត់ពណ៌មាស (បណ្តាញមាស) មកទទួល។

ចាតុម្មហារាជ រក្សាទិសទាំង៤បានទទួលយកពីមហាព្រហ្ម។ ពួកស្រីស្នំក៏ទទួលយកពីដៃចាតុម្មហារាជបន្តទៅទៀត។ ព្រះរាជកុមារទ្រង់សំរូតចុះចាកពីដៃស្រីស្នំរួចទ្រង់ប្រថាប់ឈរសិប់លើផែនដីដោយព្រះបាទទាំងគូ។ មហាព្រហ្មយក ស្វេតច័ត្រ(ខ្លោះ) មកបើកបាំងថ្វាយ។ សុយាមទេវរាជ យកវិជនី (ផ្លិត) មកបក់ថ្វាយ។ ទេវបុត្តមួយអង្គកាន់តែវ៧ប្រការទេវបុត្រមួយអង្គកាន់សុវណ្ណបាទុក (ស្បែកជើងមាស) និងទេវបុត្រមួយអង្គទៀតកាន់គ្រឿងប្រដាប់រាជ៥យ៉ាង(កុក្កុចភ័ណ្ឌ) គឺ មកុដ១ ព្រះខ័ន១ ស្វេតច្ឆត្រ១ សុពណ៌បាទ១ និងវាលវិជនី១។ ព្រះពោធិសត្វក៏ទ្រង់ប្រមើលមើលទៅកាន់ទិសទាំង១០គឺទិសធំ៤ទិសតូច៤ ទិសខាងក្រោមនិងទិសខាងលើ ក៏ពុំឃើញមានជនម្នាក់ស្មើនឹងព្រះអង្គឡើយ ទើបទ្រង់ប្រថាប់ឈរបែរព្រះភ័ក្រ្តទៅទិសឧត្តរនោះរួចហើយទ្រង់យាងទៅអស់៧ជំហាននិងក្នុងជំហាននីមួយៗមានផ្កាឈូកលេចចេញអំពីដីមកទ្រព្រះបាទ។ បន្ទាក់មក ព្រះពោធិសត្វក៏បន្លឺនូវព្រះអសភិវាចាថា៖

"ខ្លួនអញជា កំពូលនៃលោក ជាបុគ្គលដ៏ប្រសើរវិសេសលើសគេក្នុងលោកជាចម្បងជាងគេទាំង អស់នៅក្នុងលោក ជាតិនេះគឺជាកំណើតចុងក្រោយបំផុតរបស់អាត្មាអញ អំណើះអំពីជាតិនេះទៅ អាត្មាអញនឹងមិនកើតទៀតឡើយ"។

ក្នុងពេលប្រសូតនេះមានហេតុអស្ចារ្យផ្សេងៗក្នុងលោកនេះ ក៏បានកើតឡើង។ ដោយសារបារមីនៃព្រះរាជកុមារ ប្រថពីក៏កក្រើករំពើកខុសអំពីប្រក្រតី រុក្ខជាតិក៏មានផ្លែទុំខ្ចី បុប្ផាក៏រីកស្រស់ស្គុះស្គាយ បក្សាបក្សីក៏ស្រែកច្រៀងយ៉ាងសប្បាយអឹងកង។ មនុស្សម្នាប្រុសស្រីនិងពួកក្សត្រទាំងពីរនគរ កើតមានសេចក្តីសោមនស្សរីករាយ ក៏ព្រោះបានឃើញឆព្វណ្ណរង្សី(ពន្លឺ៦ពណ៌) នៃព្រះនាងមហាមាយាទេវីនិងព្រះរាជកុមារ[១]។ យ៉ាងខ្លាំង កាលបានទតឃើញព្រះអគ្គមហេសី និងព្រះរាជបុត្រាបានសេចក្តីសុខ។

នារាត្រីនោះ មានឥសីមួយអង្គឈ្មោះ អសិកតាបសកាឡទេវិល រស់នៅក្នុងព្រៃភ្នំជិតព្រះរាជវាំងនោះនិងត្រូវជាជីតុន(គ្រូអាចារ្យ) នៃព្រះបាទសុទ្ធោទន៍ផង បានសង្កេតឃើញមានពន្លឺរស្មីចាំងផុសឡើងព័ទ្ធជុំវិញព្រះរាជតំណាក់នៃព្រះមហាក្សត្រ។ អសិតឥសីក៏បានកាត់យល់ថាហេតុការណ៍នេះជាប្រផ្នូលមួយដ៏ពិសេសអស្ចារ្យលោកក៏និមន្តចុះអំពីលើភ្នំ

(១) ពេលរាជបរិពារទាំងឡាយដង្ហែព្រះនាងមហាមាយាទេវីនិងបុត្រា មកដល់ព្រះរាជវាំងវិញព្រះពោធិសត្វ ត្រូវស្រីស្នំនាំយកទៅងូតលាងជំរះមន្ទិលនឹងទឹកក្តៅឧណ្ហៗម្តងទៀត មុននឹងយកទៅផ្តេកជិតព្រះវរមាតា។



កាលបានជ្រាបដំណឹងនេះហើយ ព្រះបាទសុទ្ធោទន៍ស្តេចយាងមកជាបន្ទាន់ដើម្បីជួបជាមួយព្រះអគ្គមហេសី និងព្រះរាជបុត្រា។ ព្រះមហាក្សត្រទ្រង់ព្រះអំណរ

ដោយទប់ព្រះអង្គកាយនឹងឈើច្រត់ ចូលមកកាន់សំណាក់ព្រះរាជាដើម្បីសួរសុខទុក្ខ។ ពេលអសិតតាបសនិមន្តដល់ព្រះរាជាទ្រង់ធ្វើគារវៈស្វាគមន៍រួចហើយ ក៏ទ្រង់ត្រាស់បញ្ជាអោយពួកស្រីស្នំនាំព្រះពោធិសត្វមកថ្វាយអសិតតាបសដើម្បីទត។ ពេលអសិតតាបសអានពិនិត្យរូបលក្ខណៈព្រះរាជកុមារស្រាប់តែព្រះបាទទាំងគូរបស់ព្រះពោធិសត្វកញ្ច្រោលពីដៃស្រីស្នំ ទៅប្រថាប់ពីលើក្បាលអសិតតាបសដោយចៃដន្យ។ អសិតតាបសក៏ស្រវាទម្លាក់ខ្លួនក្រាបថ្វាយបង្គំព្រះរាជកុមារអស់ចំនួន៣ដង។ កាលព្រះរាជាបានទតឃើញនូវភាពដ៏អស្ចារ្យដូច្នោះកើតឡើង ព្រះអង្គក៏លុតជង្គង់ថ្វាយបង្គំបុត្ររបស់ព្រះអង្គជាលើកទី១ដូចអសិតតាបសក្នុងពេលនោះភ្លាមដែរ។

បន្ទាប់ពីបានពិនិត្យព្រះលក្ខណៈនៃព្រះពោធិសត្វសព្វគ្រប់មក អសិតតាបសក៏ព្យាករណ៍ក្នុងខ្លួនថា៖

"ព្រះរាជកុមារនេះនឹងបានត្រាស់ជាព្រះពុទ្ធ ឥតមានសង្ស័យឡើយ"។

កាលបានដឹងនូវហេតុយ៉ាងដូច្នោះហើយ អសិតតាបសក៏តាំងសើចក្អាកក្អាយមួយសន្ទុះមកក៏បែរជាយំសោកយ៉ាងខ្លាំងទៅវិញ។ ព្រះរាជាស្រឡាំងកាំង ទើបទ្រង់ត្រាស់សួរជាបន្ទាន់ថា៖

"កាឡទេវិលតាបស! តើមានរឿងអ្វីកើតឡើយឬ? តើព្រះរាជកុមារនេះឥតមានភ័ព្វសំណាងទេឬអ្វី?"

អសិតតាបសលើកដៃជូតទឹកភ្នែក គ្រវីក្បាល មុននឹងបង្គំទូលថា៖

"បពិត្រមហារាជ! ព្រះរាជកុមារនេះមិនមែនជាអ្នកនយោបាយទេ បើសិនជានៅគ្រប់គ្រងគេហដ្ឋានក៏នឹងបានជាស្តេចចក្រពត្តិ បើចេញទ្រង់ព្រះផ្នួសក៏នឹងបានជាសាស្តាក្នុងលោក។ ព្រះអង្គជាមហាបុរសនៃពន្លឺត្រាស់ដឹង ដែលយកឋានសួគ៌និងឋានមនុស្សលោកធ្វើជាលំនៅឋានរបស់ព្រះអង្គ និងយកសត្វលោកទាំងអស់ជាញាតិសន្តាន។ ការដែលអាត្មាសើចនោះ ក៏ព្រោះតែអាត្មាមានអំណរនឹងព្រះអយ្យបុត្រនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងពេលខាងមុខនេះ។ ប៉ុន្តែហេតុដែលអាត្មាយំវិញនោះ ក៏ព្រោះតែអាត្មាគិត អាណិតខ្លួនឯងថាជាមនុស្សអភ័ព្វឥតព្រេងវាសនានឹងនៅទាន់ព្រះពុទ្ធដូចគេ និងគ្មានភ័ព្វសំណាង

បានស្តាប់នូវសម្លេងព្រះអរិយសច្ចធម៌ ដែលព្រះអង្គបានរកឃើញផង។ បពិត្រមហារាជ! ព្រះអង្គ មានភ័ព្វសំណាងខ្ពស់ណាស់ដែលមានព្រះពោធិសត្វដ៏មានបុណ្យបែបនេះ កើតឡើយនៅក្នុងព្រះនរគរ។"

បន្ទាប់ពីព្យាករណ៍រួចមក កាឡទេវិលតាបសក៏លាព្រះបាទសុទ្ធោទន៍ទៅកាន់លំនៅនៃប្អូនស្រីរបស់ខ្លួន ហើយបានបង្គាប់អោយ នាឡក ជាក្មួយប្រុសថា៖

"ចូរក្មួយឯងបួស ដើម្បីរង់ចាំព្រះរាជឱរសនៃព្រះបាទសុទ្ធោទន៍ ដែលនឹងចេញបួសហើយនឹងបានត្រាស់ដឹងជាព្រះពុទ្ធពុំខាន។" (នាឡក ក៏បានលះបង់ផ្ទះសម្បែងទ្រព្យសម្បត្តិ ចេញទៅបួសតាមបណ្តាំឪពុកមា។ ចំណែកឯកាឡទេវិលតាបស ក្រោយមកក៏ធ្វើមរណកាលមុនពេលព្រះពុទ្ធទទួលការត្រាស់ដឹងមែន។)

ការទស្សន៍ទាយរបស់អសិតតាបស ធ្វើអោយព្រះរាជាមាព្រះហឫទ័យខ្វល់ខ្វាយយ៉ាងខ្លាំង ពីព្រោះព្រះអង្គមិនចង់អោយបុត្រាតែមួយរបស់ព្រះអង្គ ក្លាយជាអ្នកបួស ដូចតាបសឥសីរស់នៅក្នុងព្រៃភ្នំក្រំថ្មឡើយ។

បន្ទាប់អំពីព្រះរាជកុមារប្រសូត្របានប្រាំថ្ងៃមក ព្រះមហាក្សត្រទ្រង់ប្រារព្ធនូវពីធីថ្វាយព្រះនាមដល់ព្រះរាជឱរស ទើបទ្រង់កោះប្រជុំអស់ពួកវង្សក្សត្រ ប្រមុខមន្ត្រីនិងព្រាហ្មណ៍ទាំងឡាយនៅក្នុងព្រះរាជនិវេសន៍។ ព្រះរាជានិមន្តព្រាហ្មណ៍១០៨រូបមកទទួលចង្ហាន់ ប៉ុន្តែព្រះរាជាទុកតែព្រាហ្មណ៍៨រូប ដែលជាអ្នកចេះចាំស្ទាត់នូវគម្ពីរត្រៃវេទ ដើម្បីព្យាករណ៍និងថ្វាយព្រះនាម។ ព្រាហ្មណ៍ទាំង៨រូបនោះគឺ៖ រាមព្រាហ្មណ៍១ លក្ខណៈព្រាហ្មណ៍១ យញ្ញព្រាហ្មណ៍១ ធជព្រាហ្មណ៍១ ភោជព្រាហ្មណ៍១ សុទត្តព្រាហ្មណ៍១ សុយាមព្រាហ្មណ៍១ និង កោណ្ឌញ្ញព្រាហ្មណ៍១ ។ មានព្រាហ្មណ៍៧នាក់(ទី១ដល់ទី៧) បានលើកម្រាមដៃពីរទាយជាពីរចំណែកដូចជាអសិតតាបសដែរថា (បពិត្រព្រះសម្មតិទេព! បើព្រះរាជកុមារនៅជាឃរាវាសសោរាជរហូតទៅនឹងបានជាស្តេចចក្រពត្តិប្រកបដោយគុណធម៌ ជាធម្មរាជជាឥសូរ លើមហាទ្វីបដែលមានមហាសមុទ្រទាំងបួនជាព្រំប្រទល់។ ព្រះអង្គជាអ្នកគ្រប់គ្រងលើផែនដីនៃទ្វីបទាំងបួនដោយមិនដាច់ប្រើអាជ្ញាឬគ្រឿងសស្ត្រាវុធអ្វីឡើយ។ ព្រះអង្គនឹងយកព្រះធម៌ទៅអប់រំទូន្មានសត្វលោកទាំងឡាយដោយស្មើៗគ្នា។ បើព្រះរាជកុមារនឹងចេញ



ទៅសាងបព្វជ្ជាវិញ ព្រះអង្គនឹងបានត្រាស់ជាព្រះអរហំ សម្មាសម្ពុទ្ធ ក្នុងលោកទាំងមូល។"

ចំពោះកោណ្ឌញ្ញព្រាហ្មណ៍(ទី៨) ដែលជាព្រាហ្មណ៍ម្នាក់នៅក្មេងជាងគេបានលើកចង្អុលដៃតែមួយទាយថា "បពិត្រមហារាជ! ព្រះរាជកុមារនេះពុំមែនជាអ្នកនៅគ្រប់គ្រងគេហដ្ឋានទេ ព្រះអង្គពិតជានឹងចេញសាងព្រះផ្នួស ដោយឥតមានអ្វីមកទប់ទល់បានឡើយ ហើយនឹងបានត្រាស់ជាព្រះពុទ្ធយ៉ាងពិតប្រាកដ។"

កាលព្រាហ្មណ៍ទាំងអស់បានទាយថ្វាយរួចហើយ ក៏ស្រុះស្រួលមូលមតិគ្នាថ្វាយព្រះនាមដល់ព្រះរាជកុមារថា "សិទ្ធត្ថៈ" ដែលមានន័យថា "អ្នកធ្វើប្រយោជន៍គ្រប់យ៉ាងអោយសំរេច។" (លុះក្រោយមកព្រះអង្គក៏បានទទួលនូវគោត្តនាមមួយឈ្មោះថា "គោតម" មកប្រើគួបជាមួយហៅថា "សិត្ថៈគោតម"។ មហាជនតែនិយមហៅតាមគោត្រថា "គោតម"។)

ព្រះរាជាត្រាស់សួរទៅព្រាហ្មណ៍ទាំង៨រូប "ម្ចាស់ព្រាហ្មណ៍ទាំងឡាយ! តើបុត្រារបស់យើងបានឃើញនូវអារម្មណ៍ដូចម្តេច បានជាចង់ចេញទៅបួសយ៉ាងដូច្នោះ?

ព្រាហ្មណ៍ទាំងឡាយក្រាបទូលព្រះអង្គថា "បពិត្រមហារាជ! នៅពេលនោះព្រះរាកុមារនឹងទតឃើញនូវនិមិត្ត៤ប្រការគឺ ៖

-មនុស្សចាស់ជរា១

-មនុស្សឈឺ១

-មនុស្សស្លាប់១ និង

-មនុស្សអ្នកបួស១។"

ព្រះរាជាគ្មានព្រះរាជបំណងចង់អោយព្រះរាជបុត្រទៅសាងផ្នួសឡើយ។ ព្រះអង្គចង់អោយបុត្រានៅគ្រប់គ្រងរាជសម្បត្តិជំនួសព្រះអង្គ ហើយនឹងបានជាមហាចក្រពត្រាធិរាជទៅអនាគតតែម្យ៉ាង។ កាលទ្រង់ព្រះសណ្តាប់ នូវពាក្យក្រាបទូលរបស់ព្រាហ្មណ៍រួចហើយទ្រង់បញ្ជាទៅពួកសេនាកាមាត្យថា "ចាប់តាំងអំពីថ្ងៃនេះតទៅ អ្នកទាំងឡាយកុំគប្បីអោយមនុស្សទាំង៤ប្រភេទខាងលើនេះចូលមកជិតបុត្រាយើងអោយសោះ!" ព្រះអង្គដាក់គំរិតយ៉ាងតឹងរ៉ឹងមិនអោយមនុស្សពីទិសទាំង៤ដែលមានសភាពដូចខាងលើនេះ ចូលទៅត្រង់រង្វង់ចក្ខុរបស់ព្រះរាជកុមារឡើយ។

ពួកព្រាហ្មណ៍ចាស់ៗទៅហើយនោះ បានផ្តាំទៅកាន់បុត្រទាំងឡាយនៃខ្លួនថា៖

"បើព្រះរាជឱរសនៃព្រះបាទសុទ្ធោទន៍ទ្រង់បព្វជ្ជានិងបានត្រាស់ជាព្រះពុទ្ធហើយ ចូរបុត្រទៅបួសក្នុងសំណាក់ព្រះពុទ្ធនោះចុះ ពិតជាមិនខុសបំណងឡើយ។"

ព្រោះពោធិសត្វ ប្រសូតបានតែ៧ថ្ងៃនិងព្រះបាទសុទ្ធោទន៍សប្បាយព្រះហឫទ័យបានតែ៧ថ្ងៃគត់ សេចក្តីទុក្ខព្រួយមួយក៏បានកើតមានឡើងក្នុងព្រះរាជវាំង គឺព្រះនាងមហាមាយាទេវីទ្រង់សោយព្រះវិលាល័យ យ៉ាងតក់ក្រហល់ជាទីបំផុត។

ព្រះបាទសុទ្ធោទន៍តែងតាំង ព្រះនាងបជាបតិគោតមី ត្រូវជាអនុជក្សត្រីយ៍នៃព្រះនាងមហាមាយាទេវីនិងត្រូវជាប្អូនថ្លៃរបស់ព្រះអង្គផងអោយឡើយធ្វើជាព្រះមហាក្សត្រីយានី។ ព្រះនាងបជាបតីក៏មានបុត្រាមួយអង្គដែរ ព្រះនាម នន្ទ ហើយព្រះនន្ទកុមារមានព្រះជន្មប្អូនព្រះពោធិសត្វតែពីរបីថ្ងៃប៉ុណ្ណោះ។ ព្រះនាងបជាបតីគោតមីទទួលធ្វើជាមេនំបំបៅព្រះពោធិសត្វនិងបីបាច់រក្សាព្រះពោធិសត្វដោយព្រះទ័យប្រោសប្រណីដូចជាព្រះមាតាបង្កើតតរៀងទៅ។

ពេលព្រះពោធិសត្វព្រះជន្មគំរប់៧ឆ្នាំ ព្រះបិតាបានបញ្ជាអោយគេជីកស្រះ៣ថ្វាយក្រសាល និងបានបញ្ជូនទៅអោយសិក្សាក្នុងសំណាក់អាចារ្យឈ្មោះវិស្វាមិត្រ។ ព្រះពោធិសត្វចាប់ផ្តើមសិក្សាវិជ្ជាគ្រប់គ្រងរដ្ឋនិងយោធសាស្ត្រ ដូចជា អក្សរសាស្ត្រ នពន្តសាស្ត្រ តូរ្យតន្ត្រី អត្តពលកម្ម ជាដើម។ ដោយមានព្រះបញ្ញាញាណមកពីព្រះកំណើត ព្រះសិទ្ធត្ថកុមាររៀនពូកែលើគ្រប់មុខវិជ្ជាទាំងអស់យ៉ាងឆាប់រហ័សបំផុត។

ថ្ងៃមួយ ពេលព្រះអង្គគំរប់ព្រះជន្ម៩ឆ្នាំ ព្រះសិទ្ធត្ថៈនិងមិត្តរួមថ្នាក់ខ្លះ ដូចជាទេវទត្តនិងគិម្ពិល ដែលត្រូវជាបងប្អូនជីដូនមួយនឹងព្រះអង្គ បានទៅចូលរួមក្នុងពិធីបុណ្យច្រត់ព្រះន័ង្គល ដែលព្រះមហាក្សត្របានរៀបចំតាក់តែងឡើងជាលើកដំបូងនៅក្នុងវាលព្រះមេរុ៍ ជិតព្រះរាជវាំង។ មានវង្សក្សត្រ ប្រមុខមន្ត្រី គហបតី សេនា កាមាត្យ ប្រជាពលរដ្ឋប្រុសស្រី និងកុមារាកុមារីចូលរួមទស្សនាយ៉ាងច្រើនកុះករ។

ជាដំបូងបង្អស់ បព្វជិតព្រាហ្មណ៍សូត្រធម៌វេទយ៉ាងវែងអន្លាយ ហាក់រកទីបញ្ចប់គ្មាន និងធ្វើអោយព្រះរាជកុមារមានការអផ្សុករសាប់រសល់ក្នុងព្រះហឫទ័យ។ ដោយសារ



អាកាសធាតុក្តៅស្អុះផង ព្រះរាជកុមារក៏យាងចេញពីមិត្តភ័ក្រ្តតែមួយព្រះអង្គឯងទៅគង់នៅក្រោមដើមព្រីងមួយ(ជម្ពូព្រឹក្ស) ដែលមានម្លប់ដ៏ត្រជាក់នៅក្បែរដងផ្លូវជិតនោះ។ ព្រះនាងបជាបតីគោតមីបានតាមរកឃើញព្រះពោធិសត្វគង់នៅទីនោះហើយក៏សុំយាងព្រះអង្គអោយត្រឡប់ទៅទតមើលព្រះបិតាច្រត់ព្រះន័ង្គលនាពេលចុងបង្ហើយវិញ។

ព្រះសិទ្ធត្ថៈកុមារបានទូលសួរទៅកាន់ព្រះនាងគោតមីជាព្រះមាតាថា៖

"បពិត្រព្រះមាតា! ហេតុអ្វីពួកព្រាហ្មណ៍ទាំងនោះសូត្រធម៌វែងអន្លាយយ៉ាងនេះ?

ព្រះនាងបជាបតីគោតមីក៏ឆ្លើយតបទៅនឹងព្រះពោធិសត្វថា៖

"បុត្រសំឡាញ់! ពួកព្រាហ្មណ៍សូត្រធម៌វែងយ៉ាងដូច្នោះឯងណ៎ាបុត្រ! ហើយបុត្រក៏នឹងត្រូវសិក្សានូវធម៌វេទដូចគេនេះដែរ! នៅពេលបុត្រធំឡើង!"

ព្រះពោធិសត្វទ្រង់ត្រាស់សួរបន្តថា៖

"ហេតុអ្វីបានជាព្រះបិតាមិនសូត្រធម៌វេទនេះ ដោយផ្ទាល់ព្រះអង្គជំនួសពួកព្រាហ្មណ៍ទាំងនោះវិញទៅ?"

ព្រះមាតាក៏ឆ្លើយថា៖

"បានតែអ្នកដែលកើតក្នុងត្រកូលព្រាហ្មណ៍ប៉ុណ្ណោះទេដែលអាចអនុញ្ញាតអោយសូត្រធម៌ក្នុងគម្ពីរត្រៃវេទនេះ។ សូម្បីតែស្តេចផែនដីមានអំណាចដ៏ខ្លាំងពូកែ ក៏ត្រូវតែពឹងផ្អែកលើការបំរើរបស់ពួកព្រាហ្មណ៍ ដែលមានមុខនាទីជាបព្វជិតទាំងនេះដែរ។"

ព្រះពោធិសត្វសុំអនុញ្ញាតព្រះមាតាទៅគង់ក្រោមម្លប់ដើមព្រីងនោះបន្តទៀត។ ព្រះនាងគោតមីទ្រង់អនុញ្ញាតតាមការស្នើសុំរបស់ព្រះពោធិសត្វ បន្ទាប់មក ព្រះនាងក៏យាងត្រឡប់ទៅទតមើលព្រះរាជាច្រត់ព្រះនង្គ័លវិញ។ នៅពេលបព្វជិកព្រាហ្មណ៍សូត្រធម៌ចប់ ព្រះបាទសុទ្ធោទន៍ទ្រង់យាងចុះកាន់វាលចំការ ហើយទ្រង់ចាប់ផ្តើមភ្ជួរនូវគន្លងដំបូងនៃរដូវ។ បន្តមកពួកកសិករក៏ចាប់ភ្ជួរតាមពីក្រោយព្រះអង្គ។ ឮស្នូរសម្លេងមនុស្សស្រែកហ៊ោកកញ្ជ្រៀវ ធ្វើអោយព្រះពោធិសត្វអត់ទ្រាំពុំបានក៏រត់ទៅកាន់ឯខាងចុងចំការ។ ព្រះអង្គបានទតឃើញសត្វគោខំអូសនង្គ័លដ៏ធ្ងន់ ហើយកសិករវាយសំពងសត្វគោនោះនឹងរំពាត់ខ្សែតីបង្ខំអោយអូសទៅមុខយ៉ាងពិបាក។ ខណៈដែលនង្គ័លផ្លាក់អាចម៍បំណះ ព្រះពោធិសត្វ

សំគាល់ឃើញមានសត្វជន្លេនខ្លះ ត្រូវកាត់ដាច់ជាកំណាត់ៗ និងខ្លះទៀតត្រូវសត្វស្លាបឆាបឆក់ចឹកពាំនឹងចំពុះនាំយកទៅ។ ព្រះអង្គក៏ទ្រង់បានទតឃើញសត្វស្លាបធំៗឆាបចុះ រួចខ្វាំយ៉ាងជាប់នូវសត្វស្លាបតូចៗក្នុងក្រញាំ។ ជាពិសេស ព្រះអង្គបានទតឃើញសត្វពស់មួយកំពុងលេបបង្កួយយ៉ាងពិបាក រួចហើយក៏ស្រាប់តែមានសត្វខ្លែងដ៏ធំមួយមកឆាប ខ្វាំយកពស់នោះបន្តទៀត។ ព្រះពោធិសត្វក៏រត់ត្រឡប់ទៅកាន់ម្លប់ដើមព្រីងវិញយ៉ាងរហ័ស។ ព្រះអង្គទ្រង់គង់បត់ព្រះភ្នែនបិទព្រះនេត្រទាំងគូ រួចទ្រង់កំណត់នូវអានានុស្សិតញ៉ាំងបឋមជ្ឈានអោយកើតឡើង។ ព្រះអង្គផ្តោតអារម្មណ៍ខ្លាំងជាងគេតែទៅលើរូបភាពដែលកើតឡើងនៅក្នុងចំការនិងសត្វស្លាបទាំងឡាយនោះ។ ព្រះពោធិសត្វទ្រង់សញ្ជឹងគិតថា៖

"ឱ! សត្វលោកទាំងឡាយ កំពុងតែមានជីវិតរស់នៅសុខៗម្តេចឡើយក៏សម្លាប់គ្នាទៅវិញទៅមកយ៉ាងដូច្នោះ!" ដោយព្រះពោធិសត្វទើបតែបាត់បង់ព្រះមាតាថ្មីៗផងរឹតតែធ្វើអោយព្រះអង្គកើតមានសេចក្តីសង្វេគយ៉ាងខ្លាំងដល់ជីវិតសត្វតូចតាចទាំងនោះ។

គ្រាន់តែចប់ពិធីច្រត់ព្រះនង្គ័លភ្លាម ព្រះមហាក្សត្រនិងព្រះនាងបជាបតីគោតមីបានយាងទៅរកព្រះពោធិសត្វនៅក្រោមម្លប់ដើមព្រីងនោះវិញ។ ទាំងពីរព្រះអង្គបានទតឃើញព្រះពោធិសត្វកំពុងតែគង់ស្ទឹងស្មាធិ៍នឹងថ្កល់មួយកន្លែងយ៉ាងស្ងាត់ស្ងៀម។ សភាពបែបនេះធ្វើអោយព្រះរាជាភ្លឹកនិងទ្រង់ព្រះចិន្តាអស់មួយស្របក់ថា៖

"បើបុត្រានៃអាត្មាអញចេះអង្គុយស្ទឹងស្មាធិ៍តែមួយព្រះអង្គឯងតាំងពីព្រះជន្មនៅក្មេងខ្ចីយ៉ាងនេះម៉្លេះសមពាក្យព្យាករណ៍របស់អសិតតាបសនឹងក្លាយទៅជាការពិតពុំខាន។"

កាលបានទតឃើញនូវបាដិហារ្យបែបដូច្នេះ ព្រះរាជាទ្រង់ក្រាបថ្វាយបង្គំព្រះរាជបុត្រាម្តងទៀតជាលើកទី២ ក្នុងពេលនោះភ្លាមទៅ។ ព្រះរាជាក៏យាងត្រឡប់ទៅកាន់ព្រះរាជនិវេសនដ្ឋានវិញតែមួយអង្គឯង ដោយយានអាជានេយ្យ។

មិនយូរប៉ុន្មាន ព្រះសិទ្ធត្ថកុមារបានបើកព្រះនេត្រឡើង ទ្រង់ទតឃើញព្រះមាតាកំពុងតែញញឹមដាក់។ ព្រះពោធិសត្វទូលសួរទៅព្រះមាតាថា៖

"បពិត្រព្រះមាតា! ទូលបង្គំគិតថាទោះបីខំសូត្រធម៌តាមគម្ពីរត្រៃវេទយ៉ាងណាក៏ដោយក៏មិនអាចជួយសង្គ្រោះដល់ជីវិតសត្វ កបី ជន្លេន ពស់ បង្កួយ និងសត្វស្លាបទាំងឡាយនោះបានដែរ។"



ព្រះនាងគោតមីគ្មានឆ្លើយអ្វីក្រៅពីងក់ព្រះសិរតបវិញយ៉ាងស្ងាត់ស្ងើរនោះឡើយ។

ថ្ងៃមួយជាខាងក្រោយមកទៀត ព្រះសិទ្ធត្ថកុមារបានយាងប្រពាត ក្នុងឧទ្យានមួយ។ រំពេចនោះ ស្រាប់តែមានសត្វក្ងានព្រៃមួយ ដែលហើររំលងពីលើព្រះអង្គធ្លាក់ចុះមកលើដីនៅមិនឆ្ងាយប៉ុន្មានពីព្រះអង្គ។ ព្រះអង្គរត់ទៅចាប់សត្វក្ងានព្រៃនោះហើយទ្រង់ទតឃើញមានព្រួញមួយមុតជាប់យ៉ាងជ្រៅនៅលើស្លាបម្ខាង។ ព្រះអង្គក្តាប់ព្រួញនោះ រួចដកចេញយ៉ាងថ្នមៗ។ បក្សីទទះស្លាបស្រែកយំ ដោយមានឈាមហូរចេញមកអំពីស្លាប។ ព្រះអង្គយកម្រាមព្រះហស្តចុចសង្កត់ត្រង់មុខរបួសដើម្បីឃាត់ឈាម។ ព្រះអង្គបីទ្របក្សីត្រូវរបួសនោះយាងចូលទៅក្នុងព្រះរាជដំណាក់ដើម្បីអោយព្រះអនុជក្សត្រីរូបនន្ទាដែលកំពុងតែទន្ទឹងមើលផ្លូវព្រះអង្គត្រឡប់មកវិញនោះជួយ។ ព្រះនាងកញ្ញាបានយកថ្នាំស្លឹកឈើមកបុកអោយហ្មត់ទៅបិទត្រង់មុខរបួសនៃបក្សីនោះ ដើម្បីឃាត់ឈាម។ បន្ទាប់មក ព្រះសិទ្ធត្ថកុមារក៏យក្ងានព្រៃនោះ ទៅដាក់ជិតចង្ក្រានដើម្បីកំដៅអោយឧណ្ហៗ។

ពេលព្រះសិទ្ធត្ថកុមារហៀបតែនឹងយាងទៅយកស្រូវ មកអោយក្ងានព្រៃនោះស៊ី ស្រាប់តែមានព្រះរាជកុមារមួយអង្គដែលត្រូវជាបងប្អូនជីដូនមួយនឹងព្រះអង្គ ព្រះជន្មប្រមាណ៨ឆ្នាំ ព្រះនាមទេវទត្តស្ទុះចូលមកក្នុងបន្ទប់។ ទេវទត្តកុមារមានកាន់ទាំងស្នានិងព្រួញមកជាមួយផង។ ព្រះអង្គសួរទៅកាន់ព្រះសិទ្ធត្ថកុមារទាំងរហេបរហបថា "នែសិទ្ធត្ថ! តើព្រះអង្គបានឃើញក្ងានព្រៃមួយធ្លាក់នៅជិតទីនេះដែរឬទេ?"

ព្រះសិទ្ធត្ថកុមារមិនទាន់ឆ្លើយតបផង ទេវទត្តកុមារបានក្រឡេកឃើញក្ងានព្រៃនោះកំពុងក្រាបជិតចង្ក្រានរួចទៅហើយ។ ទេវទត្តកុមាររត់សំដៅកាន់បក្សីហើយពោលថា៖ "ក្ងានព្រៃនេះជារបស់ខ្ញុំ! ខ្ញុំជាអ្នកបានបាញ់វាដោយផ្ទាល់ដៃ។"

ព្រះសិទ្ធត្ថកុមារក៏ចូលទៅឈរពាំងនៅចន្លោះទេវទត្តនិងក្ងានព្រៃ ក្នុងបំណងមិនអោយទេវទត្តយកបក្សីក្ងាននោះ ហើយពោលថា ៖ "នែទេវទត្ត! បក្សីនេះត្រូវរបួសធ្ងន់ណាស់។ ខ្ញុំកំពុងថែរក្សាវា។ វាត្រូវតែស្នាក់នៅទីនេះដើម្បីព្យាបាលរបួស។"

ទេវទត្តកុមារច្រឡោតខឹងយ៉ាងខ្លាំង ដោយមិនចង់ទុកក្ងានព្រៃនៅក្នុងទីនេះ។ ទេវទត្តក៏ប្រកែកថា៖ "ចូរព្រះរាមស្តាប់ខ្ញុំសិន! ពេលបក្សីនេះហើរឯលើមេឃ វាមិនមែន

ជាកម្មសិទ្ធិរបស់អ្នកណាម្នាក់ទេ។ ខណៈដែលខ្ញុំជាអ្នកបានបាញ់វាធ្លាក់អំពីលើមេឃ វាត្រូវតែជាកម្មសិទ្ធិរបស់ខ្ញុំ។"

ពាក្យរបស់ទេវទត្តស្តាប់ទៅដូចជាត្រឹមត្រូវ ប៉ុន្តែពាក្យនេះធ្វើអោយព្រះសិទ្ធត្ថកុមារអាក់អន់ព្រះទ័យ។ ព្រះសិទ្ធត្ថកុមារដឹងថាមានការមិនសមរម្យដែរ ប៉ុន្តែព្រះអង្គគ្មានធ្វើអ្វីកើតក្រៅអំពីឈរស្ងៀម។ មួយស្របក់ក្រោយមកទើបព្រះអង្គរកមធ្យោបាយឆ្លើយថា៖ "ចូរព្រះអនុជស្តាប់ខ្ញុំវិញម្តង! អ្នកដែលជាមិត្រនឹងគ្នាអាចរស់នៅជាមួយគ្នាវីឯអ្នកដែលជាសត្រូវនឹងគ្នាមិនអាចរស់នៅជាមួយគ្នាបានទេ។ ព្រះអនុជជាអ្នកព្យាយាមសម្លាប់សត្វក្ងានព្រៃនេះ ដូច្នោះព្រះអនុជនិងក្ងានព្រៃពិតជាសត្រូវនឹងគ្នា។ បក្សីនេះមិនអាចរស់នៅជាមួយអ្នកទេ។ រីឯខ្ញុំជាអ្នកជួយសង្គ្រោះវា រុំរបួសអោយវា កំដៅអោយវា ព្រមទាំងហៀបទៅរកចំណីមកបញ្ចុកវានៅពេលអ្នកចូលមកដល់ទៀតផង។ ក្ងានព្រៃនិងខ្ញុំគឺជាមិត្រនឹងគ្នា ហើយអាចរស់នៅជាមួយគ្នា។ ដូច្នេះបក្សីនេះពិតជាត្រូវការខ្ញុំ វាមិនមែនត្រូវការអ្នកទេ!"។

ខណៈដែលព្រះរាជកុមារទាំងពីរនិយាយមិនចុះសំរុងគ្នា ក៏សំរេចចិត្តយករឿងនេះទៅអោយចាស់ព្រឹទ្ធាចារ្យជួយដោះស្រាយ។ ជួនជាពេលនោះមានកិច្ចប្រជុំធំមួយនៃរាជរដ្ឋាភិបាលនៅក្នុងព្រះរាជវាំង ក្រោមអធិបតីភាពព្រះរាជា ព្រះបាទសុទ្ធោទន៍ព្រះរាជកុមារទាំងពីរយាងចូលទៅក្នុងរោងជំនុំនោះដើម្បីអោយតុលាការកាត់សេចក្តី។ ព្រះសិទ្ធត្ថកុមារបីក្ងានព្រៃ រីឯទេវទត្តកាន់ស្នានិងព្រួញជាប់នឹងព្រះហស្ត។ ព្រះរាជកុមារទាំងពីរបានប្តឹងរឿងរ៉ាវនេះទៅចៅក្រម ហើយសុំអោយជួយវិនិច្ឆ័យសេចក្តីតាមច្បាប់។ គណៈវិនិច្ឆ័យប្រជុំពិភាក្សាគ្នាអស់ពេលយ៉ាងយូរ ប៉ុន្តែហាក់ដូចជាមិនស្របយោបល់គ្នា។ មតិភាគច្រើនបានគាំទ្រទេវទត្ត ប៉ុន្តែនៅពេលដែលព្រះរាជាសុទ្ធោទន៍ទ្រង់គ្រហែមនិងធ្វើក្អកចំនួនពីរដងទៅ គណៈវិនិច្ឆ័យក៏ឈប់ជជែកគ្នាហើយសំរេចកាត់សេចក្តីថា ព្រះសិទ្ធត្ថកុមារជាអ្នកឈ្នះនិងក្ងានព្រៃត្រូវបានមកព្រះអង្គ។ ជាការពិតណាស់ដែលទេវទត្តកុមារមិនដឹងជាធ្វើអ្វីកើត។

ព្រះសិទ្ធត្ថកុមារបានក្ងានព្រៃមែន ប៉ុន្តែព្រះអង្គមិនសប្បាយក្នុងព្រះទ័យទាល់តែសោះ។ សូម្បីតែព្រះអង្គនៅវ័យក្មេងខ្ចីមែនក៏គង់ព្រះអង្គដឹងថាជ័យជំនះរបស់ព្រះអង្គគ្រាន់តែជាការលើកតម្កើងកិត្តិយសប៉ុណ្ណោះ។ ព្រះអង្គបានក្ងានព្រៃ ក៏ព្រោះតែចៅក្រមចង់ផ្គាប់ព្រះទ័យ



ព្រះរាជា មិនមែនព្រោះតែគេឃើញសេចក្តីពិត លើអ្វីដែលព្រះអង្គបាននិយាយនោះទេ។ ព្រះរាជកុមារខំព្យាបាលក្ងានព្រៃអស់រយៈពេលបួនថ្ងៃ។ ពេលព្រះអង្គទតឃើញក្ងានព្រៃមុខរបួសស្រួលបួលនិងមានសុខភាពបរិបូណ៌ហើយព្រះអង្គក៏លែងបក្សីក្ងាននោះអោយមានសេរីភាពទៅជួបជុំគ្រួសារវិញ។

ក្នុងលោកយើងនេះ មានមនុស្សតិចណាស់ ដែលមានចក្ខុប្រកបដោយសេចក្តីមេត្តា គេតែងពោរពេញទៅដោយអំពើឃោរឃៅ និងគំគួនគ្នាទៅវិញទៅមកមិនចេះចប់។ អ្នកទន់ខ្សោយតែងមានការគាបសង្កត់ជិះជាន់អំពីសំណាក់អ្នកខ្លាំងពូកែ ឬអ្នកមានអំណាច។ មានតែសេចក្តីមេត្តានិងករុណាទេ ដែលអាចកាច់បំបាក់សេចក្តីឈឺចាប់នៃសត្វលោក។ ទោះបីជាមានការគាំទ្រពីមតិភាគច្រើនក៏ដោយ ក៏សេចក្តីពិតវានៅតែពិតដដែល។

---

## ជំពូកទី៣
## រង្វាន់ជីវិត

ព្រះសិទ្ធត្ថកុមារទ្រង់សព្វព្រះហឫទ័យចំពោះព្រះអនុជព្រះនាមនន្ទយ៉ាងខ្លាំង។ ព្រះរាជកុមារ ក៏មានបងប្អូនជីដូនមួយចំនួនបីព្រះអង្គទៀត ដែលព្រះអង្គសព្វព្រះទ័យជាងគេគឺ ៖ មហានាម តទ្ទិយៈ និង កិម្ពិល។ នៅក្នុងសាលារៀនព្រះសិទ្ធត្ថៈរៀនពូកែសព្វមុខវិជ្ជាដោយមិនពិបាក។ ព្រះអង្គរៀនពូកែទាំងក្បួនយុទ្ធសាស្ត្រផង សូម្បីតែទេវទត្តដែលថាជាអ្នករៀនពូកែដែរនោះ ក៏មិនឈ្នះនិងរហ័សរហួនស្មើព្រះអង្គដែរ។ ព្រះសិទ្ធត្ថៈមានប្រាជ្ញាមុះមុតខាងគណិតវិជ្ជា សូម្បីតែ អាជន ដែលត្រូវជាគ្រូបង្រៀនរបស់ព្រះអង្គក៏ត្រូវចំណាយពេលអស់រាប់ម៉ោងដើម្បីឆ្លើយតបនឹងសំនួររបស់ព្រះអង្គ។ ព្រះសិទ្ធត្ថកុមារក៏មានទេពកោសល្យយ៉ាងជំនាញខាងតូរ្យតន្ត្រី។ ជាញឹកញយណាស់ដែលព្រះនាងបជាបតីបានបង្ហើរព្រះសោតិន្ទ្រិយារម្មណ៍តាមសម្លេងខ្លុយដ៏ពីរោះរបស់ព្រះអង្គ នៅពេលព្រះនាងគង់សំរាកយកខ្យល់ត្រជាក់ នៅខាងក្រៅព្រះរាជតំណាក់។ ទោះបីជាយ៉ាងណា ក៏ព្រះសិទ្ធត្ថកុមារហាក់ផ្ចង់ព្រះស្មារតី តែលើការសិក្សាខាងផ្នែកសាសនានិងទស្សនវិជ្ជាប៉ុណ្ណោះ។ ព្រះអង្គត្រូវបានពួក

ព្រាហ្មណ៍ជួយបង្ហាត់បង្រៀននូវគ្រប់វិជ្ជាវេទ។ ព្រះអង្គបានខំប្រឹងសិក្សាជាពិសេស គម្ពីរ រាជវេទ និង អត្ថវេទ។ គ្រូអាចារ្យទាំងនោះ បានបង្រៀនព្រះអង្គអោយចេះដឹងនូវលោកធាតុ ដែលបែងភាគចេញអំពីព្រះអាទិទេព ដែលមានឈ្មោះថា ក្សត្រិយ៍ ឬ ព្រាហ្មណ៍ និង ប្រព័ន្ធវណ្ណៈ ផ្សេងៗទៀតផង។ ព្រះសិទ្ធត្ថកុមារខំប្រឹងសិក្សានូវអត្ថបទព្រាហ្មណ៍ជាច្រើន ដូចជា ព្រះព្រហ្ម និង ឧបនិស័ទ ជាដើម។

ទោះបីជាព្រះវរបិតាមានការតឹងតែងយ៉ាងណា ក៏ព្រះរាជកុមារបានព្រះវរមាតាអនុញ្ញាតអោយយាងចេញទៅក្រៅម្ដងម្កាល ដើម្បីទស្សនានូវភូមិដ្ឋានអ្នកស្រុកនានាដែលឋិតនៅជុំវិញរាជធានី។ ព្រះរាជកុមារបានដឹងនូវរឿងរ៉ាវជាច្រើនដែលព្រះអង្គពុំធ្លាប់ទតឃើញនៅក្នុងព្រះរាជវាំង។ ព្រះអង្គមានដឹងអំពីជីវភាពអ្នកស្រុក និងជំនឿដែលអ្នកស្រុកគោរពយ៉ាងមុតមាំចំពោះព្រះអាទិទេពទាំង៣របស់ពួកព្រាហ្មណ៍គឺ៖

ព្រះព្រហ្ម១ ព្រះវិស្ណុ១ និង ព្រះសិវៈ១។

ព្រះសិទ្ធត្ថៈមានប្រាថ្នាចង់ជួបនិងពិភាក្សាជាមួយតាបសនិងបព្វជិតនានា។ ទ្រង់បានឮដំណឹងថា មានតាបសជាច្រើនអង្គគង់នៅនគរកោសល ដែលឋិតនៅជាប់ពីខាងលិចនគរព្រះអង្គ និងនៅនគរមគធៈ ដែលលាតសន្ធឹងទៅទិសខាងត្បូង។ ព្រះសិទ្ធត្ថកុមារសង្ឃឹមញញឹមទុកនៅក្នុងព្រះទ័យថាគង់មានថ្ងៃណាមួយអាត្មាអញនឹងមានភ័ព្វចេញទៅទស្សនាតំបន់ទាំងនោះនិងសិក្សាវិជ្ជាក្នុងសំណាក់ឥសីទាំងនោះផង។

ជាការពិតណាស់ ដែលព្រះបាទសុទ្ធោទន៍ជាព្រះវរបិតាបានដឹងនូវសេចក្ដីប្រាថ្នារបស់ព្រះរាជបុត្រា។ ព្រះរាជាព្រួយបារម្ភកាន់តែខ្លាំងឡើងៗ។ ព្រះអង្គទ្រង់ព្រះតំរិះដដែលៗថា បើតាមទំនាយរបស់អសិតតាបស ថ្ងៃណាមួយព្រះរាជកុមារនឹងរត់ចាកចោលអំពីព្រះរាជវាំង ទៅបួសជាតាបសឥសីរស់នៅក្នុងព្រៃភ្នំពុំខានឡើយ។

បន្ទាប់មក ព្រះរាជក៏ទ្រង់យាងទៅពិគ្រោះការព្រួយបារម្ភនេះ ជាមួយនឹងប្អូនថ្លៃរបស់ព្រះអង្គព្រះនាម សុប្បពុទ្ធ ដែលត្រូវជាព្រះបិតារបស់ ទេវទត្តនិងព្រះនាងកញ្ញាយសោធរា។ ព្រះបាទសុទ្ធោទន៍ទ្រង់មានព្រះរាជបន្ទូលទៅកាន់ប្អូនថ្លៃថា៖ "នែអនុជ! ជាយូរណាស់មកហើយដែលនគរកោសលចង់រំលោភបំពានមកលើបូរណភាពទឹកដីរបស់យើង ហើយ



យើងត្រូវតែពឹងផ្អែកទាំងស្រុងទៅលើទេពកោសល្យរបស់បុត្រានៃយើងដូចជាព្រះអង្គម្ចាស់សិទ្ធត្ថ និងទេវទត្តជាដើម ដើម្បីការពារវាសនានគររបស់យើង។ ខ្ញុំមានក្ដីបារម្ភយ៉ាងខ្លាំង ដ្បិតអីព្រះអង្គម្ចាស់សិទ្ធត្ថ អាចដាច់ព្រះទ័យយាងចេញទៅបួសជាតាបសឥសីរស់នៅក្នុងព្រៃដូចពាក្យព្យាករណ៍របស់អសិតតាបសដែលបានទាយទុកមកហើយ។ ប្រសិនបើរឿងហ្នឹងក្លាយជាការពិតមែននោះ ទំនងជាទេវទត្តក៏អាចយកតម្រាប់តាមព្រះអង្គម្ចាស់សិទ្ធត្ថពុំខានឡើយ។ តើព្រះអនុជមិនដឹងថាព្រះអង្គម្ចាស់សិទ្ធត្ថចង់យាងចេញទៅខាងក្រៅ ដើម្បីជួបជាមួយតាបសទាំងឡាយប៉ុណ្ណោះទេឬអ្វី?"

បន្ទាប់អំពីព្រះអង្គទ្រង់ព្រះតំរិះអស់មួយស្របក់ធំមក ព្រះបាទសុប្បពុទ្ធក៏ទ្រង់អោនខ្សឹបដាក់ត្រចៀកព្រះបាទសុទ្ធោទន៍ថា៖

"បើសិនជាព្រះអង្គសួរដល់ទូលបង្គំអីញ្ចឹង ទូលបង្គំគិតថា ព្រះអង្គគួរតែជ្រើសរើសរកមហេសីថ្វាព្រះអង្គម្ចាស់ទៅ។ កាលណាព្រះអង្គម្ចាស់សិទ្ធត្ថទ្រង់ជាប់ជំពាក់ជាមួយនឹងព្រះញាតិវង្សានុវង្សរួចហើយព្រះអង្គពិតជាមិនអាចលះបង់នូវចំណងមនោសញ្ចេតនានឹងប្រពន្ធកូនទៅសាងផ្នួសតែមួយអង្គឯងក្នុងព្រៃបានឡើយ!"

ព្រះបាទសុទ្ធោទន៍ទ្រង់ញញឹម និងងក់ព្រះសិរសម្ដែងនូវការយល់ព្រម។

លុះដល់ពេលរាត្រី ព្រះបាទសុទ្ធោទន៍ទ្រង់បានយកព្រះកង្វល់នេះទៅពិគ្រោះជាមួយព្រះនាងបជាបតីគោតមីទៀត។ ព្រះនាងបានសន្យាថានឹងសំរួលរៀបចំកិច្ចការរាជាភិសេកព្រះអង្គម្ចាស់សិទ្ធត្ថ នៅពេលអនាគតដ៏ខ្លីខាងមុខនេះ សូម្បីតែព្រះនាងទើបបានសំរាលបានបុត្រីមួយព្រះអង្គទៀតព្រះនាម រូបនន្ទា ក៏ដោយ។

ចំណេរក្រោយបន្តិចមក ព្រះនាងបជាបតីគោតមីក៏ផ្ដើមបង្កើតអោយមានទិវាប្រឡងប្រជែងសិល្បសាស្ត្រមួយសំរាប់ពួកយុវជននៅក្នុងព្រះរាជាណាចក្រទាំងមូល។ ព្រះនាងបានពឹងព្រះរាមព្រះបាទសុប្បពុទ្ធនិងព្រះអគ្គមហេសី បមិកា អោយជួយចាត់ចែងរៀបចំកម្មវិធីមហោស្រពនេះ។ ព្រះបាទសុទ្ធោទន៍ទ្រង់ជាព្រះអធិបតីនៃពិធីប្រឡងប្រជែងនោះ។ យុវជននិងយុវតីទាំងឡាយនៅក្នុងរាជធានី ក៏ត្រូវបានអញ្ជើញអោយមកចូលរួមដែរ។ ព្រះអង្គម្ចាស់សិទ្ធត្ថក៏បានចូលប្រកួតគ្រប់មុខវិជ្ជាដែរ។ ព្រះនាងកញ្ញាយសោធរា ដែលជា

បុត្រីនៃព្រះនាងបមិតានិងព្រះបាទសុប្បពុទ្ធ ទទួលបន្ទុកជាអ្នករៀបចំពិធីការ និងធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវកិត្តិយសទាំងឡាយ។ ព្រះនាងកញ្ញយសោធរាមានសម្ផស្សធម្មជាតិយ៉ាងស្រស់ប្រិមប្រិយ៍គួរជាទីស្រឡាញ់រាប់អាន។

ព្រះអង្គម្ចាស់សិទ្ធត្ថប្រឡងជាប់លេខ១លើគ្រប់ផ្នែកនៃវិញ្ញសារ ដូចជា៖ តូរ្យតន្ត្រីកីឡាអត្តពលកម្ម បាញ់ធ្នូ ចាក់សាប ប្រណាំងសេះនិងលើកទម្ងន់ ជាដើម។

ព្រះនាងកញ្ញាយសោធរាទទួលកិត្តិយសជាអ្នកប្រគល់រង្វាន់ពិសេស ចំពោះបេក្ខជនដែលប្រឡងជាប់លេខ១គឺថ្វាយដំរីសមួយដល់ព្រះអង្គម្ចាស់សិទ្ធត្ថ។ ចំណែកឯងព្រះអង្គម្ចាស់ទេវទត្តវិញ ទ្រង់មិនសប្បាយព្រះទ័យទាល់តែសោះព្រោះព្រះអង្គឈ្នះត្រឹមតែលេខ២ ។ ទេវទត្តក៏មានការអាក់អន់ព្រះទ័យនឹងព្រះនាងកញ្ញាយសោធរាដែរព្រោះព្រះនាងពុំសូវចាប់អារម្មណ៍នឹងព្រះអង្គ។

"សេចក្ដីស្អប់ មិនអាចបញ្ចប់ដោយសេចក្ដីស្អប់បានទេ លុះត្រាតែមាន
សេចក្ដីស្រឡាញ់ ទើបអាចបញ្ចប់សេចក្ដីស្អប់នោះបាន។"

ធម្មបទភាគ ៥

---

# ជំពូកទី៤
# ខ្សែព្រះសុវណ្ណ

ពេលព្រះអង្គចំរើនវ័យពេញរូបរាង ព្រះអង្គម្ចាស់សិទ្ធត្ថៈតែងយាងទៅណាមកណាជាមួយនឹងនាយសារថីម្នាក់ឈ្មោះ ឆន្ន ជាអ្នកថែរក្សាយានអាជានេយ្យ ដ៏ស្មោះត្រង់របស់ព្រះអង្គ។ ព្រះអង្គម្ចាស់តែងយាងជាមួយនាយសារថីទៅកំសាន្តតាមតំបន់នានាក្នុងព្រះរាជាអាណាចក្រសក្យៈ ចាប់តាំងពីជើង ភ្នំព្រះសុមេរុ៍ ផ្នែកខាងជើងរហូតទៅដល់តំបន់វាលរាបផ្នែកខាងត្បូង។ ព្រះអង្គម្ចាស់សិទ្ធត្ថៈនិងនាយសារថីឆន្នតែងផ្លាស់ប្តូរវេនគ្នាបរយាន។ ព្រះអង្គម្ចាស់សិទ្ធត្ថៈមិនដែលប្រើរំពាត់ខ្សែតីដើម្បីវាយសេះទេ រីឯនាយសារថីឆន្នក៏ដូច្នោះដែរ។



សម័យថ្ងៃមួយ ក្នុងព្រះរាជដំណើរវិលមកកាន់ព្រះរាជវាំងវិញ ព្រះអង្គម្ចាស់សិទ្ធត្ថៈមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយទ្រង់បានទតឃើញព្រះនាងយសោធរានៅក្នុងភូមិកំសត់តូចមួយ ជាមួយស្រីស្នំមួយចំនួន កំពុងព្យាបាលរោគដល់កូនអ្នកស្រុកដែលមានជម្ងឺភ្នែក គ្រុនសន្ធំ កមរមាស់ ក្អក និងជម្ងឺជាច្រើនមុខទៀត។ ព្រះនាងកញ្ញាយសោធរាបានជួយព្យាបាលដល់កូនក្មេងក្រីក្របែបនេះអស់រយៈពេលជិតពីរឆ្នាំកន្លងមកហើយ ប៉ុន្តែនេះជាលើកទីពីរហើយ ដែលព្រះនាងកញ្ញាបានមកជួយនៅក្នុងភូមិតូចនេះ។ ព្រះអង្គម្ចាស់សិទ្ធត្ថៈបានចូលទៅពិភាក្សាអំពីបញ្ហាសុខភាពប្រជាពលរដ្ឋជាមួយនឹងព្រះនាងយសោធរាអស់ពេលយ៉ាងយូរ និងទ្រង់បានកោតស្ញប់ស្ញែងនូវស្នាដៃដ៏ប្រពៃរបស់ព្រះនាងកញ្ញា។ ព្រះនាងមិនមែនចេះតែគោរពដោយងងិតងងល់នូវទំនៀមទំលាប់ដ៏ចាស់គំរិល របស់ព្រាហ្មណ៍ទាំងនោះទេ។ ព្រះនាងក៏បានសិក្សានូវគម្ពីរត្រៃវេទទាំងនោះផងដែរ ព្រមទាំងបានប្រឆាំងដោយស្ងៀមស្ងាត់បំផុតនូវអំពើអយុត្តិធម៌ក្នុងសង្គមទៀតផង។

ថ្ងៃមួយខាងក្រោមមកទៀត ព្រះនាងបជាបតិគោតមីបានរៀបចំអោយមានជាពិធីប្រឡងជ្រើសរើសបវរកញ្ញានៅក្នុងរាជធានី។ បវរកញ្ញាម្នាក់ៗត្រូវចេញបង្ហាញរូបសម្បត្តិនិងគ្រឿងអលង្ការល្អៗដល់ភ្ញៀវ។ ដោយមានការថ្វាយយោបល់ពីព្រះនាងបមិតា ព្រះអង្គម្ចាស់សិទ្ធត្ថៈត្រូវបានទទួលកិត្តិយស ជាអ្នកបំពាក់គ្រឿងអលង្ការដល់បវរកញ្ញាទាំងអស់ប្រហែលមួយពាន់(១០០០)រូប។ គេសង្កេតឃើញបវរកញ្ញាទី១ដែលព្រះអង្គម្ចាស់សិទ្ធត្ថៈបំពាក់គ្រឿងអលង្ការជូនគឺ៖ នាងសោមា ជាបុត្រីមួយអង្គនៃខត្តិយត្រកូល។ បវរកញ្ញាបន្ទាប់គឺនាងរោហិនី (យកឈ្មោះតាមស្ទឹងរោហិនី) និងបន្តរហូតដល់បវរកញ្ញាចុងក្រោយគេបង្អស់គឺនាង សីលា។

ប៉ុន្តែ នៅពេលដែលព្រះអង្គម្ចាស់សិទ្ធត្ថៈកំពុងតែសញ្ជឹងគិតថា អាត្មាអញហាក់ដូចជាបានបំពេញភារកិច្ចក្នុងពិធីមហោស្រពនេះចប់សព្វគ្រប់ហើយនោះ ក៏ស្រាប់តែខត្តិយកញ្ញាដ៏ស្រស់បំព្រងនិងទន់ល្វតល្វន់មួយអង្គយាងចេញពីក្នុងចំណោមទស្សនិកជនមក ព្រះនាងយាងសន្សឹមៗឆ្ពោះទៅកាន់តុដាក់រង្វាន់។ ខត្តិយកញ្ញាដ៏ល្អឯងនោះគ្មានអ្នកណាក្រៅអំពីព្រះនាងទេពធីតាយសោធរាឡើយ។ ព្រះនាងទ្រង់ព្រះពស្ត្រនូវសំពត់សារីពណ៌ភ្លុក។

ព្រះនាងទេពីឱនព្រះកាយសំពះព្រះរាជានិងព្រះអគ្គមហេសីគ្រប់ព្រះអង្គនិងភ្ញៀវតូចធំទាំងអស់ រួចហើយព្រះនាងក៏យាងឆ្ពោះទៅកាន់ព្រះសិទ្ធត្ថៈដែលកំពុងតែឈរនៅជិតតុរង្វាន់នោះ។ ព្រះនាងទតចំព្រះភ័ក្ត្រព្រះអង្គម្ចាស់សិទ្ធត្ថៈដោយញញឹមយ៉ាងស្រស់ មុននឹងមានបន្ទូលថា៖

"តើព្រះអង្គម្ចាស់មានអ្វីសល់សំរាប់ ទូលព្រះបង្គំដែរឬទេ?

ព្រះអង្គម្ចាស់សិទ្ធត្ថៈក៏បែរព្រះភ័ក្ត្រទៅរកព្រះនាងវិញ ហើយទ្រង់សម្លឹងដោយព្រះនេត្រាថ្លាឆ្វង់និងដោយក្តីសប្បុរសបំផុត។ ព្រះអង្គម្ចាស់ក្រឡេកទៅលើតុរង្វាន់ ក៏មិនឃើញមានអ្វីនៅសល់បន្តិចសោះទើបព្រះអង្គលើកព្រះហស្តទាំងទ្វេដោយព្រះភ័ក្ត្រញញឹមដោះយកខ្សែព្រះសុរង(ខ្សែក) ផ្ទាល់ព្រះអង្គមកបំពាក់ថ្វាយព្រះនាងយសោធរាហើយមានព្រះបន្ទូលថា៖

"ព្រះនាងកញ្ញា! នេះជារង្វាន់ពិសេសសំរាប់ព្រះនាង"

ភ្ញៀវកិត្តិយសទាំងអស់នាំគ្នាក្រោកឈរនិងផ្ទុះសំណើចគិលឡើង។ ស្នូរទះដៃនិងសម្រែកជ័យឃោសន៍លាន់សូរកងរំពង ហាក់រកទីបញ្ចប់គ្មាន។

"គេអាចច្បាំងឈ្នះសត្រូវរាបពាន់នាក់ ក្នុងលានប្រយុទ្ធរាប់ពាន់កន្លែង។
ប៉ុន្តែ អ្នកដែលច្បាំងឈ្នះខ្លួនឯង ជាជ័យជំនះប្រសើរបំផុត។"

ធម្មបទភាគ ១០៣

---

# ជំពូកទី៥
# គន្លងនៃមេត្តាធម៌

នា សរទរដូវ(រដូវរំហើយ) ឆ្នាំក្រោយមកទៀត នៅរាជធានីកបិលពស្តុមានប្រារព្ធពិធីរាជាភិសេក រវាងព្រះអង្គម្ចាស់សិទ្ធត្ថៈ និងព្រះនាងកញ្ញាសោធរា យ៉ាងមហោឡារិកជាទីបំផុត។

ព្រះបាទសុទ្ធោទន៍បានរៀបចំរាជាភិសេកអាពាហ៍ពិពាហ៍ព្រះឱរសក្នុងព្រះជន្ម១៦ឆ្នាំ



ជាមួយព្រះកញ្ញាពិម្ពាយសោធរា ដែលត្រូវជាបុត្រី នៃព្រះបាទសុប្បពុទ្ធនិងព្រះនាងបមិតា នៅឯនគរទេវទហៈ នាថ្ងៃសៅរ៍ ពេញបូរមី ខែអាសាធ ឆ្នាំឆ្លូវ។ ព្រះសុទ្ធោទន៍បានចាត់អោយគេសាងប្រាសាទ៣ ថ្វាយដល់រាជបុត្រាបុត្រីទាំងពីរដើម្បីក្រសាល។ ប្រាសាទមួយសមតាមរដូវមួយ។ ប្រាសាទទី១ឈ្មោះ ចន្ទប្រាសាទ មាន៩ជាន់សំរាប់គង់នៅក្នុង ហេមន្តរដូវ (រដូវរងារ) សង់នៅជាប់ជើងភ្នំព្រះសុមេរុ៍។ ប្រាសាទទី២ឈ្មោះ គោទនប្រាសាទ មាន៥ជាន់ សំរាប់គង់ក្នុង គិម្ហរដូវ(រដូវក្តៅ) និងប្រាសាទទី៣ឈ្មោះ កោញ្ញប្រាសាទ មាន៣ជាន់សំរាប់គង់នៅក្នុង វស្សានរដូវ(រដូវភ្លៀង)។ ប្រាសាទទី២និងទី៣សង់នៅក្នុងរាជធានី។ ប្រាសាទនីមួយៗសុទ្ធតែមានជីកស្រះទឹកនៅជិតនោះផង។ ព្រះបាទសុទ្ធោទន៍បានត្រាស់បញ្ជាអោយគេជ្រើសរើសសុទ្ធតែតន្ត្រីកររជើងឯកនិងអ្នកចម្រៀងរបាំដ៏ល្បីៗ អោយមកប្រគំនិងសំដែងថ្វាយដល់បុត្រា ដើម្បីបានសប្បាយរីករាយក្នុងព្រះហឫទ័យ។ គូស្វាមីភរិយាថ្មីទាំងពីរព្រះអង្គពុំដែលសព្វព្រះហឫទ័យ ក្នុងជីវិតជាអ្នកមានទ្រព្យសម្បត្តិច្រើន និងក្នុងឋានៈខ្ពង់ខ្ពស់ឡើយ។ សេចក្តីសប្បាយទាំងពីរព្រះអង្គគឺប្រាថ្នាស្វែងរកចម្លើយពិតដែលទាក់ទងទៅនឹងការស្វែងរកខាងផ្លូវអារម្មណ៍និងការកែឆ្នៃនូវរចនាសម្ព័ន្ធជីវភាពសង្គមរបស់មនុស្សលោក។

នារដូវប្រាំងក្រោយមក ព្រះអង្គម្ចាស់សិទ្ធត្ថៈ និងព្រះជាយាយសោធរា ត្រូវបាននាយសារថីឆន្ន ជូនព្រះរាជដំណើរដោយយានអាជានេយ្យ ដើម្បីធ្វើទស្សនកិច្ចតាមទីកន្លែងនានាក្នុងព្រះនគរ។ ភាគច្រើនជាកន្លែងដែលព្រះនាងយសោធរាពុំធ្លាប់ដែលស្គាល់។ ទាំងពីរព្រះអង្គទ្រង់ស្នាក់នៅអស់កាលច្រើនថ្ងៃច្រើនយប់ក្នុងសំណាក់ផ្ទះអ្នកស្រុក សោយម្ហូបអាហារធម្មតានិងផ្ទំនៅលើអង្រឹងត្បាញអំពីខ្សែផ្ទៃ។ ស្តេចទាំងពីរអង្គបានយល់យ៉ាងច្បាស់អំពីជីវភាពរស់នៅនិងទំនៀមទម្លាប់របស់ពួកអ្នកស្រុកតាមទីកន្លែងនីមួយៗ ដែលទាំងពីរព្រះអង្គបានធ្វើទស្សនកិច្ចរួចមកហើយ។

មានរឿងចម្លែកជាច្រើនដែលព្រះអង្គម្ចាស់សិទ្ធត្ថៈនិងព្រះជាយាបានជួបប្រទះដូចជាបានជួបជាមួយក្រុមគ្រួសារដែលមានកូនយ៉ាងតិចពី៩ឬ១០នាក់ក្នុងបន្ទុកហើយកូនក្មេងម្នាក់ៗសុទ្ធតែមានជម្ងឺរាំរៃនិងខ្វះអាហារ។ ឪពុកម្តាយសូម្បីតែខំធ្វើការធ្ងន់ទាំងយប់ទាំងថ្ងៃ

យ៉ាងណាក៏ពុំអាចរកប្រាក់កាសគ្រប់គ្រាន់មកចិញ្ចឹមកូនដ៏ច្រើនសន្ធឹកនោះបានដែរ។ សេច
ក្តីលំបាកវេទនា នៅតែបន្តមួយជំនាន់ហើយមួយជំនាន់ទៀតសំរាប់ជីវិតកសិករក្រីក្រ។
ព្រះអង្គម្ចាស់សិទ្ធត្ថៈទ្រង់សម្លឹងមិនដាក់ព្រះនេត្រ ទៅកាន់កុមារទាំងឡាយដែលមាន
អវយវៈស្គមកំព្រឹងដូចជើងធូបនិងក្បាលពោះកំប៉ោងដោយជម្ងឺព្រូន ព្រមទាំងជម្ងឺខ្លះជីវ
ជាតិផ្សេងៗទៀតផង។ ព្រះអង្គម្ចាស់ក៏ទ្រង់បានទតឃើញមនុស្សពិការដើរសុំទានគេតាដង
ផ្លូវនិងមនុស្សមានជម្ងឺប្រចាំកាយជាច្រើន។ បន្ថែមទៅលើភាពក្រីក្រនិងជម្ងឺតម្កាត់ មនុស្ស
ទាំងនោះមានការគាបសង្កត់ខាងផ្លូវចិត្តយ៉ាងខ្លាំងពីសំណាក់ពួកព្រាហ្មណ៍ដោយគ្មានអ្នក
ណាម្នាក់ហ៊ានចេញមុខរាំប្រឆាំងឡើយ។ ព្រះអង្គម្ចាស់សិទ្ធត្ថបានដឹងច្បាស់ណាស់ថា
សូម្បីតែព្រះរាជាក៏ពុំអាចមានសិទ្ធិឬអំណាចទៅផ្លាស់ប្តូរស្ថានការណ៍បែបនេះបានឡើយ។
ព្រះអង្គក៏បានដឹងនូវរឿងផ្ទៃក្នុងនៃព្រះរាជវាំង ជាយូរយាណាស់មកហើយដែរ។ អ្នករាជ
ការម្នាក់ៗសុទ្ធតែមានបំណងការពារពង្រឹងអំណាចផ្ទាល់ខ្លួន ឥតគិតដល់ការឈឺចាប់និង
សេចក្តីត្រូវការនៃអ្នកក្រខ្សត់ដទៃសោះឡើយ។ ព្រះអង្គបានដឹងយ៉ាងប្រាកដថាសូម្បីតែ
អំណាចរបស់ព្រះបិតាព្រះអង្គក៏គ្មានការធានានិងគ្មានសណ្តាប់ធ្នាប់ដែរ។ ពោលព្រះបិតា
របស់ព្រះអង្គគឺជាស្តេចដែលមិនប្រកាន់នូវសេរីភាពពិត ប៉ុន្តែ គឺជាស្តេចដែលជាប់ឃុំ
ឃាំងក្នុងមុខតំណែងផ្ទាល់ព្រះអង្គ។ ព្រះវរបិតារបស់ព្រះអង្គក៏បានជ្រាបនូវការលោភលន់
និងអំពើពុករលួយរបស់មន្ត្រីរាជការដ៏ច្រើនសន្ធឹកសន្ធាប់នោះដែរ ក៏ប៉ុន្តែព្រះអង្គត្រូវបង្ខំ
ព្រះហឫទ័យផ្តេកផ្តួលទៅតាមបុគ្គលទាំងអស់នោះ ដើម្បីរក្សាស្ថេរភាពក្នុងរាជសម្បត្តិ
របស់ព្រះអង្គ។ ព្រះអង្គម្ចាស់សិទ្ធត្ថទ្រង់ព្រះចិន្តាថា៖

"បើសិនអាត្មាអញទទួលតំណែង ឡើងគ្រងរាជសម្បត្តិជំនួសព្រះវរបិតាវិញអាត្មាអញ
ក៏ត្រូវតែធ្វើដូចជាព្រះអង្គដែរ។ មានតែមនុស្សដែលច្បាំងឈ្នះនូវសេចក្តីលោភលន់និង
សេចក្តីច្រណែន នៅក្នុងខ្លួនឯងប៉ុណ្ណោះទេ ដែលអាចធ្វើអោយស្ថានការណ៍ទាំងនោះផ្លាស់



ប្តូរបាន។"

កាលព្រះអង្គម្ចាស់សិទ្ធត្ថទ្រង់ព្រះតំរិះយ៉ាងដូច្នេះហើយសេចក្តីប៉ងប្រាថ្នារបស់ព្រះ
អង្គក្នុងការស្វែងរកដំណោះស្រាយខាងផ្លូវអារម្មណ៍ ក៏ត្រូវបានលេចធ្លោឡើង។
ព្រះអង្គបានទ្រង់ព្រះចិន្តាទៀតថា៖

"មនុស្សលោកកំពុងជាប់អន្ទាក់ មិនចំពោះតែជម្ងឺនិងអំពើអយុត្តិធម៌នៅក្នុងសង្គម
ប៉ុណ្ណោះទេ ប៉ុន្តែមានសេចក្តីទុក្ខព្រួយនិងតណ្ហា ដែលដក់ជាប់ក្នុងបេះដូងនិងខួរក្បាល
របស់គេរាល់គ្នាផងដែរ។"

ព្រះអង្គម្ចាស់សិទ្ធត្ថៈទ្រង់មានការពិសោធផ្ទាល់ព្រះអង្គ នូវការមន្ទិលសង្ស័យការមិន
បានសំរេចព្រះបំណង និងការឈឺចាប់ទាំងឡាយ ដែលព្រះអង្គបានទតឃើញនៅក្នុងព្រះ
បរមរាជវាំងនិងនៅក្នុងសង្គមមនុស្សទូទៅ។

ព្រះនាងយសោធរា ក៏ជាស្ត្រីរហ័សរហួន មានប្រាជ្ញាវៃឆ្លាត ចេះគិតគូរវែងឆ្ងាយ
មិនប្រកាន់ខ្លួន ស្លូតបូត មិនពឹងផ្អែកលើកម្លាំងអ្នកដ៏ទៃ និង ចូលចិត្តធ្វើការទៅតាមសមត្ថ
ភាពរបស់ព្រះនាង(អំណាចអព្ភន្តរញាណ)។ ព្រះនាងបានយល់យ៉ាងច្បាស់នូវព្រះចំណង់
ដ៏ខ្លាំងក្លារបស់ព្រះស្វាមី។ សូម្បីតែព្រះនាងបជាបតីគោតមី ក៏ធ្លាប់មានព្រះបន្ទូលទៅកាន់
បុត្រីយសោធរាថា ៖

"បុត្រី! ស្ត្រីក៏មានបញ្ញានិងឋាមពលដូចគ្នានឹងបុរសដែរ ហើយក៏អាចទទួលខុសត្រូវនៅ
ក្នុងកិច្ចការបំរើសង្គមជាតិផងដែរ។ ប្រសិនបើស្ត្រីភេទ មានសមត្ថភាពគ្រប់គ្រាន់អាច
បង្កើតអោយមានភាពកក់ក្តៅនិងសុភមង្គលនៅក្នុងសង្គមគ្រួសាររបស់ខ្លួនបាន គ្មារឿង
អ្វីដែលថាស្ត្រីទាំងនោះ នៅតែអង្គុយក្រវែលជើងក្រាន ឬក៏នៅតែសំកុកក្នុងផ្ទះនោះ
ឡើយ។"

កាលពីកុមារភាព ព្រះអង្គម្ចាស់សិទ្ធត្ថៈធ្លាប់បានសិក្សាអំពីជីវិតរបស់ព្រាហ្មណ៍ទាំង៤

ប្រការដែរ។

ប្រការទី១. នៅក្នុងយុវវ័យពួកព្រាហ្មណ៍ត្រូវតែសិក្សានូវសាសនាវេទ។

ប្រការទី២. នៅពេលរៀបការប្ដីឬប្រពន្ធ ពួកព្រាហ្មណ៍ត្រូវតែរកទទួលទានចិញ្ចឹមគ្រួសារនិងធ្វើការបំរើសង្គម។

ប្រការទី៣. នៅពេលកូនចំអស់ពួកព្រាហ្មណ៍នោះអាចឈប់សំរាក និងត្រូវបូជាចំពោះការសិក្សាសាសនា។

ប្រការទី៤. ដើម្បីរំដោះខ្លួនអោយផុតអំពីសេចក្ដីប្រាថ្នា និងកាតព្វកិច្ចផ្សេងៗពួកព្រាហ្មណ៍ត្រូវតែរបស់នៅក្នុងជីវិតជាអ្នកបួស។

ព្រះអង្គម្ចាស់សិទ្ធត្ថៈបានលើកយកការអប់រំទាំង៤ប្រការ របស់ពួកព្រាហ្មណ៍នេះមកធ្វើការពិចារណាដោយសង្ខេបថា ៖

"បើអាត្មាអញនៅរង់ចាំដល់ខ្លួនចាស់ហាក់ដូចជាយឺតពេលណាស់ទេដឹងសំរាប់សិក្សានូវគន្លងធម៌ទាំងឡាយ។"

ព្រះអង្គគ្មានបំណងរង់ចាំពេលវែងដូច្នោះឡើយ។ ទ្រង់ពិចារណាបន្ថែមថា៖

"ហេតុអ្វីក៏មនុស្សមិនអាចរស់នៅបានគ្រប់វ័យទាំងអស់នៅក្នុងពេលតែមួយ? បើមនុស្សគោរពសាសនា នៅពេលខ្លួនមានប្ដីឬប្រពន្ធ តើយ៉ាងដូចម្ដេចដែរ?"

ព្រះអង្គមានព្រះបំណងចង់សិក្សានូវគន្លងធម៌ នាពាក់កណ្ដាលវ័យ នៃជីវិតបច្ចុប្បន្នរបស់ព្រះអង្គតែម្ដង។

រសៀលថ្ងៃមួយ ពេលយាងត្រឡប់មកដល់ប្រាសាទវិញ ព្រះនាងយសោធរាទ្រង់មានព្រះភ័ក្ត្រក្រៀមស្រពោននិងមិនមានព្រះបន្ទូលស្ដីទៅកាន់នរណាម្នាក់ឡើយ។ ពីព្រោះតែកូនក្មេងដែលព្រះនាងបានថែរក្សាអស់រយៈពេលជាងមួយសប្ដាហ៍កន្លងមកនោះទើបនឹងស្លាប់។ ព្រះនាងបានប្រឹងប្រែងអស់ពីសមត្ថភាពដែរ ប៉ុន្តែមិនអាចជួយសង្គ្រោះក្មេង



នោះអោយផុតអំពីក្រញាំមច្ចុរាជបានឡើយ។ ដើម្បីរម្ងាប់នូវសេចក្ដីទុក្ខសោកនេះ ព្រះនាងគង់សញ្ជឹងគិតដោយមានទឹកនេត្រាហូររហាមចុះមកលើផែនថ្ពាល់ទាំងសង្ខាង។

គ្រាដែលព្រះនាងជួបនឹងព្រះស្វាមី ពេលព្រះអង្គត្រឡប់មកអំពីប្រជុំនៅឯព្រះបរមរាជវាំងវិញ ព្រះនាងយសោធរាទប់ព្រះទ័យពុំបានក៏ទ្រង់ព្រះកន្សែងម្ដងទៀត។ ព្រះអង្គម្ចាស់សិទ្ធត្ថក៏ចាប់ត្រកងព្រះនាងនៅក្នុងព្រះហត្ថាទាំងទ្វេ រួចក៏ទ្រង់អង្វរលួងលោមថា៖

"ពិម្ពាអូន! ថ្ងៃស្អែកបងនឹងយាងទៅកាន់កន្លែងបូជាសពកុមារនោះ ជាមួយអូនដែរ។ សូមម្ចាស់អូនទ្រង់ព្រះកន្សែងអោយអស់ចិត្តអំពីឥឡូវនេះទៅចុះទើបសេចក្ដីឈឺចាប់ចុះអន់ថយពីក្នុងឧរារបស់អូន។ ពិម្ពាអូន! ការកើត ចាស់ ឈឺ និង ស្លាប់ គឺជារឿងពិតដែលមនុស្សយើងម្នាក់ៗមានប្រចាំជីវិត។ អ្វីដែលកើតមានដល់កុមារតូចនោះ វាក៏នឹងកើតមានចំពោះយើងរាល់គ្នានៅពេលណាមួយពុំខានដែរ។"

ព្រះនាងយសោធរាទ្រង់មានព្រះសវនីយ៍ដោយខ្សឹតខ្សួលតបវិញថា៖

"ម្ចាស់បង! អូនបានដឹងយ៉ាងច្បាស់នូវអ្វីដែលម្ចាស់បងមានព្រះបន្ទូលប្រាប់អូន។ ព្រះហស្តទាំងគូរបស់អូនតូចពេកណាស់ បើប្រៀបធៀបទៅនឹងភាពដ៏ធំមហិមានៃការឈឺចាប់របស់អូន។ បេះដូងរបស់អូនពោរពេញទៅដោយកង្វល់ និងទុក្ខសោកជានិច្ចជាកាល។ ឱព្រះស្វាមី! សូមម្ចាស់បងបង្ហាញអោយអូនដឹងផងថា តើអូនត្រូវរម្ងាប់សេចក្ដីឈឺចាប់ នៅក្នុងព្រះឱរារបស់អូនដោយវិធីណាទៅ?"

ព្រះអង្គម្ចាស់សិទ្ធត្ថទ្រង់ឱបរិតព្រះជាយាយ៉ាងណែននៅក្នុងព្រះហស្ត ហើយទ្រង់មានបន្ទូលបន្តទៀតថា៖

"មិម្ពាអូន! រូបបងក៏កំពុងតែស្វែងរកផ្លូវដើម្បីរម្ងាប់នូវសេចក្ដីឈឺចាប់ និងទុក្ខព្រួយ ដែលកំពុងតែកើតមានឡើងនៅក្នុងបេះដូងរបស់បងដែរ។ បងក៏បានទតឃើញស្ថានការណ៍បែបនេះកើតមានច្រើនណាស់នៅក្នុងសង្គមមនុស្សជាតិ។ ប៉ុន្តែទោះបីជាបង

ខំប្រឹងប្រែងអស់អំពីសមត្ថភាពយ៉ាងណាក៏ដោយក៏បងពុំទាន់រកឃើញនូវមធ្យោបាយឆ្ពោះទៅរកការរំដោះខ្លួនអោយមានសេរីភាពបានឡើយ។ បងពិចារណាក្នុងចិត្តថា ថ្ងៃណាមួយបងនឹងរកឃើញនូវគន្លងធម៌ដ៏ឧត្តមគឺការត្រាស់ដឹងសំរាប់ជួយដល់យើងរាល់គ្នា។ ពិម្ពាមាសបង! សូមអូនជឿទុកចិត្តលើរូបបងមួយគ្រាសិនចុះ!"

ស្អែកឡើង ពេលព្រះអង្គម្ចាស់សិទ្ធត្ថនិងព្រះជាយា យាងទៅដល់ផ្ទះកុមារដែលទើបនឹងស្លាប់នោះ។ សាកសពក្មេងនោះកំពុងដេកសន្ធឹងស្តូកស្តឹងលើគ្រែនៅឡើយ។ សញ្ញានៃជីវិតរលត់បាត់សូន្យឈឹងទៅហើយ។ ស្បែកកុមារនោះមានពណ៌ស្លេកស្លាំងនិងស្វិតរមួត។ ដងខ្លួនមើលទៅគ្មានឃើញអ្វីក្រៅអំពីស្បែកដណ្តប់ឆ្អឹងឡើយ។ មាតានៃកុមារកំពុងលុតជង្គង់នៅជិតគ្រែ និងជូតទឹកភ្នែកដែលហូរចុះមិនចេះចប់នោះ។ មួយស្របក់ក្រោយមកទើបពួកព្រាហ្មណ៍មកដល់ រួចក៏ចាប់ផ្តើមរៀបចំធ្វើបុណ្យបូជាសបដល់កុមារនោះទៅ។

គ្រាមួយនោះ ព្រះនាងយសោធរាបានទូលសួរព្រះស្វាមីថា៖

"ព្រះស្វាមី! អូនមានបំណងចង់ទូលសួរម្ចាស់បងថា បើម្ចាស់បងមានបុត្រជាមួយនឹងអូន តើម្ចាស់បងចង់បានបុត្ររបស់យើងនោះ ជាបុត្រាឬក៏ជាបុត្រី?

ព្រះអង្គម្ចាស់សិទ្ធត្ថៈទ្រង់ភ្ញាក់ស្រឡាំងកាំង ទ្រង់ផ្តោតព្រះនេត្រដោយយកចិត្តទុកដាក់ឆ្ពោះទៅកាន់ព្រះនេត្រព្រះជាយា ហើយទ្រង់មានបន្ទូលថា៖

"ពិម្ពាអូន! តើម្ចាស់អូនចង់មានព្រះសវនីយ៍ថាយ៉ាងដូម្តេចដែរ? ម្ចាស់អូនចង់មានន័យថា ម្ចាស់អូនទ្រង់ព្រះគភ៌មែនឬទេ?

ព្រះនាងពិម្ពាយសោធរាងក់ព្រះសិររួចទ្រង់យកព្រះហស្តចង្អុលចំត្រង់ព្រះឧទរនិងមានព្រះសវនីយ៍ថា៖

"ព្រះពរម្ចាស់បង! អូនមានសេចក្តីរីករាយឥតឧបមា កាលដែលបានពរផ្ទៃដែលជា



ផលនៃសេចក្តីស្នេហារវាងយើងទាំងពីរ។ អូនប្រាថ្នាចង់បានបុត្រនៅក្នុងព្រះគភ៌នេះជាបុត្រាណាំម្ចាស់បង ហើយដែលមានសភាពដូចគ្នាបេះបិទនឹងម្ចាស់បងទាំងបញ្ញានិងទាំងគុណធម៌។"

ព្រះអង្គម្ចាស់សិទ្ធត្ថទ្រង់លើកព្រះហស្តបីត្រកងព្រះមហេសីយ៉ាងថ្នមៗមុននឹងមានព្រះបន្ទូលថា៖

"ពិម្ពាអូន! សូមអូនរហ័សយកដំណឹងនេះទៅគាល់ព្រះមាតារបស់យើងដើម្បីព្រះអង្គទ្រង់ជ្រាបផង។ ព្រះមាតាទាំងពីរព្រះអង្គនឹងសព្វព្រះហឫទ័យ ព្រមទាំងជួយផ្តល់ដំបូន្មានដ៏ប្រសើរដល់រូបអូន ក្នុងការថែរក្សាព្រះគភ៌នេះពុំខានឡើយ។"

---

# ជំពូកទី ៦
# រាហុលប្រសូត

ពេលវេលាចេះតែកន្លងទៅ ទិវាដែលព្រះនាងយសោធរា ត្រូវសំរាលរាជបុត្រក៏បានមកដល់។ ព្រះមាតាទាំងពីរព្រះអង្គគឺ៖ ព្រះនាងបជាបតីគោតមីនិងព្រះនាងបមិតាមិនយាងទៅណាឆ្ងាយឡើយ រង់ចាំថែទាំបុត្រីពិម្ពាគ្រប់ទិវារាត្រី។ ព្រះអង្គម្ចាស់សិទ្ធត្ថៈទ្រង់បាននឹកឃើញឡើយវិញនូវរឿងមួយដែលព្រះអង្គបានជួបជាមួយព្រះសង្ឃមួយអង្គក្នុងរវាងពីរបីខែកន្លងមកនេះ។ ព្រះអង្គចាប់ផ្តើមគង់បត់ព្រះភ្នែនដូចផ្កាឈូកក្រពុំ រួចទ្រង់តាំងអធិដ្ឋាននៅក្នុងព្រះចិន្តាថា៖

"ព្រះវរមាតារបស់អាត្មាអញ គឺព្រះនាងសិរិមហាមាយាទ្រង់សោយព្រះទីវង្គតទៅ ក៏ព្រោះតែព្រះអង្គប្រសូតរូបអាត្មាអញនេះ គឺជាស្តេចទុក្ខសោកដែលអាត្មាអញមិនអាចបំភ្លេចបាន។ ឥឡូវនេះ ដល់វេនអូនពិម្ពាយសោធរាប្រសូតបុត្រដែលជាបុត្ររបស់អាត្មាអញតែម្តង។ ការសំរាលបុត្រ គឺជាដំណើរដែលស្ត្រីមានប្តីភាគច្រើនត្រូវឆ្លងកាត់ដោយគ្រោះថ្នាក់បំផុត ជូនក៏បណ្តាលអោយស្ត្រីជាម្តាយស្លាប់បាត់បង់ជីវិតឬក៏ស្លាប់ទាំងម្តាយទាំងកូនតែម្តងផងក៏មាន។"

វំពេចនោះ រូបភាពទារកតូចមួយបានផ្តោតជាប់ក្នុងព្រះអារម្មណ៍របស់ព្រះអង្គពោលគឺជារូបភាពបុត្រារបស់ព្រះអង្គតែម្តង។ ព្រះអង្គក៏ស្តាប់ឮសម្លេងទួញយំរបស់មហេសីយសោធរាយ៉ាងច្បាស់នៅក្នុងព្រះសោតា។ បន្តិចក្រោយមកស្រាប់តែសម្លេងទំនួញនោះក៏រសាត់បាត់ទៅ។ សម្លេងទារកពិតក៏ស្រែកយំង៉ាឡើង។ ព្រះទារកបានប្រសូតឡើងហើយ! ព្រះអង្គស្ទុះក្រោកឈរឡើងទាំងជំហ៊ររួចទ្រង់លើកព្រះហស្តជូតញើសនៅលើថ្ងាស។ ព្រះនាងបជាបតីគោតមីបើកទ្វារខ្វាកឡើង និងចោលព្រះនេត្រសម្លឹងរកមើលព្រះសិទ្ធត្ថ។ ព្រះនាងញញឹមធ្វើអោយព្រះអង្គម្ចាស់សិទ្ធត្ថដឹងជាស្រេចថាព្រះនាងពិម្ពាមហេសីពិតជាបានប្រកបដោយសេចក្តីសុខសប្បាយ។ ព្រះនាងបជាបតីគោតមីមានព្រះបន្ទូលឡើងថា៖

"បុត្រសំឡាញ់! ពិម្ពាប្រសូតបានបុត្រាមួយព្រះអង្គស្អាតណាស់។"

ព្រះសិទ្ធត្ថៈទ្រង់ញញឹម និងសម្លឹងទៅកាន់ព្រះមាតាវិញ ដោយសេចក្តីគោរពហើយទ្រង់មានព្រះបន្ទូលថា៖

"ព្រះមាតា! ទូលបង្គំនឹងដាក់ព្រះនាមដល់បុត្រាសំឡាញ់នៃទូលព្រះបង្គំនេះថា រាហុលហើយ!"

ថ្ងៃមួយ ពេលព្រះអង្គម្ចាស់សិទ្ធត្ថៈកំពុងតែបីទ្ររាហុលកុមារនៅក្នុងព្រះហស្តព្រះអង្គទ្រង់កោតស្ញប់ស្ញែងដល់ជីវិតដ៏មានតម្លៃ និងដ៏ផុយស្រួយបំផុត ដែលមនុស្សលោកមាន។ ព្រះអង្គបាននឹកឃើញឡើងវិញកាលពីថ្ងៃដែលព្រះអង្គនិងព្រះនាងពិម្ពាយសោធរាបានយាងទៅចូលរួមនៅក្នុងពិធិបូជាសពកុមារទុគ៌តម្នាក់ អាយុប្រមាណជា៤ឆ្នាំនោះ។ ព្រះអង្គបានសម្លឹងទៅកាន់ព្រះនាងយសោធរាដោយមានទឹកនេត្រារលីងរលោងដែលមើលទៅហាក់ដូចជាទ្រង់ព្រះកន្សែងដែរ។ ព្រះអង្គទ្រង់ព្រះតំរិះថា៖

"ឱបុត្រាសំឡាញ់! តើបុត្រាត្រូវវិលទៅកាន់ទីណាដែរ ក្នុងពេលឥឡូវនេះ?"

ព្រះអង្គទ្រង់ហុចបុត្រារាហុលជូនទៅព្រះមហេសីវិញ។ បន្ទាប់មកទើបទ្រង់យាងចេញទៅគង់នៅក្នុងឧទ្យាននាខាងក្រៅព្រះរាជដំណាក់តែមួយអង្គឯង រហូតដល់ស្រមោលរាត្រីធ្លាក់ចុះដណ្តប់លើផែនពសុធា។



"កើតមកជាមនុស្សជាការពិបាក។ រស់ជាមនុស្សដែលត្រូវតែស្លាប់ទៅវិញជាការពិបាក។ បានស្តាប់ឮសេចក្តីពិតបំផុតជាការពិបាក។ បានមើលឃើញព្រះពុទ្ធជាការពិបាក។"

ធម្មបទភាគ ១៨២

---

# ជំពូកទី ៧
# សេះកណ្ឋក:

ថ្ងៃមួយ នៅក្នុងនិទាឃរដូវ នាយសារថីឆន្នបានបររទេះសេះនាំព្រះអង្គម្ចាស់សិទ្ធត្ថ ព្រះនាងពិម្ពាយសោធរា រាហុលកុមារ និងស្រីស្នំម្នាក់ឈ្មោះ រ័ត្ន សំដៅទៅកាន់ស្រុកស្រែដើម្បីយាត្រាកំសាន្ត។

នៅពេលធ្វើដំណើរជិតដល់មាត់ទន្លេគង្គាក៏ស្រាប់តែប្រទះនឹងមនុស្សឈឺម្នាក់អាយុប្រម៉ាណជា៣០ឆ្នាំ កំពុងដេកស្តូកស្តឹងកាត់ទទឹងផ្លូវនៅចំពីមុខរាជរថ។ កាលបានទតឃើញដូច្នោះ ព្រះអង្គម្ចាស់សិទ្ធត្ថៈទ្រង់លោតចុះអំពីយានយ៉ាងរហ័ស ឆន្នអាមាត្យក៏ស្ទុះរត់តាមប្រកិតពីខាងក្រោយ។ ព្រះអង្គសម្លឹងយ៉ាងយូរ មុននឹងយកព្រះហស្តចាប់ក្តាប់ដៃជនរងគ្រោះនោះ។ ឆន្នអាមាត្យឃើញដូច្នោះក៏បង្គំទូលព្រះអង្គថា៖

"បពិត្រព្រះអង្គម្ចាស់! ទោះបីជាវេជ្ជបណ្ឌិតនៅក្នុងព្រះរាជវាំង ក៏ពុំអាចនឹងព្យាបាលជម្ងឺជនរងគ្រោះនេះបានដែរ។ ទូលព្រះបង្គំដឹងយ៉ាងច្បាស់ថាជម្ងឺប្រភេទនេះអាចឆ្លងរាលដាលយ៉ាងសាហាវបំផុត។"

នៅពេលព្រះអង្គម្ចាស់សិទ្ធត្ថៈទតទៅកាន់ជនរងគ្រោះនោះម្តងទៀត ស្រាប់តែបាត់ដង្ហើមឈឹង។ ព្រះអង្គដកព្រះហស្តចេញមកវិញ រួចយកទៅបិទភ្នែកទាំងគូនៃជនរងគ្រោះនោះដោយស្ងាត់ស្ងៀម។ បន្ទាប់មក ព្រះសិទ្ធត្ថក៏បន្តព្រះរាជដំណើរទៅកាន់ភូមិខាងមុខទៀត ដើម្បីប្រាប់ដល់រដ្ឋអំណាចនៅទីនោះ ដោយគេយកសពនោះទៅបូជាតាមប្រពៃណី។ ក្រោយពីបានឃើញនូវឧប្បត្តិហេតុដ៏ចម្លែកនេះព្រះអង្គម្ចាស់សិទ្ធត្ថនិងព្រះនាងពិម្ពា ពុំមានបំណងបន្តដំណើរកំសាន្តទៅមុខទៀតឡើយ។ ព្រះអង្គម្ចាស់ទ្រង់បង្គាប់អោយនាយសារថី

ឆន្ទបរយានអាជានេយ្យ ត្រឡប់ចូលកាន់ព្រះបរមរាជវាំងវិញ។ នៅតាមដងផ្លូវត្រឡប់ទៅកាន់ព្រះរាជវាំងវិញនោះ គ្មាននរណាម្នាក់ជជែកគ្នាមួយមាត់ឡើយ។

នារាត្រីនោះ ព្រះនាងពិម្ពាយបានសុបិនឃើញនូវរឿងដ៏ចម្លែកៗ៣លើកគឺ៖

សុបិនលើទី១ ព្រះនាងទតឃើញ គោឧសភរាជ(គោរាជ) សម្បុរសក្បុសមួយ ពាក់គ្រឿងអលង្ការពីលើក្បាល ចាំងពន្លឺភ្លឺព័ណ្ណរាយដូចជាពន្លឺផ្កាយទិសឧត្តរ។ គោឧសភរាជដើរយ៉ាងលំហែកាត់តាមរាជធានីកបិលពស្តុក្បាលឆ្ពោះទៅកាន់ក្លោងទ្វារក្រុង។ ស្នូរសម្លេងស្រែកកងរំពងពីរានព្រះឥន្ទថា៖

"បើអ្នកមិនអាចរក្សាគោឧសភរាជនេះបានទេ រាជធានីទាំងមូលច្បាស់ជាគ្មានពន្លឺរស្មីឡើយ។"

មនុស្សម្នាក់ៗនៅក្នុងរាជធានីនាំគ្នារត់ប្រដេញតាមពីក្រោយគោឧសភរាជនោះប៉ុន្តែគ្មាននរណាម្នាក់អាចស្ទាក់ចាប់គោឧសភរាជនោះបានឡើយ។ គោឧសភរាជដើរចេញទៅតាមក្លោងទ្វាររាជធានី ធ្វើព្រងើយរហូតដល់មើលលែងឃើញ។

សុបិនលើកទី២ ព្រះនាងពិម្ពាយសោធរាទតឃើញសកទេវរាជបួនអង្គ នៅលើកំពូលភ្នំព្រះសុមេរ៉ុបញ្ចេញរស្មីភ្លឺផ្លេកមកលើរាជធានីកបិលពស្តុ។ ក្នុងគ្រានោះទង់ដែលដោតនៅលើរានព្រះឥន្ទត្រូវខ្យល់បោកបក់យ៉ាងខ្លាំងហើយក៏ដួលធ្លាក់ចុះមកលើដី។ មានផ្កាគ្រប់ពណ៌ធ្លាក់ចុះមកពីលើមេឃរោយរាយដូចទឹកភ្លៀងនិងមានទេពអប្សរច្រៀងលាន់សូរកងរំពងពេញទាំងរាជធានី។

សុបិនលើកទី៣ ព្រះនាងពិម្ពាយសោធរាបានស្តាប់ឮសម្រែកយ៉ាងខ្លាំងដែលធ្វើអោយរង្គើដល់ឋានសួគ៌ថា៖

"ដល់ពេលហើយ! ដល់ពេលហើយ! ដោយមានការភ័យតក់ស្លុតខ្លាំងពេកព្រះនាងពិម្ពាក៏ទតឆ្ពោះទៅកាន់កៅអី ដែលព្រះសិទ្ធត្ថធ្លាប់គង់ ដើម្បីចង់ដឹងថាតើព្រះស្វាមីយាងទៅទីណា? ផ្កាម្ជុះដែលព្រះនាងខ្ទាស់ជាប់នៅលើព្រះសិរសាក៏របូតធ្លាក់ចុះទៅលើកំរាលព្រំ ហើយក៏ក្លាយជាលំអងធូលី។ ព្រះពស្ត្រនិងគ្រឿងសំអាងកាយដែលព្រះអង្គម្ចាស់សិទ្ធត្ថៈទុកចោលនៅលើកៅអីនោះ ក៏បានប្រែក្លាយទៅជាសត្វពស់ហើយលូនចេញតាម



ទ្វារបាត់ទៅ។ ព្រះនាងពិម្ពាយសោធរាមានការភ័យតក់ស្លុតយ៉ាងខ្លាំង។ ក្នុងគ្រាដដែលនោះ ព្រះនាងក៏បានឮសម្លេង គដោកគោឧសភរាជអំពីសម្ពាយឯនាយក្លោងទ្វាររាជធានី។ ព្រះនាងក៏បានឮសម្លេងទង់បក់ភ្លឹបៗ នៅលើរានព្រះឥន្ទនិងបានឮសម្លេងស្រែកពីឋានសួគ៌មកថា ពេលវេលាមកដល់ហើយ! ពេលវេលាមកដល់ហើយ!"

រំពេចនោះ ព្រះនាងពិម្ពាក៏ទ្រង់ភ្ញាក់ក្រញាងឡើង ថ្ងាសរបស់ព្រះនាងទទឹកជោកសុទ្ធតែញើស។ ព្រះនាងបែរព្រះភ័ក្ត្រឆ្ពោះទោរកព្រះស្វាមី ហើយក៏ចាប់អង្រួនព្រះអង្គអោយតើនឡើង។

តាមពិត ព្រះអង្គម្ចាស់សិទ្ធត្ថទ្រង់តើន រួចជាស្រេចទៅហើយ។ ព្រះអង្គទ្រង់លើកព្រះហស្តទទះអង្អែលព្រះសិរសាមហេសី និងទ្រង់មានព្រះបន្ទូលល្ហងលោមថា៖

"អូនពិម្ពាសំឡាញ់! តើអូនសុបិនឃើញដូចម្តេចដែរ? ព្រះនាងពិម្ពាក៏បង្គំទូលរៀបរាប់សារឡើងវិញ នូវរឿងសុបិននិមិត្តទាំង៣លើកនេះថ្វាយព្រះស្វាមី ទ្រង់ព្រះសណ្តាប់។ ជាទីបញ្ចប់ព្រះនាងបានសួរបញ្ជាក់ព្រះស្វាមីថា៖

"ម្ចាស់បង! តើសុបិនដ៏ចម្លែកនេះពិតជាប្រផ្នូលថាម្ចាស់បងនឹងត្រូវយាងចាកចោលអំពីរូបអូនក្នុងពេលឆាប់ៗនេះ ដើម្បីស្វែងរកនូវគន្លងធម៌ដ៏ឧត្តមនោះមែនទេ?"

ព្រះសិទ្ធត្ថគង់នៅស្ងៀមមួយសន្ទុះ ទើបទ្រង់អង្វរល្ហួងលោមមហេសីថា៖

"ពិម្ពាអូន! សូមអូនកុំព្រួយបារម្ភអី អូនជាស្រ្តីដែលចេះយល់ជម្រៅកិច្ចការ។ អូនពិតជាដៃគូរបស់បង ជាអ្នកដែលអាចជួយបងបានក្នុងបេសកម្មស្វែងរកពន្លឺត្រាស់ដឹងដ៏ឧត្តម។ អូនពិតជាយល់ចិត្តបងជាងអ្នកណាទាំងអស់។ បើសិនជាអនាគតដ៏ខ្លីខាងមុខនេះ បងនឹងត្រូវចាកចោលអំពីអូនឬនឹងធ្វើដំណើរឃ្លាតឆ្ងាយអំពីរូបអូន បងដឹងជាប្រាកដថា អូនពិតជាមានសេចក្តីក្លាហាន ក្នុងការបន្តកិច្ចការរបស់អូនទៅមុខទៀតពុំខានឡើយ។ ពិម្ពាអូននឹងថែធូន ព្រមទាំងបីចាប់រក្សាដល់បុត្រារាហុលរបស់យើងបានយ៉ាងប្រពៃ។ បើដូច្នេះបងនឹងយាងចេញទៅបងនឹងត្រូវឃ្លាតឆ្ងាយពីរូបអូនយ៉ាងពិតប្រាកដ។ ពិម្ពាអូន! សេចក្តីស្រឡាញ់របស់បងចំពោះរូបអូនស្ថិតនៅដដែលឥតមានការផ្លាស់ប្តូរអ្វីបន្តិចបន្តួចឡើយ។ បងមិនអាចឈប់ស្រឡាញ់អូនបានទេ! ជាមួយអ្វីដែលអូនធ្លាប់បានដឹងរួចមកហើយ អូនប្រាកដ

ជាអាចអត់ទ្រាំបាន ចំពោះការរស់នៅបែកពីគ្នានេះ។ ពេលណាដែលបងបានរកឃើញនូវពន្លឺត្រាស់ដឹងនោះហើយបងនឹងវិលត្រឡប់មករកអូនពិសីនិងបុត្រារាហុលសំឡាញ់របស់យើងវិញជាដាច់ខាត។ ពិម្ពាអូន! ហាក់ដូចជានៅយប់យូរក្រៃលណាស់ដែលសូមអូនចូលទៅផ្ទំបន្តទៀតចុះ។"

ព្រឹកស្អែកឡើង ព្រះសិទ្ធត្ថៈយាងចូលទៅគាល់ព្រះបាទសុទ្ធោទន៍ ជាព្រះបិតាដើម្បីទ្រង់ព្រះមេត្តាប្រោសនិងរាជាអនុញ្ញាតចេញទៅសាងបព្វជ្ជា ស្វែងរកពន្លឺត្រាស់ដឹង។ ព្រះមហាក្សត្រមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ទ្រង់មិនយល់ព្រមតាមសំណូមពររបស់ព្រះរាជបុត្រឡើយ។ ព្រះរាជាព្យាយាមពន្យល់និងអង្វរករដល់ព្រះរាជបុត្រថា៖

"សិទ្ធត្ថៈ! នៅក្នុងប្រវត្តិសាស្ត្រនៃសក្យត្រកូលនេះ គ្មានក្សត្រអង្គណាមួយចេញទៅបួសជាព្រះសង្ឃទាំងក្មេងល្ងក់ប្រហែលព្រះជន្មរបស់បុត្រដូច្នោះទេ។ បុត្រត្រូវតែគិតអំពីនគររបស់យើង គិតអំពីមាតាបិតា មហេសីយសោធរា រាហុលកុមារ ដែលនៅតូចខ្ចី ព្រមទាំងប្រជាពលរដ្ឋ ក្មេងចាស់ ប្រុសស្រីទូទាំងនគរ ដែលគេនាំគ្នាទីពឹងទាំងស្រុងមកលើបុត្រាតែមួយអង្គគត់នោះផង។ បុត្របានដឹងទេថា តើបិតាត្រូវការបុត្រប៉ុណ្ណានោះ? បុត្រត្រូវនៅស្នងរាជ្យសម្បត្តិជំនួសបិតា និងគ្រប់គ្រងប្រជាពលរដ្ឋក្នុងនគរ។ សូមបុត្រកុំយាងទៅឯណាឆ្ងាយអំពីបិតាអោយសោះណា!"

ព្រះសិទ្ធត្ថទ្រង់បានខំព្យាយាមពន្យល់ព្រះបិតាអោយជឿព្រះអង្គណាស់ដែរថា៖

"បពិត្រព្រះវរបិតា! សូមព្រះបិតាទ្រង់ប្រោសប្រណីដល់បុត្រផងទៅចុះ ទូលព្រះបង្គំនឹងមិនបោះបង់ចោលព្រះបិតាព្រះមាតា អូនពិម្ពាយសោធរានិងរាហុលកុមារព្រះទាំងព្រះញាតិវង្សានុវង្ស និងប្រជាពលរដ្ឋទាំងអស់ឡើយ។ ទូលព្រះបង្គំគ្រាន់តែសូមព្រះរាជាអនុញ្ញាតចេញទៅឆ្ងាយមួយរយៈប៉ុណ្ណោះ។ ពេលណាដែលបុត្រាបានរកឃើញពន្លឺត្រាស់ដឹងដ៏ឧត្តមនោះហើយ បុត្រសន្យាថានឹងវិលថ្កានចូលនគរវិញ។"

ព្រះរាជាប្រកែកដាច់អហង្ការថា៖ "សិទ្ធត្ថ! បុត្រធ្វើយ៉ាងនេះមិនបានដាច់ខាត!"

ព្រះសិទ្ធត្ថៈក៏មិនហ៊ានពន្យល់ព្រះវរបិតាតទៅទៀតទើបទ្រង់ថ្វាយបង្គំលាចេញបាត់ទៅ។ ព្រះមហាក្សត្រក៏ស្តេចយាងទៅសំរាកព្រះកាយពលនៅក្នុងក្រឡាបន្ទំដែរ។



នាថ្ងៃព្រហស្បតិ៍១៥កើតពេញបូណ៌មី ខែអាសាឍឆ្នាំថោះ នៅក្នុងវាំងមានធ្វើពិធីជប់លៀងរាំរែកមួយយ៉ាងសប្បាយ។ យប់ជ្រៅណាស់ទៅហើយ ព្រះនាងបជាបតិគោតមីដែលមកលេងនឹងព្រះនាងយសោធរា ក៏មិនទាន់ត្រឡប់ទៅកាន់ប្រាសាទព្រះនាងវិញដែរ។ ព្រះនាងពិម្ពាអើតមើលតាមថៃវប្រាសាទ ពួកភ្លេងរាំរែកនោះក៏មិនទាន់ឈប់នៅឡើយ។ ពេលដែលព្រះនាងយសោធរាត្រឡប់មកពីជូនដំណើរព្រះនាងគោតមីទៅកាន់ប្រាសាទវិញ ព្រះនាងក៏យាងសំដៅទៅកាន់ផ្ទះនាយសារថីឆន្ទតែមួយព្រះអង្គឯង។ ព្រះនាងបានដាស់ឆន្ទអាមាត្យអោយក្រោកឡើង រួចទ្រង់ខ្សឹបប្រាប់ថា៖

"នែឆន្ទ! ជាប្រាកដណាស់ដែលព្រះស្វាមីត្រូវការរូបអ្នក ទាំងពាក់កណ្តាលអធ្រាត្រនេះ។ ចូរអ្នករៀបចំអាជានេយ្យកណ្ឋកៈយ៉ាងប្រញាប់ ហើយសូមអ្នកដាក់បង្ហៀរនិងកែបថ្វាយព្រះអង្គអោយបានស្រួលបួលផង។"

នាយសារថីឆន្ទមានការងឿងឆ្ងល់ក៏បង្គំទូលសួរថា៖

"ព្រះអង្គម្ចាស់ក្សត្រី! តើព្រះអង្គម្ចាស់សិទ្ធត្ថមានព្រះបំណងយ៉ាងណាដែរ?"

ព្រះនាងពិម្ពាទ្រង់បន្តថា៖

"ម្នាលឆន្ទ! អ្នកកុំចាំបាច់សួរដេញដោលអី ធ្វើតាមបង្គាប់ខ្ញុំទៅបានហើយ។"

នាយសារថីឆន្ទមិននិយាយអ្វីក្រៅពីងក់ក្បាលបង្ហាញការយល់ព្រមប៉ុណ្ណោះ។

ព្រះនាងពិម្ពាលាឆន្ទ យាងចូលកាន់ព្រះរាជតំណាក់វិញដោយស្ងាត់ស្ងៀម។ ព្រះនាងរងចាំស្វាមីអស់ពេលយ៉ាងយូរ ក៏ពុំឃើញព្រះអង្គត្រឡប់ចូលក្រឡាបន្ទំវិញ។

ព្រះអង្គម្ចាស់សិទ្ធត្ថ គង់នៅខាងក្រៅតែមួយព្រះអង្គឯង ទតឃើញពន្លឺព្រះច័ន្ទនិងហ្វូងតារាទាំងឡាយ។ ព្រះអង្គបានដាក់ព្រះទ័យចាកចេញអំពីព្រះរាជវាំងទាំងពាក់កណ្តាលរាត្រីនេះជាដាច់ខាត។ ទីបំផុតព្រះអង្គយាងចូលទៅក្នុងបន្ទប់ រួចក៏ទ្រង់ផ្លាស់គ្រឿងអម្ពរសំរាប់ធ្វើដំណើរដែលព្រះនាងពិម្ពាបានរៀបចំទុកថ្វាយនៅលើកៅអីនោះ។ ព្រះអង្គយកព្រះហស្តវែកវាំងននរសន្សឹមៗ រួចសម្លឹងទៅកាន់ពិម្ពាមហេសី និងរាហុលបុត្រាដែលកំពុងផ្ទំលង់លក់។ ព្រះអង្គហាក់ចង់យាងចូលទៅផ្តែផ្តាំនូវពាក្យខ្លះមុននឹងទ្រង់យាងព្រះដំណើរចេញ តែទ្រង់នៅស្ងាក់ស្ទើរក្នុងព្រះចិន្តា។ រួចក៏ទ្រង់ព្រះតំរិះថា៖

"អាត្មាអញបានពោលរៀបរាប់នូវអ្វីៗ ដែលមានសារៈសំខាន់ ប្រាប់ដល់ពិម្ពាមហេសីសំឡាញ់រួចអស់ហើយ។ ប្រសិនបើអាត្មាអញដាស់មហេសីក្នុងពេលឥឡូវនេះនឹងអាចធ្វើអោយការចេញដំណើររបស់អាត្មាអញមានការឈឺចាប់រឹតតែខ្លាំងឡើង។"

កាលទ្រង់ព្រះតំរិះរួចហើយ ព្រះអង្គក៏ទម្លាក់វាំងននចុះមកវិញ ហើយយាងថយចេញភ្លាមទៅ។ ព្រះសិទ្ធត្ថៈមិនអស់ចិត្តសោះ ក៏ទ្រង់ចាប់បង្ហើបវាំងននម្តងទៀតដើម្បីទតមើលមហេសី និងបុត្រាក្នុងនាទីចុងក្រោយបំផុត។ ព្រះអង្គខំទតយ៉ាងខ្លាំងរហូតដល់រូបភាពនៃមហេសីនិងបុត្រាជិតជាប់ក្នុងព្រះអារម្មណ៍។ ទីបំផុតព្រះអង្គទ្រង់ទម្លាក់វាំងននចុះមកវិញសន្សឹមៗ រួចហើយក៏យាងចេញបាត់តែម្តងទៅ។

ខណៈដែលព្រះអង្គម្ចាស់សិទ្ធត្ថៈយាងកាត់តាមល្វែងទទួលភ្ញៀវ ទ្រង់បានទតឃើញនារីចម្រៀងរបាំដេកលក់ស្តូកស្តឹងលើកំរាលមានសក់សំពីងសំពោង ហារមាត់ច្រវាបដូចត្រីងាប់។ ដៃដែលគេរាំដ៏ទន់ល្វន់ល្វែតពីព្រលប់នោះ ឥឡូវនេះក៏ក្លាយរឹងឆ្អឹងដូចជាអង្កត់អុស។ ជើងរបស់គេគងគាក់លើគ្នាទៅវិញទៅមកបីដូចជាមនុស្សស្លាប់ក្នុងទីសមរភូមិ។ ព្រះសិទ្ធត្ថមានព្រះអារម្មណ៍ដូចជាទ្រង់យាងកាត់ព្រៃខ្មោចដ៏ស្ងាត់។

ពេលស្តេចយាងទៅដល់ក្រោលសេះ ទ្រង់ទតឃើញនាយសារថីនៅភ្ញាក់នៅឡើយ។ ឆន្នអាមាត្យបានដឹកសេះកណ្ឋកៈ ដែលបានពាក់បង្ហៀរនិងកែបរួចជាស្រេចហើយនោះថ្វាយដល់ព្រះអង្គ។ នាយឆន្នអាមាត្យត្រូវបានព្រះសិទ្ធត្ថអនុញ្ញាតអោយធ្វើដំណើរទៅជាមួយដែរ។ ព្រះសិទ្ធត្ថៈនិងនាយសារថីបណ្តើរសេះកណ្ឋកៈចេញដំណើរយឺតៗនិងយ៉ាងស្ងៀមស្ងាត់បំផុត សំដៅទៅកាន់ក្លោងទ្វារវាំងខាងក្រៅ។ ឆ្មាំទ្វារទាំងអស់ដេកលក់ស្ងាត់ឈឹង ដែលជាឱកាសល្អមួយ ធ្វើអោយព្រះសិទ្ធត្ថនិងឆន្នអាមាត្យអាចឆ្លងកាត់ក្លោងទ្វារវាំងបានយ៉ាងស្រួល។ ព្រះសិទ្ធត្ថទ្រង់ឡើងគង់លើសេះកណ្ឋកៈដោយដាក់ឆន្នអាមាត្យអង្គុយពីខាងក្រោយ។ សេះលន់យ៉ាងពេញទំហឹងឆ្ពោះទៅទិសខាងត្បូង ក្រោមពន្លឺព្រះច័ន្ទដ៏ថ្លា នាថ្ងៃពេញបូណ៌មី។

កាលទ្រង់យាទៅបានបន្តិច ក៏មានវាមាធិរាជមកបង្អាក់ដំណើរព្រះអង្គថា៖

"នៃសិទ្ធត្ថ! ចូរអ្នកកុំចេញទៅបួសអី អំណើះតែ៧ថ្ងៃទៀតទេ សម្បត្តិចក្រនឹងកើត



ឡើងដល់អ្នកហើយ។"

ប៉ុន្តែព្រះអង្គទ្រង់កាត់ព្រះទ័យ ដោយពោលតបនឹងមារថា៖

"អាត្មាអញមិន អាលោះអាល័យនឹងសម្បត្តិមហាចក្រនោះឡើយ។"

លុះព្រះអង្គបានឃ្លាតខន្ធសន្តានអស់ហើយ ទ្រង់បន្លឺនូវព្រះវាចាថា៖ "រាហុល! រាហុល! រួចទ្រង់ញាក់សេះអស្សតរ បន្តព្រះដំណើរទៅមុខទៀតយ៉ាងលឿន។

---

# ជំពូកទី៨
# ព្រះសិទ្ធត្ថយាងចេញសាងព្រះផ្នួស

នេះគឺជាការធ្វើដំណើរមួយយ៉ាងវែង លេចវាលចូលព្រៃ លេចព្រៃចូលវាល រហូតដល់ពេលថ្ងៃរះ ទើបព្រះអង្គម្ចាស់សិទ្ធត្ថនិងឆន្នអាមាត្យបានឆ្លងផុតព្រំដែននគរទាំងបីគឺ៖ កបិលពស្តុ១ សាវត្ថី១ និង វេសាលី១ អស់ចម្ងាយផ្លូវ៣០យោជន៍(ប្រមាណជា២១៨គីឡូម៉ែត្រ) និងឆ្លងកាត់ ស្ទឹងអនោមា មុននឹងស្តេចយាងទៅដល់មាត់ព្រៃស្តុកមួយឈ្មោះ អនុបិយម្ពវ័ន ក្នុង ដែនមល្លៈ ក្នុងរដ្ឋពិហារ សព្វថ្ងៃ។

ព្រះអង្គម្ចាស់សិទ្ធត្ថទ្រង់លោតចុះអំពីខ្នងសេះកណ្ឋកៈ ហើយទ្រង់ថ្លែងអំណរគុណដល់សេះនោះថា៖

"កណ្ឋកៈសំឡាញ់! ខ្ញុំអរគុណច្រើនណាស់ ដែលអ្នកបានជូនដំណើរខ្ញុំមកដល់ទីនេះ។"

អាជានេយ្យកណ្ឋកៈក៏ងើបក្បាលអង្រួន ហើយសម្លឹងទៅកាន់ព្រះអង្គដោយយកចិត្តទុកដាក់និងពេញចិត្តបំផុត។

ព្រះអង្គម្ចាស់សិទ្ធត្ថបានដកព្រះខ័នចេញពីស្រោមដែល ចងភ្ជាប់នឹងកែបសេះរួចទ្រង់ចាប់ក្របួចព្រះមោលី(ថ្នួងសក់) ដោយព្រះហស្តឆ្វេង កាត់ព្រះកេសា(សក់) អោយនៅខ្លីស្មើត្រឹមឫសឬត្រឹមពីរធ្នាប់។ ទ្រង់ក៏ហុចព្រះមោលី ព្រមទាំងព្រះខ័ននោះទៅអោយឆន្នអាមាត្យ។ បន្ទាប់មក ព្រះអង្គដោះខ្សែព្រះសុវង ហុចទៅអោយមុននឹងមានព្រះបន្ទូលថា៖

"ឆន្នអាមាត្យ! សូមបងប្រុសយករបស់ទាំងនេះទៅថ្វាយដល់ព្រះវរបិតា បិតាខ្ញុំផង និងបង្គំទូលព្រះអង្គអោយទុកព្រះទ័យលើខ្ញុំចុះ។ ខ្ញុំមិនមែនជាអ្នករត់ចោលផ្ទះ ដើម្បីគេចវេះនូវការទទួលខុសត្រូវការងាររបស់ខ្ញុំនោះទេ។ ខ្ញុំមកនេះ ក្នុងនាមនៃមនុស្សទាំងឡាយ និងសំរាប់សព្វសត្វលោក។ សូមបងប្រុសជួយអង្វរលួងលោមដល់ព្រះវរបិតា ព្រះវរមាតា និងអូនពិម្ពាយសោធរាជំនួសខ្ញុំផងណា!"

ពេលលើកដៃទទួលខ្សែព្រះសុរងជាចុងក្រោយ នាយឆន្នស្រក់ទឹកភ្នែកម៉ាត់ៗហើយក៏បង្គំទូលវិញយ៉ាងរអាក់រអួលថា៖

"បពិត្រព្រះអង្គម្ចាស់! វាល់ព្រះអង្គនឹងព្រួយព្រះហឫទ័យខ្លាំងហើយ ចំពោះព្រះអង្គ។ ទូលបង្គំមិនដឹងជាយកពាក្យអ្វីទៅពណ៌នាទូលដល់ព្រះមហាក្សត្រ និងព្រះមហាក្សត្រីយានី ព្រះទាំងព្រះនាងពិម្ពាដែលជាព្រះមហេសីរបស់ព្រះអង្គបានឡើយ។ បពិត្រព្រះអង្គម្ចាស់! តើព្រះអង្គផ្ទំនៅក្រោមដើមឈើដូចតាបសឥសីម្ដេចនឹងកើតបើក្នុងជីវិតរបស់ព្រះអង្គៗពុំដែលស្គាល់អ្វីក្រៅអំពីព្រះសយនា និងជាហ៊ុមដ៏ទន់ល្មើយនិងកក់ក្ដៅដូច្នោះសោះនោះ?"

ព្រះសិទ្ធត្ថៈទ្រង់មានព្រះបន្ទូលដោយព្រះភ័ក្ត្រញញឹមថា៖

"កុំបារម្ភអីឆន្នអាមាត្យ! មនុស្សដទៃគេរស់នៅយ៉ាងណាកើត ខ្ញុំក៏អាចរស់បានដូចជាគេយ៉ាងនោះដែរ។ សូមទុកអោយខ្ញុំនៅទីនេះម្នាក់ឯងចុះ មិនអីទេ!"

ព្រះសិទ្ធត្ថយកព្រះហស្ដអង្អែលក្បាលអាជានេយ្យកណ្ឋកៈម្ដងទៀតថា៖

"កណ្ឋកៈសំឡាញ់! ឥឡូវនេះអ្នកវិលទៅវាំងជាមួយនឹងឆន្នអាមាត្យវិញចុះ!"

កាលចេញដំណើរផុតពីរង្វង់ចក្ខុព្រះសិទ្ធត្ថមក សេះកណ្ឋកៈដែលមានចិត្តនឹកស្រណោះអាល័យម្ចាស់ខ្លាំងពេកក៏បែកទ្រូងស្លាប់ទៅ។ ចំណែកឯឆន្នះអាមាត្យ កាលបើសេះកណ្ឋកៈបែកទ្រូងស្លាប់ហើយ ក៏ស្ដាយបង្វិចត្រឡប់ទៅនគរវិញដោយសេចក្ដីទោមនស្សយ៉ាងខ្លាំងក្រៃលែង។

មួយស្របក់ក្រោយមក មានបុរសម្នាក់ដើរចេញពីក្នុងព្រៃមក។ នៅពេលព្រះអង្គក្រឡេកឃើញពីដំបូង ព្រះសិទ្ធត្ថស្មានក្នុងព្រះចិន្ដាថាជាព្រះសង្ឃ ពីព្រោះបុរសនោះស្លៀកពាក់ដូចជាអ្នកបួស។ នៅពេលបុរសនោះដើរមកជិតដល់ទើបព្រះអង្គទតឃើញបុរសនោះ



កាន់ធ្នូនិងមានបំពង់ព្រួញពាក់ឆៀងនៅពីក្រោយខ្នងផង។ ព្រះសិទ្ធត្ថទ្រង់ត្រាស់សួរថា៖

"ម្នាល់សំឡាញ់! តើអ្នកជាព្រានព្រៃមែនទេ?"

បុរសក៏ឆ្លើយថា៖ "បាទទានប្រុស ខ្ញុំបាទនេះជាព្រានព្រៃមែនហើយទាន!"

ព្រះអង្គទ្រង់សួរថា៖ "បើអ្នកជាព្រាន ហេតុអ្វីបានជាអ្នកស្លៀកពាក់ដូចជាអ្នកបួសយ៉ាងដូច្នោះ?"

ព្រានញញឹមហើយឆ្លើយតបថា៖ "ដោយសារតែសំលៀកបំពាក់នេះហើយដែលមិនធ្វើអោយសត្វទាំងឡាយផ្អើលនឹងរូបខ្ញុំហើយខ្ញុំបាទក៏អាចបាញ់វាបានស្រួល!"

ព្រះអង្គម្ចាស់សិទ្ធត្ថងក់ព្រះសិរបង្ហាញការយល់ព្រម រួចទ្រង់មានព្រះបន្ទូលទៀតថា "ម្នាលព្រាន! តើអ្នកសុខចិត្តប្ដូរអាវរបស់អ្នកជាមួយនឹងសំលៀកបំពាក់របស់ខ្ញុំនេះបានដែរទេ?"

ព្រានព្រៃសួរបញ្ជាក់ថា៖ "តើលោកប្រាកដជាចង់ដូរមែនឬ?"

ព្រះអង្គម្ចាស់សិទ្ធត្ថឆ្លើយថា៖ "ប្រាកដណាស់ហើយ! គ្រាន់តែលក់សំលៀកបំពាក់អស់ទាំងនេះ ក៏អ្នកអាចមានប្រាក់គ្រប់គ្រាន់សំរាប់ចាយវាយក្នុងការចិញ្ចឹមជីវិតដែរ មិនចាំបាច់ដើរបាញ់សត្វទៀតឡើយ។ ដោយខ្ញុំមានប្រាថ្នាចង់បួសជាព្រះសង្ឃទើបខ្ញុំត្រូវការសំលៀកបំពាក់បែបព្រានឯងនេះណា!"

បន្ទាប់ពីបានប្ដូរសំលៀកបំពាក់ជាមួយព្រះអង្គម្ចាស់សិទ្ធត្ថៈរួចមក ព្រានព្រៃនោះសប្បាយចិត្តហក់កញ្ឆេង រួចហើយក៏ដើររួតរះយ៉ាងលឿនចេញបាត់ទៅ។

ឥឡូវនេះ ព្រះសិទ្ធត្ថទ្រង់មានអាការៈខាងក្រៅ ដូចជាបព្វជិតមួយអង្គហើយ។ ព្រះអង្គយាងចូលទៅក្នុងព្រៃនោះដើម្បីរកម្លប់ឈើគង់។ ក្នុងនាមជាបព្វជិតឥតទីជម្រកព្រះអង្គទ្រង់គង់ក្នុងរបៀបសមាធិ ដើម្បីក្រេបយកសេរីភាពនៃគំនិតធម្មជាតិដែលព្រះអង្គបានទទួលជាលើកដំបូង នៅពេលយាងមកដល់ក្នុងព្រៃនេះ។ នៅពេលព្រះអង្គបើកព្រះនេត្រឡើងស្រាប់តែព្រះសិទ្ធត្ថឃើញព្រះសង្ឃមួយអង្គ ឈរនឹងថ្កល់នៅចំពោះព្រះភ័ក្ត្រព្រះអង្គ។ ព្រះសង្ឃអង្គនោះមានព្រះភ័ក្ត្រនិងព្រះកាយស្គមស្គាំងហាក់រស់នៅក្នុងជីវភាពដ៏គ្រៀមក្រោះដែលមានព្រះនាមថា "ភគវា"។ ព្រះសមណសិទ្ធត្ថទ្រង់ធ្វើគារវកិច្ចថ្វាយបង្គំហើយសួរថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះករុណាធ្វើដំណើរទៅកាន់ទិសខាងត្បូងនេះក្នុងគោលបំណងស្វែងរកអាស្រមអាឡារតាបសកាលាមគោត្រ"។

ព្រះសង្ឃអង្គនោះបានទូលព្រះសមណសិទ្ធត្ថថា៖

"រូបអាត្មាផ្ទាល់ ក៏ត្រូវជា សិស្សរបស់អាឡារតាបសដែរ។"

ព្រះសង្ឃភគវាមានការសប្បាយចិត្តយ៉ាងខ្លាំងកាលដែលបានឮថាព្រះសិទ្ធត្ថទ្រង់មានបំណងចង់ទៅជួបជាមួយអាឡារតាបសដែលជាគ្រូរបស់ព្រះអង្គ។ សមណៈទាំងពីរអង្គក៏ធ្វើដំណើរចូលទៅកាន់សំណាក់អាឡារតាបស។ ក្នុងព្រះដំណើរតាមផ្លូវព្រះសង្ឃភគវាឆ្លៀតឱកាសពន្យល់ព្រះសមណសិទ្ធត្ថ អំពីចំណីអាហារណាដែលអាចឆាន់បានដូចជាផ្លែ ស្លឹក និងឫសរុក្ខជាតិជាដើម។ ព្រះសមណៈសិទ្ធត្ថបានសង្កេតមើលនូវរបៀបប្រតិបត្តិតបះនៃព្រះសង្ឃភគវានោះ។

៩ថ្ងៃកន្លងមកទើបសមណៈទាំងពីរអង្គ និមន្តដល់អាស្រមអាឡារតាបស ឋិតនៅជិតអនុបិយម្ពវ័ន។ អាឡារតាបសមានព្រះជន្មប្រហែល៧០ឆ្នាំ ហើយមានព្រះ ព្រះកាយស្គមស្គាំងមិនសូវមានកម្លាំងមាំមួនទេ។ ប៉ុន្តែ ព្រះនេត្ររបស់ព្រះអង្គភ្លឺចាំងឆ្លុះរស្មីនិងមានសម្លេងឮសូរខ្ទ័រដូចរគាំង។ អាឡារតាបសគង់នៅក្នុងខ្ទមប្រក់ស្បូវជាមួយនឹងសាវ័ករបស់ព្រះអង្គចំនួន៤០០រូបទៀត។ អាឡារតាបសបានទទួលព្រះសិទ្ធត្ថធ្វើជាសាវ័ករបស់ព្រះអង្គនៅក្នុងថ្ងៃទៅដល់តែម្តង។ ព្រឹកស្អែកឡើង ព្រះសិទ្ធត្ថទ្រង់ទទួលបានបាត្រមួយ និងត្រូវបានអាឡារតាបសបង្រៀនអោយចេះត្រាច់ដើរបិណ្ឌបាតផង។ ព្រះសមណៈសិទ្ធត្ថរៀនទ្រូបាត្រ ដើរឈរទ្រង់បាត្រ និងសូត្រធម៌ជូនពរដល់អ្នកប្រគេនចង្ហាន់។ ថ្ងៃដំបូងនៃការត្រាច់បិណ្ឌបាត្រនៅក្នុងក្រុងវេសាលី ព្រះអង្គទទួលបានចង្ហាន់ជាបាយនិងសម្លការី ល្មមតែមួយចំអែត។

អាឡារតាបសបានបង្រៀនសមណសិទ្ធត្ថ ដោយយកចិត្តទុកដាក់បំផុត នូវរបៀបធ្វើចង្ក្រមភាវនា។ ក្នុងសំណាក់អាឡារតាបសនេះ ព្រះអង្គរៀនឈាន បានសំរេចត្រឹម សមាបត្តិទី៧ (ក្នុងសមាបត្តិ៨)គឺ៖ រូបឈាន៤ និង អរូបឈាន៣។

មនុស្សយើងគ្រប់រូបតែងគ្របសង្កត់ដោយចិត្ត១០យ៉ាង គឺ៖ ភាវនង្គ៥ និងមហានង្គ៥ (នីវរណៈ៥)។ ភាវនង្គ៥បានដល់៖ សមាធិ១(ចិត្តមូលតែមួយ) បីតិ១(ចិត្តអំណរខ្លាំង)



វិតក្កៈ១(ចិត្តត្រិះរិះនៅក្នុងកម្មដ្ឋាន) វិចារៈ១(ពិចារណាដុសខាត់ចិត្ត) និងសុខៈ១(សេចក្តីសុខកាយសប្បាយចិត្ត) និងមហានង្គឬនីវរណៈ៥ បានដល់ កាមច្ឆន្ទៈ១(ចិត្តត្រេកអរក្នុងកាមគុណ៥) ព្យាបាទ១(ចិត្តគុំគួនព្យាបាទគេ) ថីនមិទ្ធៈ១(ចិត្តធុញទ្រាន់ឬងោកងុយខ្លាំង) ឧទ្ធច្ចកុក្កុច្ចៈ១(ចិត្តរាយមាសាវ៉ា) និងវិចិកច្ឆា១(ចិត្តសង្ស័យស្ទាក់ស្ទើរ)។

អ្នកដែលបានសំរេច បឋមជ្ឈាន បានលះបង់ចោលនូវនីវរណៈ៥ នៅសល់តែភាវនង្គ៥គឺ៖ សមាធិ បីតិ វិតក្កៈ វិចារៈ និងសុខៈ ប៉ុណ្ណោះ។ ព្រះសមណសិទ្ធត្ថទ្រង់បានសំរេចឈានទី១ នេះរួចហើយ។

ក្នុងបណ្តាភាវនង្គទាំង៥ វិតក្កៈនិងវិចារៈ ជាធម៌មានសភាពគ្រោតគ្រាតនៅឡើយ ពីព្រោះអាចធ្វើអោយចិត្តវិលវល់បាន។ ត្រូវតែព្យាយាមបំបាត់វិតក្កៈនិងវិចារៈចេញ អោយនៅសល់តែ សមាធិ បីតិ និងសុខៈ។ កាលបើសំរេចដូច្នេះបានឈ្មោះថាជាអ្នកបានសំរេចទុតិយជ្ឈាន។ ព្រះសិទ្ធត្ថបានសំរេចនូវឈានទី២នេះរួចហើយ។

បីតិក៏ជាធម៌នៅមានសភាពគ្រោតគ្រាតដែរ ចៀសវាងការនាំចូលមក នូវធម្មជាតិអាក្រក់ដល់ចិត្ត ត្រូវតែព្យាយាមលះបីតិនេះចេញទៀតអោយនៅសល់តែសមាធិនិងសុខៈ។ អ្នកដែលបានសំរេចផលក្នុងថ្នាក់នេះឈ្មោះថាបានសំរេច តតិយជ្ឈាន។ ព្រះសមណសិទ្ធត្ថទ្រង់បានសំរេចនូវឈានទី៣នេះរួចហើយ។

សេចក្តីសុខក៏នៅមានសភាពគ្រោតគ្រាតដែរ ព្រោះសុខនិងទុក្ខជាគូនឹងគ្នា។ បើសុខមានទុក្ខក៏គង់នឹងមាន។ ដូច្នេះត្រូវតែព្យាយាមលះនូវសេចក្តីសុខចេញទៀតអោយនៅសល់តែសមាធិដែលកើតពីចិត្ត ឧបេក្ខា (ចិត្តព្រងើយមិនរវល់នឹងអ្វីទាំងអស់) ប៉ុណ្ណោះ។ ការតម្កល់ចិត្តនឹងតែមួយហៅថា "ឯកគ្គតា"។ អ្នកបានសំរេចផលថ្នាក់នេះឈ្មោះថាសំរេចចតុត្ថជ្ឈាន។ ព្រះសមណសិទ្ធត្ថទ្រង់សំរេចឈានទី៤នេះហើយ។

អរូបឈានទី១ហៅថា "អាកាសានញ្ចាយតនឈាន" គឺការពិចារណាឃើញនូវបដិភាគនិមិត្ត ដោយធ្វើចិត្តអោយមូលនៅតែមួយ។ សម្ភារៈនិងធម៌ទាំងឡាយដែលធ្លាប់មើលឃើញត្រូវបន្សាត់ចេញអោយអស់ពីអារម្មណ៍ និងពិចារណារហូតដល់ឃើញតែអាកាសទទេគ្មានអ្វីសោះ។ មិនបានទាំង៣ថ្ងៃស្រួលបួលផង ព្រះសមណសិទ្ធត្ថទ្រង់បានសំរេច

នូវអរូបឈានទី១នេះដោយជោគជ័យ។

អរូបឈានទី១ហៅ "វិញ្ញាណញ្ចាយតនឈាន" គឺយកវិញ្ញាណជាអារម្មណ៍ដោយគិតថា វត្ថុទាំងអស់ក្នុងលោកសុទ្ធតែកើតឡើងចេញអំពីសតិរបស់យើង។ ព្រះសិទ្ធត្ថបានសំរេចអរូបឈានទី២នេះយ៉ាងឆាប់រហ័សបំផុត។ ព្រះអង្គទតឃើញវត្ថុទាំងអស់នៅក្នុងលោកមានទំនាក់ទំនងគ្នាទៅវិញទៅមកដូចក្រឡាសំណាញ់។ តែព្រះអង្គនៅមិនទាន់អស់ចិត្តសោះក៏ចូលទៅទូលសួរអាឡារតាបសអោយពន្យល់បន្ថែមទៀត។

អាឡារតាបសសម្លឹងទៅកាន់ព្រះសមណសិទ្ធត្ថដោយគោរព និង ពន្យល់ថា៖

"សិទ្ធត្ថ! ព្រះអង្គជិតបានសំរេចគោលដៅហើយ។ សូមព្រះអង្គបន្តភាវនាលើធម៌ទាំងឡាយដែលកើតចេញពីចិត្តរបស់យើងថែមទៀត។ អ្វីៗទាំងអស់ក្នុងលោកកើតចេញពីចិត្តរបស់យើង និងចិត្តរបស់យើងក៏ជាប្រភពនៃវត្ថុទាំងអស់នោះដែរ។ រូប ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ ដូចជាក្តៅនិងត្រជាក់ រឹងនិងទន់ វត្ថុទាំងអស់នេះសុទ្ធតែកើតចេញមកពីចិត្តរបស់យើង។ សមណៈសិទ្ធត្ថ! នៅមានមេរៀនមួយទៀតដែលអ្នកត្រូវបំពេញ។ មេរៀនទី៣ណោះឈ្មោះថា "អាកិញ្ចញ្ញាយតនឈាន" គឺការពិចារណាដោយមើលឃើញថាគ្មានអ្វីជាអារម្មណ៍ឬគ្មានសម្ភារៈ និងធម៌ឯណាឋិតនៅខាងក្រៅចិត្តរបស់យើងឡើយ។"

ក្នុងរយៈមិនដល់១ខែស្រួលបួលផង ព្រះសមណសិទ្ធត្ថបានសំរេចអរូបឈានទី៣នេះដោយជោគជ័យទៀត។ ព្រះអង្គបន្តភាវនាយ៉ាងជ្រៅទៅក្នុងរូបកាយ និងចិត្តរបស់ព្រះអង្គអស់ចំនួនច្រើនអាទិត្យបន្តទៀត។ ប៉ុន្តែព្រះអង្គក៏នៅតែមិនសព្វព្រះទ័យដោយព្រះអង្គយល់ឃើញថានេះមិនមែនជាផ្លូវនៃពន្លឺត្រាស់ដឹង។

អាឡារតាបសពោលសរសើរព្រះសមណៈសិទ្ធត្ថថា៖

"សមណសិទ្ធត្ថ! ព្រះអង្គជារង្វាន់មួយដ៏វិសេសវិសាលណាស់។ ព្រះអង្គបានសំរេចនូវកំរិតវិជ្ជាខ្ពស់បំផុតដែលអាត្មាបានបង្រៀន។ វិជ្ជាទាំងអស់ដែលអាត្មាបានសំរេច ព្រះអង្គក៏បានសំរេចដែរ។ ដូច្នេះយើងទាំងពីរនាក់ គួរចាប់ដៃគ្នាបង្ហាត់បង្រៀនសិស្សនិងគ្រប់គ្រងគណៈនេះជាមួយគ្នាបន្តទៅមុខទៀត។"



ព្រះសមណសិទ្ធត្ថឥតមានព្រះបំណងចង់ធ្វើជាអ្នកដឹកនាំសង្គមឬនយោបាយជាតិទេ ក៏ប៉ុន្តែ ជាអ្នកស្វែងរកពន្លឺត្រាស់ដឹងដ៏ពិតប្រាកដ។ ព្រះអង្គក៏ថ្វាយបង្គំលាអាឡារតាបសដោយពោលពាក្យយ៉ាងនេះថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ភាវៈនៃវិស័យដែលមិនទាក់ទងនៅនឹងសម្ភារៈ មិនមែនជាគោលបំណងចុងក្រោយ ដែលខ្ញុំព្រះអង្គត្រូវការស្វែងរកនោះទេ។ សូមព្រះតេជគុណទទួលអំពីខ្ញុំព្រះអង្គនូវគារវភក្តីដ៏ជ្រាលជ្រៅបំផុតចំពោះការជួយឧបត្ថម្ភនិងទំនុកបំរុងរបស់ព្រះអង្គ។ ប៉ុន្តែឥឡូវនេះខ្ញុំព្រះអង្គ សូមសេចក្តីអនុញ្ញាតលាចាកអំពីគណៈនេះដើម្បីទៅស្វែងរកអរិយសច្ចធម៌នៅទីកន្លែងដទៃផ្សេងទៀត។ ព្រះអង្គបានខំបង្ហាត់បង្រៀនខ្ញុំព្រះអង្គយ៉ាងអស់សមត្ថភាពក្នុងរយៈប៉ុន្មានខែកន្លងមកនេះ ខ្ញុំព្រះអង្គសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅនឹងស្មោះត្រង់ជាទីបំផុត ដែលមិនអាចបំភ្លេចព្រះគុណនេះបានឡើយ។"

អាឡារតាបសមើលទៅហាក់ដូចជាមានការអាក់អន់ព្រះទ័យដែរ តែធ្វើដូចម្តេចបើព្រះសមណៈសិទ្ធត្ថបានសំរេចព្រះហឫទ័យរួចបាត់ទៅហើយ។

ព្រឹកស្អែកឡើង ព្រះសមណសិទ្ធត្ថក៏ចាប់ផ្តើមចេញព្រះដំណើរតែម្តង។

**"រស់នៅតែ១ថ្ងៃ ហើយបានយល់សេចក្តីពិតបំផុត ប្រសើរជាងរស់មួយរយឆ្នាំ ហើយមិនបានយល់សេចក្តីពិតបំផុតនេះ។**

**ធម្មបទគាថា ១១៥**

# ជំពូកទី ៩
# ព្រះសិទ្ធត្ថធ្វើទុក្ករកិរិយា

ព្រះសមណសិទ្ធត្ថទ្រង់យាងឆ្លងទន្លេគង្គាចូលទៅកាន់នគរមគធៈ។ ទីនេះគឺជាកន្លែងដែលព្រះអង្គបានសំរេចព្រះចិន្តាថានឹងស្វែងរកគ្រូអាចារ្យណាម្នាក់ដើម្បីបង្រៀនព្រះអង្គអោយមានជ័យជំនះលើការកើតនិងការស្លាប់។ ព្រះអង្គត្រាច់ចរកាត់តាមជួរភ្នំជ្រោះជ្រលងដងអូរ កាត់តាមព្រៃជ្រៅ ខ្យល់ភ្លៀងនិងកំដៅថ្ងៃពីមួយខែទៅមួយខែ។ ក្នុងព្រះរាជដំណើរនេះព្រះអង្គបានជួបជាមួយតាបសខ្លះស្រាតននលគក ខ្លះទៀតមិនព្រះបរិភោគចង្ហាន់ដែលអ្នកស្រុកប្រគេនទេ សុខចិត្តរស់នៅដោយការទទួលទានតែផ្លែ ស្លឹកនិងឫសឈើដែលដុះក្នុងព្រៃ។ តាបសមួយចំនួនទៀតសំដិលខ្លួនទទេលើវត្ថុផ្សេងៗ ដូចជាដេកលើដីខ្សាច់ដ៏ក្តៅឬក៏លើដើមឈើមានបន្លាជាដើម។ តាបសទាំងនោះមានជំនឿថាការធ្វើទុក្ករកិរិយាធ្វើខ្លួនអោយវេទនាដ៏ខ្លាំងបែបនេះ អាចជួយពួកគេអោយឡើងឋានសួគ៌ បន្ទាប់អំពីពេលដែលគេស្លាប់ទៅ។

ព្រះសមណសិទ្ធត្ថយាងចាកចេញពិកបិលព័ស្ថុ អស់ពេលជាង៣ឆ្នាំកន្លងមកហើយ។ ឥឡូវនេះព្រះអង្គទ្រង់គង់ស្នាក់នៅញក ភ្នំបណ្ឌវៈ ដែលនៅមិនឆ្ងាយប៉ុន្មានពីទីក្រុងរាជគ្រឹះ។ ថ្ងៃមួយគឺថ្ងៃព្រហស្បតិ៍ ៨រោច ខែអាសាធ ឆ្នាំថោះ ព្រះអង្គទ្រង់ប្រដាប់ដោយបាត្រនិងស្បង់ចីវរ យ៉ាងស្រគត់ស្រគំ ត្រាច់សំដៅទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត។ ពួកមហាជនក្នុងនគរបានឃើញហើយ ក៏មានចិត្តត្រេកអរនិងនឹកចម្លែកក្នុងចិត្តគ្រប់ៗគ្នា។ ដំណឹងថាមានព្រះសង្ឃក្មេងរូបស្អាតមួយអង្គត្រាច់ចរបិណ្ឌបាតបានលេចឮពីមាត់មួយទៅមាត់មួយពេញទូទាំងរាជធានី។ ពាក្យនេះក៏បានលេចឮដល់ព្រះបាទពិម្ពិសារព្រះចៅនគរមគធៈ។ ពួករាជបុរសកាលបានឃើញព្រះសមណសិទ្ធត្ថហើយ ក៏យកពត៌មាននោះទៅបង្គំទូលព្រះបាទពិម្ពិសារ ដើម្បីស្តេចទ្រង់ជ្រាប។ ព្រះបាទពិម្ពិសារទ្រង់បើកបង្អួចទតទៅឃើញប្លែកដូច្នោះក៏ទ្រង់ចាត់អោយពួករាជបុរសទាំងនោះ ទៅចាំឃ្លាំមើលទីកន្លែងដែលព្រះសិទ្ធត្ថទ្រង់គង់នៅ។ ព្រះពោធិសត្វ កាលយាងបិណ្ឌបាតបានភត្តាហារល្មមហើយ ក៏ទ្រង់យាងចូលទៅកាន់ញកភ្នំបណ្ឌវៈនោះវិញហើយរៀបចំសោយអាហារដោយបដិកូលសញ្ញា។ លុះព្រះ



រាជាទ្រង់ព្រះសណ្តាប់នូវប្រភពច្បាស់ការអំពីពួករាជបុរសហើយស្តេកឡើងនាពេលរសៀលព្រះបាទពិម្ពិសារស្តេចយាងទៅកាន់សំណាក់ព្រះសមណសិទ្ធត្ថ ជាមួយនឹងអាមាត្យមួយចំនួន ដើម្បីសាកសួរពូជពង្សវង្សត្រកូល។ ព្រះសិទ្ធត្ថកាលបានជួបជាមួយព្រះរាជាហើយ ទ្រង់សំដែងនូវបដិសណ្ឋារកិច្ចនិងថ្វាយព្រះពរសព្វប្រការ។ ព្រះមហាក្សត្រសព្វព្រះរាជហឫទ័យយ៉ាងខ្លាំងចំពោះព្រះឥរិយាបថដ៏ទន់ភ្លន់នៃភិក្ខុអង្គនេះ។ លុះទ្រង់បានជ្រាបច្បាស់ហើយ ព្រះរាជាក៏សុំយាងព្រះសិទ្ធត្ថអោយលាភេទ(សឹក) និងសូមថ្វាយទ្រព្យសម្បត្តិពាក់កណ្តាល។ ព្រះរាជាសូមថ្វាយកិត្តិយសដល់ព្រះសមណសិទ្ធត្ថដើម្បីគ្រប់គ្រងប្រទេសជាមួយគ្នា។ ការដែលព្រះរាជាចង់បានព្រះសិទ្ធត្ថគង់នៅជិត ពីព្រោះតែស្តេចចង់បានទទួលនូវការអប់រំគុណធម៌ទាំងឡាយ។

ព្រះសមណសិទ្ធត្ថទ្រង់មានបន្ទូលប្រកែកថា៖

"បពិត្រមហារាជ! ជីវិតស្តេចមិនស័ក្តិសមនឹងអាត្មាជាព្រះសង្ឃទេ។ អាត្មាសូមថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅ ចំពោះព្រះរាជហឫទ័យដ៏មហាសប្បុរសនិងការសុំធ្វើបរិបាលកិច្ច (ការសុំជួយឧបត្ថម្ភ)នេះ។ ប៉ុន្តែដោយការពិតទៅអាត្មាមានគោលបំណងតែម្យ៉ាងគត់គឺចង់ស្វែងរក សម្មាសម្ពោធិញ្ញាណ ដើម្បីដោះខ្លួនឯងនិងសព្វសត្វ អោយផុតពីភ្លើងទុក្ខភ្លើងកិលេសប៉ុណ្ណោះ។"

បន្ទាប់ពីបានសំណេះសំណាលអស់ពេលមួយស្របក់ធំមក ព្រះបាទពិម្ពិសារទ្រង់ភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយបានដឹងថាព្រះសង្ឃដ៏ក្មេងនេះជាព្រះអង្គម្ចាស់នៃសក្យៈត្រកូល។ ព្រះសមណសិទ្ធត្ថទ្រង់ទូលបញ្ជាក់ព្រះរាជាថា៖

"បពិត្រមហារាជ! អាត្មាភាពសូមសន្យាថា បើកាលណាអាត្មាបានរកឃើញនូវពន្លឺត្រាស់ដឹងដ៏ឧត្តមហើយ អាត្មានឹងវិលមកទូលព្រះអង្គ ដើម្បីទ្រង់ជ្រាបវិញ។"

ព្រះបាទពិម្ពិសារទ្រង់ប្រមោទ(សប្បាយចិត្ត) យ៉ាងខ្លាំង ទ្រង់ឱនសំពះលាយ៉ាងទាបចំពោះព្រះភ័ក្ត្រព្រះសមណសសិទ្ធត្ថ រួចហើយក៏ស្តេចយាងចុះអំពីភ្នំនោះជាមួយនឹងបរិវារទាំងឡាយរបស់ព្រះអង្គទៅ។

បន្ទាប់អំពីព្រះបាទពិម្ពិសារយាងផុតទៅ ព្រះសមណសិទ្ធត្ថក៏សំរេចព្រះទ័យបោះបង់

ចោលអាស្រមនេះ រួចទ្រង់យាងឆ្ពោះទៅកាន់ទិសខាងត្បូងដើម្បីនឹងស្វែងរកអាស្រមមួយទៀត ដែលនៅមិនឆ្ងាយប៉ុន្មានអំពីក្រុងរាជគ្រឹះ។ នៅទីនេះព្រះអង្គបានឮដំណឹងថាមានអាចារ្យល្បីឈ្មោះម្នាក់ទៀតឈ្មោះ ឧទ្ទកតាបសរាមបុត្រ ដែលជាអ្នកបានសំរេចនូវពន្លឺត្រាស់ដឹងដ៏ខ្ពង់ខ្ពស់បំផុត។

ថ្ងៃមួយ ព្រះសមណសិទ្ធត្ថបានជួបនឹងឧទ្ទកតាបសរាមបុត្រ។ ឧទ្ទកតាបសមានព្រះជន្មប្រមាណ៧៥ឆ្នាំហើយ។ ព្រះសិទ្ធត្ថក៏បានទទួលការអនុញ្ញាតអោយចូលសិក្សាវិជ្ជាសមាធិម្តងទៀតនៅទីនេះ។ ក្នុងសំណាក់ឧទ្ទកតាបសនេះ ព្រះសមណៈសិទ្ធត្ថបានសំរេចរហូតដល់សមាបត្តិទី៨ដែលរៀនតែក្នុងរយៈពេល២អាទិត្យប៉ុណ្ណោះ។ សមាបត្តិទី៨នោះឈ្មោះថា "នេវសញ្ញាសញ្ញាយតនឈាន" គឺការពិចារណាថាគ្មានអារម្មណ៍អ្វីសោះឡើយ។ បុគ្គលដែលបានសំរេចសមាបត្តិនេះ នឹងថាដឹងខ្លួនក៏ពុំបាន មិនដឹងខ្លួនក៏ពុំបាន។

ក្នុងរយៈពេលតែ១៥ថ្ងៃប៉ុណ្ណោះ ព្រះសមណសិទ្ធត្ថបានយល់ដឹងនិងសំរេចនូវឈានអស់ទាំងនេះ។ ឧទ្ទកតាបសមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការចេះចាំដ៏អស្ចារ្យនេះ។ ឧទ្ទកតាបសបានពោលទៅកាន់ព្រះសិទ្ធត្ថថា៖

"បពិត្រព្រះសមណៈ! ព្រះអង្គមានការលូតលាស់យ៉ាងសម្បើមក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ ហើយបានសំរេចដល់កំរិតខ្ពស់បំផុតនូវចំណេះដែលអាត្មាមាន។ អាត្មាចង់អោយព្រះអង្គស្នាក់នៅទីនេះគ្រាន់បានជាគ្នា ដោយអាត្មាគិតថាព្រះអង្គអាចជំនួសអាត្មាក្នុងឋានៈជាអ្នកគ្រប់គ្រង គណៈនេះបន្ទាប់ពីពេលអាត្មាស្លាប់ទៅ។"

ព្រះសមណសិទ្ធត្ថបានយល់ដឹងយ៉ាងច្បាស់ថា ភាវៈនៃការមានសញ្ញាខ័ន្ធនិងការគ្មានសញ្ញាខ័ន្ធមិនមែនជាកូនសោរសំរាប់រំដោះអោយផុតអំពីការកើតនិងការស្លាប់បានឡើយ។ ហេតុដូច្នោះហើយបានជាព្រះអង្គសំរេចព្រះហឫទ័យថា ព្រះអង្គត្រូវតែធ្វើដំណើរបន្តទៅមុខទៀត។ ព្រះអង្គប្រកែកមិនព្រមទទួលសំណូមពរឧទ្ទកតាបសដូចកាលដែលព្រះអង្គធ្លាប់បានប្រកែកនឹងអាឡារតាបសពីមុននោះដែរ។

បន្ទាប់មក ព្រះសមណសិទ្ធត្ថក៏លើកព្រះហស្តថ្វាយបង្គំលា និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះឧទ្ទកតាបសរាមបុត្រ និងបព្វជិតជាសំឡាញ់ប្អូនរយរូបទៀត រួច



ហើយក៏និមន្តចៀសចេញបាត់ទៅ។

ឧទ្ទកតាបសរាមបុត្រនិងបរិស័ទរបស់ព្រះអង្គមានការសោកស្តាយយ៉ាងខ្លាំង។ ជាពិសេសមិត្រសំណប់ចិត្តម្នាក់របស់ព្រះសិទ្ធត្ថ ព្រះនាមកោណ្ឌញ្ញ។ កោណ្ឌញ្ញបានជូនដំណើរព្រះសមណសិទ្ធត្ថចុះអំពីលើភ្នំ និងរង់ចាំរហូតដល់ព្រះអង្គ យាងឆ្ងាយផុតកន្ទុយភ្នែក ទើបនិមន្តត្រឡប់មកកាន់អាស្រមវិញ។

ព្រះសិទ្ធត្ថនិមន្តឆ្ពោះទៅទិសខាងលិច ឆ្លងកាត់តាមវាលភក់ ដងអូរនិងស្ទឹង នេរញ្ជរា។ ព្រះអង្គយាងដល់ភ្នំមួយឈ្មោះ ទងសិរី (បើធ្វើដំណើរពីភូមិឧរុវេលនិគមមកវិញត្រូវចំណាយពេលអស់កន្លះថ្ងៃ) នៅក្នុងដែនមគធៈ។ ព្រះសមណសិទ្ធត្ថទ្រង់សំរេចព្រះទ័យស្វែងរក មោក្ខធម៌ ដោយខ្លួនឯងនៅទីនេះ ដរាបណាព្រះអង្គបានរកឃើញពន្លឺត្រាស់ដឹង។ ព្រះអង្គជ្រើសរើសបានគុហាមួយដែលល្មមព្រះអង្គអាចគង់ធ្វើសមាធិបានយូរ។ ពេលព្រះសិទ្ធត្ថគង់ធ្វើសមាធិម្តងៗព្រះអង្គបានរំលឹកឡើងវិញនូវការអនុវត្តន៍ទាំងឡាយដែលព្រះអង្គធ្លាប់បានប្រតិបត្តិក្នុងរវាង៥ឆ្នាំកន្លងមកហើយ។

ពេលនេះ ព្រះអង្គប្តូរព្រះចិន្តាមកសញ្ជឹងគិតដោយប្រុងប្រយ័ត្ន លើរូបកាយរបស់ព្រះអង្គផ្ទាល់វិញម្តង។ ព្រះអង្គសំរេចធ្វើ អត្តកិលមកម្ម(ធ្វើទុក្ខទោសខ្លួនឯង) ដើម្បីដោះទុក្ខវេទនាអោយចេញផុតអំពីខ្លួន។ ព្រះអង្គធ្វើទុក្ករកិរិយា ក្នុងរបៀបបីគឺ៖

១. យកធ្មេញសង្កត់ធ្មេញ យកអណ្តាតទល់ពិតាន(ក្រអូមខាងលើ)

២. ទប់ខ្យល់ដង្ហើមចេញចូល និង

៣. បន្ថយអាហារជាលំដាប់ រហូតនៅប៉ុនគ្រាប់សណ្តែក។

នៅក្នុងរាត្រីដ៏ងងឹតសូន្យសុងមួយ ព្រះសិទ្ធត្ថបានយាងចូលទៅក្នុងព្រៃស្តុកដែលសម្បូណ៍ទៅដោយសត្វព្រៃយ៉ាងកាចសាហាវ។ ព្រះអង្គទ្រង់គង់នៅក្រោមដើមពោធិជ្រៃមួយហើយក៏ចាប់ផ្តើមតាំងនូវ តាបសធម៌ យ៉ាងខ្លាំង។ ពេលសត្វប្រើសមួយដើរមកជិតបន្លឺសម្លេងធ្វើក្រិកៗ ការភ័យខ្លាចរបស់ព្រះអង្គក៏បានបញ្ជាក់អោយដឹងថាវាគ្រាន់តែជាបិសាចដែលមកបន្លាច និងយាយីដល់ព្រះជន្មព្រះអង្គ ប៉ុន្តែព្រះអង្គគ្មានការភ្ញាក់ផ្អើលឬកំរើកសោះឡើយ។ ពេលសត្វក្ងោកកាច់បំបាក់មែកឈើងាប់តូចៗចុះមក ការភ័យរបស់

ព្រះអង្គបានប្រាប់ព្រះអង្គអោយដឹងថាវាគ្រាន់តែជាពស់ថ្លាន់ដែលធ្លាក់ចុះអំពីដើមឈើប៉ុណ្ណោះ ព្រះអង្គក៏នៅតែមិនកំរើកព្រះកាយដដែល។ សូម្បីតែស្រមោចអង្ក្រងខាំឬសន្សើមធ្លាក់ទទឹកជោគព្រះអង្គកាយយ៉ាងត្រជាក់ក៏ព្រះអង្គនៅតែមិនកំរើកដែរ។ ពេលមួយនោះព្រះអង្គទ្រាំទប់ខ្យល់ដង្ហើមយ៉ាងយូរទាល់តែលាន់សូរភោទ៍ដូចរន្ទះ ឬក៏ហាក់ដូចជាមានដុំភ្លើងដ៏ក្តៅបុកមាំងក្នុងព្រះការណ៍ និងព្រះសិររបស់ព្រះអង្គ។ ទ្រង់មានព្រះអារម្មណ៍បីដូចជាគេយកពូថៅមកពុះចំព្រះកេសបំបែកជាពីរចំណែកដាច់ចេញពីគ្នា។ ជូនកាលព្រះអង្គចាប់អារម្មណ៍ហាក់ដូចជាគេគាបច្របាច់ព្រះកេសដោយបន្ទះដែកដ៏មាំ។ រីឯក្រពះរបស់ព្រះអង្គក៏ត្រូវគេកាត់ចំហរធ្លុងដូចជាសត្វពពែដែលត្រូវគេកាប់ចិញ្ច្រាំ។ ព្រះអង្គព្យាយាមហើយព្យាយាមទៀតដើម្បីអោយបានឈ្នះលើសេចក្តីភ័យខ្លាចទាំងអស់ ដែលមាននៅក្នុងរូបកាយរបស់ព្រះអង្គ។ ព្រះអង្គជឿថារូបកាយព្រះអង្គនឹងឥតមានរុំព័ទ្ធដោយសេចក្តីភ័យខ្លាចទៀតទេ។ គំនិតព្រះអង្គអាចកាច់បំបាក់នូវច្រវាក់នៃសេចក្តីឈឺចាប់បាន។ ដោយការអនុវត្តន៍ដ៏តឹងរឹងនេះព្រះអង្គអាចកំណត់នូវសេចក្តីក្លាហាននិងវិន័យរបស់ព្រះអង្គបាន និងខាងរូបកាយក៏ព្រះអង្គអាចអត់ទ្រាំនូវការឈឺចាប់ដ៏សែនទារុណបានដែរ។ ព្រះអង្គក៏ធ្វើវិចារណៈថា៖

"គ្មានតាបសឥសីណាមួយ ក្នុងអតីតកាលក្តី ក្នុងបច្ចុប្បន្នកាលក្តី និងក្នុងអនាគតកាលក្តី ដែលបានប្រតិបត្តិ ឬកំពុងប្រតិបត្តិ ឬនឹងប្រតិបត្តិ ដោយភាពតឹងរឹងបំផុតជាងរូបអាត្មាអញនេះទេ។" តែដួងហឫទ័យព្រះអង្គនៅតែគ្មានសន្តិភាពសោះ។

ព្រះអង្គបានខំហាត់ពត់នូវតបកម្មរបៀបនេះអស់រយៈពេល៦ខែមកហើយក៏នៅពុំទាន់បានសំរេចគោលបំណងដែរ។ ក្នុងរយៈពេលបីខែដំបូងព្រះអង្គព្យាយាមធ្វើធម៌តែមួយអង្គឯងនៅលើភ្នំ។ ក្នុងកំឡុងខែទី៤ ព្រះអង្គបានទទួលភិក្ខុ៥អង្គទៀតជាគូរួមទាំងកោណ្ឌញ្ញព្រាហ្មណ៍ធ្លាប់ទាយលក្ខណៈព្រះអង្គកាលពីព្រះអង្គទើបប្រសូត។ កូនព្រាហ្មណ៍ទាំងអស់បបួលគ្នាចេញទៅបួសតាមបណ្តាំបិតារបស់ខ្លួន បន្ទាប់ពីបានដឹងថា ព្រះអង្គម្ចាស់សិទ្ធត្ថយាងចេញបាត់មក។ ភិក្ខុទាំង៥អង្គនោះគឺ៖ កោណ្ឌញ្ញ១ វប្បៈ១ កទ្ទិយ១ អស្សជិ១ និងមហានាម១។ ជារៀងរាល់ថ្ងៃ ព្រះសិទ្ធត្ថនិងភិក្ខុទាំង៥អង្គ តែងត្រាច់ទៅបិណ្ឌបាតក្នុងទី



ក្រុង។ ចង្ហាន់ដែលបានមកពីការបិណ្ឌបាតនោះ ត្រូវបែងចែកជា៦ចំណែកស្មើៗគ្នា។ ឃើញថាគ្មានភិក្ខុអង្គណាមួយបានចង្ហាន់ច្រើនលើសពីមួយពំនូតក្នុងមួយថ្ងៃៗឡើយ។

ថ្ងៃខែចេះតែកន្លងផុតទៅ ភិក្ខុទាំង៦អង្គចុះស្គមស្គាំងយ៉ាងខ្លាំង មកពីឆាន់មិនគ្រប់គ្រាន់។ ព្រះសិទ្ធត្ថនិងបញ្ចវគ្គីយភិក្ខុសំរេចនិមន្តចាកចេញពីភ្នំទងសិរីនេះឆ្ពោះទៅទិសខាងកើតទៅកាន់ភូមិមួយឈ្មោះ ឧរុវេលនិគម (សព្វថ្ងៃហៅ ឧរេស) នៅប្របក្រុង គយា (សព្វថ្ងៃហៅ គយាដដែល) ដែលស្ថិតនៅខាងស្តាំមាត់ស្ទឹងនេរញ្ជរា (សព្វថ្ងៃហៅ ស្ទឹងផល្គុ)។ នៅពេលនេះការធ្វើទុក្ករកិរិយារបស់ព្រះសិទ្ធត្ថក៏ចាប់ផ្តើមអោយឃើញសញ្ញាឡើង និងសូម្បីតែកល្យាយមិត្តភិក្ខុទាំង៥រូបក៏ដូច្នោះដែរ។ ព្រះសិទ្ធត្ថនិងភិក្ខុទាំង៥រូបតែងតែឈប់ចុះស្រត់ទឹកនិងចែកចង្ហាន់គ្នាឆាន់នៅមាត់ស្ទឹងនេរញ្ជរា។ ជូនពេលខ្លះព្រះសិទ្ធត្ថនិងភិក្ខុទាំង៥រូប ឆាន់តែផ្លែត្របែកស្លឹក ដែលជ្រុះនៅលើដី។ ក្នុងរយៈពេល៦ខែនៃការធ្វើ មហាបធានទុក្ករកិរិយា (កិរិយានៃការព្យាយាមធំ) នេះព្រះសិទ្ធត្ថមានព្រះកាយចុះស្គមស្គាំង មើលឃើញតែឆ្អឹងជំនីររគាមនិងស្លេកស្លាំងទន់ខ្សោយហួសប្រមាណ។នៅពាក់កណ្តាលផ្លូវ នាពេលដែលព្រះអង្គយាងមកពីស្រង់ទឹកនិងបោកស្បង់ចីវរនាស្ទឹងនេរញ្ជរាវិញ ព្រះអង្គទ្រង់ខ្សោះអស់ព្រះកាយពលយ៉ាងខ្លាំង រហូតដល់ដេកសន្លប់ស្តូកស្តឹងនៅលើប្រថពី។

ថ្ងៃមួយ ក្នុងពេលព្រះអង្គគង់ធ្វើសមាធិ ព្រះសិទ្ធត្ថយល់ដឹងដោយក្តីរន្ធត់នូវផ្លូវខុសនៃការធ្វើអត្តកិលមកម្មនេះ។ ព្រះអង្គទ្រង់សន្និដ្ឋានថា៖

"ផ្លូវនេះមិនមែនជាផ្លូវ នៃកិរិយាត្រាស់ដឹងឡើយ។"

ព្រះអង្គទ្រង់បានយល់ឃើញច្បាស់ទៀតថា៖

"រូបកាយនិងចិត្តកើតឡើងនៅក្នុងបុព្វហេតុតែមួយ ដែលមិនអាចបែងចែកដាច់អំពីគ្នាបាន។ បើមានសន្តិភាព(សេចក្តីស្ងប់) កើតឡើងនៅក្នុងផ្លូវកាយសន្តិភាពក៏អាចកើតមាននៅក្នុងផ្លូវចិត្តដែរ និងបើមានការគំរាមកំហែងខាងផ្លូវកាយក៏មានការគំរាមកំហែងខាងផ្លូវចិត្តដែរ។"

ក្នុងថ្ងៃដដែលនោះ ព្រះសមណសិទ្ធត្ថបានសំរេចព្រះទ័យបោះបង់ចោលនូវការធ្វើ

ទុក្ករកិរិយាដល់ខ្លួនឯង។ ព្រះអង្គនិមន្តទៅកាន់ត្រើយម្ខាងនៃស្ទឹងដើម្បីប្រតិបត្តិធម៌តាមធម្មតានៅទីនោះវិញ។ សេចក្តីតំណាថា៖

"ក្នុងគ្រានោះ មានព្រះឥន្ទយកពិណខ្សែ៣ មកដេញថ្វាយព្រះពោធិសត្វដោយរិតខ្សែមួយអោយធូរដែលមិនអាចមានសម្លេងពីរោះបាន រួចក៏រិតខ្សែមួយទៀតតឹងហួសពេកទាល់តែដាច់ និងរិតខ្សែកណ្តាលអោយតឹងល្មម ក៏មានសម្លេងពីរោះឡើង។ កាលបានឮសម្លេងយ៉ាងដូច្នេះព្រះពោធិសត្វក៏ពិចារណារកឃើញហេតុផល។

១. អ្នកមានកាយនិងចិត្តមិនចេញចាកកាម មិនអាចនឹងត្រាស់ដឹងបានទេប្រៀបដូចជាឈើស្រស់ជុះ(ត្រាំ)ក្នុងទឹក យកទៅកួតគ្នាមិនឆេះជាភ្លើងទេ។

២. អ្នកមានកាយចេញចាកកាមហើយ ប៉ុន្តែចិត្តមិនទាន់ចេញមិនបានត្រាស់ដឹងទេប្រៀបដូចជាឈើស្រស់ជុះ(ឬនៅ)លើគោក យកទៅកួតមិនឆេះជាភ្លើងទេ។

៣. អ្នកមានកាយនិងចិត្តចេញចាកកាមហើយ អាចនឹងត្រាស់ដឹងបានដោយប្រាកដប្រៀបដូចជាឈើស្ងួតនៅលើគោគ យកទៅកួតគ្នាក៏អាចឆេះជាភ្លើងបាន។

ដោយការបានយល់ច្បាស់នូវឧបមាទាំងបីខនេះ ព្រះសិទ្ធត្ថក៏ចាប់សំរួលទាំងខាងផ្លូវកាយទាំងខាងផ្លូវចិត្តហើយក៏ចាប់ផ្តើមសោយអាហារដូចធម្មតាវិញ។ ព្រះអង្គទ្រង់លះបង់ការប្រតិបត្តិនូវ អត្តកិលមថានុយោគ ហើយក៏ត្រឡប់មកប្រតិបត្តិតាមផ្លូវ មជ្ឈិមាបដិបទាដែលជាផ្លូវកណ្តាលដូចជាសម្លេងខ្សែពិណដ៏ពីរោះនោះវិញ។

បន្ទាប់ពីពេលនោះមកជួនកាលនាងសុជាតាយកចង្ហាន់មកប្រគេន ជួនកាលព្រះអង្គនិមន្តចេញទៅបិណ្ឌបាតផ្ទាល់ព្រះអង្គតាមលំដាប់ភូមិអ្នកស្រុក។ ព្រះសមណៈសិទ្ធត្ថចាប់បន្តធ្វើសមាធិទាំងយប់ទាំងថ្ងៃ នៅក្រោមម្លប់ដើមពោធិព្រឹក្សពិចារណាលើ កាយ ចិត្តសញ្ញាក្ខ័ន្ធ និងអារម្មណ៍ទាំងអស់ដែលមាននៅក្នុងគំនិតរបស់ព្រះអង្គ។

ក្នុងពេលជាមួយគ្នានេះ បញ្ចវគ្គីយភិក្ខុមិនបានឋិតនៅក្នុងព្យាករណ៍របស់ខ្លួនទៀតឡើយ។ ភិក្ខុទាំង៥រូបមានការទាស់ចិត្តយ៉ាងខ្លាំង កាលបានឃើញព្រះសិទ្ធត្ថញញឹមរាក់ទាក់និងទទួលយកទឹកដោះគោអំពីដៃក្មេងស្រី ព្រះទាំងឃើញព្រះអង្គឆាន់ចង្ហាន់ដែលបានមកអំពីភូមិអ្នកស្រុកទៀតផង។ កោណ្ឌញ្ញភិក្ខុ បានពោលទៅកាន់ភិក្ខុជាសំឡាញ់ថា៖



"ម្នាលសំឡាញ់! សមណៈសិទ្ធត្ថនេះអស់មានសីលធម៌ទៀតហើយ គ្មានអ្នកណាម្នាក់អាចទីពឹងបានទៀតទេព្រោះព្រះអង្គបោះបង់មគ្គធម៌ចោលទាំងពាក់កណ្តាលផ្លូវយ៉ាងនេះ។ ឥឡូវនេះ ព្រះអង្គក្លាយជាមនុស្សអាត្មានិយម គិតតែជាមួយគំនិតឥតបានការ លើរូបកាយផ្ទាល់ខ្លួនប៉ុណ្ណោះ។ គ្មានប្រយោជន៍អ្វី ធ្វើអោយពួកយើងនៅបំរើព្រះអង្គទៀតទេ។ ពួកយើងត្រូវតែចាកចោលព្រះអង្គទៅរកកន្លែងផ្សេងទៀតដើម្បីធ្វើសមាធិរបស់យើងបន្តទៅមុខទៀត។ យើងមិនឃើញមានហេតុផលឯណាមួយ គួរអោយយើងបន្តរស់នៅក្នុងទីនេះទៀតបានឡើយ។"

បន្ទាប់ពីបានពិភាក្សាគ្នារួចហើយ ភិក្ខុទាំង៥រូបក៏បបួលគ្នាទៅយកបាត្រ និងស្បង់ចីវរ រួចធ្វើដំណើរចេញបាត់ទៅ។ ភិក្ខុទាំង៥រូបបានទៅស្នាក់នៅក្នុងព្រៃធំមួយឈ្មោះឥសិបតនមិគទាយវ័ន (សព្វថ្ងៃហៅ សារនាថ) ឋិតនៅទៀបក្រុងពារាណសីក្នុងដែន កាសី (សព្វថ្ងៃហៅ ប៉េណារ៉េស)។

ព្រះសមណសិទ្ធត្ថបានដឹងពីអវត្តមាននៃបញ្ចវគ្គីយភិក្ខុទាំង៥រូបនោះដែរ តែព្រះអង្គនៅខ្សោយព្រះកាយពលនៅឡើយ។ ព្រះអង្គខំប្រឹងកម្លាទឹកចិត្តនិងសាកល្បងភាវនាសារជាថ្មីម្តងទៀត ដោយឥតមានខ្លាចអស់ព្រះជន្មសង្ខារឡើយ។ ព្រះអង្គរវល់ជាប់ធ្វើសមាធិដូច្នេះហើយបានជាព្រះអង្គពុំអាចមានពេលទៅពន្យល់ដល់មិត្តសំឡាញ់ទាំងនោះអោយយល់បាន។

ព្រះសមណសិទ្ធត្ថគិតថាបញ្ចវគ្គីយជាសំឡាញ់ទាំង៥រូប ពិតជាយល់ច្រឡំចំពោះព្រះអង្គ នៅពេលណាព្រះអង្គបានស្វែងរកឃើញពន្លឺត្រាស់ដឹងពិតប្រាកដព្រះអង្គនឹងវិលទៅប្រោសមិត្តទាំង៥រូបនោះមុនគេ។

---

# ជំពូកទី ១០
# ព្រះពោធិសត្វបានត្រាស់ដឹង

ឥឡូវនេះ ខែពិសាខ ក៏ចូលមកដល់ ឱរុវេលនិគមដែលព្រះអង្គធ្លាប់គង់នៅដើម្បីស្វែងរកការត្រាស់ដឹង ស្រាប់តែប្រែក្លាយទៅជាស្រស់បំព្រងមានធម្មជាតិលាស់ខៀវស្រងាត់នាដើមគិម្ហរដូវ ដើម្បីរង់ចាំទទួលស្វាគមន៍ចំពោះការត្រាស់ដឹងរបស់ព្រះពោធិសត្វ ក្នុងពេលដ៏ខ្លីខាងមុខនេះ។

នៅពេលទៀបភ្លឺ នាថ្ងៃ១៥កើតខែពិសាខ ឆ្នាំរកា ព្រះសិទ្ធត្ថបរមពោធិសត្វទ្រង់សុបិននិមិត្តឃើញរឿងចម្លែកអស្ចារ្យចំនួន៥លើក ដែលគួរអោយព្រឺព្រួចបំផុត។

សុបិនលើកទី១ ព្រះអង្គទ្រង់ទតឃើញរូបព្រះអង្គមួយទៀតមកផ្ទំសន្ធឹងផ្ងារនៅលើប្រថពីក្បែរព្រះអង្គផ្ទាល់ដោយយកប្រថពីជាទីសយនាក្រឡាបន្ទំ យកភ្នំហេមពាន្តជាខ្នើយរងព្រះសិរ យកព្រះហស្តឆ្វេង សណ្តូកចុះទៅក្នុងមហាសមុទ្រខាងកើតយកព្រះហស្តស្តាំសណ្តូកចុះទៅក្នុងមហាសមុទ្រខាងលិច និងយកព្រះបាទទាំងគូសណ្តូកចុះទៅក្នុងមហាសមុទ្រខាងត្បូង។ ទ្រង់ផ្ទំបើកព្រះនេត្រហើយទតឃើញពន្លឺភ្លឺរហូតទៅដល់ ឋានភគវព្រហ្ម។

សុបិនលើកទី២ ព្រះអង្គទ្រង់ទតឃើញថាមានផ្កាឈូកដ៏ធំអស្ចារ្យមួយទំហំប៉ុនកង់រទេះ ដុះចេញមកពី ព្រះនាភី(ផ្ចិត)របស់ព្រះអង្គលូតឡើងទៅទល់នឹងអាកាសដ៏ខ្ពស់ស្កឹមស្កៃ(គម្ពីរខ្លះថាស្មៅចិញ្ចៀន)។

សុបិនលើកទី៣ ព្រះអង្គទ្រង់ទតឃើញមានសត្វដង្កូវទាំងឡាយខ្លួនពណ៌សនិងក្បាលពណ៌ខ្មៅវារឡើងពីចុងព្រះបាទព្រះអង្គទៅដល់ព្រះ ជាណុមណ្ឌល(ជង្គង់)។

សុបិនលើកទី៤ ព្រះអង្គទ្រង់ទតឃើញមានសត្វបក្សាបក្សីគ្រប់ពណ៌៤ពួកមានពណ៌សម្បុរ(វណ្ណៈ)ផ្សេងៗពីគ្នា ហើរចេញពីទិសទាំង៤ មកក្រាបទៀបព្រះបាទព្រះអង្គ ហើយបក្សាបក្សីទាំងនោះក៏ប្រែក្លាយជាមានសម្បុរសដូចគ្នាទាំងអស់វិញ។

សុបិនលើកទី៥ ព្រះអង្គទ្រង់ទតឃើញរូបព្រះអង្គយាងចង្រ្កមលើភ្នំ លាមក(អាចម៍)ដ៏ធំ តែព្រះបាទព្រះអង្គមិនមានប្រឡាក់ដោយលាមកនោះឡើយ។



ពេលព្រះអង្គទ្រង់តើនចាកទីសយនាឡើងទ្រង់ធ្វើការសន្និដ្ឋានក្នុងព្រះចិន្តាថា៖

"មហាសុបិននិមិត្តទាំង៥ប្រការនេះហាក់ដូចជាសេចក្តីប្រកាសមួយបញ្ជាក់ប្រាប់អាត្មាអញអោយដឹងថា ពន្លឺត្រាស់ដឹងនឹងធ្លាក់មកក្នុងកណ្តាប់ព្រះហស្តអាត្មាអញហើយ។ ព្រះអង្គទ្រង់ធ្វើព្យាករណ៍ដោយព្រះប្រាជ្ញាផ្ទាល់ព្រះអង្គឯងថា៖

-ការផ្ទំលើផែនដី គឺជាបុព្វនិមិត្តនៃការបាននូវអនុត្តរសម្មាសម្ពោធិញ្ញាណ។

-ការយកភ្នំហេមពាន្តធ្វើជាខ្នើយគឺបុព្វនិមិត្តនៃការបាននូវសព្វញ្ញុតញ្ញាណ។

-ការសណ្តូកព្រះហស្តនិងព្រះបាទចុះទៅក្នុងមហាសមុទ្រ គឺជាបុព្វនិមិត្តនៃការសំដែងធម្មចក្កប្បវត្តនសូត្រ ប្រោសមនុស្សនិងទេវតា។

-ការផ្ទំផ្ងារលើផែនដី គឺជាបុព្វនិមិត្តនៃកិរិយា ធ្វើអោយសត្វ ដែលមានមុខផ្កាប់នោះបានផ្ងារឡើងវិញ។

-ការផ្ទំបើកព្រះនេត្រឃើញពន្លឺភ្លឺដល់ភវគ្គព្រហ្ម គឺជាបុព្វនិមិត្តនៃការបាននូវទិព្វចក្ខុនិងប្រាជ្ញាអានាវរណញ្ញាណ។

-ការទតឃើញស្មៅចិញ្ចៀន (ឬតិណជាតិ)ចុះចេញអំពីផ្ចិត គឺជាបុព្វនិមិត្តនៃការសំដែងនូវអដ្ឋង្គិកមគ្គៈ។

-ការទតឃើញសត្វដង្កូវខ្លួនសក្បាលខ្មៅវាឡើងតាមព្រះបាទគឺជាបុព្វនិមិត្តនៃការទទួលនូវបរិស័ទទាំង៤ពួកបានដល់នូវព្រះត្រៃសរណគមន៍ស្មើជីវិត។

-ការទតឃើញបក្សាបក្សីទាំង៤ពួកមានពណ៌ផ្សេងៗគ្នាហើរចេញពីទិសទាំង៤មកក្រាបទៀបព្រះបាទា ហើយប្រែក្លាយជាមានពណ៌សដូចគ្នា គឺជាបុព្វនិមិត្តនៃវណ្ណៈទាំង៤(ព្រាហ្មណ៍១ ក្សត្រ១ វេស្ស១និងសូត្រ១)ចេញសាងបព្វជ្ជាប្រព្រឹត្តតាមធម៌វិន័យរបស់ព្រះអង្គដែលមានពណ៌សតែមួយ។

-ការទតឃើញព្រះអង្គយាងចង្រ្កមលើភ្នំលាមក តែមិនប្រឡាក់នូវលាមកនោះគឺជាបុព្វនិមិត្តនៃចតុប្បច្ច័យ(ជាលាភសក្ការៈ)ប្រាកដជាកើតមានដល់ព្រះអង្គតែព្រះទ័យព្រះអង្គមិនជាប់ជំពាក់នៅក្នុងលាភសក្ការៈនោះឡើយ។"

លុះព្រឹកស្អែកឡើង ថ្ងៃពុធ ១៥កើតពេញបូណ៌មី ខែអាសាឍ ឆ្នាំរកា ព្រះបរមពោធិ

សត្វទ្រង់រៀបចំព្រះអង្គទៅគង់នៅក្រោមដើមជ្រៃមួយ នៅជិតឧរុវេលនិគមនោះ ដើម្បីរង់ចាំពេលល្មមនឹងចេញទៅបិណ្ឌបាត។ ប៉ុន្តែ ព្រះអង្គមិនបានយាងទៅបិណ្ឌបាតវិញដោយនាង សុជាតា ដែលត្រូវជាបុត្រីនៃ សេនកុដុម្ពិក៍ (អ្នកមានស្រុកស្រែចំការ) បានយលចង្ហាន់មធុបាយាស មកថ្វាយព្រះអង្គៗទ្រង់ទទួលយកទាំងភាជន៍អំពីដៃនាង ព្រោះបាត្រព្រះអង្គដែលទ្រង់ទុកខាងក្រោយខ្នងនោះរកពុំឃើញ។

ព្រះពោធិសត្វ កាលទ្រង់បានទទួលមធុបាយាសអំពីនាងសុជាតាហើយទ្រង់ពុំទាន់សោយភ្លាមទេទ្រង់កាន់ភាជន៍ដាក់មធុបាយាសយាងទៅកាន់ស្ទឹងនេរញ្ជរា។ ចុះស្រង់ទឹករួចហើយទើបទ្រង់យាងមកលើឆ្នេរស្ទឹងវិញ ដើម្បីសោយមធុបាយាសនោះ។ កាលព្រះអង្គសោយរួចហើយក៏ទ្រង់យាងចុះទៅក្នុងស្ទឹងម្តងទៀតដើម្បីលាងព្រះហស្តសោយទឹក។ គ្រានោះឯង ព្រះអង្គក៏បានផ្សងថា៖

"បើអាត្មាអញបានត្រាស់ដឹងក្នុងថ្ងៃនេះមែន សូមអោយភាជន៍មាស ដែលអាត្មាអញបោះចូលទៅក្នុងទឹកនេះអណ្តែតច្រាសទឹកឡើង។"

លុះផ្សងរួចហើយ ទ្រង់បោះភាជន៍នោះទៅក្នុងទឹកស្ទឹង ភាជន៍នោះក៏អណ្តែតច្រាសទឹកឡើងបាន៨០ហត្ថ ទើបលិចចុះបាត់ទៅ។ ព្រះពោធិសត្វទ្រង់ឈរទតឃើញដូច្នោះ ក៏ទ្រង់ជ្រាបច្បាស់ថាព្រះអង្គនឹងបានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃនេះមិនខាន។

ព្រះពោធិសត្វទ្រង់ព្រះចិន្តាថានាងសុជាតាជាអ្នកបានជួយដល់ការស្រេកឃ្លានរបស់ព្រះអង្គ ធ្វើអោយព្រះអង្គមានសុខភាពបរិបូណ៌ឡើងវិញ។ ទ្រង់ល្បែងយល់ថា៖

"គ្មានសេចក្តីសង្ឃឹមឯណា កើតឡើងដោយសារពាក្យសំដីតែឯកឯង។ គ្មានសេចក្តីសង្ឃឹមឯណា កើតឡើងដោយការហាត់រៀនដូចតាបសតែឯកឯង។ សេចក្តីសង្ឃឹមពិតជាកើតមានក្នុងសេចក្តីមេត្តានៃមនុស្សលោកផងដែរ។"

ព្រះពោធិសត្វទ្រង់យាងចេញពីមាត់ស្ទឹងនេះតែមួយព្រះអង្គឯង ឆ្ពោះទៅកាន់ព្រៃសាលវ័ន។ នៅតាមដងផ្លូវមានព្រាហ្មណ៍ម្នាក់ឈ្មោះសោត្ថិយកុមារ កំពុងតែច្រូតស្បូវភ្លាំង (គម្ពីរខ្លះថាស្មៅស្ពារ) លុះបានជួបនឹងព្រះអង្គហើយៗមិនដឹងជាបានអ្វីយកគួរសមក៏ប្រគេនស្បូវភ្លាំងនោះចំនួន៨ក្តាប់មកព្រះពោធិសត្វ។ ព្រះអង្គក៏កាន់យកស្បូវភ្លាំងនោះ ទៅដល់



ព្រៃសាលវ័ន។ ព្រះអង្គគង់សំរាកព្រះកាយ ក្នុងព្រៃសាលវ័ននោះ តាំងពីព្រឹកដល់ពេលរសៀលទើបព្រះអង្គយាងទៅគង់នៅក្រោមដើមពោធិព្រឹក្សមួយ ជារុក្ខជាតិដុះដំណាលព្រះអង្គដែរ។ ពីដំបូងព្រះអង្គគង់ពីខាងត្បូង រួចទ្រង់គង់ពីខាងលិច រួចមកទ្រង់គង់ពីខាងជើង យកខ្នងទល់នឹងដើមពោធិនោះ។ តែការគង់ទាំងបីលើកនេះ ហាក់រដិបរដុបមិនស្រួលក្នុងព្រះទ័យសោះ។ ព្រះអង្គពិចារណាថា៖

"ទីនេះមិនមែនជាទីស្រួល ហើយមិនមែនជាទីកើតរតនបល្ល័ង្កទេ។"

ព្រះអង្គសំរេចព្រះទ័យយាងទៅគង់អំពីខាងកើតគល់ពោធិព្រឹក្សវិញដោយយកព្រះភ័ក្ត្របែរទៅទិសបូព៌ ដាក់ខ្នងទៅរកគល់ពោធិនោះ និងទ្រង់យកស្បូវភ្លាំង ទាំង៨ក្តាប់ដែលសោត្ថិយកុមារបានប្រគេននោះទៅក្រាលធ្វើជាទ្រនាប់គង់ពីលើ។ ដំណាលថាស្រាប់តែមានរតនបល្លង្កមួយផុសឡើងកំពស់១៤ហត្ថទ្រព្រះអង្គពីខាងក្រោម។

កាលរតនបល្លង្កផុសទ្រព្រះអង្គអោយគង់ស្រួលដូច្នោះហើយ ព្រះពោធិសត្វទ្រង់ពត់ព្រះភ្នែន រួចទ្រង់អធិដ្ឋានដោយអង្គ៤ថា៖

"ស្បែក សរសៃ សាច់និងឈាមរបស់អាត្មាអញចូររីងស្ងួតចុះ បើអាត្មាអញមិនបានសំរេចពន្លឺត្រាស់ដឹងទេអាត្មាអញនឹងមិនក្រោកចាកពីរតនបល្លង្កនេះឡើយ។"

បន្ទាប់មក ព្រះអង្គទ្រង់ចាប់ផ្តើមចំរើន អនាបានុស្សតិធ្វើចិត្តអោយស្ងប់ចាកនីវរណធម៌ទាំង៥ ដើម្បីសំរេចឈានជាលំដាប់។

នៅក្រោមម្លប់ពោធិព្រឹក្សឥសីគោតមផ្ចង់ព្រះស្មារតីលើគ្រប់កម្លាំងធាតុក្នុងការសញ្ជឹងគិតយ៉ាងជ្រៅទៅក្នុងរូបកាយព្រះអង្គ។ ព្រះអង្គបានសញ្ជឹងគិតឃើញនូវស្ទឹងនៃសង្ខារខន្ធ ឬសញ្ញាខន្ធ ដែលហូរទៅតាមបណ្តោយស្ទឹងនៃរូបខន្ធនិងវិញ្ញាណខន្ធ។ ព្រះអង្គទតឃើញមនុស្សលោកកំពុងជាប់ជំពាក់គ្មានទីបញ្ចប់ នូវសេចក្តីទុក្ខវេទនា ក៏ព្រោះតែការភ័ន្តច្រឡំនៃសញ្ញាខន្ធរបស់គេ។ មនុស្សម្នាក់ៗនៅមានជំនឿថា អ្វីៗដែលមិនទៀងទាត់ថាជារបស់ទៀងទាត់ អ្វីៗដែលមិនមែនជារបស់ខ្លួន(អនត្តា)ថាជារបស់ខ្លួន(អត្តា) អ្វីៗដែលគ្មានកើតនិងគ្មានស្លាប់ថាមានកើតនិងមានស្លាប់ និង អ្វីៗដែលនៅជាប់គ្នាថាជារបស់ដាច់ចេញដោយឡែកពីគ្នា។

បន្ទាប់មក ព្រះបរមពោធិសត្វបានបញ្ចេញអោយឃើញនូវការយល់ដឹងរបស់ព្រះអង្គចំពោះភាវៈខាងគំនិតប្រាជ្ញា ដែលជាប្រភពនៃសេចក្តីទុក្ខ ដូចជាការភ័យខ្លាច ខឹង ស្អប់ ក្រអឺតក្រអោង ច្រណែន ប្រច័ណ្ឌ លោភ និង ល្ងិតល្ងង់ ជាដើម។ សេចក្តីទុក្ខប្រភេទនេះមានសភាពផ្ទុយគ្នាស្រឡះទៅនឹងការពិចារណាដ៏ត្រឹមត្រូវ។ ព្រះអង្គទ្រង់យល់យ៉ាងច្បាស់ថា ប្រភពនៃទុក្ខទាំងឡាយពិតជាកើតឡើងដោយសារ អវិជ្ជា។ ដើម្បីរំដោះសេចក្តីទុក្ខនេះត្រូវតែវាយទម្លុះនូវអវិជ្ជា រុលចូលជ្រៅទៅក្នុងបេះដូងរបស់វានិងវែករកបុព្វហេតុពិតនៃស្ទឹងទាំង៥គឺ៖ រូបខន្ធ១ វេទនាខន្ធ១ សញ្ញាខន្ធ១ សង្ខារសខន្ធ១ និង វិញ្ញាណខន្ធ១។ ឥឡូវនេះ ព្រះអង្គបានយល់ច្បាស់ថាភាពមិនឋិតថេរ(អនិច្ចំ) និងភាពមិនមែនជារបស់ខ្លួន(អនត្តា) គឺជាល័ក្ខណ្ឌចាំបាច់នៃជីវិត។ បើគ្មានអនិច្ចំអនត្តាទេ ក៏គ្មានអ្វីអាចកើតឡើង និងចំរើនលូតលាស់បានឡើយ។ ឧទាហរណ៍ដូចជាគ្រាប់ស្រូវ បើសិនជាគ្មានធម្មជាតិអនិច្ចំនិងអនត្តានៃគ្រាប់ស្រូវនោះទេ ក៏គ្រាប់ស្រូវនោះពុំអាចដុះកើតជាដើមស្រូវបានដែរ។ ពពកបើឥតមានអនិច្ចំនិងអនត្តានៃពពកនោះទេ ក៏ពពកនោះពុំអាចក្លាយទៅជាភ្លៀងបានឡើយ។ បើគ្មានធម្មជាតិអនិច្ចំនិងអនត្តាទេកូនក្មេងក៏មិនអាចក្លាយទៅជាមនុស្សចាស់បានឡើយ។ ដូច្នេះហើយបានជាព្រះអង្គទ្រង់ឈ្វេងយល់ថា "មានជីវិតត្រូវតែមានភាពអនិច្ចំនិងអនត្តា។" ប្រភពនៃសេចក្តីទុក្ខគឺការជឿខុសថា អ្វីៗសុទ្ធតែមានការឋិតថេរ(អនិច្ចំ) និងជារបស់ខ្លួន(អត្តៈ)។ មនុស្សម្នាក់ៗនៅតែយល់ថាបើមិនមានកើតក៏មិនមានស្លាប់ បើគ្មានធំក៏គ្មានតូច បើគ្មានអាក្រក់ក៏គ្មានល្អ បើគ្មានចាស់ក៏គ្មានថ្មី។ល។ ព្រពោធិសត្វមានទស្សនៈថា "មនុស្សឬសត្វកើតឡើងដោយច្បាប់ធម្មជាតិនិងដោយធាតុទាំង៤គឺ ៖ ទឹក ដី ភ្លើង និង ខ្យល់ ព្រះទាំងមានកម្មជាអ្នកចាត់ចែងវាសនា។ ទាំងមនុស្សទាំងសត្វ ធាតុដែលផ្សំអោយកើតជារូបរាងឡើងនិងធ្វើអោយរូបរាងនោះរលាយបាត់ទៅវិញក៏ដោយសារតែសញ្ញាខន្ធទាំង៥នេះឯង។ មិនដូចគ្នានឹងសទ្ធិព្រាហ្មណ៍ដែលនិយាយថាមនុស្សឬសត្វកើតឡើងដោយមានអាទិទេពជាអ្នកបង្កើតនោះឡើយ។ បើកាលណាធាតុទាំងឡាយបានជួបគ្នាឬផ្សំគ្នាទើបធ្វើអោយកើតជារូបរាងឡើងនិងរូបរាងនោះរមែងប្រែប្រួលមានសុខភាពល្អឬអាក្រក់ ធាត់ឬស្គម រួចហើយរលត់បាត់(ស្លាប់)ទៅវិញជាធម្មតា។ បន្ទាប់មកទើបរត់ទៅជួបផ្សំផ្គុំគ្នាសារជាថ្មីឡើង



វិញ(កើតជីវិតថ្មីទៀត)។ ខ្លួននិងសង្ខារជាប់គ្នាដូចជាទឹកនិងរលកដែលតែងមុជងើបៗជាប់គ្នាដឹកមិនដាច់ជារៀងរហូតទៅ។"

ព្រពោធិសត្វមានជំនឿថាខន្ធទាំងនៃមនុស្សឬសត្វ ត្រូវលត់ស្លាប់បាតទៅក៏ពិតមែនហើយ តែថាមពលឬចំហាយនៃខន្ធនៅសល់ ដែលនឹងទៅផ្សំជាមួយធាតុដទៃទៀត បណ្តាលអោយកើតជារូបថ្មីមួយឡើង។ ថាមពលឬចំហាយនៃជីវិតចាស់នេះហើយឈ្មោះថា "កម្មផល"។ ជីវិតចាស់និងជីវិតថ្មី ដូចគ្នាផងប្លែកគ្នាផង។ ដូចគ្នាត្រង់ជីវិតថ្មីទទួលចំហាយកម្មផលអំពីជីវិតចាស់ ប៉ុន្តែប្លែកគ្នាត្រង់ជីវិតថ្មី មានការកសាងឬអប់រំថ្មីទៀត។ ជីវិតមនុស្សនិងសត្វតែងវិលកើតវិលស្លាប់មិនចេះអស់មិនចេះហើយ វិលវល់ក្នុងវាលវដ្តសង្សារ។ កាលបើជីវិតកើតឡើងហើយរមែងមានការចាស់ ឈឺ និងស្លាប់ ទៅវិញជាធម្មតា។

ពាក្យថា "កម្ម" មានន័យថាអំពើឬកិច្ចការដែលមនុស្សម្នាក់ៗបានប្រព្រឹត្តដោយ កាយ វា និង ចិត្ត។ កម្មដែលសំគាល់នូវអំពើនោះចែកជាបីយ៉ាងគឺ៖ កុសលកម្ម១ គឺអំពើជាកុសល អកុសលកម្ម១ គឺអំពើជាអកុសល និង អព្យាកតកម្ម១ គឺអំពើជាអព្យាក្រិត្យ។

ពាក្យថា "ផល" មានន័យថាផ្លែផ្កាដែលលេចចេញមកពីកម្ម។ បើកម្មល្អផលក៏ល្អ បើកម្មអាក្រក់ផលក៏អាក្រក់ បើកម្មល្អផងអាក្រក់ផង ផលក៏ល្អផងអាក្រក់ផង។ កម្មនិងផលតែងមានសម្ពន្ធភាពទាក់ទងគ្នាជានិច្ច ហើយកម្មតែងតែផ្តល់ផលជាដរាប គ្រាន់តែយូរនិងឆាប់ប៉ុណ្ណោះ។ កម្មខ្លះផ្តល់ផលភ្លាមៗគឺក្នុងបច្ចុប្បន្នជាតិនេះកម្មខ្លះផ្តល់ផលទៅដល់ជាតិក្រោយ គឺអនាគតជាតិ និងកម្មខ្លះផ្តល់ផលក្នុងជាតិជាលំដាប់បន្តទៅទៀត គឺជាតិក្រោយៗទៅទៀត។

ក្នុងពេលព្រលប់ ព្រះពោធិសត្វទ្រង់គង់នៅលើរតនបល្លង្ក ក្រោមដើមពោធិព្រឹក្សដោយមានទេពនិករចោមរោមធ្វើសក្ការបូជាយ៉ាងណែនណាន់តាន់តាប់។ គ្រានោះ ព្រះអង្គទ្រង់ភាវនាឃើញមនុស្សចិត្តអាក្រក់ម្នាក់ឈ្មោះ "មារ" បានហៅកូនស្រីបីនាក់ របស់ខ្លួនឈ្មោះ តណ្ហា១ អរតី១ និង រាគា១ អោយមកបញ្ជួលចិត្តព្រះសមណគោតម ដើម្បីលះបង់នូវការស្វែងរកផ្លូវត្រាស់ដឹងនោះចេញចោលទៅ។ ប៉ុន្តែព្រះគោតមទ្រង់ពុំមានចាប់អារម្មណ៍បន្តិចសោះឡើយ។

បន្ទាប់ពីទទួលបរាជ័យក្នុងការបញ្ចុលចិត្តមក ហារបានព្រលែងកងទ័ពបិសាចដ៏កាចសាហាវនិងសត្វចម្លែកតូចធំដ៏ច្រើនសន្ធឹក អោយមកច្បាំងដណ្តើមរតនបល្លង្កពីព្រះអង្គ។ មារឡើងជិះដំរីឈ្មោះ គ្រីមេខលា កំពស់១៥០យោជន៍ (១យោជន៍ស្មើ១៦គីឡូម៉ែត្រ)និម្មិតដៃ១ពាន់កាន់នូវគ្រឿងសាស្ត្រាវុធគ្រប់ប្រការ។ មារបានបញ្ជាពលសេនាដ៏ច្រើនរាប់មិនអស់កម្រាសពីខាងមុខ១២យោជន៍ ពីខាងស្តាំនិងឆ្វេង១២យោជន៍ ពីខាងលើ៩យោជន៍។ សន្ធឹកកក្រើកផែនដីឮខ្ទរអាកាសអស់ចម្ងាយ១សែនយោជន៍។ ពលសេនារបស់មារបាននិម្មិតកាយមានពណ៌ លឿង ខៀវ ខ្មៅ ពល សេនាខ្លះមានខ្លួនជាសត្វ មានក្បាលជាយក្សពួកខ្លះមានខ្លួនជាយក្ស មានក្បាលជាសត្វម្រឹគនិងជាបក្សី ហើយមានរូបកាយខ្ពស់ៗខុសគ្នាតាំងអំពីកំពស់មនុស្សធម្មតារហូតដល់កំពស់១យោជន៍។ គ្រាន់តែឮសន្ធឹកកងទ័ពមារចូលមកជិតដល់ ធ្វើអោយទេវតាចិត្តល្អដែលនៅថែរក្សាព្រះអង្គ ដូចជា សក្កទេវរាជ ដែលជាអ្នកកាន់ សង្ខវិជយុត្ត មហាព្រហ្ម ដែលជាអ្នកកាន់ ស្វេតឆ័ត្រ និងស្តេចកាឡនាគ ដែលជាអ្នកនាំកញ្ញារបាំមកច្រៀងរាំថ្វាយ នាំគ្នីគ្នារត់យកប្រាសអាយុរៀងៗខ្លួនទៅកាន់កន្លែងទីទៃៗពីគ្នា ទុកព្រះពោធិសត្វទ្រង់គង់នៅក្រោមដើមពោធិព្រឹក្សនោះ តែមួយព្រះអង្គឯង។ ព្រះសមណគោតមទ្រង់ទតឃើញ ទៅឃើញតែពលមារលើមកពីខាងទិសឧត្តរយ៉ាងណែនណាន់តាន់តាប់ រកមើលពួកទេវតាក៏មិនឃើញ សូម្បីតែព្រះញាតិវង្សានុវង្សមានព្រះមាតាព្រះបិតា ព្រះនាងពិម្ពាយសោធរាឬក៏រាហុលកុមារក៏មិនឃើញមានដែរ។ តែទោះជាយ៉ាងណា ក៏ព្រះអង្គគង់ធ្វើព្រងើយឥតមានតក់ស្លុតឬភ័យខ្លាចអ្វីឡើយ។

វាមារធិរាជស្រែកប្រាប់ពលរេហ៍របស់ខ្លួនថា៖

"នែវ៉ើយពួកយើង! សិទ្ធត្ថនេះមានបារមីខ្លាំងពូកែណាស់ ពួកយើងចូលពីខាងមុខមិនបានទេ ពួកយើងអាចចូលបានតែ ពីចំហៀងខាងឆ្វេងនិងខាងស្តាំឬក៏ពីខាងក្រោយប៉ុណ្ណោះ។" មារក៏ចាប់ថ្លែងសអោយ កើតជាខ្យល់ព្យុះដែលមានកម្លាំងអាចបក់បោកកំពូលភ្នំអោយរលំបានទៅបក់បោករូបព្រះអង្គអោយវិនាស។ តែកម្លាំងខ្យល់នោះមិនធ្វើអោយព្រះសិទ្ធត្ថចាប់អារម្មណ៍បន្តិចសោះឡើយ សូម្បីតែជាយស្បង់ចីវររបស់ព្រះអង្គក៏មិនកំរើផង។ បន្ទាប់មកក្រុងមារក៏បានបណ្តាលអោយកើតជា ផ្គរ រន្ទះ ផ្លេកបន្ទោរ ភ្លៀងព្យុះធំ ភ្លៀងដុំថ្ម ភ្លៀង



គ្រឿងប្រហារ ភ្លៀងរងើកភ្លើង ភ្លៀងផេះក្តៅ ភ្លៀងដីខ្សាច់ ភ្លៀងភក់ និង ផ្សែងអ័ព្ទងងឹតសូន្យសុងពីគ្រប់ទិសបាចសាចមកលើព្រះអង្គ តែគ្រឿងប្រហារទាំងនោះមិនអាចមក បៀតបៀនព្រះអង្គបានឡើយប្រែក្លាយទៅជាគ្រឿងបូជាទៅវិញ។ កាលឃើញដូច្នោះ វាមារធិរាជក៏បរដំរីដៃកាន់អាវុធមួយពាន់ចូលទៅជិតហើយស្រែកថា៖

"នែសិទ្ធត្ថ! ចូរអ្នកដើរចេញពីរតនបល្លង្កនេះភ្លាមទៅ ព្រោះអីរតនបល្លង្កនេះជារបស់យើងទេតើ?"

ព្រះអង្គបានពោលតបទៅកាន់វាមារធិរាជថា៖

"ម្នាល់មារអើយ! រតនបល្លង្កនេះមិនមែនកើតមកសំរាប់អ្នកទេ ពីពិតជាកើតមកសំរាប់យើងដែលជាអ្នកបានបំពេញនូវបារមី ៣០ មហាបរិច្ចាគ៥ និង ចរិយា៣ ឯណោះទេតើ។ ឃើញថាមានតែរូបអ្នកឯងវិញទេដែលមិនមែនជាអ្នកបានបំពេញនូវបារមីទាំងអស់នេះ អ្នកត្រូវតែថយចេញអំពីមណ្ឌលនៃរតនបល្លង្កក្រោមដើមពោធិព្រឹក្សនេះភ្លាមទៅ!"

ព្រះបរមពោធិសត្វ ត្រូវបានការពារដោយអានុភាពនៃគុណធម៌ រាប់មិនអស់ដែលព្រះអង្គធ្លាប់បានកសាងសន្សំនិងបន្ទំទុកតាំងអំពីអតីតជាតិមក។ កម្លាំងនៃការភាវនារបស់ព្រះអង្គពិតជាពុំអាចមានអ្វីមកបំបែកបំបាក់បានឡើយ។

កាលឮដូច្នោះ មារចិត្តបាបរិតតែខឹងខ្លាំងឡើងហើយក៏ដកយកចក្រាវុធដ៏មានមុខស្រួចមុតចោលសំដៅព្រះពោធិសត្វ តែចក្រាវុធនោះក៏បានក្លាយទៅជាពិតានបិតនៅពីលើរូបព្រះអង្គទៅវិញ។ ចំណែកឯពលរេហ៍ដែលយកកំពូលភ្នំធំៗចោលសំដៅទៅលើព្រះអង្គដែរនោះ តែដុំថ្មទាំងនោះក៏ប្រែក្លាយទៅជាកម្រងផ្កា និងគ្រឿងសក្ការបូជាថ្វាយព្រះអង្គទៅវិញ។

បន្ទាប់ពីការធ្លាក់ចុះក្នុងក្តីអស់សង្ឃឹមយ៉ាងខ្លាំងមក ក្រុងមារក៏តាំងសម្លុតទាររកភ័ស្តុតាងនៃគុណធម៌ទាំងឡាយដែលព្រះសមណគោតមមាន។

ព្រះគោតមទ្រង់ព្រះចិន្តាថា តាមធម្មតានៅថ្ងៃត្រាស់ដឹងរតនបល្លង្កតែងកើតមានសំរាប់ព្រះពោធិសត្វរាល់ព្រះអង្គជានិច្ច ឯរតនបល្លង្កនេះក៏កើតឡើងសំរាប់រូបអាត្មាអញហើយក៏សំរាប់តែអាត្មាអញដែរ។ ទ្រង់ព្រះចិន្តាដូច្នោះហើយ ក៏ត្រាស់សួរទៅមារវិញថា៖

"ម្នាលមារ! បើរតនបល្លង្កនេះជារបស់អ្នក តើអ្នកបាននរណាធ្វើជាសាក្សី?"

មារឆ្លើយតបវិញយ៉ាងខែងរែងថា៖

"ពួកពលសេនាទាំងអស់នេះហើយ ជាបន្ទាល់របស់យើង ចុះសិទ្ធត្ថឯងវិញមាននរណាធ្វើជាសាក្សីដែរ?"

ព្រះបរមពោធិសត្វយកចង្អុលព្រះហស្តស្តាំទៅពាល់ព្រះធរណី និងអំពាវនាវព្រះធរណីអោយជួយធ្វើជាសាក្សីទទួលដឹងឮចំពោះអំពើល្អរបស់ព្រះអង្គផង។ ព្រះអង្គទ្រង់ត្រាស់ថា៖

"សាក្សីរបស់អ្នកសុទ្ធតែមានចិត្តចេតនា រីឯសាក្សីរបស់យើង គឺក្រឡាមហាប្រថពីនេះឯង។"

មុទ្រៈឬកាយវិការនៃព្រះហស្តនេះបានសន្មតិថា "ការបង្ក្រាប ឬ ផ្ចាញ់មារ" ឬថា "ការយកព្រះធរណីធ្វើជាសាក្សី"។ គ្រាន់តែទ្រង់មានព្រះបន្ទូលដូច្នេះ មហាប្រថពីក៏លាន់រញ្ជួយកក្រើកឡើងហាក់ដូចជាមកទទួលថា ខ្លួនយល់ព្រមធ្វើជាបន្ទាល់របស់ព្រះពោធិសត្វមែន។ ក្នុងគ្រានោះឯង ព្រះពោធិសត្វក៏ទ្រង់បាននឹកឃើញ ដល់ ដំរីបច្ច័យនាគេន្ទ្រ ដែលព្រះអង្គបានប្រទានដល់ពួកអ្នកស្រុក កលិង្គរាស្ត្រ កាលពីទ្រង់សោយព្រះជាតិជា វេស្សន្តរពោធិសត្វ។ ពេលនោះ ដំរីគ្រីខេមលាក៏លុតជង្គង់ទ្រោមក្បាលចុះ ក្រាបថ្វាយបង្គំព្រះអង្គ។ ចំណែកឯនាង កង្ហីងព្រះធរណី ក៏បានច្បួតសក់បណ្តាលអោយទឹកជន់លិចពួកពលសេនាមារអស់មួយផ្ទែកធំ។ ក្រុងមារឃើញដូច្នោះក៏ក្រាបថ្វាយបង្គំនិងពោលសរសើរថា "បពិត្រមហាបុរសអ្នកមានញាណញេយ្យខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គជាកំពូលនៃបុរស។ ទ្រង់ជាអ្នកគ្មានបុគ្គលណាប្រៀបបាននៅក្នុងលោកនេះនិងទេវលោក។ ព្រះអង្គជាអ្នកត្រាស់ដឹង ជាមហាសាស្តាចារ្យ ជាអ្នកប្រាជ្ញអាចគ្របសង្កត់មារបាន។ ទ្រង់កាត់ផ្តាច់នូវគ្រឿងត្រាំកិលេសហើយអាចនាំពួកសត្វអោយឆ្លងផុតអំពីភពបី ដាក់ដល់ឋានបរមសុខជាអវសាន។"

មារនិងពលសេនា កាលបានពោលពាក្យយ៉ាងនេះហើយ ក៏នាំគ្នាគេចខ្លួនចេញបាត់អស់ទៅ នៅក្នុងវេលាព្រះអាទិត្យជិតអស្តង្គត។ រីឯពួកទេពនិករវិញកាលឃើញពួកមារបាក់ទ័ពរត់ខ្ចាត់ខ្ចាយអស់ ក៏នាំគ្នាត្រឡប់ចូលមកធ្វើសក្ការបូជា ថ្វាយសព្វសាធុការពរចំពោះ



ព្រះពោធិសត្វយ៉ាងគឹកកង។ មហាប្រថពី និងធម្មជាតិនានាបានសំដែងនូវអាការៈនិងកាយវិការថ្វាយព្រះពោធិសត្វដោយប្រការផ្សេងៗគ្នា។ ព្រះពោធិសត្វទ្រង់គង់លើរតនបល្លង្កក្រោមដើមពោធិព្រឹក្សនោះដោយស្ងាត់ស្ងៀម ដើម្បីពិចារណានូវ ការស្វែងស្វាធីរកពន្លឺត្រាស់ដឹងបន្តទៅមុខទៀត។

ព្រះបរមពោធិសត្វទ្រង់បន្តធ្វើភាវនាទៅពេលរាត្រីទៀត។ ព្រះអង្គសង្ឃឹមក្នុងព្រះចិន្តាថា ផ្លូវនៃពន្លឺត្រាស់ដឹងប្រហែលជានឹងបើកថ្វាយព្រះអង្គក្នុងរាត្រីនេះហើយ។

បឋមយាមនៃរាត្រី (ពេលមុនអធ្រាត្រ) ហ្វូងតារាៈព្រោងព្រាត ព្រះបរមពោធិ ទ្រង់ប្រមូលការយល់ដឹងទាំងអស់ទៅក្នុងដង្ហើមភាវនា រួចទ្រង់បិទព្រះនេត្រចុះសន្សឹមៗ។ ព្រះអង្គទ្រង់ភាវនាឃើញមានសត្វច្រើនរាប់មិនអស់បិតនៅក្នុងរូបកាយព្រះអង្គ។ សត្វខ្លះមានជីវិត សត្វខ្លះឥតជីវិតដូចជាស្លែ ស្មៅ បាណជាតិ ខនិជ(រ៉ែ) សត្វតិរច្ឆាន មនុស្សលោក និងសត្វខ្លះជារូបព្រះអង្គផ្ទាល់តែម្តង។ ព្រះអង្គភាវនាឃើញជីវិតអំពីអតីតជាតិរបស់ព្រះអង្គផ្ទាល់ ទាំងពេលប្រសូត ទាំងពេលសោយព្រះទីវង្គត។ ព្រះអង្គបានយល់យ៉ាងច្បាស់អំពីសេចក្តីសុខ និងសេចក្តីទុក្ខនៃជីវិតសត្វលោក ទាំងសត្វកើតចេញពីឧទរម្តាយឬមេ ទាំងសត្វញាស់ចេញអំពីស៊ុត(ពង) និងទាំងសត្វដែលកើតចេញពីការផ្សាំ ឬបំបៅ គឺសត្វដែលបំបែកខ្លួនឯងអោយទៅជាសត្វមួយថ្មីទៀត។ ព្រះអង្គទ្រង់ភាវនាឃើញគ្រប់កោសិការក្នុងរូបកាយព្រះអង្គទាំងនៅក្នុងឋានសួគ៌ និងទាំងនៅក្នុងឋានមនុស្សលោក ហើយត្រូវឆ្លងកាត់វដ្តសង្សារទាំងបីកាលគឺ៖ អតីតកាល១ បច្ចុប្បន្នកាល១ និង អនាគតកាល១។ព្រះសមណគោតមទ្រង់បានជ្រាបច្បាស់នូវសេចក្តីនេះហើយក៏ទ្រង់បន្លឺនូវឧទានគាថាយ៉ាងនេះថា "ធម៌ទាំងឡាយរមែងមានដល់ ខីណាសវព្រាហ្មណ៍ណា ដែលជាអ្នកបានព្យាយាមញ៉ាំងបិលេសអោយក្តៅ និងលះបង់នូវកិលេសទាំងអស់នោះ។ សេចក្តីសង្ស័យទាំងឡាយក៏រម្ងាប់អស់ក្នុងកាលនោះដែរ ពីព្រោះតែខីណាសវព្រាហ្មណ៍នោះ បានដឹងច្បាស់នូវធម៌និងបុព្វហេតុនៃធម៌ទាំងនោះ។"

ការភាវនានៅក្នុងបឋមយាមនៃរាត្រីនោះ ព្រះសមណគោតមទ្រង់បានសំរេចនូវ "បុព្វេនិវាសាបុស្សតិញ្ញាណ" គឺប្រាជ្ញាជាគ្រឿងរំលឹកនូវខ័ន្ធទាំងឡាយដែលធ្លាប់បានប្រព្រឹត្ត

កាលអំពីជាតិមុនៗមក។

មជ្ឈិមយាមនៃរាត្រី(ពេលពាក់កណ្ដាលអធ្រាត្រ) ការទតលើកទីពីរនៃរាត្រីទ្រង់បានសញ្ជឹងជ្រៅទៅក្នុងសមាធិហើយ។ ព្រះអង្គភាវនាឃើញពិភពឬឋានរាប់មិនអស់អណ្ដែតឡើងហើយលិចចុះទៅវិញ។ ពិភពលោកជាច្រើនបានកើតឡើងថ្មី រួចក៏រលាយបាត់ទៅ។ ព្រះអង្គទ្រង់ទតឃើញសត្វដ៏ច្រើនឥតគណនាកើតហើយ ស្លាប់ទៅវិញរាប់ដងមិនអស់ វិស័យដូចជារលកទឹករាប់លាន ដែលលេចឡើងហើយរលាយធ្លាក់ចុះទៅវិញឥតឈប់ឈរ នៅលើផ្ទៃទឹកសមុទ្រ (នៅពេលសមុទ្រខ្លួនឯងស្ថិតនៅឆ្ងាយអំពីការកើតនិងការស្លាប់ដូច្នោះឯង)។ បើសិនជារលកទាំងនោះយល់ថាខ្លួនឯងជាទឹក ទើបរលកនោះអាចរុះពារសេចក្ដីកើតនិងស្លាប់ ព្រមទាំងមកដល់សេចក្ដីស្ងប់ខាងក្នុងចិត្តដែលអាចមានជ័យជំនះលើការភ័យខ្លាចទាំងអស់បាន។

ព្រះអង្គទតឃើញសត្វទាំងឡាយប្រកបដោយ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាអ្នកតិះដៀលនូវ ព្រះអរិយៈ ជាមនុស្សមិច្ឆាទិដ្ឋិ សមាទាននូវ មិច្ឆាទិដ្ឋិកម្មលុះស្លាប់ទៅនឹងទៅកើតក្នុង អបាយទុគ្គតិវិនិបាត នា ឋាននរក។ សត្វទាំងឡាយប្រកបដោយ កាយសុចរិត វចីសុចរិត មនោសុចរិត ជាអ្នកមិនតិះដៀលនូវព្រះអរិយៈជាមនុស្ស សម្មាទិដ្ឋិ សមាទាននូវ សម្មាទិដ្ឋិកម្ម លុះពេលស្លាប់ទៅនឹងទៅកើតក្នុង សុគតិសួគ៌ នាឋានទេវលោក។ ព្រះគោតមទ្រង់ជ្រាបច្បាស់នូវសេចក្ដីនេះហើយព្រះអង្គទ្រង់បន្លឺនូវឧទានគាថាយ៉ាងនេះថា៖

"ធម៌ទាំងឡាយរមែងមានដល់ខីណាសវព្រាហ្មណ៍ដែលជាអ្នកព្យាយាមញុំាងកិលេសអោយក្ដៅ និង លះបង់ចោលនូវកិលេសទាំងអស់នោះ។ សេចក្ដីសង្ស័យទាំងឡាយ ក៏រម្ងាប់អស់ក្នុងពេលនោះដែរ ព្រោះខីណាសវព្រាហ្មណ៍នោះ បានដឹងច្បាស់នូវព្រះនិព្វានដែលជាទីអស់ទៅនៃបច្ច័យហើយ។"

ការយល់ ដឹងនេះអាចនាំអោយព្រះសិទ្ធត្ថរុះពារលើសំណាញ់នៃការកើតនិងស្លាប់បាន។ ព្រះសមណគោតមទ្រង់ញញឹម ដោយបានសំរេចការទតលើកទីពីរនៃរាត្រីនេះនូវ "ចុតូបបាតញ្ញាណ" គឺប្រាជ្ញាជាគ្រឿងមើលឃើញច្បាស់ ចំពោះសត្វដែលកើតក្នុងទីថោក



ទាបឬឧត្ដមខ្ពង់ខ្ពស់ មានដំណើរជីវិតអាក្រក់ឬល្អ យោលតាមអំពើដែលខ្លួនបានសាង។

បច្ឆិមយាមនៃរាត្រី(ពេលទៀបភ្លឺ) ការទតជាទីបំផុតនៃរាត្រី ព្រះគោតមទ្រង់ពិចារណាថា៖

"សត្វលោកទាំងឡាយតែងមានទុក្ខដោយការ កើត ចាស់ ឈឺ និង ស្លាប់ ហើយមិនដឹងនូវនូវឧបាយសំរាប់រលាស់ខ្លួនអោយផុតចាកពីសេចក្ដីទុក្ខបាន។"

ព្រះអង្គរំពឹងរកបុព្វហេតុនៃសេចក្ដីស្លាប់នេះថាតើមកពីប្រភពណា? ព្រះអង្គទ្រង់ត្រិះដោយញាណថា៖

"កាលបើនេះមាននោះក៏មាន បើនេះគ្មាននោះក៏គ្មាន បើនេះរលត់នោះក៏រលត់ដែរ ។ល។"

ព្រះអង្គទ្រង់ប្រៀបធៀបទៅរកការកើតនិងការស្លាប់ថា៖
"បើភពមានជាតិក៏មាន ដូច្នេះតើភពមានអ្វីជាបច្ច័យ?"

ព្រះអង្គគិតដេញរហូតទាល់តែរកឃើញថា៖ ពុំមានភាវៈណាមួយកើតឡើងដាច់តែឯកឯងដោយគ្មានហេតុបច្ច័យទាក់ទងគ្នានោះទេ និងក៏ពុំមានភាវៈណាមួយសំខាន់ឬដើមគេ ដូចភាវៈព្រហ្ម័ននៅក្នុងព្រាហ្មណ៍លិទ្ធិឡើយ។ ព្រះអង្គរកឃើញឫសគល់នៃសេចក្ដីទុក្ខចំពោះការកើតនិងស្លាប់ថាពិតជាកើត ឡើងដោយ "អវិជ្ជា" ហើយជាប់ទាក់ទងរវាងគ្នានិងគ្នាក្នុងបុព្វហេតុ១២យ៉ាងដូចតទៅ៖

| | | |
|---|---|---|
| ១. អវិជ្ជា | នាំអោយកើត | សង្ខារ |
| ២. សង្ខារ | នាំអោយកើត | វិញ្ញាណ |
| ៣. វិញ្ញាណ | នាំអោយកើត | នាមរូប |
| ៤. នាមរូប | នាំអោយកើត | អាយតនៈ |
| ៥. អាយតនៈ | នាំអោយកើត | ផស្សៈ |
| ៦. ផស្សៈ | នាំអោយកើត | វេទនា |
| ៧. វេទនា | នាំអោយកើត | តណ្ហា |
| ៨. តណ្ហា | នាំអោយកើត | ឧបាទាន |

| | | |
|---|---|---|
| ៩. ឧបាទាន | នាំអោយកើត | ភព |
| ១០. ភព | នាំអោយកើត | ជាតិ |
| ១១. ជាតិ | នាំអោយកើត | ជរា និង |
| ១២. ជរា១ | នាំអោយកើត | មរណៈ។ |

ព្រះអង្គទ្រង់ពិចារណាជាអនុលោមគឺគិតជាបណ្តោយថា បើធាតុឬភាវៈណាមួយកើតឡើយហើយ ធាតុឬភាវៈដទៃទៀតនៅក្នុងចំណោមទាំង១២ ត្រូវតែកើតឡើងជាបន្តបន្ទាប់គ្នា។ មានន័យថាបើអវិជ្ជាកើតសង្ខារក៏កើត ឯសង្ខារនាំអោយវិញ្ញាណកើតតៗគ្នាជាហូរហែរហូតដល់មរណៈ។

ព្រះអង្គទ្រង់ពិចារណាជាបដិលោមគឺគិតបញ្ច្រាសមកវិញថា បើអវិជ្ជារលត់សង្ខារក៏រលត់គឺរលត់តៗគ្នា លុះត្រាតែអស់រលីងសូន្យសុង ដែលហៅថា "និរោធ" គឺការជ្រះស្រឡះឬរលត់រលាយអស់នូវឫសគល់នៃការកើត និងស្លាប់ឬនៃសេចក្តីទុក្ខនេះឯង។ ការទាក់ទងគ្នាទៅវិញទៅមកតាមបែបខាងលើនេះមានសភាពដូចជាច្រវាក់ដែលទាក់ទងគ្នាជាកម្រង ឬជារង្វង់មូលពុំមានដើម ហើយមានចលនាវិលចុះវិលឡើងមិនចេះចប់។ បុព្វហេតុនៃការកើតនិងស្លាប់របស់សត្វលោក ដែលជាធម៌ភាពភ្ជាប់ហេតុនិងផលនេះ ព្រះពោធិសត្វទ្រង់ព្រះបញ្ញត្តិជាទ្រឹស្តីថា "ទ្រឹស្តីបដិច្ចសមុប្បាទ"។

ព្រះអង្គបានពិចារណាឃើញទៀតថាការយល់ដឹងនិងសេចក្តីស្រឡាញ់មានតែមួយ បើគ្មានការយល់ដឹងក៏គ្មានសេចក្តីស្រឡាញ់ដែរ មានការយល់ដឹងច្បាស់លាស់ពិតជានាំអោយកើតមានសេចក្តីមេត្តានិងសេចក្តីស្រឡាញ់ ដែលអាចរំលាយនូវគ្រប់សេចក្តីទុក្ខនិងព្រួយបារម្ភបាន។ ដើម្បីអោយបានសំរេចនូវការយល់ដឹងនេះ ចាំបាត់មនុស្សម្នាក់ៗត្រូវរស់នៅដោយមានការពិចារណាត្រឹមត្រូវ។ ការពិចារណាត្រឹមត្រូវអាចនាំអោយមានការយល់ដឹងនូវការរំដោះខ្លួនចេញអំពីសេចក្តីទុក្ខនិងឆ្ពោះទៅរកពន្លឺត្រាស់ដឹង។ ជីវិតអាចបំភ្លឺអោយឃើញច្បាស់ ដោយការពិតដ៏ប្រសើរឧត្តមមួយដែលព្រះអង្គបានពិចារណារកឃើញនូវអរិយសច្ចៈ៤ ឬ ចតុរារិយសច្ចៈ គឺ៖ ទុក្ខអរិយសច្ចៈ១ សមុទយអរិយសច្ចៈ១ និរោធអរិយសច្ចៈ១ និង មគ្គអរិយសច្ចៈ១។



ឥឡូវនេះដល់ទីបញ្ចប់នៃការទតលើកទីបំផុតនៃរាត្រីហើយ។ ផ្គរ រន្ទះ ភ្លៀង ក៏បាត់ស្ងាត់ឈឹង ពពកខ្មៅរសាត់បាត់អស់ពីផ្ទៃមេឃ ព្រះច័ន្ទបញ្ចេញពន្លឺថ្លាត្រចង់និងហ្វូងតារារះភ្លឺព្រោងព្រាត។ ព្រះសមណគោតមមានព្រះហឫទ័យដូចជាព័ន្ធនាគារដែលបានឃុំឃាំងព្រះអង្គអស់រាប់ពាន់ឆ្នាំមកហើយនោះត្រូវរបើកទ្វារចំហរធ្លុងឡើង។ អវិជ្ជាទុកដូចជាឆ្មាំយាមព័ន្ធនាគារ។ ដោយសារអវិជ្ជានេះហើយ ដែលធ្វើអោយព្រះចិន្តាព្រះអង្គងងិតសូន្យសុងប្រៀបដូចជាពន្លឺព្រះច័ន្ទនិងផ្កាយដែលត្រូវបិទបាំងអាប់រស្មីដោយផ្ទាំងពពកខ្មៅខ្ពលដូច្នោះដែរ។ ព្រះអង្គទ្រង់បន្លឺនូវព្រះឧទានវាចាមួយវគ្គថា៖

| | |
|---|---|
| កាលពីអង្គអញតថាគត | អន្ទោលក្នុងវាលវដ្តសង្សារ |
| ច្រើនអសង្ខេយ្យកោដិកប្បា | តែងបានទុក្ខារាល់ជាតិភព។ |
| ឥឡូវតណ្ហាគឺជាផ្ទះ | តថាគតយល់ច្បាស់ក្នុងចិត្តស៊ប់ |
| បានដឹងបានឃើញដោយសព្វគ្រប់ | អ្នកឈប់សង់ផ្ទះបានទៀតហើយ។ |
| ឆ្អឹងជំនី និងដំបូលអ្នក | ត្រូវអញបំបាក់ឥតសល់ឡើយ |
| ចិត្តតថាគតបានដល់ត្រើយ | ឥតតណ្ហាឡើយគឺនិព្វាន។ |

សេចក្តីទុក្ខនៃការ កើត ចាស់ ឈឺ និងស្លាប់ គ្រាន់តែធ្វើអោយជញ្ជាំងគុកកាន់តែក្រាស់ឡើងប៉ុណ្ណោះ។ មានរឿងតែមួយគត់ ដែលយើងត្រូវធ្វើគឺចាប់អ្នកយាមគុកអវិជ្ជាអោយបានហើយមើលមុខវាអោយច្បាស់។ ដើម្បីនឹងច្បាំងឈ្នះនូវអវិជ្ជានេះយើងម្នាក់ៗត្រូវតែអនុវត្តនូវ មគ្គអរិយសច្ចៈ៤(អដ្ឋង្គិកមគ្គ) អោយបានខ្ជាប់ខ្ជួន។ នៅពេលអ្នកយាមគុកត្រូវចាប់ខ្លួន ពន្ធនាគារក៏បាត់រូបដែរ ហើយមិនអាចសង់ឡើងវិញម្តងទៀតឡើយ។ ព្រះគោតមជ្រាបសេចក្តីនេះច្បាស់ហើយ ក៏ទ្រង់បន្លឺឧទានគាថាចុងក្រោយថា៖

"ធម៌ទាំងឡាយរមែងមានដល់ខីណាសវព្រាហ្មណ៍ ដែលជាអ្នកបានព្យាយាមញ៉ាំងកិលេសអោយក្តៅ និងបានលះបង់ចោលនូវកិលេសទាំងអស់នោះ។ ខីណាសវព្រាហ្មណ៍បានកំចាត់បង់នូវមារ ព្រមទាំងសេនារបស់វាក្នុងពេលនោះបីដូចជាបន្លឺរស្មីព្រះអាទិត្យរះឡើងកំចាត់បង់នូវភាពងងឹត និងធ្វើអោយអាកាសភ្លឺរុងរឿងដូច្នោះដែរ។"

ពេលព្រះអង្គងើយព្រះសិរទៅលើមេឃ ព្រះគោតមទ្រង់ទតឃើញផ្កាយព្រឹករះឡើង

នាជើងមេឃទិសបូព៌ា កំពុងតែបញ្ចេញរស្មីភ្លឺពណ្ណរាយ បីដូចជាដុំពេជ្រ ដ៏ធំមហិមាមួយ។ ព្រះសមណគោតមធ្លាប់ទតឃើញផ្កាយព្រឹកនេះរាប់រយដងមិនអស់មកហើយនៅពេលព្រះអង្គគង់ធ្វើសមាធិក្រោមដើមពោធិព្រឹក្ស ប៉ុន្តែនៅព្រឹកនេះព្រះអង្គហាក់ដូចជាទើបនឹងទតឃើញផ្កាយព្រឹកនេះជាលើកដំបូងបង្អស់នៅក្នុងជីវិតព្រះអង្គ។ ព្រះឈ្មោះមារក៏បានដឹងយ៉ាងច្បាស់ថា ព្រះអង្គបានរកឃើញពន្លឺនៃការត្រាស់ដឹង និងបានសំរេចព្រះបំណងហើយ។ ឥឡូវនេះព្រះហឫទ័យរបស់ព្រះអង្គបានទទួលនូវសុខសន្តិភាពល្អឥតខ្ចោះ ប្រាសចាកស្រឡះកងទុក្ខទាំងពួងនិងការងោកងុយ។ ព្រះអង្គបានទទួលនូវព្រះបរមសុខពេញបរិបូណ៌ហើយ។

កាលបានត្រាស់ដឹងនូវព្រះសម្មាសម្ពោធិញ្ញាណហើយ ព្រះអង្គហាក់មានពន្លឺរស្មីចាំងសាយចេញអំពីព្រះកាយដែលប្រកបទៅដោយ សិរីសោភគ្គសម្បត្តិ ដ៏រុងរឿងក្រៃពេក។ ជំនោរត្រជាក់បករំភើយៗមកប៉ះនឹងស្លឹកពោធិព្រឹក្សពណ៌ប្រាក់ ក្រោមពន្លឺព្រះចន្ទថ្លា ធ្វើអោយលាន់ឮសម្លេងរងំដូចគេប្រគំតន្ត្រីដ៏ពីរោះ។ បុប្ផាជាតិទាំងឡាយដែលត្រូវទឹកសន្សើមរីកស្រស់ស្គុះស្គាយ ចោលសុគន្ធពិដោរក្រអូបសាយ ហាក់ចូលមកបូជានិងថ្វាយព្រះពរជ័យដល់ការត្រាស់ដឹងរបស់ព្រះអង្គ នាពេលមុនព្រះអរុណរះក្នុងថ្ងៃពុធ ១៥កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ត្រូវនឹងថ្ងៃទី ៨ ខែធ្នូ មុនព្រះពុទ្ធសករាជ៤៥ឆ្នាំ ក្នុងគំរប់ព្រះជន្មាយុ៣៥ព្រះវស្សានោះឯង។

ព្រហាមស្រាងៗឡើង រុក្ខាលតាវល្លិទាំងឡាយ បញ្ចេញផ្កាចំរុះពណ៌មីរដេរដាស។ ព្រះអាទិត្យរេរាំលើចុងព្រឹក្សានិងចាំងឆ្លុះទៅក្នុងផ្ទៃទឹក។ អ្វីៗទាំងអស់ហាក់ដូចជាកើតឡើងប្លែកៗ។ ព្រះគោតមទ្រង់ព្រះចិន្តាថា៖

"អ្វីៗទាំងអស់ក្នុងលោកសន្និវាសនេះ កើតឡើងថ្មីស្រឡាងទាំងអស់។"

រំពេចនោះសោត្ថិយកុមារបានដើរចូលមក។ ពេលព្រះសមណគោតមញញឹមដាកនិងទ្រង់ស្រែកហៅថា៖

"សោត្ថិយកុមារ ចូលមកនេះ!"

សោត្ថិកុមារម្ទីម្ទាស្ទុះ ចូលទៅជិតព្រះអង្គហើយបង្គំទូលថា៖



"បពិត្រព្រះអង្គដ៏ចំរើន! តើមានហេតុអ្វីកើតឡើង បានជាថ្ងៃនេះព្រះអង្គមើលទៅប្លែកខុសពីធម្មតាឆ្ងាយម្ល៉េះ?"

ព្រះសមណគោតមចាប់កាន់ដៃសោត្ថិយកុមារនិងទ្រង់ត្រាស់សួរថា៖

"នែសោត្ថិយកុមារ! តើតថាគតមើលទៅប្លែកដូចម្តេចខ្លះ ថ្ងៃនេះ?"

សោត្ថិយកុមារបង្គំទូលថា៖

"បពិត្រព្រះគោតម! ខ្ញុំព្រះអង្គដូចជាពិបាកថាណាស់ គ្រាន់តែមើលទៅឃើញព្រះអង្គប្លែកតែម្តង! ព្រះអង្គ ដូ ដូ ដូចជាតារាមួយដួងអីញ៉ឹង!"

ព្រះអង្គយកព្រះហស្តអង្អែលក្បាលសោត្ថិយកុមារ ហើយត្រាស់សួរថា៖

"គ្រាន់តែមើលទៅឃើញប្លែកប៉ុណ្ណឹងទេឬ? តើអ្នកមើលទៅឃើញដូចអ្វីខ្លះទៀតដែរឬទេ?"

សោត្ថិយកុមារក្រាបបង្គំទូលថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ព្រះអង្គមើលទៅហាក់បីដូចបទុមបុប្ផា (ផ្កាឈូក) ដែលកំពុងតែរីកស្រស់ក្រពុំ។ ហើយ ដូ ដូ ដូចជាព្រះចន្ទ្ររះនៅលើក្បាលកោះគយាសីសៈអីញ៉ឹង!"

ព្រះអង្គទតឆ្ពោះត្រង់ចំភ្នែកសោត្ថិយកុមារ រួចទ្រង់ត្រាស់សួរទៀតថា៖

"សោត្ថិយកុមារ ហេតុអ្វីអ្នកចេះនិយាយបានល្អដូចជាកវីម្ល៉េះ! ចូរអ្នកប្រាប់តថាគតផងមើល៍ តើហេតុអ្វីបានជាថ្ងៃនេះ អ្នកមកដល់ទីនេះទាំងព្រលឹមអុលម្ល៉េះ? ហើយតើសត្វក្របីទាំងឡាយរបស់អ្នកនៅឯណាដែរហ្នឹង?"

សោត្ថិយកុមារក៏បង្គំទូលរៀបរាប់ថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ថ្ងៃនេះខ្ញុំព្រះអង្គត្រូវបានឈប់សំរាកមួយថ្ងៃ ព្រោះសត្វក្របីទាំងអស់ត្រូវគេយកទៅភ្ជួរស្រែអស់។ នៅសល់តែកូនតូចៗមួយចំនួន ក្នុងក្រោលប៉ុណ្ណោះក៏ប៉ុន្តែ ខ្ញុំព្រះអង្គបានច្រូតស្មៅដាក់ អោយវាស៊ីរួចស្រេចហើយ។ កាលពីយប់មិញនេះទូលបង្គំនិងបងប្អូនទាំងអស់ទទួល ទានដំណេកមិនលក់ទាល់តែសោះមកពីឮស្គររន្ទះបាញ់ខ្លាំងពេក ហើយទឹកភ្លៀងក៏លិចតាមដំបូលទទឹកកន្លែងដេកជោគអស់។ ខ្ញុំព្រះអង្គទាំងអស់គ្នាមិនដែលបានជួបប្រទះនូវភ្លៀងព្យុះធំបែបហ្នឹងទេ។ ខ្ញុំព្រះអង្គទាំងអស់គ្នានឹកព្រួយបារម្ភមក

ព្រះអង្គ ដែលគង់នៅកណ្តាលវាលតែមួយព្រះអង្គឯងក្នុងព្រៃនេះមិនដឹងជាពិបាកយ៉ាងណាទៅ។ ហេតុដូច្នេះហើយបានជាថ្ងៃរះមិនទាន់ស្រួលបួលផង ខ្ញុំព្រះអង្គក៏រូតរះយកស្មៅទៅដាក់អោយកូនក្របី ដែលនៅសល់ក្នុងក្រោលនោះសិនទើបខ្ញុំព្រះអង្គធ្វើដំណើរមករកព្រះអង្គទាំងព្រលឹមអុលយ៉ាងនេះ!"

ព្រះអង្គក្តាប់ដៃសោត្ថិយកុមារយ៉ាងណែននិងទ្រង់ត្រាស់សួរថា៖

"ម្នាស់សោត្ថិយ! ថ្ងៃនេះជាថ្ងៃដែលតថាគតបានរកឃើញនូវ សម្មាសម្ពោធិញ្ញាណជាលើកដំបូងក្នុងជីវិតរបស់តថាគតនេះ។ ប្រសិនបើអ្នកអាចនាំមិត្តភក្តិរបស់អ្នកមកកាន់សំណាក់តថាគតនៅក្រោមដើមពោធិព្រឹក្សក្នុងពេលរសៀលនេះបាន ចូរអ្នកទៅហៅគ្នាមកចុះ។"

សោត្ថិយកុមារអរហាក់កញ្ឆេងក៏ក្រាបបង្គំលាព្រះគោតមចេញបាត់ទៅ។

គ្រាន់តែសោត្ថិយកុមារចេញផុតបន្តិច ស្រាប់តែនាងសុជាតា យកចង្ហាន់មកដល់។ នាងសុជាតាមានអារម្មណ៍ចម្លែក កាលបានឃើញព្រះសមណគោតមគង់នៅក្រោមពោធិព្រៃនោះ មានព្រះកាយល្អដូចជាទេវតានិមិត្ត ឬដូចជាបុប្ផាព្រឹកព្រហាម។ ព្រះភ័ក្ត្រនិងព្រះកាយរបស់ព្រះអង្គ បង្ហាញអោយឃើញនូវសេចក្តីសុខសប្បាយ និងស្ងប់ស្ងៀមជាទីបំផុត។ នាងសុជាតាធ្លាប់បានឃើញព្រះគោតម គង់នៅក្រោមដើមពោធិព្រៃនេះរាប់រយដងមិនអស់មកហើយ ក៏ប៉ុន្តែមិនដូចជាថ្ងៃនេះសោះ ដែលព្រះអង្គមើលទៅមានសភាពផ្ទុយស្រឡះអំពីធម្មតា។ នាងសញ្ជឹងគិតដោយក្តីរំភើបថាព្រះគោតមពិតជាបានទទួលនូវពន្លឺត្រាស់ដឹងរួចផុតអំពីសេចក្តីទុក្ខកង្វល់ទាំងអស់ហើយ។

បន្ទាប់ពីនាងសុជាតាប្រគេនចង្ហាន់ដល់ព្រះសម្មាសម្ពុទ្ធរួចមក សោត្ថិយកុមារនិងមិត្តភក្តិ រួមទាំងបងប្អូនប្រុសស្រីរបស់ខ្លួនផងចូលមកដល់។ គេបានយកមកជាមួយនូវផែនស្ករត្នោត ផ្លែដូងខ្ចីនិងក្រូចឃ្វិច។ នាងសុជាតាបានណែននាំក្មេងទាំងឡាយអោយស្គាល់ព្រះសមណគោតម ហើយព្រះគោតមក៏បានសំដែងធម៌ស្តីអំពីការរស់នៅដោយដឹងខ្លួន(សតិប្បដ្ឋាន៤) អោយ។ នាងសុជាតាបានបង្គំទូលសួរព្រះអង្គថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ព្រះអង្គជាអ្នកត្រាស់ដឹងដ៏ពិតប្រាកដនិងជាអ្នកបានទូន្មានខ្ញុំ



ព្រះអង្គទាំងឡាយអោយយល់ច្បាស់អំពីរបៀបរស់នៅដោយដឹងខ្លួន ថាយ៉ាងដូចម្តេចទៀតផង បើដូច្នេះតែខ្ញុំព្រះអង្គទាំងឡាយ អាចហៅព្រះនាមព្រះអង្គថា ជា "បុគ្គលត្រាសដឹង" បានដែរឬទេ?"

ព្រះពុទ្ធជាម្ចាស់ទ្រង់បានយល់ព្រមចំពោះពាក្យនាងសុជាតាដោយតុណ្ហីភាព។

នាងសុជាតាបង្គំទូលសួរបន្តទៀតថា៖

"បពិត្រមហាសាស្តាចារ្យ! ពាក្យថា "ពុទ្ធ" ជាភាសាមគធីប្រែថា "ត្រាស់ដឹង" ដូច្នេះបុគ្គលអ្នកត្រាស់ដឹងគួរតែហៅតាម ភាសាមគធីថា "ពុទ្ធៈ"ដែរ។ តើព្រះអង្គអាចអនុញ្ញាតអោយខ្ញុំព្រះអង្គទាំងឡាយហៅព្រះនាមព្រះអង្គថា "ពុទ្ធៈ" យ៉ាងដូច្នេះជារៀងរហូតទៅបានដែរឬទេ?"

ព្រះពុទ្ធទ្រង់ងក់ព្រះសិរជាសញ្ញាបង្ហាញនូវការយល់ព្រមម្តងទៀត។

មានក្មេងប្រុសចំណាស់ជាងគេឈ្មោះ នាឡិកៈ អាយុ១៤ឆ្នាំ បង្គំទូលថា៖

"ព្រះពុទ្ធជាទីគោរព! នាងសុជាតាបាននិយាយប្រាប់ទូលព្រះបង្គំថា ព្រះអង្គបានតាំងសមាធិនៅក្រោមដើមពោធិព្រៃនេះ អស់រយៈកាល៦ខែកន្លងមកហើយៗ បើយប់មិញនេះទៀត ក៏ព្រះអង្គបានសំរេចនូវការត្រាស់ដឹងដ៏ឧត្តមទៀតផង បើដូច្នោះមែ តើខ្ញុំព្រះអង្គទាំងឡាយអាចហៅដើមព្រៃនេះថា "ដើមឈើត្រាស់ដឹង ឬ ដើមពោធិព្រឹក្ស" បានដែរឬទេ? ពីព្រោះអីពាក្យ "ពោធិ៍" ក៏មានឫសគល់ដូចគ្នានឹងពាក្យ "ពុទ្ធៈ" ដែរ ហើយក៏មានន័យថា "ត្រាស់ដឹង" ទៀតផង។

ព្រះពុទ្ធទ្រង់មានព្រះបិតិសោមនស្សយ៉ាងខ្លាំង ទ្រង់ញញឹមហើយងក់ព្រះសិរបង្ហាញការយល់ព្រមម្តងទៀត។

នាងសុជាតា សោត្ថិយកុមារនិងក្មេងទាំងឡាយ មានសេចក្តីសប្បាយរីករាយឥតឧបមា ក៏នាំគ្នាក្រោកឈរហើយលើកដៃសំពះថ្លែងអំណរគុណព្រះពុទ្ធ។

---

ពាក្យគួរចងចាំ៖

# ទ្រឹស្តីបដិច្ចសមុប្បាទ

អនុលោម (គិតបណ្តោយទៅ)

| | | |
|---|---|---|
| ១. អវិជាបច្ចយា | សង្ខារា | អវិជ្ជា នាំអោយកើត សង្ខារ។ |
| ២. សង្ខារប្បច្ចយា | វិញ្ញាណំ | សង្ខារ នាំអោយកើត វិញ្ញាណ។ |
| ៣. វិញ្ញាណប្បច្ចយា | នាមរូបំ | វិញ្ញាណ នាំអោយកើត នាមរូប។ |
| ៤. នាមរូបប្បច្ចយា | សឡាយតនំ | នាមរូប នាំអោយកើត អាយតនៈ។ |
| ៥. សឡាយតនប្បច្ចយា | ផស្សោ | អាយតនៈ នាំអោយកើត ផស្សៈ។ |
| ៦. ផស្សប្បច្ចយា | វេទនា | ផស្សៈ នាំអោយកើត វេទនា។ |
| ៧. វេទនាបច្ចយា | តណ្ហា | វេទនា នាំអោយកើត តណ្ហា។ |
| ៨. តណ្ហាបច្ចយា | ឧបាទានំ | តណ្ហា នាំអោយកើត ឧបាទាន។ |
| ៩. ឧបាទានប្បច្ចយា | ភវោ | ឧបាទាន នាំអោយកើត ភព។ |
| ១០. ភវប្បច្ចយា | ជាតិ | ភព នាំអោយកើត ជាតិ។ |
| ១១. ជាតិប្បច្ចយា | ជរាមរណៈ | ជាតិ នាំអោយកើត ជរាមរណៈ។ |

១២ ជរាមរណប្បច្ចយា ជរាមរណៈនាំអោយកើតសេចក្តីសោកបរិវេទនាទោមនស្សុបាយាសា ទោមនស្ស ក្សិកក្សួល សម្ភវន្តិ ឯវមេតស្ស កេវលស្ស សេចក្តីលំបាកកាយលំបាកចិត្តនិង ទុក្ខក្ខន្ធស្ស សមុទយេ ហោតិ។ សេចក្តីចង្អៀតចង្អល់ក៏កើតព្រមគ្នាដោយប្រការនេះឯង។ កងទុក្ខទាំងអស់រមែងកើតឡើងយ៉ាងនេះ។

---



ពាក្យគួរចងចាំ

# ទ្រឹស្តីបដិច្ចសមុប្បាទ

បដិលោម (គិតបញ្ច្រាសមកវិញ)

| | | |
|---|---|---|
| ១. អវិជ្ជាយ | ត្វេវ | អសេសវិរាគនិរោធា អវិជ្ជារលត់ សង្ខារក៏រលត់។ |
| ២. សង្ខារនិរោធោ | វិញ្ញាណនិរោធោ | សង្ខាររលត់វិញ្ញាណក៏រលត់។ |
| ៣. វិញ្ញាណនិរោធោ | នាមរូបនិរោធោ | វិញ្ញាណរលត់នាមរូបក៏រលត់។ |
| ៤. នាមរូបនិរោធោសឡាយតននិរោធោ | | នាមរូបរលត់អាយតនៈក៏រលត់។ |
| ៥. សឡាយតននិរោធោផស្សនិរោធោ | | អាយតនៈរលត់ផស្សៈក៏រលត់។ |
| ៦. ផស្សនិរោធោ | តណ្ហានិរោធោ | ផស្សៈរលត់វេទនាក៏រលត់។ |
| ៧. វេទនានិរោធោ | តណ្ហានិរោធោ | វេទនារលត់តណ្ហាក៏រលត់។ |
| ៨. តណ្ហានិរោធោ | ឧបាទាននិរោធោ | តណ្ហាររលត់ឧបាទានក៏រលត់។ |
| ៩. ឧបាទាននិរោធោ | ភវនិរោធោ | ឧបាទានរលត់ភពក៏រលត់។ |
| ១០. ភវនិរោធោ | ជាតិនិរោធោ | ភពរលត់ ជាតិក៏រលត់។ |
| ១១. ជាតិនិរោធោ | ជរាមរណំ | ជាតិរលត់ជារាមរណៈក៏រលត់។ |

១២. សោកបរិវេទក្ខទោមនស្សុបាយាសា សេចក្តីសោកសេក្តីក្សិកក្សួលនិរុជ្ឈន្តិ ឯវមេតស្ស លេវលស្ស សេចក្តីលំបាកកាយលំបាកចិត្ត ទុក្ខក្ខន្ធស្ស និរោធោ ហោតិ។ និងសេចក្តីចង្អៀតចង្អល់ក៏រលត់ព្រមគ្នាដោយប្រការនេះឯង។ កងទុក្ខទាំងអស់នេះ រមែងរលត់ទៅជាយ៉ាងនេះ។

---

# ជំពូកទី ១១
# ព្រះពុទ្ធសោយវិមុត្តិសុខ៧សប្តាហ៍

បន្ទាប់ពីបានទទួលការត្រាស់ដឹងនូវព្រះសម្មាសម្ពោធិញ្ញាណមក ព្រះពុទ្ធមិនទាន់យាងចេញទៅប្រោសសត្វនៅឡើយ ដោយព្រះអង្គរវល់នៅបំពេញពុទ្ធសកម្មភាពផ្សេងៗ ។ ព្រះអង្គគង់ សោយវិមុត្តិសុខ (ទទួលសេចក្តីសុខមកពីការត្រាស់ដឹង) អស់៧សប្តាហ៍ (៤៩ថ្ងៃ) ក្នុង៧កន្លែងផ្សេងៗគ្នានិងកន្លែងនីមួយៗអស់ចំនួន៧ថ្ងៃ។

សប្តាហ៍ទី១. ចាប់ពីថ្ងៃព្រហស្បតិ៍១រោច ខែពិសាខ ទៅដល់ថ្ងៃព្រះហស្បតិ៍ ៨រោច ខែពិសាខ ទ្រង់គង់នៅលើរតនបល្លង្កក្រោមដើមពោធិព្រឹក្សនោះ។

សប្តាហ៍ទី២. ចាប់ពីថ្ងៃព្រហស្បតិ៍៨រោច ខែពិសាខ ទៅទល់ថ្ងៃព្រហស្បតិ៍១៥រោច ខែពិសាខ ពេលព្រឹកទ្រង់ឆ្លើយមកបា្បដិហារ្យដោះសេចក្តីសង្ស័យរបស់ពួកទេវតា ដើម្បី ទ្រង់ចុះទៅគង់នៅត្រង់ទិសឦសាននៃរតនបល្លង្កនោះ។ ទ្រង់ព្រះចិន្តាថា៖

"តថាគតបានទទួលនូវ សព្វញ្ញុតញ្ញាណ (ការត្រាស់ដឹងកំពូល) នៅលើរតនបល្លង្ក នាគល់ពោធិព្រឹក្សនេះហើយ។" ព្រះអង្គទតព្រះនេត្រទៅកាន់ដើមពោធិព្រឹក្សដោយពុំព្រិចព្រះនេត្រអស់៧ថ្ងៃទៀត។ ទីនោះហៅថា "អនិមិស្សកចេតិយដ្ឋាន"។

សប្តាហ៍ទី៣. ចាប់តាំងពីព្រឹកថ្ងៃព្រហស្បតិ៍១៥កើតខែពិសាខ ទៅទល់នឹងថ្ងៃព្រហស្បតិ៍៧កើត ខែជេស្ឋ ទ្រង់កំណត់យកទីចង្ក្រមលើផ្ទះកែវ ដ៏វែងតាំងពី ទិសបូព៌ ដល់គ្នានឹងទិស បច្ចិម ត្រង់ចន្លោះរតនបល្លង្ក និងអនិមិស្សកចេតិយ(កន្លែងដែលព្រះអង្គគង់)។ ទីនេះហៅថា "រតនចង្ក្រម"។

សប្តាហ៍ទី៤. ចាប់តាំងពីព្រឹកថ្ងៃព្រហស្បតិ៍៧កើតខែជេស្ឋ ទៅទល់នឹងថ្ងៃព្រហស្បតិ៍១៤កើខែជេស្ឋ ទ្រង់គង់នៅក្នុងផ្ទះកែវខាង ទិសពាយ័ព្យ នៃគល់ពោធិព្រឹក្ស។ ព្រះអង្គពិចារណាធម៌ដែលព្រះអង្គបានត្រាស់ដឹងហើយដើម្បីយកទៅសំដែងប្រោសសត្វ សព្វថ្ងៃហៅព្រះត្រៃបិដកគឺ ៖ វិន័យបិដក១ សុត្តន្តបិដក១ និង អភិធម្មបិដក១ ដែលប្រកដដោយនិកាយ៥ អង្គ៩ និង ធម្មក្ខន្ធ៨៤០០០។ ពេលព្រះអង្គបានសំរេចនូវព្រះសព្វញ្ញុតញ្ញាណនៃបិដកទាំងបី ធ្វើអោយព្រះអង្គមានរស្មី៦ពណ៌ ៖ ខៀវ លឿង ក្រហម ស និង សង្សបាទ (ពណ៌ចំរុះដូចជើងហង្ស) ចាំងភ្លឺផ្លេកផ្សាយចេញពីព្រះកាយទៅកាន់សព្វទិសានុទិស។



ទីនេះហៅថា "រតនឃរចេតិយដ្ឋាន"។

សប្តាហ៍ទី៥. ចាប់ពីថ្ងៃព្រហស្បតិ៍១៤កើតខែជេស្ឋ ទៅទល់នឹងថ្ងៃព្រហស្បតិ៍៦រោចខែជេស្ឋ ទ្រង់យាងចាកពីរតនឃរដ្ឋានទៅគង់នៅក្រោមដើម អជបាលនិគ្រោធ (ដើមជ្រៃដែលពួកគង្វាលចៀមឬពពែតែងឈប់ជ្រក)វិញ។ ក្នុងទីនោះទ្រង់ពិចារណានូវព្រះសទ្ធម្ម និងមនុស្សដែលគួរប្រោសបាន៦ពួក។ ព្រះអង្គទ្រង់ភាវនាឃើញព្រាហ្មណ៍ម្នាក់ឈ្មោះ ហុំហុំកជាតិកៈ (ជាអ្នកចូលចិត្តគំរាមគេដោយធ្វើសំឡេងហុំហុំ) បានចូលទៅគាល់និងបង្គំទូលសួរព្រះពុទ្ធថា៖

"បពិត្រព្រះអង្គដ៏ចំរើន! តើបុគ្គលបែបណាដែល អាចចាត់ទុកជាព្រាហ្មណ៍ប្រកបដោយធម៌នោះ?"

ព្រះពុទ្ធទ្រង់ត្រាស់ជាគាថាប្រាប់ថា៖

"ម្នាលហុំហុំកជាតិកៈ! ព្រាហ្មណ៍ណាដែល បានលះបង់ចោលនូវបាបធម៌ហើយ លះបង់ចោលសំឡេងគំរាមថាហុំហុំហើយ លះបង់ចោលនូវ រាគាទិក្កិលេស ហើយ ព្រមទាំងមានចិត្តសង្រួមហើយ ចេះចប់នូវគម្ពីរវេទគឺ មគ្គញ្ញាណ៤ ហើយមានព្រហ្មចរិយក្នុងខ្លួនហើយ និងមិនមានគំនររាគាទិក្កិលេសក្នុងអារម្មណ៍សោះ ក្នុងលោកសន្និវាសនេះ ព្រាហ្មណ៍នោះឯងគឺជាព្រាហ្មណ៍ប្រកបដោយធម៌ហើយ។"

នៅក្នុងទីនោះដដែល ព្រះពុទ្ធទ្រង់បន្តពិចារណានូវព្រះសទ្ធម្មគឺលិទ្ធិនៃអំពើល្អដែលព្រះអង្គបានត្រាស់ដឹង និងរមិលមើលថាតើសត្វលោកណាខ្លះមានចរិតលក្ខណៈដែលព្រះអង្គគប្បីទូន្មាននិងប្រោសបាន។ ព្រះអង្គក៏ទ្រង់ឈ្វេងយល់យ៉ាងច្បាស់ថា៖

"សត្វលោកទាំងឡាយមិនងាយស្តាប់យល់ធ្លុះជ្រៅទៅក្នុងធម៌ ដែលព្រះអង្គបានរកឃើញនោះឡើយ។"

ទើបព្រះអង្គគង់នៅស្ងៀមនិងសោយវិមុត្តិសុខនៅក្រោម ដើមជ្រៃនោះទៅ។

លំដាប់នោះ មារចិត្តឫស្យា ដែលជាអ្នកធ្លាប់ស្វែងរកនូវទោសរបស់ព្រះអង្គតាំងពីដើមមកនោះចូលមក ហើយបង្គំទូលអារាធនាព្រះអង្គថា៖

"នែព្រះពុទ្ធ! បើអ្នកបានសោយនូវវិមុត្តិសុខហើយ ម្តេចឡើយក៏មិនចូលព្រះបរិនិព្វាន

ភ្លាមទៅ នៅខ្វល់ខ្វាយចង់ជួយសង្គ្រោះសត្វលោកលិ្ងតល្ងង់អស់ហ្នឹងបានជាការអ្វី គិតតែពីប្រយោជន៍ផ្ទាល់ខ្លួនឯងទៅបានហើយ។"

ព្រះពុទ្ធទ្រង់ឆ្លើយតបវិញជាបន្ទាន់ថា៖

"ម្នាលមារមានចិត្តបាប! ដរាបណាតថាគត មិនទាន់បានសំដែងធម៌ប្រោសសត្វអោយបានសំរេចមគ្គផលទេ តថាគតពុំទាន់រំលត់ ខន្ធបរិនិព្វានឡើយ។"

កាលបើឮដូច្នោះ មារកើតក្តីទោមនស្សយ៉ាងខ្លាំង រួចគេចខ្លួនចេញទៅអង្គុយគូរដីលេង នៅផ្លូវបំបែកជា៤ដោយប្រការផ្សេងៗទៅ។ ព្រះពុទ្ធទ្រង់សោយវិមុត្តសុខនៅក្នុងទីនេះអស់រយៈពេល៧ថ្ងៃទៀត។

សប្តាហ៍ទី៦. ចាប់ពីថ្ងៃព្រហស្បតិ៍៦រោច ខែជេស្ឋ ទៅទល់នឹងថ្ងៃព្រហស្បតិ៍១៣រោច ខែជេស្ឋ ទ្រង់ក្រោកចាកគល់ជ្រៃយាងឆ្លងកាត់ស្ទឹង និង តាមភ្លឺស្រែឆ្ពោះទៅកាន់ស្រះឈូកមួយដែលព្រះអង្គសព្វព្រះទ័យជាខ្លាំង។ លុះចូលដល់ហើយ ព្រះអង្គរជ្រើសរើសរកអាសនៈដ៏សមគួរ នៅក្រោមដើមរាំង រួចហើយទ្រង់គង់ចំរើនភាវនាចំពោះផ្កាឈូកក៏ល្អទាំងនោះ។ ខណៈដែលព្រះទុព្ធកំពុងទតមើលជ្រៅទៅក្នុងដើមនិងផ្កាឈូកទាំងនោះ ព្រះអង្គទ្រង់ព្រះបរវិតក្កថា៖ ការរីកដុះដាលនៃដើមនិងផ្កាឈូកមានដំណាក់កាលខុសគ្នាទាំងអស់។ ឫសឈូកនៅកប់ជ្រៅទៅក្នុងភក់ល្បប់នៅពេលដើមឈូកខ្លះដុះមិនទាន់ផុតអំពីទឹកផង មានដើមខ្លះទៀតលេចចេញផុតពីផ្ទៃទឹកប៉ុន្តែស្លឹកនៅក្តោបនៅឡើយ។ នៅពេលផ្កាឈូកខ្លះនៅក្រពុំ មានផ្កាខ្លះលេចត្របករីស្គុសស្គាយ។ មានផ្លែឈូកខ្លះរុះលំអងអស់មានផ្លែខ្លះមិនទាន់រុះលំអងនៅឡើយ។ មានផ្កាខ្លះពណ៌ស ខ្លះពណ៌ខៀវខ្ចី និង ផ្កាខ្លះពណ៌ក្រហមស៊ីជម្ពូ។ ព្រះអង្គពិចារណាបន្ថែមទៀតថា "មនុស្សលោកទាំងឡាយក៏មិនខុសគ្នាអំពី ដើម ផ្កា និងផ្លែឈូកទាំងនេះដែរ។ មនុស្សម្នាក់ៗសុទ្ធតែមានអារម្មណ៍ធម្មជាតិផ្ទាល់ខ្លួនរបស់គេ។" និងទ្រង់បានប្រៀបធៀបថា "ទេវទត្តពិតជាមិនដូចអានន្ទ។ ព្រះនាងពិម្ពាយសោធរាពិតជាមិនដូចព្រះមាតាបមិតា។ មនុស្សម្នាក់ៗសុទ្ធតែមានបញ្ញា គុណធម៌ ទេពកោសល្យនិងបុគ្គលិលក្ខណៈប្លែកៗអំពីគ្នា។ មគ្គៈនៃការត្រាស់ដឹង ដែលអាត្មាអញបានរកឃើញត្រូវការបរិយាយតាមមធ្យោបាយផ្សេងច្រើនទៀតដើម្បីអោយស្របតាម



ប្រភេទមនុស្សដែលមានសភាពខុសគ្នានោះ។" ព្រះអង្គទ្រង់សោយវិមុត្តិសុខនៅទីនេះ ៧ថ្ងៃទៀត។

តាមនិទានបានដំណាលថា ស្រះឈូកនោះមាននាមបញ្ញត្តិថា "មុច្ចលិន្ទស្រះ" យកតាមឈ្មោះ ស្តេចនាគ មួយដែលរស់នៅក្នុងស្រះនោះ។ ដោយហេតុថាក្នុងពេល៧ថ្ងៃដែលព្រះពុទ្ធគង់ភាវនានៅនាមាត់ស្រះនោះ មានភ្លៀងបង្អុរចុះមកយ៉ាងខ្លាំង។ ក្សណនោះមានស្តេចនាគឈ្មោះមុច្ចលិន្ទនេះក៏លូនចេញមកអំពីស្រះនោះ រួចហើយក៏និម្មិតកាយដ៏ធំពេនព័ន្ធខ្លួន៧ជុំជារង្វេលទ្រពីក្រោមព្រះពុទ្ធអង្គ លើកអោយផុតអំពីទឹកជំនន់ និងបើកពពារដូចជាបុសប្បុកបាំងគ្របពីលើព្រះសិរសាដើម្បីការពារដំណក់ភ្លៀងនិងកំដៅថ្ងៃ។ លុះដល់ថ្ងៃទី៧ ភ្លៀងរលឹមក៏រាំង ស្រាប់តែមុច្ចលិន្ទនាគរាជនោះនិម្មិតកាយក្លាយភេទជាមាណពកម្លោះម្នាក់ឈរប្រណម្យសំពះចំពោះព្រះភ័ក្ត្រព្រះពុទ្ធទៅវិញ។ កាលបានជ្រាបនូវសេចក្តីនេះហើយ ព្រះពុទ្ធទ្រង់បន្លឺនូវឧទានគាថា យ៉ាងនេះថា "សេចក្តីស្ងាត់ចាកកិលេសរបស់អ្នកត្រេអរដោយមគ្គញាណ មានធម៌ប្រាកដហើយ បានឃើញធម៌(ដោយញាណចក្ខុ) ដែលជាគុណ នាំអោយកើតសេចក្តីសុខហើយ។ សេចក្តីមិនព្យាបាទនិងសេចក្តីសង្រួមមិនបៀតបៀនដល់សត្វទាំងឡាយក៏ជាគុណនាំអោយកើតសេចក្តីសុខក្នុងលោក។ សេចក្តីឃ្លាតចាករាគៈនិងការប្រព្រឹត្តកាមទាំងឡាយគឺជាគុណនាំអោយកើតសេចក្តីសុខនៅក្នុងលោក។ កិរិយាកំចាត់ចង់នូវ អស្មិមានៈ លើអ្វីមួយគឺជាសេចក្តីសុខដ៏ក្រៃលែង។"

សប្តាហ៍ទី៧. ចាប់ពីថ្ងៃព្រហស្បតិ៍១៣រោច ខែជេស្ឋ ទល់នឹងថ្ងៃព្រហស្បតិ៍៥កើត ខែសាធ ទ្រង់យាងចាកអំពីស្រះឈូកនោះ ទៅគង់នៅក្រោមដើមកែស១ដើម អស់៧ថ្ងៃទៀត។ ក្នុងរយៈ៤៩ថ្ងៃនេះ ព្រះអង្គពុំសោយចង្ហាន់ទេ គឺទ្រង់សោយនូវវិមុត្តិសុខតែម្យ៉ាង។ មកដល់ថ្ងៃទី៧នៃសប្តាហ៍ទី៧នេះ ទើបព្រះអង្គបានសោយផ្លែស្រម៉។ បន្ទាប់មក មានពាណិជ្ជពីរនាក់បងប្អូន បងឈ្មោះ តបុស្សៈ និងប្អូនឈ្មោះ ភល្លិកៈ បាននាំពួកឈ្នួលរទេះទំនិញចំនួនប្រាំរយមកពី ឧត្តលជនបទ ទៅលក់នៅឯ ឧត្តរាបថជនបទក្នុងមជ្ឈិមប្រទេស។ ពាណិជ្ជទាំងពីរនាក់បងប្អូនបានឮដំណឹងអំពីមិត្តសំឡាញ់ម្នាក់នៃខ្លួនប្រាប់ថាមានព្រះពុទ្ធមួយព្រះអង្គទើបនឹងត្រាស់ដឹងហើយកំពុងតែគង់ធ្វើសមាធិនៅក្រោមដើមកែសនោះ។

ពាណិជ្ជទាំងពីរនាក់បងប្អូន ក៏នាំគ្នាចូលទៅថ្វាយបង្គំព្រះពុទ្ធ ហើយកើតមានសេចក្ដីជ្រះថ្លាប្រគេននូវចង្ហាន់ជាសាដូវដុំ និងសាដូវផង់ដល់ព្រះអង្គសោយ។ ពាណិជ្ជទាំងពីរបានសុំខ្លួនធ្វើជាឧបាសកដំបូងបង្អស់របស់ព្រះអង្គក្នុងពេលនោះតែម្ដង។ ពាណិជ្ជតបុស្សនិងភល្លិក ក៏បាននាបញ្ញត្តិថា "ទ្វេវាចិកឧបាចាក គឺជាឧបាសកនៃព្រះពុទ្ធសាសនាលើកដំបូងបង្អស់ក្នុងលោក។" រួចមក បឋមឧបាសកទាំងពីរនាក់លើកដៃថ្វាយបង្គំសុំនូវវត្ថុសំរាប់ទុកធ្វើសក្ការបូជា។ ព្រះពុទ្ធទ្រង់បរមាសព្រះសិរិសា(អង្អែលព្រះកេស) ស្រាប់តែព្រះកេសធាតុ៨សរសៃរបូតជាប់នឹងព្រះហស្ត រួចហើយទ្រង់ប្រទានដល់ពាណិជ្ជទាំង២នាក់បងប្អូននោះទៅ។

និទានថា៖ ពាណិជ្ជពីរនាក់បងប្អូន នាំយកព្រះកេសធាតុទាំង៨សរសៃនេះ ទៅកាន់នគរនៃខ្លួនហើយក៏យកទៅបញ្ចុះទុកក្នុងចេតិយមួយឈ្មោះ សិង្គុត្តរចេតិយ តាមបណ្ដាំរបស់ព្រះពុទ្ធ ដើម្បីធ្វើសក្ការបូជា។ ពេលធ្វើបុណ្យបញ្ចុះព្រះកេសធាតុ៨សរសៃនោះ មានវត្តមានព្រះបាទឧបលាបរាជនិងប្រជាពលរដ្ឋដ៏ច្រើនសន្ធឹក ចូលមកបូជានូវគ្រឿងក្រអូបមានផ្កាភ្ញីនិងទៀនធូប ព្រមទាំងវត្ថុមានតម្លៃផ្សេងៗ។

បន្ទាប់មកព្រះពុទ្ធទ្រង់យាងចាកដើមកែសទៅគង់នៅគល់អជបាលនិគ្រោធវិញ។ នៅទីនេះ ព្រះអង្គទ្រង់ព្រះតំរិះក្នុងព្រះហឫទ័យថា៖

"ធម៌ដែលអង្គអញតថាគតបានរកឃើញហើយ មានសភាពជ្រាលជ្រៅ ល្អិតសុខុមពេកណាស់ ពពួកសត្វទាំងឡាយណាដែលមានកិលេស មានតណ្ហាជាគ្រឿងសៅហ្មងនៅក្នុងចិត្តមិនងាយនឹងដឹងបានទេ ដូច្នោះបើតថាគតយកធម៌ដែលមានន័យជ្រៅទូលាយទៅសសំដែងអោយសត្វលោកទាំងនោះស្ដាប់ ក៏ជាការឥតប្រយោជន៍ដែរ។"

អាស្រ័យហេតុនេះហើយ បានជាព្រះអង្គមានព្រះទ័យរួញរាក្នុងការសំដែងធម៌ដើម្បីណែនាំសត្វលោកអោយប្រព្រឹត្តតាម។

សេចក្ដីដំណាលថា៖ ព្រះពុទ្ធមានការរារែកក្នុងការសំដែងធម៌ប្រោសសត្វនេះបានជ្រាបដល់ សហម្បតីព្រហ្ម នៅ ឋានព្រហ្មលោក។ សហម្បតីព្រហ្មក៏ចូលមកកាន់សំណាក់ព្រះអង្គ ដើម្បីអារាធនាសុំអោយព្រះអង្គ យាងចេញទៅសំដែងព្រះធម្មទេសនាប្រោសសត្វ



លោក ដែលកំពុងងោកងុយក្នុងតណ្ហា រងទុក្ខវេទនា និងវង្វេងក្នុងវាលវដ្ដសង្សារ។

កាលបានទទួលសាវនាការរបស់ពួកព្រហ្មរួចហើយព្រះពុទ្ធទ្រង់ព្រះបរិវិតក្កទៀតថា "ឥឡូវនេះអាត្មាអញគួរសំដែងធម៌ដែលអាត្មាអញត្រាស់ដឹងដោយកម្រនោះទៅចុះ! ប៉ុន្តែសត្វលោកទាំងឡាយដែលមានរាគៈ និងទោសៈគ្របសង្កត់ ពិតជាមិនអាចនឹងត្រាស់ដឹងនូវធម៌នេះដោយងាយទេ។ សត្វលោកទាំងឡាយដែលកំពុងត្រេកត្រអាលក្នុងកាមតណ្ហា និងបិទបាំងដោយអវិជ្ជាពិតជាមើលមិនឃើញនូវធម៌ដ៏ល្អិតឆ្មារ និងដ៏ជ្រាលជ្រៅដែលនាំរកព្រះនិព្វានបានឡើយ។ បដិច្ចសមុប្បទធម៌ទាំង១០ប្រការការផ្ដាច់បង់នូវភ្លើងកិលេស និងតណ្ហានិងការរម្ងាប់នូវសង្ខារទាំងពួងក៏សត្វលោកទាំងនោះកម្រនឹងយល់ដឹងបានដែរ។" លុះព្រះអង្គពិចារណាដូច្នេះហើយ ព្រះអង្គក៏មានការខ្វាល់ខ្វាយតិចក្នុងការសំដែងធម៌ប្រោសសត្វ។

សហម្បតីព្រហ្មក៏ទទូចអង្វរព្រះពុទ្ធថា៖

"បពិត្រព្រះអង្គដ៏ចំរើន! សូមព្រះមានព្រះភាគសំដែងធម៌ប្រោសដល់សត្វលោកណាដែលមានរាគាទិក្កិលេសស្រាលស្តើងនោះផង បើសិនជាមិនបានស្ដាប់ធម៌របស់ព្រះអង្គទេសត្វទាំងនោះមុខជានឹងវិនាសសាបសូន្យអស់ហើយ។ សូមទ្រង់បើកទ្វារនៃព្រះនិព្វាននោះសូមទ្រង់សំដែងធម៌របស់ព្រះអង្គនោះចុះ ដើម្បីសត្វទាំងឡាយដែលមានភ្លើងកិលេសតិចនោះបានត្រាស់ដឹងផង!"

ប៉ុន្តែ បន្ទាប់អំពីសហម្បតីព្រហ្មអង្វរសុំអារាធនាអស់វារៈបីដងមក ព្រះពុទ្ធទ្រង់បានជ្រាបច្បាស់នូវសេចក្ដីអារាធនារបស់សហម្បតីព្រហ្មផង ទ្រង់មានសេចក្ដីករុណាចំពោះសត្វលោកផង ទើបទ្រង់រមិលមើល ដោយចក្ខុទិព្វដល់ឧបនិស្ស័យសត្វលោកទាំងឡាយ។ ព្រះពុទ្ធបានយល់យ៉ាងច្បាស់នូវវាលនៃលោក ដែលជាទីនៅនៃមនុស្សសត្វ ហើយទ្រង់ចាត់ទុកវដ្ដសង្សារជាស្រះមួយយ៉ាងធំ ដែលពោរពេញទៅដោយផ្កាឈូក ព្រលិត រំចង់។ ព្រះអង្គចាត់ទុកពពួកសត្វអាស្រ័យនៅក្នុងស្រះវដ្ដសង្សារនេះជា៤ពួកគឺ៖

១- ឧគ្ឃដិតញ្ញូ ៖ ជនដែលមានប្រាជ្ញាបារមីចាស់ក្លា កាលណាបានស្ដាប់យករសនៃព្រះធម៌ហើយក៏នឹងបានសំរេចមគ្គផលភ្លាម។ ប្រៀបដូចផ្កាឈូកដែលដុះផុតពីទឹកមានទំហំ

ធំដោយបានត្រូវកំដៅព្រះអាទិត្យច្រើនថ្ងៃ។ កាលណាត្រូវពន្លឺថ្ងៃគ្រប់គ្រាន់ផ្ការឈូកក៏រីកស្គុះស្គាយភ្លាម។

២- វិបច្ចិតញ្ញូ ៖ ជនដែលមានប្រាជ្ញាបារមីពុំទាន់ក្លាខ្លាំងពេកទេ កាលបើបានស្តាប់ធម៌ហើយ ទាល់តែព្រះធម៌នោះមានន័យពិស្តារវែងឆ្ងាយ ទើបអាចយល់បាន។ ប្រៀបដូចជាផ្កាឈូក ដែលដុះផុតពីទឹកហើយតែពុំទាន់ដល់ពេលនឹងរីក ក្នុងថ្ងៃនេះបាន លុះត្រាតែត្រូវពន្លឺព្រះអាទិត្យបីបួនថ្ងៃសិនទើបរីកកើត។

៣- នេយ្យបរិស័ទ ៖ ជនដែលមានប្រាជ្ញាបារមីពុំទានរឹងប៉ឹងនៅឡើយ លុះត្រាតែបានស្តាប់ធម៌ញឹកញាប់ទើបអាចយល់បាន។ ប្រៀបដូចផ្កាឈូកនៅប៉ប្រះទឹកលុះត្រាតែដុះផុតពីទឹកនិងត្រូវពន្លឺព្រះអាទិត្យច្រើនថ្ងៃ ទើបអាចរីកបាន។

៤- បទបរមបរិស័ទ ៖ ជនដែលគ្មានប្រាជ្ញាបារមីសោះ គឺជនដែលមិនព្រមស្តាប់មិនព្រមប្រតិបត្តិតាមការទូន្មានរបស់ព្រះអង្គ និងទោះជាព្រះអង្គខំទូន្មានប្រៀនប្រដៅយ៉ាងណា ក៏កម្រនឹងយល់ធម៌នោះបាន។ ប្រៀបដូចជាឈូកដែលទើបនឹងប៉ិចពកក្នុងទឹក វាតែងតែបានជាចំណីត្រីនិងអណ្តើកជានិច្ច។

ព្រះពុទ្ធក៏ពិចារណាឃើញនូវ សត្វខ្លះមានធូលី(រាគាទិក្កិលេស) តិចក្នុងភ្នែកនិងខ្លះមានធូលីច្រើន សត្វខ្លះមានឥន្ទ្រីយ៍រឹង និងខ្លះមានឥន្ទ្រីយ៍ទន់ សត្វខ្លះមានអាការៈល្អ និងខ្លះមានអាការៈអាក្រក់ សត្វខ្លះអាចត្រាស់ដឹងដោយងាយនិងខ្លះអាចត្រាស់ដឹងដោយកម្រ និងសត្វខ្លះមើលឃើញបរលោកនិងទោសគួរអោយខ្លាច។ លុះព្រះអង្គបានសញ្ជឹងគិតឃើញថា សមហេតុផលហើយ ទើបទ្រង់សំដែងជាគាថានឹងសហម្បតីព្រហ្មថា៖

"ម្នាលសហម្បតីព្រហ្ម ទ្វារនៃព្រះនិព្វានទាំងឡាយនោះបើកហើយ សត្វទាំងឡាយណាមានសោតបសាទ ចូរសត្វទាំងឡាយនោះបញ្ចេញនូវសទ្ធាចុះ!"

កាលបានឮពុទ្ធដីកាថា ព្រះពុទ្ធព្រមទទួលសំដែងនូវធម្មទេសនាប្រោសសត្វលោក ហើយសហម្បតីព្រហ្មនិងបរិវារមានសេចក្តីត្រេកអររកអ្វីប្រៀបពុំបាន រួចហើយក៏ផ្គងអញ្ជលីក្រាបថ្វាយបង្គំលាព្រះពុទ្ធ ទៅកាន់ឋានព្រហ្មវិញទៅ។

បន្ទាប់ពីបានប្រទាននូវ បដិញ្ញា ដល់មហាព្រហ្មរួចមកព្រះពុទ្ធទ្រង់ព្រះចិន្តាថា៖



"ជាការចាំបាច់អាត្មាអញត្រូវតែត្រឡប់ទៅកាន់សង្គមមនុស្សវិញ ដើម្បីបង្វិលកង់ធម្មចក្រ និងសាបព្រោះនូវកងធម្មទាំងឡាយសំរាប់ត្រាស់ដឹងជាសេចក្តីពិត។ ឥឡូវនេះតើអ្នកណាដែលអាត្មាអញគួរនឹងសំដែងធម៌អោយស្តាប់មុនគេហ្ន៎? អាឡារតាបសនិងឧទ្ទកតាបស ជាបណ្ឌិតមានបញ្ញាឈ្លាសវៃ និងមានរាគាទិក្កិលេសតិចដែលគួរអាត្មាអញសំដែងធម៌ប្រោសមុនគេ និងបានត្រាស់ដឹងរហ័ស។ បន្ទាប់មកអាត្មាអញគួរតែសំដែងធម៌ប្រោសដល់ បញ្ចវគ្គីយភិក្ខុទាំង៥ ដែលជាមិត្តធ្លាប់ធ្វើតបកម្មជាមួយគ្នា។ បន្ទាប់ពីនោះទៀត អាត្មាអញគួរតែសំដែងធម៌ប្រោសព្រះបាទពិម្ពិសារាជនៃនគរមគធៈដែលអាត្មាអញធ្លាប់បានសន្យា។"

ព្រះពុទ្ធសំរេចព្រះទ័យយាងចាកពីឱរុវេលនិគម ដែលជាទីព្រៃមានម្លប់ត្រជាក់ដុះតាមបណ្តោយដងស្ទឹងនេរញ្ជរា និងជាទីមានដើមពោធិព្រឹក្ស ផ្តល់នូវសេចក្តីសុខដល់ព្រះអង្គនិងក្មេងកូនអ្នកស្រុកទៀតផង។

ព្រឹកស្អែកឡើង ព្រះពុទ្ធទ្រង់គ្រងដណ្តប់ស្រេចដោយស្បង់ចីវរថ្មីពណ៌អិដ្ឋដ៏ល្អវិចិត្រដែលនាង នន្ទបាល និងនាងសុជាតាបានដេរថ្វាយព្រះអង្គ។ ព្រះអង្គនិមន្តទៅកាន់សំណាក់សោត្ថិយកុមារនិងបងប្អូនជាមុន រួចទើបព្រះអង្គនាំកុមារទាំងឡាយនោះទៅកាន់សំណាក់នាងសុជាតាជាខាងក្រោយ។ កាលបានដឹងនូវរឿងនេះភ្លាម នាងសុជាតាស្រែកទ្រហោយំយ៉ាងខ្លាំង។ ព្រះពុទ្ធមានពុទ្ធដីកាទៅកាន់កុមារទាំងអស់ថា៖

"ម្នាលកុមារទាំងឡាយ! តថាគតសូមលាអ្នកមួយគ្រាសិនហើយ តថាគតមានកាតព្វកិច្ចត្រូវបំពេញជាបន្តទៅទៀត។ ប៉ុន្តែ តថាគតនឹងមិនបោះបង់ចោលអ្នករាល់គ្នាទេ។ តថាគតសូមសន្យាថានឹងវិលមកជួបអ្នកទាំងអស់វិញ នៅពេលណាតថាគតមានឱកាស។ អ្នករាប់គ្នាបានជួយតថាគតច្រើនពេកណាស់ តថាគតសូមសំដែងនូវការដឹងគុណដល់អ្នកទាំងឡាយដ៏ជ្រាលជ្រៅបំផុត។"

កុមារកុមារីទាំងនោះនាំគ្នាជូនដំណើរព្រះពុទ្ធរហូតចុងភូមិមុនត្រឡប់មកវិញ។

នៅពេលដែលព្រះពុទ្ធបែរព្រះភ័ក្ត្រលាកុមារទាំងនោះ ស្រាប់តែព្រះអង្គទតឃើញអាជីវកៈ (អ្នកបួសក្រៅសាសនាព្រះពុទ្ធ) មួយអង្គនិមន្តចូលមក។

អាជីវកៈនោះលើកព្រះហស្តសំពះព្រះពុទ្ធហើយបង្គំទូលសួរថា៖

"ម្នាលអាវុសោ! ឥន្ទ្រីយ៍របស់អ្នកមើលទៅហាក់មានសម្បុរ(ឆវីវណ្ណ) ស្រស់ផូរផង់ និងមានភាពនឹងនបរិសុទ្ធម្ល៉េះ! តើអ្នកឈ្មោះអ្វីដែរ? តើអ្នកបួសនឹងអ្នកណា? តើអ្នកណាទៅត្រូវជាគ្រូអាចារ្យរបស់អ្នក? តើអ្នកនឹងធ្វើដំណើរទៅកាន់ទីណាដែរ?"

ព្រះពុទ្ធទ្រង់ឆ្លើយតបថា៖

"ម្នាលអាវុសោ! តថាគតនាមសិទ្ធត្ថគោតម។ តថាគតធ្លាប់បានសិក្សាក្នុងសំណាក់តាបសជាច្រើន ប៉ុន្តែនៅក្នុងពេលនេះគ្មានអ្នកណាម្នាក់ ជាគ្រូអាចារ្យរបស់តថាគតឡើយ។ តថាគតជាអ្នករកឃើញការត្រាស់ដឹងដោយខ្លួនឯង គ្មានប្រឡាក់ដោយកិលេសក្នុងភូមិកធម៌ទាំងអស់ទៀតទេ។ តថាគតនឹងទៅនាក់ទីក្រុងនៃពួកកាសីដើម្បីនឹងសំដែងធម្មចក្ក។ តថាគតនឹងទូងនូវស្គរ គឺ អមតនិព្វាន ចំពោះសព្វសត្វលោកដែលកំពុងគ្របសង្កត់ងងឹតសូន្យឈឹងដោយអវិជ្ជា។ ចុះព្រះអង្គវិញតើព្រះអង្គព្រះនាមអ្វីដែរ និងតើព្រះអង្គនិមន្តទៅណាមកណាដែរ?"

"ខ្ញុំព្រះអង្គនាម ឧបកៈ ទើបនិមន្តចេញមកអំពីអាស្រម ឧទ្ទកតាបសរាមបុត្រដែលត្រូវជាគ្រូរបស់ខ្ញុំព្រះអង្គ។ ម្នាលអាវុសោ! ម្ដេចឡើយក៏ អ្នកហ៊ានប្ដេជ្ញាខ្លួនឯងថាជា "អនន្តជិន" យ៉ាងនេះ?"

ព្រះពុទ្ធទ្រង់ទតចំភ្នែកអាជិវកៈ ហើយត្រាស់ថា៖

"ម្នាលឧបកៈ! ជនទាំងឡាយណាដែលបានដល់ នូវធម៌សំរាប់ធ្វើ អាសវៈ អោយអស់ទៅជនទាំងឡាយនោះឈ្មោះថា "ជិន" ជាអ្នកឈ្នះកិលេស ប្រាកដដូចជាតថាគតអីញ៉ឹងដែរ។ តថាគតបានឈ្នះបាបធម៌ទាំងឡាយរួច ហើយព្រោះហេតុនោះទើបអាត្មាហ៊ានពោលនូវឈ្មោះថា "ជិន" នេះ។ ម្នាលឧបកៈ តើលោកគ្រូឧទ្ទករាមបុត្តមានព្រះសុខភាពល្អដែរឬទេ?"

អាជីវកឧបកៈងក់ក្បាលយល់ព្រមចំពោះព្រះពុទ្ធដីកា មុននឹងឆ្លើយបន្តទៀតថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ឧទ្ទកតាបសរាមបុត្រ បានទទួលមរណភាពក្នុងវេលាព្រលប់នេះបាត់ទៅហើយ។"



ព្រះពុទ្ធទ្រង់មានការសោកស្ដាយយ៉ាងខ្លាំងដែលមិនមានសំណាងបានជួបផ្ទាល់នឹងឧទ្ទកតាបស។ បន្ទាប់មក ក៏ព្រះអង្គត្រាស់សួរឧបកៈបន្តទៀតថា៖

"ម្នាលឧបកៈ! តើព្រះអង្គធ្លាប់បានសិក្សាជាមួយអាឡារតាបសដែរឬទេ?"

អាជីវកឧបកៈបានឆ្លើយយ៉ាងម៉ឺងម៉ាត់ថា៖

"ខ្ញុំព្រះអង្គ ក៏ជាសិស្សរបស់លោកគ្រូអាឡារដែរ ហើយព្រះអង្គក៏បានទទួលមរណភាព តាំងពី៧ថ្ងៃមុនមកម្ល៉េះ!"

ព្រះពុទ្ធទ្រង់ពិចារណាថា តាបសព្រាហ្មណ៍ទាំងពីររូបនេះ ជាមនុស្សអភ័ពធំណាស់ដែលមិនបានស្ដាប់ធម៌របស់ព្រះពុទ្ធ។ រួចហើយមើលព្រះអង្គសួរបន្តថា៖

"ម្នាលឧបកៈសំឡាញ់! តើព្រះអង្គដែលបានស្ដាប់ព្រះសង្ឃមួយអង្គព្រះនាមកោណ្ឌញ្ញ ដែរឬទេ?"

"ខ្ញុំព្រះអង្គឮថាកោណ្ឌញ្ញភិក្ខុ និងមិត្តរបស់ព្រះអង្គ៤រូបទៀត កំពុងតែគង់នៅក្នុងព្រៃឥសិបតនមិគទាយវ័នទៀបក្រុងពារាណសីឯណោះ។ បើព្រះអង្គមិនយល់ទាស់ទេ ខ្ញុំព្រះអង្គសូមថ្វាយបង្គំលាទៅមុខទៀតសិនហើយ។"

ព្រះពុទ្ធទ្រង់លើកព្រះហស្តសំពះតប រួចហើយព្រះអង្គបែរព្រះភ័ក្ត្រទៅរកកុមារទាំងឡាយនិងត្រាស់ថា៖

"ម្នាលកុមារាកុមារីទាំងឡាយ! តថាគតនឹងចូលទៅកាន់ក្រុងពារាណសីដើម្បីស្វែងរកមិត្តភិក្ខុ៥រូបទៀត។ ចូរអ្នកនាំគ្នាត្រឡប់ទៅផ្ទះវិញចុះណ៎ា!

ព្រះពុទ្ធទ្រង់លើកព្រះហស្តលាកុមារទាំងឡាយនោះរួចហើយក៏និមន្តចេញទៅ។ កុមារទាំងឡាយនោះ លើកដៃសំពះតបព្រះអង្គវិញព្រមៗគ្នា ហើយក៏នាំគ្នាតាមមើលព្រះពុទ្ធរហូតទល់ផុតកន្ទុយភ្នែក។ កុមារទាំងឡាយមានទឹកមុខស្រងូតស្រងាត់ និងសំដែងនូវអាការៈហាក់ដូចជាអស់សង្ឃឹម។ នាងសុជាតាយំហ៊ូឡើងសោត្ថិយកុមារទប់ទឹកភ្នែកមិនបានក៏យំហ៊ូដែរ។ កុមារទាំងអស់ក៏យំតៗគ្នា។ នាងសុជាតានិងសោត្ថិយកុមារនាំមិត្តសំឡាញ់នៃខ្លួនដើរតាមមាត់ស្ទឹងត្រឡប់ទៅផ្ទះវិញដោយឫកពារស្លូតបូត។

# ជំពូកទី១២
# ព្រះពុទ្ធប្រោសបញ្ចវគ្គីយភិក្ខុ

ពីរខែបន្ទាប់អំពីថ្ងៃព្រះសមណគោតមបានត្រាស់ដឹងមក គឺនៅថ្ងៃ១៥កើត ខែអាសាធ ឆ្នាំរកានោះឯង ព្រះពុទ្ធទ្រង់សំដែងនូវ ធម្មចក្កប្បវត្តនសូត្រ ដើម្បីប្រោសបញ្ចវគ្គីយភិក្ខុ៥រូប នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី។ ពេលជួបនឹងព្រះពុទ្ធដំបូង ព្រហ្មណ៍ទាំង៥រូបរកកលគេចចេញអំពីព្រះអង្គ។ ប៉ុន្តែបន្ទាប់ពីបានស្តាប់ព្រះធម្មទេសនារបស់ព្រះពុទ្ធរួចមក បញ្ចវគ្គីយទាំង៥រូប ក៏បែរជាមានជំនឿជឿជាក់លើព្រះអង្គទៅវិញ ព្រមទាំងសុំបួសជាភិក្ខុក្នុងពេលនោះតែម្តង។

អស្សជិព្រាហ្មណ៍ដែលកំពុងអង្គុយភាវនាតបធម៌នៅក្នុង ឧទ្យានម្រិគទវៈ នាព្រៃសិតបនមិគទាយវ័ននោះ បានក្រឡេកឃើញព្រះសង្ឃមួយអង្គលឹមៗអំពីចម្ងាយកំពុងនិមន្តចូលមកតាមក្លោងទ្វារឧទ្យាន។ ពេលព្រះសង្ឃនោះនិមន្តចូលមកជិតដល់ទើបអស្សជិដឹងថា គ្មានអ្នកណាក្រៅអំពីព្រះសិទ្ធត្ថគោតមឡើយ។ អស្សជិព្រហ្មណ៍ក៏ស្ទុះក្រោកម្ទីម្នាទៅប្រាប់ដល់ភិក្ខុព្រាហ្មណ៍ជាសំឡាញ់៤រូបទៀតអោយបានដឹងផង។

ភទ្ទិយៈបានពោលប្រាប់សំឡាញ់នៃខ្លួនថា៖

"ម្នាលអាវុសោទាំងឡាយ! សិទ្ធត្ថគោតមនេះ ជាអ្នកប្រតិបត្តិ ដើម្បីល្មោភបោះបង់មគ្គៈចោលទាំងពាក់កណ្តាលផ្លូវ។ ជាអ្នកបរិភោគនូវបាយនិង ទឹកដោះគោព្រមទាំងប្រលែងលេងជាមួយក្មេងៗកូនអ្នកស្រុកទៀតផង។ សិទ្ធត្ថនេះប្រមាទមើលងាយដល់ពួកយើងខ្លាំងណាស់ និងធ្វើអោយពួកយើងអាប់ឱនកិត្តិយសទៀតផង។ ឥឡូវនេះព្រះអង្គនិមន្តមកហើយ អាត្មាគិតថាពួកយើងមិនគួរថ្វាយបង្គំ មិនគួរនាំគ្នាក្រោកទទួលនិងមិនគួរទទួលយក បាត្រអំពីព្រះអង្គឡើយ។ ប៉ុន្តែ យើងត្រូវតែក្រាល អាសនៈ(កន្ទេល)បំរុងទុក បើព្រះអង្គចង់អង្គុយក៏អង្គុយទៅចុះ។"

បញ្ចវគ្គីយភិក្ខុប្តេជ្ញានឹងគ្នាថា យើងមិនត្រូវស្វាគមន៍ព្រះសិទ្ធត្ថជាដាច់ខាត។ ប៉ុន្តែអ្វីៗដែលបានកើតឡើងក្នុងពេលព្រះពុទ្ធចូលមកដល់នោះ វាផ្ទុយស្រឡះតែម្តង។

ពេលព្រះពុទ្ធយាងចូលដល់ក្លោងទ្វារឧទ្យាន បញ្ចវគ្គីយទាំង៥រូប ចាប់អារម្មណ៍



យ៉ាងខ្លាំងនូវពន្លឺរស្មីដែលចាំងចេញអំពីព្រះកាយរបស់ព្រះអង្គ។ បញ្ចវគ្គីយទាំង៥រូបភ្លេចពាក្យបដិញ្ញានឹងគ្នាងអស់រលីង បែរជានាំគ្នាត្រេកអរ ស្ទុះក្រោកឈរហើយរត់ទៅទទួលព្រះពុទ្ធដោយមិនដឹងខ្លួន។

ព្រះពុទ្ធហាក់ដូចជាហ៊ុំព័ទ្ធជុំវិញដោយអាការៈនៃពន្លឺ។ មួយជំហានៗដែលព្រះអង្គឈានបញ្ជាក់នូវកម្លាំងទឹកចិត្តដែលកម្ររកបាន។ ការសម្លឹងយ៉ាងយកចិត្តទុកដាក់របស់ព្រះអង្គអាចធ្វើអោយអន្តរាយដល់ចេតនារបស់បញ្ចវគ្គីយទាំង៥រូប ដែលថាចង់ព្រងើយកន្តើយនិងមើលងាយព្រះអង្គ។ កោណ្ឌញ្ញព្រាហ្មណ៍ស្ទុះទៅជិតព្រះពុទ្ធ រួចក៏ទទួលយកបាត្រអំពីព្រះអង្គ។ មហានាមស្ទុះទៅដងទឹកយកមកប្រគេនព្រះអង្គលាងព្រះហស្តនិងព្រះបាទ។ ភទ្ទិយៈទាញយកកន្ទេលមកក្រាលថ្វាយ។ វប្បៈរកបានផ្ចិតស្លឹកត្នោតមួយមកបកថ្វាយព្រះអង្គ។ អស្សជិឈរនៅជ្រុងម្ខាងមីងមាំងមិនដឹងជាធ្វើអ្វីកើត។ បន្ទាប់អំពីព្រះពុទ្ធលាងជំរះព្រហស្តនិងព្រះបាទរួចមក ទើបអស្សជិដឹងថាខ្លួនត្រូវចាក់ទឹកក្តៅឧណ្ហៗមួយផ្តិលទៀតថ្វាយព្រះអង្គ។ ពេលនោះ បញ្ចវគ្គីយនាំគ្នាហៅព្រះពុទ្ធដោយចំព្រះនាមថា "សិទ្ធត្ថ" ផង និងពាក្យថា "អាវុសោ" ផង។

ភិក្ខុទាំង៥រូបអង្គុយព័ទ្ធជុំវិញព្រះពុទ្ធ លើកហត្ថាប្រណម្យហើយទតឆ្ពោះត្រង់ចំព្រះភ័ក្ត្រព្រះសាស្តាដែលព្រះអង្គកំពុងតែទតមើលដោយសុភាព មកកាន់ភិក្ខុទាំង៥រូបនោះដែរ។ ព្រះពុទ្ធទ្រង់ព្រះតម្រាស់ថា៖

"ម្នាលអាវុសោទាំងឡាយ! តថាគតបានឆ្ងាយចាកកិលេស រួចអស់ហើយតថាគតបានរកឃើញនូវព្រះសម្មាសម្ពោធិញ្ញាណដ៏ឧត្តម ដោយខ្លួនតថាគតផ្ទាល់។ ចូរអ្នកទាំងឡាយតម្កល់នូវសោតប្បសាទ រង់ចាំស្តាប់នូវអមតធម៌នោះចុះ តថាគតនឹងសំដែងនូវធម៌នោះដល់កុលបុត្រទាំងឡាយ ដែលចាកចោលផ្ទះ ហើយមកបួសដើម្បីជាប្រយោជន៍ដល់អនុត្តរធម៌។ បើអ្នកទាំងឡាយណា បានប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់តថាគតហើយ អ្នកទាំងនោះពុំយូរឡើយ ក៏នឹងបានយល់ច្បាស់ដោយបញ្ញាខ្លួនឯងនូវអនុត្តរធម៌ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ រួចនឹងបានសំរេចសំរាននៅដោយឥរិយាបថទាំង៤គឺ៖ ដេក ដើរ ឈរ និងអង្គុយ។"

អស្សជិភិក្ខុហាក់ជឿពាក់កណ្តាលពុំជឿពាក់កណ្តាលនូវព្រះពុទ្ធដីកានេះ។ ភិក្ខុ៤អង្គទៀតប្រហែលជាមានការចាប់អារម្មណ៍ដូចជាអស្សជិភិក្ខុដែរ។ ដោយគ្មានភិក្ខុអង្គណាបញ្ចេញយោបល់អស់មួយស្របក់មកទើបកោណ្ឌញ្ញពោលឡើងដោយរបូតមាត់ថា៖

"ម្នាលអាវុសោគោតម! ព្រះអង្គមិនទាំងទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ដែលជាធម៌វិសេសដោយញាណនិងទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេសដោយការប្រព្រឹត្តផង ដោយការប្រតិបត្តិផង ដោយអំពើដែលអ្នកដទៃធ្វើតាមបានដោយកម្រផង និងឥឡូវនេះ ក៏ព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើនផង និងឃ្លាតចាកព្យាយាមផង។ តើអោយពួកយើងជឿព្រះអង្គថាជាអ្នកបានរកឃើញផ្លូវត្រាស់ដឹងនោះដូចម្តេចកើត?"

ព្រះពុទ្ធតឆ្ពោះទៅកាន់ភិក្ខុកោណ្ឌញ្ញហើយទ្រង់ត្រាស់សួរថា៖

"មើល៍កោណ្ឌញ្ញ! អ្នកធ្លាប់ស្គាល់តថាគតយូរណាស់មកហើយ តើរាល់ពេលទាំងអស់នោះតថាគតបាន ភូតភរអ្នកដែរឬទេ?"

កោណ្ឌញ្ញឆ្លើយថា៖ "ពិតជាមិនដែលមានទេព្រះអង្គ! ខ្ញុំមិនដែលឮព្រះអង្គពោលពាក្យកុហកសោះឡើយ!"

ព្រះពុទ្ធទ្រង់ត្រាស់បន្តថា៖

"បើដូច្នោះមែន សូមសំឡាញ់ទាំងឡាយ ផ្ទៀងសោតាស្តាប់ តថាគតអោយបានច្បាស់នូវអមតធម៌ដែលតថាគតបានរកឃើញនោះចុះ! ម្នាលអ្នកទាំងឡាយ! អ្នកពិតជាមនុស្សមានសំណាងធំណាស់ ដោយបានស្តាប់ឮនូវអមតធម៌ ដែលជាផ្លូវដ៏ប្រសើរនេះមុនគេបង្អស់។ ធម៌នេះមិនមែនជាលទ្ធផលនៃការសញ្ជឹងគិតទេ តែជាផលដែលបានមកពីការពិសោធរបស់តថាគតផ្ទាល់តែម្តង។"

កោណ្ឌញ្ញភិក្ខុលើកដៃប្រណម្យ ហើយពោលជំនួសភិក្ខុជាមិត្តសំឡាញ់នៃខ្លួនថា៖

"បពិត្រសំឡាញ់គោតម! សូមព្រះអង្គបង្ហាញពួកយើងអោយបានដឹង អំពីមេត្តាធម៌និងផ្លូវដ៏ប្រសើរ (អរិយមគ្គៈ) របស់ព្រះអង្គនោះផងមើល៍។"

ព្រះពុទ្ធចាប់ផ្តើមសំដែងនូវអន្តធម៌ (ធម៌ថោកទាប)ពីរប្រការ ប្រាប់បញ្ចវគ្គីយថា៖

"ម្នាលអាវុសោទាំងឡាយ! មានធម៌អមសង្ខាងពីរប្រការដែលមនុស្សនៅលើមគ្គៈ



ឬបព្វជិតត្រូវចៀសវាងនិងមិនគួរសេពគប់។ ធម៌អមសង្ខាងទាំងពីរប្រការនោះគឺ៖

១- កាមសុខល្លិកានុយោគ ៖ ការជំរុញខ្លួនអោយធ្លាក់ក្នុងអន្លង់កាមកិលេសដែលជារបស់បុថុជ្ជន។

២- អត្តកិលមថានុយោគ ៖ ការប្រឹងធ្វើតបកម្មដែលបង្អត់ធ្វើបាបខ្លួនឯងអោយលំបាកវេទនានៅពេលដែលខ្លួនកំពុងត្រូវការចៀសមិនរួចនៅឡើយ។

អន្តធម៌ទាំងពីរប្រការនេះ មានលក្ខណៈថោកទាប ជាធម៌អ្នកស្រុក មិនមែនជាធម៌របស់អរិយបុគ្គលឡើយ។ អន្តធម៌នេះ តថាគតធ្លាប់បានសេពគប់ប្រព្រឹត្តពីដើមរួចមកហើយៗបានយល់យ៉ាងច្បាស់ ទើបតថាគតលះបង់ចោល នៅពេលធ្វើទុក្ករកិរិយានៅទៅ។ ផ្លូវខុសទាំងពីរយ៉ាងនេះ មិនអាចនាំបុគ្គលអោយសំរេចនូវពន្លឺត្រាស់ដឹងបានទេ។ ផ្លូវដ៏ប្រសើរដែលតថាគតបានរកឃើញនោះគឺ ផ្លូវកណ្តាល ឬ មជ្ឈិមាបដិបទា ដោយប្រានចោលនូវផ្លូវអមសង្ខាងទាំង២យ៉ាងនេះ និងជាផ្លូវដ៏ត្រង់ដែលអាចនាំអោយអ្នកប្រតិបត្តិកើតមានចក្ខុបញ្ញា សំរេចការត្រាស់ដឹងនូវអរិយសច្ចធម៌ ដើម្បីព្រះនិព្វាន និងដើម្បីក្សេមចាកទុក្ខ។ ផ្លូវដ៏ប្រសើរនោះប្រកបដោយអង្គ៨ហៅថា "អដ្ឋង្គិមគ្គ" គឺជាផ្លូវដែលតថាគតបានប្រតិបត្តិខ្លួនឯង រួចមកហើយៗបានធ្វើអោយតថាគតសំរេចនូវពន្លឺត្រាស់ដឹង។ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ៨នោះគឺ៖

១. សម្មាទិដ្ឋិ ការឃើញត្រូវ គឺឃើញអរិយសច្ចធម៌។

២. សម្មាសង្កប្បៈ ការត្រិះរិះត្រូវ គឺត្រិះរិះមិនបៀតបៀន មិនចង់បានទ្រព្យ សម្បត្តិអ្នកដទៃ និងត្រិះរិះចេញចាកកាម។

៣. សម្មាវាចា ការពោលពាក្យត្រូវគឺនិយាយតែពាក្យសំដីត្រឹមត្រូវ វៀរចាក វចីទុច្ចរិត៤យ៉ាងគឺ៖ វៀរចាក មុសាវាទ(ការពោលពាក្យមិនពិត)១ វៀរចាក បិសុនាវាទ(ការពោលពាក្យញុះញុងបំបែកបំបាក)១ វៀរចាក ផរុសវាទ(ការជេរប្រទេចផ្តាសារនិងដៀមដាម)១ និងវៀរចាក សម្ផប្បលាវាទ(ការនិយាយលេង)១។

៤. សម្មាកម្មមន្ត ការងារត្រូវគឺការប្រកបការងារសុចរិត យុត្តិធម៌ វៀរចាក កាយទុច្ចរិត៣ យ៉ាងគឺ៖ បាណា(វៀរចាកការប្រព្រឹត្តកាមខុសច្បាប់ដោយចាប់បង្ខំឬរំលោភលើស្ត្រីភេទ)១។

៥. សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ គឺរស់នៅក្នុងមុខរបរដែលស្របច្បាប់និងដោយគន្លងធម៌។ វៀរចាកនូវ ជំនួញខុស៥ប្រការគឺ ៖ ជួញគ្រឿង សាស្ត្រាវុធ១ ជួញមនុស្ស១ ជួញសាច់១ ជួញគ្រឿងស្រវឹង១ និងជួញថ្នាំពិស១។

៦. សម្មាវាយាម ការព្យាយាមត្រូវគឺព្យាយាមលះបាបដែលកើតរួចហើយខាយាំងមិនអោយកើតធ្វើអោយកើតឡើង។

៧. សម្មាសតិ ការនឹករលឹកត្រូវគឺការដំកល់ចិត្តត្រូវក្នុង សតិបដ្ឋាន៤ គឺ៖ ដំកល់ក្នុងកាយ វេទនា ចិត្ត និងធម្មៈ ថាគ្រាន់តែជាកាយ វេទនា ចិត្ត និងធម្មៈ តែប៉ុណ្ណោះ។ ពុំមែនជាសត្វឬបុគ្គល ដែលមានសភាពសោះសូន្យទទេៗនោះឡើយ។

៨. សម្មាសមាធិ ការដំកល់ចិត្តនឹងត្រូវគឺជាភាពរបស់ចិត្តនិង ចេតសិកជាកុសលដែលកំកល់ស្មើល្អក្នុងអារម្មណ៍តែមួយ គឺស្ងប់នូវនីវរណធម៌ទាំង៥។

"ម្នាលអាវុសោទាំងឡាយ! ផ្លូវកណ្តាល(មជ្ឈិមាបដិបទា)តថាគតបានត្រាស់ដឹងរួចហើយ។ ចូរអ្នកទាំងឡាយចងចាំទុកក្នុងចិត្តអោយច្បាស់ថាមានតែផ្លូវដ៏ប្រសើរទាំង៨យ៉ាងឬអដ្ឋង្គិតមគ្គៈនេះទេ។ ដែលអាចជួយដល់សត្វលោកវៀរចាកផុតពីសេចក្តីទុក្ខក្នុងចំណង់លោកិយ និងនាំទៅដល់ពន្លឺត្រាស់ដឹងជាទីបំផុតបាន។

ផ្លូវដ៏ប្រសើរទាំង៨យ៉ាងខាងលើនេះបង្រួញមកបានត្រឹមតែ៣ប្រការធំៗគឺ៖
សីល សមាធិ បញ្ញា។ ការឃើញត្រូវនិងត្រិះរិះត្រូវ(សម្មាទិដ្ឋិនិងសម្មាសង្កប្បៈ)បានដល់បញ្ញា។ ការពោលពាក្យត្រូវ ការធ្វើការងារត្រូវនិងការចិញ្ចឹមជីវិតត្រឹមត្រូវ(សម្មាវាចា សម្មាកម្មមន្ត និងសម្មាអាជីវិតៈ) បានដល់ សីល។ ការព្យាយាមត្រូវ ការនឹករលឹកត្រូវនិងដំកល់ចិត្តត្រូវ(សម្មាវាយាម សម្មាសតិនិងសម្មាសមាធិ) បានដល់ សមាធិ។

"ម្នាលអាវុសោទាំងឡាយ! តថាគតក៏បានពិចារណារកឃើញនូវសេចក្តីទុក្ខដែលកើតមានដល់សត្វលោក។ សត្វលោកមានសេចក្តីទុក្ខធំៗចៀសពុំរួច៤យ៉ាងគឺ៖

១. ទុក្ខអរិយសច្ចៈ គឺទុក្ខជាសេចក្តីពិត ឬវត្តមាននៃទុក្ខដែលកើតមានដល់មនុស្សនិងសព្វសត្វលោកពុំអាចចៀសផុតគ្រាន់តែអ្នកខ្លះមានតិច អ្នកខ្លះមានច្រើនប៉ុណ្ណោះ។ ទុក្ខធំៗទាំងឡាយនោះគឺ:



-ជាតិទុក្ខ គឺទុក្ខព្រោះមានជាតិកំណើត(តាំងពីនៅក្នុងផ្ទៃម្តាយម្ល៉េះ)។
-ព្យាធិទុក្ខ គឺទុក្ខព្រោះឈឺ មានជម្ងឺតម្កាត់មកបៀតបៀនដល់រូបរាងកាយ។
-ជរាទុក្ខ គឺទុក្ខព្រោះរូបកាយចាស់គ្រាំគ្រា និងទ្រុឌទ្រោម។
-មរណទុក្ខ គឺទុក្ខព្រោះសេចក្តីស្លាប់(ឈឺចុកចាប់ខ្លាំងនៅពេលស្លាប់)។

ក្រៅអំពីទុក្ខធំទាំង៤យ៉ាងនេះ មនុស្សនិងសត្វមានទុក្ខច្រើនប្រភេទទៀត ដូចជាទុក្ខព្រោះព្រួយបារម្ភ ភ័យ ខ្លាច ខឹង ច្រណែន ប្រច័ណ្ឌ អស់សង្ឃឹម ព្រាត់ប្រាស់ លែងលះប្តីប្រពន្ធ ចង់មានចង់បាន សេពគប់ជាមួយមនុស្សមានចិត្តអាក្រក់(ពាល) មិនបានសំរេចបំណងអ្វីមួយ និងជំពាក់ចិត្តខ្លាំងទៅលើវត្ថុអ្វីមួយ។

២. សមុទយអរិយសច្ចៈ គឺទុក្ខជាសេចក្តីពិត ដែលកើតឡើងអំពីហេតុអ្វីមួយដ៏ពិតប្រាកដ ឬជាបុព្វហេតុនៃទុក្ខ។ តថាគតបានពិចារណាទៅឃើញថាហេតុដែលនាំអោយមានទុក្ខបែបនេះមាន២គឺ ៖ អវិជ្ជា និង តណ្ហា។

-អវិជ្ជា គឺសេចក្តីល្ងង់ខ្លៅដែលមិនយល់ដឹងនូវហេតុដែលនាំអោយមានទុក្ខ។ អវិជ្ជានេះហើយដែលជាហេតុនាំអោយកើតមានតណ្ហាឡើង។ ដោយសារតែ អវិជ្ជាមនុស្សមិនអាចមើលឃើញរឿងពិតនៃជីវិតរបស់ខ្លួនទេ ហើយគេតែងត្រាំជាប់ជានិច្ចនៅក្នុង ភ្លើងតណ្ហា លោភៈ កំហឹង ច្រណែន ប្រច័ណ្ឌ សោកសង្រេង ភ័យខ្លាចសប្បាយភ្លើតភ្លើន និងការអស់សង្ឃឹម។ល។

-តណ្ហា គឺជាធម្មជាតិនាំសត្វអោយកើតទៀតនិងអោយត្រេកត្រអាលក្នុងភពនានាឬក្នុងអារម្មណ៍នានា។ តណ្ហាទាំងអស់នោះគឺ៖ កាមតណ្ហា ឬសេចក្តីប្រាថ្នាក្នុង កាមភព១ ភវតណ្ហាឬសេចក្តីប្រាថ្នាក្នុងរូបភព១ និងវិភវតណ្ហាឬសេចក្តីប្រាថ្នាក្នុងអរូបភព១។ តណ្ហាទាំងនេះហើយជាប្រភពនៃសេចក្តីទុក្ខគ្រប់បែបយ៉ាង។

៣. និរោធអរិយសច្ចៈ គឺជាការផុតរលត់ទុក្ខជាសេចក្តីពិតឬការបញ្ឈប់នៃទុក្ខ។ តថាគតបានពិចារណាទៅឃើញថាមានតែ និព្វាន មួយទេដែលជាកន្លែងសំរាប់រំលត់ទុក្ខ។ ដើម្បីអោយបានផុតអំពីទុក្ខត្រូវតែកាត់ផ្តាច់ឫសកែវរបស់វាគឺអវិជ្ជាអោយអស់រលីង។ ការយល់ដឹងនូវសច្ចៈនៃជីវិតអាចនាំមកនូវការបញ្ឈប់នៃទុក្ខជាទីបំផុតហើយក៏នាំអោយ

កើតមានសេចក្ដីស្ងប់ និងរីករាយក្នុងចិត្ត។ តថាគតប្រតិបត្តិតាមអដ្ឋង្គិមគ្គជាផ្លូវដ៏ប្រសើរ ប្រកបដោយអង្គ៨នេះ ទុកជាមាគ៌ាសំរាប់រំលត់ទុក្ខ។

៤. មគ្គអរិយសច្ចៈ គឺផ្លូវនាំអោយផុតទុក្ខជាសេចក្ដីពិតឬផ្លូវរំលត់ទុក្ខ។ តថាគតបានពិចារណាទៅឃើញថា មានតែការប្រតិបត្តិតាមផ្លូវកណ្ដាលឬមជ្ឈិមាបដិបទានេះទេ ដែលអាចរំលត់ទុក្ខឆ្លងទៅដល់និព្វានបាន។"

នៅពេលដែលព្រះពុទ្ធកំពុងតែសំដែងនូវចតុរារិយសច្ចនេះ ធម្មចក្ខុ ឬភ្នែកមើលឃើញធម៌ ប្រាសចាកកិលេសនិងមន្ទិលក៏កើតមានដល់កោណ្ឌញ្ញភិក្ខុ។ ភិក្ខុកោណ្ឌញ្ញបានពិចារណាឃើញថា៖

"សង្ខារទាំងឡាយដែលបានកើតឡើងហើយរមែងរលត់បាត់ទៅវិញជាធម្មតា" ព្រះអង្គបានក្រេបរសជាតិពន្លឺត្រាស់ដឹងដោយទឹកចិត្តរីករាយនិងច្បាស់លាស់ហើយ។

កាលបើ ព្រះធម្មចក្ករបស់ព្រះមានព្រះភាគ ទ្រង់សំដែងទៅ ដូចជាគេបង្វិលហើយ ភុម្មទេវតា ទាំងឡាយក៏បន្លឺនូវសូរស័ព្ទថាព្រះធម្មចក្កនេះមិនមានចក្កដទៃណាប្រសើរជាងឡើយ ទោះបីជា សមណៈក្ដី ព្រាហ្មណ៍ក្ដី មារក្ដី ព្រហ្មក្ដី ជនណា នីមួយក្ដី នៅក្នុងលោកនេះមិនអាចប្រព្រឹត្តទៅបានឡើយ។ ឥឡូវនេះ ព្រះពុទ្ធគោតមទ្រង់ប្រព្រឹត្តទៅបានហើយ ក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី។ ទេវតាទាំងឡាយក្នុង ឋានចាតុម្មហារាជិកា បានឮសំឡេងរបស់ភុម្មទេវតាហើយ ក៏បន្លឺនូវសំឡេងនេះដូចគ្នា។ ទេវតាទាំងឡាយក្នុង ឋានតាវត្តិង្ស បានឮសំឡេងរបស់ ចាតុម្មមហារាជិកាទេវតា ក៏បន្លឺនូវសំឡេងនេះដូចគ្នា។ ទេវតាទាំងឡាយក្នុង ឋានយាមា...ក្នុង ឋានតុសិត....ក្នុង ឋាននិម្មានរតិ...បរនិម្មិតវសវត្តី...ក្នុង ឋានព្រហ្មក៏បន្លឺនូវសូរស័ព្ទដូចគ្នាយ៉ាងនេះដែរ។ កាលសូរស័ព្ទនេះបានលាន់ឮកងរំពងដល់ឋានព្រហ្មលោកហើយ លោកធាតុទាំង១ហ្មឺនក៏កក្រើករំពើកញាប់ញ័រចំប្រប់ឡើង។ ពន្លឺរស្មីដ៏ធំមហិមា រកប្រមាណមិនបាន(លើសអំពីអានុភាពរបស់ទេវតាទាំងឡាយ) ក៏ភ្លឺចាំងប្រាកដឡើងក្នុងលោកយើងនេះ។

ព្រះពុទ្ធទ្រង់ចង្អុលទៅកាន់កោណ្ឌញ្ញភិក្ខុនិងបន្លឺនូវឧទានវាចាថា៖

"មើល៍ហ្ន៎ក! ភិក្ខុកោណ្ឌញ្ញៈបានត្រាស់ដឹងពិតប្រាកដហើយ! មើល៍ហ្ន៎ក! កោណ្ឌញ្ញ



ភិក្ខុបានទទួលមគ្គៈនៃពន្លឺត្រាស់ដឹងហើយ!"

នៅក្នុងគ្រានោះឯង កោណ្ឌញ្ញភិក្ខុបានឃើញ បានដល់ បានជឿស៊ប់ បានត្រាស់ដឹងនូវអរិយសច្ចធម៌ហើយ បានឆ្លងផុតសេចក្ដីមន្ទិលសង្ស័យ និងបានដល់នូវសេចក្ដីក្លៀវក្លាមិនជឿបុគ្គលដទៃណាក្រៅអំពីព្រះសាស្ដាទៀតឡើយ ក៏ក្រាបបង្គំទូលព្រះពុទ្ធ ជាពាក្យយ៉ាងនេះថា៖

"បពិត្រព្រះអង្គដ៏ចំរើន! សូមទ្រង់ព្រះមេត្តាប្រោសខ្ញុំព្រះអង្គសូម បព្វជ្ជា និង ឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ។"

ព្រះពុទ្ធទ្រង់ត្រាស់នូវពាក្យយ៉ាងនេះថា៖

"ម្នាលអាវុសោកោណ្ឌញ្ញៈ! អ្នកចូរជាភិក្ខុចុះ! ចូរអ្នកប្រព្រឹត្ត ព្រហ្មចរិយធម៌ដើម្បីនឹងធ្វើនូវនិព្វាន ជាទីបំផុតនៃកងទុក្ខទាំងឡាយដោយប្រពៃចុះ។"

កោណ្ឌញ្ញភិក្ខុក៏មាននាមបញ្ញត្តិថា "អញ្ញាកោណ្ឌញ្ញៈ" និងបានជា ឯកទគ្គ គឺអ្នកស្គាល់នូវរាត្រីកាល ហៅថា "រត្តញ្ញូ" ចាប់តាំងពីពេលនោះមក។

កាលឃើញសភាពបែបនេះកើតឡើង ភិក្ខុ៤អង្គទៀតក៏ស្រវាងើបទៅថ្វាយបង្គំសុំប្រគល់កាយថ្វាយខ្លួនធ្វើជាសាវកដែរ។ ពេលភិក្ខុទាំងអស់ត្រឡប់ទៅអង្គុយនៅក្នុងកន្លែងដ៏សមគួរវិញ ព្រះពុទ្ធទ្រង់ត្រាស់ថា៖

"ម្នាលអាវុសោទាំងឡាយ! កុមារជាច្រើននៅឯឧរុវេលនិគម បាននាំគ្នាហៅតថាគតថា "ពុទ្ធៈ"។ ពាក្យនេះជាពាក្យពិត ព្រោះតថាគតបានត្រាស់ដឹងរួចហើយ។"

បញ្ចវគ្គិយភិក្ខុបានសរសើរនូវគំនិតដ៏អស្ចារ្យនៃកុមារទាំងនោះ ក្នុងការប្រសិទ្ធិនាមដែលមានន័យល្អត្រឹមត្រូវ ហើយបានមូលមតិគ្នាទទួលព្រះសមណគោតមធ្វើជាមហាសាស្ដាចារ្យ ហើយហៅព្រះអង្គថា "ព្រះពុទ្ធៈ" តរៀងទៅ។

ព្រះពុទ្ធទ្រង់ញញឹមនិងមានពុទ្ធដីកាថា៖

"សូមអ្នកទាំងឡាយខំហាត់រៀនដោយវិរិយភាព នូវគំនិតទូលំទូលាយ និងវៃឆ្លាត។ ក្នុងរយៈតែបីខែប៉ុណ្ណោះ អ្នកនឹងបានសំរេចផលនៃពន្លឺត្រាស់ដឹងជាប្រាកដ។"

ដោយមានវិរិយភាពដ៏ខ្ពង់ខ្ពស់ បញ្ចវគ្គិយភិក្ខុបានយល់នូវព្រហ្មចរិយធម៌នៃការ

ត្រាស់ដឹងយ៉ាងឆាប់រហ័សបំផុត។ អញ្ញាកោណ្ឌញ្ញភិក្ខុបានសំរេចនូវ លោកុត្តរធម៌ មុនគេបង្អស់គឺបានសំរេច សោតាបត្តិផល នៅក្នុងថ្ងៃ១៥កើតពេញបូណ៌មីខែអាសាឍឆ្នាំរកា។ បន្ទាប់មក ព្រះមានព្រះភាគទ្រង់ប្រទាន ឯហិភិក្ខុ ដល់វប្បៈក្នុងថ្ងៃ១រោច។ ភិក្ខុទាំង៥រូបបានទទួលឧបសម្បទាជាឯហិភិក្ខុ និងបានប្រព្រឹត្តនូវព្រហ្មចរិយធម៌ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ។

លុះស្អែកឡើង ថ្ងៃ៥រោច ខែនិងឆ្នាំដដែល ព្រះពុទ្ធទ្រង់ទតឃើញ ឧបនិស្ស័យ ព្រះអរហន្ត កើតមានដល់បញ្ចវគ្គីយទើបព្រះអង្គត្រាស់ហៅភិក្ខុទាំងឡាយហើយទ្រង់សំដែងនូវ អនត្តលក្ខណសូត្រ ប្រាប់ថា បញ្ចក្ខន្ធ(ខន្ធ៥) គឺជាសភាវៈមិនបានប្រព្រឹត្តក្នុងអំណាចទេ សុទ្ធតែមិនមែនជារបស់នៃខ្លួន (អនត្តា) និងមិនទៀតទាត់ (អនិច្ចំ) ទេ។ ព្រះពុទ្ធទ្រង់បានពន្យល់បញ្ចវគ្គីយភិក្ខុ អោយពិនិត្យច្បាស់លាស់ ទៅលើបញ្ចក្ខន្ធគឺៈ រូបខន្ធ១ វេទនាខន្ធ១ សញ្ញាខន្ធ១ សង្ខារខន្ធ១ និង វិញ្ញាណខន្ធ១ ដែលទុកដូចជាស្នឹងទាំង៥ហូរពុំចេះឈប់ឈរនៅក្នុងវាលវដ្តសង្សារ។ ដូច្នេះ គ្មានអ្វីដែលគួរថាសាភាវៈទាំងអស់ជារបស់នៃខ្លួន ឬមានការទៀងទាត់នោះឡើយ។

ព្រះពុទ្ធទ្រង់បញ្ជាក់បន្ថែមថា៖

"ម្នាលភិក្ខុទាំងឡាយ! រូបកាយជាវត្ថុអនត្តា គឺមិនមែនជារបស់ខ្លួនឡើយ។ ប្រសិនបើរូបកាយនេះជារបស់ខ្លួនពិតមែន រូបកាយនេះមិនគប្បីមានជម្ងឺតម្កាត់ឡើយហើយបុគ្គលអាចនិយាយថា រូបរបស់អញជាយ៉ាងនេះក៏បានឬជាយ៉ាងនោះបានឡើយ គឺមិនអាចបង្គាប់រូបអោយប្រព្រឹត្តទៅតាមអំណាចខ្លួនបាន។

"ម្នាលភិក្ខុទាំងឡាយ! វេទនា ក៏មិនមែនជារបស់ខ្លួន សញ្ញាក៏មិនមែនជារបស់ខ្លួន សង្ខារក៏មិនមែនជារបស់ខ្លួន និងវិញ្ញាណក៏មិនមែនជារបស់ខ្លួន។ ដូច្នេះខន្ធទាំង៥គឺជារបស់អនត្តា។ ម្នាលភិក្ខុទាំងឡាយ! តើអ្នកដែលបានសំគាល់ឃើញថារូបកាយទៀងឬមិនទៀង?"

បញ្ចវគ្គីយភិក្ខុក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន! រូបកាយមិនទៀងទាត់ទេ!"

ព្រះពុទ្ធត្រាស់ "តើរូបឬរបស់ដែលមិនទៀងទាត់នោះផ្តល់សេចក្តីសុខឬទុក្ខ?"



បញ្ចវគ្គីយភិក្ខុក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន! រូបឬរបស់នោះពិតជាផ្តល់នូវសេចក្តីទុក្ខ។"

ព្រះពុទ្ធត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! បើរបស់នោះមិនទៀតទាត់ ជាទុក្ខនិងមានការប្រែប្រួលជាធម្មតា តើអ្នកគួរគិតថារបស់នោះជារបស់អញ ជាអញ និង ជាខ្លួនអញបានឬទេ?"

បញ្ចវគ្គីយភិក្ខុក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន! យើងមិនគួរយល់ឃើញថាយ៉ាងដូច្នោះឡើយ។"

ព្រះពុទ្ធត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! តើវេទនា សញ្ញា សង្ខារ និង វិញ្ញាណក៏មិនទៀងដែរ ក៏ជាទុក្ខដែរ ក៏មិនត្រូវគិតថាជារបស់អញ ជាអញ និងជាខ្លួនអញឡើយ។"

ព្រះពុទ្ធត្រាស់បន្តថា៖

"ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុហ្នឹងហើយនៅក្នុងលោកនេះ រូបណាមួយវេទនាណាមួយ សញ្ញាណាមួយ សង្ខារណាមួយ និង វិញ្ញាណណាមួយ ទោះជាអតីតកាលក្តី ទោះជាអនាគតកាលក្តី ទោះជាល្អិតក្តី ទោះជាថោកទាបក្តី ទោះជាឧត្តមក្តី ទោះនៅក្នុងទីជិតក្តី ទោះនៅក្នុងទីឆ្ងាយក្តី រូបនោះ វេទនានោះ សញ្ញានោះ សង្ខារនោះ និង វិញ្ញាណនោះ ក៏គ្រាន់តែជារូប គ្រាន់តែជាវេទនា គ្រាន់តែជាសញ្ញា គ្រាន់តែជាសង្ខារ និងគ្រាន់តែជាវិញ្ញាណប៉ុណ្ណោះឯង។ អ្នកទាំងឡាយគួរគិតឃើញនូវសេចក្តីទាំងអស់នោះដោយប្រាជ្ញាចុះថា វានោះមិនមែនជារបស់អញវានោះមិនមែនជាអញ និងវានោះមិនមែនជាខ្លួនអញឡើយ។

"ម្នាលភិក្ខុទាំងឡាយ! អរិយសាវ័កស្តាប់និងយល់ឃើញយ៉ាងនេះក៏មានសេចក្តីនឿយណាយក្នុងរូបផង ក្នុងវេទនាផង ក្នុងសញ្ញាផង ក្នុងសង្ខារផងនិងក្នុងវិញ្ញាណផង។ កាលបើមានសេចក្តីនឿយណាយយ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះប្រាសចាកតំរេកឬអាសវៈ។ កាលបើចិត្តផុតស្រឡះអស់ហើយ ញាណនៃអរិយសាវ័កនោះ ក៏កើតមានឡើងប្រាកដថាចិត្តរបស់អាត្មាអញផុតស្រឡះពីអាសវៈហើយ។ អរិយសាវ័កនោះក៏ដឹងដូច្នោះថាជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយធម៌អាត្មាអញបាននៅរួចហើយ កិច្ចគួរធ្វើក៏អាត្មាអញ

បានធ្វើរួចហើយ កិច្ចដទៃទៀតក្រៅអំពីនេះក៏មិនមានដល់អាត្មាទៀតទេ។"

បញ្ចវគ្គីភិក្ខុមានចិត្តត្រេកអរ ចំពោះការសំដែងធម៌របស់ព្រះពុទ្ធជាម្ចាស់។ ចិត្តរបស់ភិក្ខុទាំង៥រូបក៏បានស្រឡះចាកអាសវៈទាំងឡាយ មិនពោលប្រកាន់ពាក្យថា "អញ" ឬ "យើង" ទៀតឡើយ។ ចិត្តរបស់ភិក្ខុទាំង៥រូបក៏បានរួចចាកអាសវៈទាំងពួង ហើយក៏បានសំរេចនូវព្រះអរហន្តជាស្ថាពរ។ គ្រានោះហើយដែលព្រះអរហន្ត ៦អង្គ ប្រាកដមានឡើងមុនដំបូងបង្អស់ក្នុងលោក។

ព្រះពុទ្ធមានពុទ្ធដីកាដោយសេចក្ដីសោមនស្សរីករាយ ទៅកាន់ព្រះអរហន្តទាំង៥អង្គនោះថា៖

"ឥឡូវនេះ យើងមានសហាគមពិតប្រាកដហើយ ដែលហៅថា "សង្ឃ"។ សង្ឃគឺជាគណនៈនៃបព្វជិតដែលរស់នៅដោយចុះសម្រុងគ្នា និងយល់ធម៌ត្រាស់ដឹង។ យើងត្រូវនាំគ្នាយកគ្រាប់ពូជនៃការត្រាស់ដឹងនេះ ទៅសាបព្រោះលើថ្នាលមនុស្សលោក នៅសព្វទិសានុទិស ក្នុងពិភពលោកចាប់ពីពេលនេះតទៅ។"

---

## សូមសមាទាន ÷ អរិយសច្ចៈឬចតុរារិយសច្ចៈ

| | |
|---|---|
| ១. ទុក្ខអរិយសច្ចៈ | ទុក្ខធំ៤គឺ ទុក្ខនៃការកើត ចាស់ ឈឺ និង ស្លាប់។ |
| ២. សមុទយអរិយសច្ចៈ | ទុក្ខកើតអំពី លោភៈ ទោសៈ មោហៈ និងអវិជ្ជា។ |
| ៣. និរោធអរិយសច្ចៈ | ការរំលត់ទុក្ខឆ្ពោះទៅកាន់និរោធឋានគឺ ព្រះនិព្វាន។ |
| ៤. មគ្គអរិយសច្ចៈ | ផ្លូវឬមធ្យោបាយនាំអោយផុតទុក្ខគឺមជ្ឈិមាបដិបទា។ |

## សូមសមាទាន÷ អរិយមគ្គមានអង្គ៨ឬអដ្ឋង្គិកមគ្គ

| | |
|---|---|
| ១. សម្មាទិដ្ឋិ | ការឃើញត្រូវ គឺឃើញអរិយសច្ចៈ៤។ |
| ២. សម្មាសង្កប្បៈ | ការត្រិះរិះត្រូវ គឺត្រិះរិះមិនបៀតបៀន មិនចង់បានទ្រព្យអ្នកដទៃ និងមិនត្រាំជាប់ក្នុងកាម។ |
| ៣. សម្មាវាចា | ការពោលពាក្យត្រូវ គឺវៀរចាកវចីទុច្ចរិត៤យ៉ាងគឺៈ ភូតកុហក១ ញុះញង់១ ជេរប្រទេច១ និងនិយាយឡេះឡោះ លេងសើច១។ |
| ៤. សម្មាកម្មមន្ត | ការធ្វើការងារត្រូវ គឺវៀរចាកកាយទុច្ចរិត៣យ៉ាង៖ សម្លាប់សត្វ១ លួចទ្រព្យគេ១ និងចាប់រំលោភប្រពន្ធកូនគេ១។ |
| ៥. សម្មាអាជីវៈ | ការចិញ្ចឹមជីវិតត្រូវ គឺរស់នៅស្របច្បាប់ និង ដោយកន្លងធម៌។ វៀរចាកជំនួញខុស៥ប្រការគឺ៖ ជួញគ្រឿងសាស្ត្រាវុធ១ ជួញមនុស្ស១ ជួញសាច់១ ជួញគ្រឿងស្រវឹង១ និង ថ្នាំពិស១។ |
| ៦. សម្មាវាយាមៈ | ការព្យាយាមត្រូវ គឺព្យាយាមលះបាបដែលកើតក្នុងចិត្តហើយ។ ខាឃាំងកុំអោយបាបថ្មីកើតឡើង។ រក្សាទុកនូវកុសលដែលមានរួចហើយ កុសលដែលមិនទាន់កើតធ្វើអោយកើតឡើង។ |
| ៧. សម្មាសតិ | ការនឹករលឹកត្រូវគឺដំកល់ចិត្តក្នុងសតិបដ្ឋាន៤ គឺដំកល់ចិត្តក្នុងកាយ វេទនា ចិត្ត និងធម្មៈ ថាគ្រាន់ជាកាយ វេទនា ចិត្តនិងធម្មៈប៉ុណ្ណោះ ពុំមែនជាសត្វ ឬបុគ្គលមានសភាពសោះសូន្យទទេនោះឡើយ ។ |
| ៨. សម្មាសមាធិ | ការដំកល់ចិត្តត្រូវ គឺជាភាពរបស់ចិត្ត និងចេតសិកជាកុសលដែលដំកល់ស្មើល្អក្នុងអារម្មណ៍តែមួយ គឺសេចក្ដីស្ងប់ចាកនីវរណធម៌ទាំង៥ ។ |



---

## ជំពូកទី ១៣
## យសកុលបុត្តបព្វជា

ការតើនចាកអំពីសាយនាពីព្រលឹមនិងការយាងចង្រ្កតាមដងព្រៃគឺជាទម្លាប់ធម្មតារបស់ព្រះពុទ្ធ។ ព្រឹកមួយនោះ ពេលព្រះអង្គយាងចង្រ្កមនៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសីនោះ ព្រះពុទ្ធទ្រង់ទតឃើញបុរសសង្ហារ ស្លៀកពាក់ទាន់សម័យម្នាក់ ដើរចូលមកពីចម្ងាយ ដោយបង្កប់អស់ពាក់តណ្ដាលខ្លួនទៅក្នុងអ័ព្ទដ៏ក្រាស់ នាពេលព្រឹកព្រហាម។

ព្រះពុទ្ធទ្រង់យាងចេញពីទីចង្រ្កមទៅគង់ធ្វើសមាធិនៅលើផ្ទាំងថ្មធំមួយ។ បុរសនៅដើរមកជិតដល់ព្រះពុទ្ធហើយក៏នៅតែមើលព្រះអង្គមិនឃើញ។ បុរសសង្ហារបាននិយាយរអ៊ូរទាំងតែម្នាក់ឯងថា ៖

"ឱហ្ន៎! គួរឲ្យជិនឆ្អន់ណាស់តើ! ឱហ្ន៎! គួរឲ្យស្អប់ខ្ពើមណាស់តើ!"

ព្រះពុទ្ធទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏ទ្រង់មានពុទ្ធដីកាថា ៖

"នៅទីនេះគ្មានអ្វីគួរអោយជិនឆ្អន់ទេ! នៅទីនេះគ្មានអ្វីគួរអោយស្អប់ខ្ពើមទេ!"

បុរសសង្ហារនោះអាក់ដំណើរនឹងសម្លេងដ៏ស្រួយស្រែះរបស់ព្រះពុទ្ធ ក្រឡេកទៅក៏ឃើញព្រះពុទ្ធកំពង់គង់នៅលើថ្មធ្វើព្រងើយនិងយ៉ាងស្ងាត់ស្ងៀម។ បុរសនោះក៏យកដៃដោះស្បែកជើងមាសចេញ ដើរឱនត្រុនៗចូលទៅកាន់ព្រះពុទ្ធអង្គ រួចហើយក៏អង្គុយនៅលើថ្មមួយជុំជិតព្រះអង្គនោះ។

ព្រះពុទ្ធទ្រង់ត្រាស់សួរថា៖

"ម្នាលមាណព! តើអ្វីទៅដែលគួរអោយអ្នកជិនឆ្អន់យ៉ាងខ្លាំងនោះ? និងតើទៅដែលគួរអោយអ្នកស្អប់ខ្ពើមយ៉ាងខ្លាំងនោះ?"

មាណពបានទូលអោយព្រះពុទ្ធស្គាល់ឈ្មោះខ្លួនថា "យសកុលបុត្ត" ជាបុត្រានៃសេដ្ឋីគហបតីមានឈ្មោះល្បីល្បាញម្នាក់នៅក្នុងក្រុងពារាណសី។ យសរស់នៅក្នុងជីវិតដ៏សែនសប្បាយនិងមានការថ្នាក់ថ្នមជាទីបំផុត។ មាតាបិតាបានបំពេញចិត្តយសគ្រប់ពេលវេលា មានប្រាសាទ៣ដ៏ល្អប្រណីតសំរាប់លំហែកាយតាមរដូវគឺសំរាប់រដូវ រងារ រដូវក្តៅ និងរដូវភ្លៀវ។ មាតាបិតាតែងអោយពួកអ្នកភ្លេងសុទ្ធតែស្រីៗទៅប្រគំតន្ត្រីអោយស្តាប់ មានស្ត្រីបំរើឆ្វេងស្តាំ ជប់លៀងរាំរែកអស់កំណត់៤ខែក្នុងរដូវភ្លៀងមិនអោយចុះពីលើប្រាសាទឡើយ។

ពេលព្រលប់នារាត្រីកន្លងមកនេះ យសនិងមិត្តភ័ក្ត្របានជួបជុំគ្នាជប់លៀងរាំរែក ផឹកស៊ីជាមួយស្រីក្មេងៗយ៉ាងសប្បាយ។ លុះដល់ពេលពាក់កណ្តាលអធ្រាត្រយសភ្ញាក់ឡើងហើយក្រឡេកទៅមើលឃើញមិត្រភក្តិស្រីរបាំដេកអាក្រាតជំហ៊ីងជំហាំង គងគាក់លើគ្នាលក់ស្តូកស្តឹងបីដូចខ្មោចស្លាប់គរជើងក្នុងសង្គ្រាម។ ដោយសារយសជាមនុស្សឆាប់ភ្ញាក់រលឹក យសនឹកប្រយោគដល់រូបមនុស្សទាំងអស់ហើយក៏កើតសេចក្តីជិនណាយក្នុងជីវិតពាលាបែបនេះភ្លាម។ យសក៏បានយល់ដឹងដោយខ្លួនឯងថា អាត្មាអញមិនគួរបន្តរស់នៅក្នុងជីវិតបែបហ្នឹងទៀតទេ។ យសក៏ចាប់ទាញយកអាវជាយមកពាក់ និងស៊កបានស្បែកជើងមាសមួយសម្រាប់ដើរចេញសំដៅទៅកាន់ក្លោងទ្វារដើរៗទៅពេញមួយយប់ រហូតមានវាសនាទៅដល់ម្រឹមឧទ្យាន ក្នុងឥសបតនមិគទាយវ័ន ដែលជាទីព្រះពុទ្ធអាស្រ័យនៅ



នាពេលថ្ងៃរះព្រាងៗ។

ដោយព្រះពុទ្ធទ្រង់ជ្រាបថា យសកុលបុត្តជាមនុស្សមានបញ្ញានិងមានចិត្តទន់ស្រួលទើបព្រះអង្គញ៉ាំងយលកុលបុត្តដោយសំដែងនូវ អនុបុព្វីកថា មាន ទានកថាគឺការធ្វើទាន១ សីលកថាគឺ ការរក្សាសីល១ សគ្គកថា គឺការគិតដល់សុខក្នុងឋានសួគ៌១ ទោសនៃការប្រព្រឹត្តកាម១ និងអានិសង្សក្នុងការចាកកាមចេញទៅបួស១។

បន្ទាប់ពីព្រះអង្គបានដឹងថាយសកុលបុត្តមានចិត្តភ្លៀវភ្លានិងបានជ្រះថ្លាហើយព្រះពុទ្ធទ្រង់បន្តសំដែងនូវ ចតុរារិយសច្ចៈ អោយយសកាន់តែយល់ច្បាស់ថែមទៀត។

ព្រះពុទ្ធបន្តប្រទានយោបល់ដល់យសកុលបុត្តថា៖

"ម្នាលយស! ក៏ពិតមែនជីវិតពោរពេញទៅដោយទុក្ខ ប៉ុន្តែ ជីវិតក៏ពោរពេលទៅដោយភាពអស្ចារ្យដ៏ច្រើនដែរ។ ការវង្វេងលិចលង់ក្នុងកាមតណ្ហាបណ្តាលអោយមានទុក្ខទាំងខាងផ្លូវកាយទាំងខាងផ្លូវចិត្ត។ បើអ្នកចង់រស់នៅស្រួលហើយមានសុខភាពល្អ ចូរអ្នកកុំបណ្តោយខ្លួនទៅតាមចំណង់តណ្ហាអោយសោះ ពីព្រោះនៅក្នុងជីវិតមនុស្សលោកមានអំពើសៅហ្មងច្រើនប្រការណាស់។ នៃយស! ចូរអ្នកក្រឡេកមើលជុំវិញខ្លួនអ្នកទៅមើល៍! តើអ្នកអាចមើលឃើញរុក្ខជាតិទាំងអស់ហ្នឹង មិនល្អទេឬ? ព្រះច័ន្ទ ដួងតារា ស្ទឹង បឹងបួរ ទន្លេ ព្រៃភ្នំក្រំថ្ម ពន្លឺព្រះអាទិត្យ សំនៀងនៃសត្វ បក្សាបក្សី និងស្នូរខ្យល់រដូវ វត្ថុទាំងឡាយនេះហើយដែលបញ្ចេញអោយយើងឃើញថាពិភពលោកអាចជួយផ្តល់អោយយើង នូវសេចក្តីសប្បាយរីករាយរកទីបំផុតគ្មាន។ សុភមង្គលដែលគេទទួលមកអំពីវត្ថុធម្មជាតិទាំងនោះហើយ ដែលចិញ្ចឹមរូបកាយនិងចិត្តរបស់គេនោះ។ សូមអ្នកបិទភ្នែកទាំងពីរ ហើយដកដង្ហើម ចូលនិងចេញ អោយបានពីរបីដងសាកមើល៍! ឥឡូវនេះ បើកភ្នែកឡើង តើអ្នកបានឃើញអ្វីប្លែកខ្លះ? ដើមឈើ អ័ព្ទសន្សើម ផ្ទៃមេឃពណ៌ខៀវ ពន្លឺព្រះអាទិត្យ។ល។ កាលពីដើម ភ្នែកទាំងគូររបស់អ្នកអភ័ព្វណាស់ពីព្រោះអ្នកបានជួបប្រទះនូវវត្ថុធម្មជាតិដ៏អស្ចារ្យបែបនេះហើយ ប៉ុន្តែអ្នកមិនដែលបានយកបញ្ញាទៅប្រើ ដូច្នេះហើយបានជា អ្នកត្រូវតែស្អប់ដល់ចិត្តនិងកាយខ្លួនឯង។ មនុស្សខ្លះស្អប់ខ្ពើមចិត្តនិងកាយខ្លួនឯងខ្លាំង រហូតដល់ចង់ធ្វើអត្តឃាត(សម្លាប់ខ្លួនឯង)ទៀតផង។ គេមើលឃើញតែសេចក្តីទុក្ខ ក្នុងជីវិតប៉ុណ្ណោះ។

សេចក្តីទុក្ខមួយបែបទៀត គឺជាលទ្ធផលនៃមធ្យោបាយដែលយើងរស់នៅនិងជាការយល់ច្រឡំរបស់យើងក្នុងជីវិតតែប៉ុណ្ណោះ។ បើពោលអោយខ្ពស់ជាងនេះទៅទៀត សេចក្តីទុក្ខគឺកើតមកអំពីការមានខន្ធ៥។"

ពាក្យប្រៀនប្រដៅទាំងអស់របស់ព្រះពុទ្ធ ធ្វើអោយជវ៉នចិត្តរបស់យសកុលបុត្រ រំភើបរីករាយឥតឧបមា។ យសលើកដៃទាំងគូប្រណម្យ ហើយក្រាបថ្វាយបង្គំដល់ចុងព្រះបាទាព្រះពុទ្ធ សុំខ្លួនធ្វើជាសាវ័ករបស់ព្រះអង្គ។

ព្រះពុទ្ធយកព្រះហស្តជួយលើកមាណពអោយឈរឡើង ហើយទ្រង់ត្រាស់ថា៖

"ម្នាលយសដ៏ចំរើន! ព្រះសង្ឃរស់នៅក្នុងជីវិតសាមញ្ញនិងដាក់ខ្លួនយ៉ាងទាបបំផុត។ ព្រះសង្ឃគ្មានសម្បត្តិស្តុកស្តម្ភទេ។ លោកសិងតែក្នុងខ្ទមប្រក់ស្លឹកត្នោតឬស្បូវ ឬគង់នៅក្រោមដើមឈើ ឆាន់តែម្ហូបអាហារដែលបរិស័ទប្រគេនហើយឆាន់តែមួយពេលក្នុងមួយថ្ងៃទៀតផង។ តើអ្នកអាចរស់ក្នុងជីវិតអ្នកបួលបែបហ្នឹងបានឬទេ?"

យសកុលបុត្តក៏បង្គំទូលថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គសប្បាយចិត្តនឹងរស់នៅក្នុងជីវិតជាអ្នកបួសបែបនេះណាស់!"

ព្រះពុទ្ធទ្រង់ត្រាស់ថា៖

"ម្នាលយសដ៏ចំរើន! ព្រះសង្ឃបូជាពីកម្លាំងកាយនិងចិត្តរបស់ខ្លួនចំពោះការត្រាស់ដឹង ដើម្បីជួយដល់ខ្លួនឯងផ្ទាល់ផង និងជួយដល់អ្នកដទៃផ្សេងទៀតផង។ លោកខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីជួយសំរាលទុក្ខដល់សព្វសត្វលោក។ ម្នាលយស! តើអ្នកហ៊ានប្តេជ្ញាថានឹងដើរតាមមាគ៌ានៃពន្លឺត្រាស់ដឹងនេះ បានដែរឬទេ?

យសកុលបុត្តបង្គំទូលថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ទូលបង្គំសន្យាថានឹងប្រតិបត្តិតាមមាគ៌ានេះបាន!"

ព្រះពុទ្ធទ្រង់ត្រាស់បន្ថែមថា៖

"ដូច្នេះតថាគតសុខចិត្តទទួលយសធ្វើជាសាវ័ករបស់តថាគតហើយ។ សាវ័កនៅក្នុងគណៈនេះឈ្មោះថា "ភិក្ខុ ឬ ស្មូមដើរសុំទានគេ"។ ជារៀងរាល់ថ្ងៃ អ្នកត្រូវតែនិមន្តចេញ



បិណ្ឌបាត តាមលំដាប់ផ្ទះអ្នកស្រុក ដើម្បីយកចង្ហាន់បិណ្ឌបាតនោះមកចិញ្ចឹមខ្លួនផង ដើម្បីហាត់បំពត់ចិត្តបន្ទាបខ្លួនផង និង ហាត់ប្រាស្រ័យទាក់ទងជាមួយអ្នកស្រុកផង និងដើម្បីអប់រំដល់អ្នកស្រុកទាំងឡាយនោះនូវព្រហ្មចរិយធម៌ផង។"

លំដាប់នោះស្រាប់តែបញ្ចវគ្គីយភិក្ខុជាបឋមសាវ័ករបស់ព្រះពុទ្ធចូលមកដល់។ យសក្រោកឈរ ហើយក៏ធ្វើវន្ទនកិច្ចដល់បញ្ចវគ្គីយភិក្ខុម្តងមួយអង្គៗរហូតដល់ចប់។ ព្រះពុទ្ធបានបង្ហាញបញ្ចវគ្គីយភិក្ខុអោយស្គាល់យសកុលបុត្ត រួចក៏ព្រះអង្គបែរព្រះភ័ក្ត្រទៅរកកោណ្ឌញ្ញភិក្ខុ ហើយត្រាស់ថា៖

"ម្នាលកោណ្ឌញ្ញ! យសក៏មានបំណងចង់សាងផ្នួសដែរ។ តថាគតបានយល់ព្រមរួចហើយ។ សូមអ្នកជួយបង្ហាត់បង្ហាញយសអោយចេះ គ្រងស្បង់ចីវរ ទ្របាត្រកំណត់ដង្ហើមចេញចូល និងអង្គុយឬដើរចង្ក្រមភាវនាផង។"

កោណ្ឌញ្ញត្ថេរបាននាំយសទៅកាន់ខ្ទម រួចហើយចាប់ផ្តើមកោរសក់និងបង្រៀនយសតាមព្រះបំណងរបស់ព្រះពុទ្ធ។ កោណ្ឌញ្ញភិក្ខុបានប្រគេនស្បង់ចីវរដែលព្រះអង្គមិនទាន់ប្រើសោះទៅអោយយស។

ចំណែកខាងមាតាបិតារបស់យសវិញ កាលបានដឹងថាបុត្រាស្ងួនសំឡាញ់ចេញបាត់ពីប្រាសាទដូច្នេះ ក៏ចាត់អោយគេដើររកបុត្រគ្រប់ទិសទី អស់មួយព្រឹកមកហើយនៅតែរកមិនឃើញ។ ដល់ពេលរសៀលអ្នកបំរើម្នាក់បានដើរតាមដានជើងរបស់យសរហូតដល់សួនប្រើសក្នុងឥសបតនមិគទាយវ័ន ហើយបានរកឃើញស្បែកជើងមាសរបស់យសដែលដោះចោលនៅជិតដុំថ្មមួយផ្ទាំងធំនោះ។ បន្ទាប់ពីបានសាកសួរដឹងដំណឹងថា លោកម្ចាស់យសរបស់ខ្លួនកំពុងតែស្នាក់នៅជាមួយភិក្ខុសង្ឃមួយចំនួននៅក្នុងទីនោះមក អ្នកបំរើក៏រូតរះត្រឡប់ទៅជំរាបដល់បិតារបស់យសវិញ។

កាលបានជ្រាបនូវការពិតដូច្នេះហើយ បិតារបស់យសប្រញាប់ធ្វើដំណើរទៅជួបដើម្បីអោយអស់សង្ស័យ។ ពេលចូលទៅដល់សួនប្រើសគាត់បានឃើញព្រះពុទ្ធកំពុងគង់ធ្វើសមាធិយ៉ាងស្ងាត់ស្ងៀមតែមួយអង្គឯងនៅលើផ្ទាំងថ្មមួយដុំ។ គហបតីក៏លើកដៃទាំងគូសំពះដោយគោរព ហើយសួរថា៖

"បពិត្រព្រះសមណដ៏ចំរើន! តើព្រះអង្គបានឃើញបុត្រាទូលព្រះបង្គំឈ្មោះយស ផងដែរឬទេ?"

ព្រះពុទ្ធទ្រង់ធ្វើនិទ្ទេស (ចង្អុលបង្ហាញ) ទៅកាន់ថ្មមួយដុំ នៅជិតទីនោះ រួចហើយក៏អញ្ជើញគហបតីអោយអង្គុយចុះ។

"ម្នាលគហបតី! សូមលោកអង្គុយសិនចុះ បន្តិចទៀត លោកនឹងបានជួបមុខយសជាបុត្រា ក្នុងទីនេះតែម្តង។"

បិតារបស់យសអង្គុយស្តាប់ព្រះពុទ្ធនិទាននូវរឿងរ៉ាវដែលព្រះអង្គបានជួបជាមួយយសកាលពីព្រឹកមិញ។ ព្រះពុទ្ធទ្រង់បានពន្យល់គហបតីអោយបានយល់អំពីទឹកចិត្តជ្រះថ្លានិងសេចក្តីប្រាថ្នារបស់យស។ ព្រះអង្គត្រាស់សួរបិតាយសបន្តទៀតថា៖

"ម្នាលគហបតី! យសជាមនុស្សមានប្រាជ្ញា មានស្មារតីភ្ញាក់រឭក និងជាអ្នកបានរកឃើញមាគ៌ានៃការត្រាស់ដឹងក្នុងបេះដូងហើយ។ ឥឡូវនេះ យសមានចារឹកនឹងន មានចិត្តស្មោះត្រង់និងសប្បាយរីករាយក្នុងព្រះធម៌ហើយ។ សូមលោកសេដ្ឋីជួយអបអរសាទរចំពោះសេចក្តីល្អរបស់យសជាបុត្រាផងចុះ។

បន្ទាប់មក ដោយព្រះអង្គយល់នូវចិត្តរបស់យសបិតាជាអ្នកមានបញ្ញានិងមានចិត្តទប់ល្អទើបព្រះអង្គទ្រង់ប្រទាននូវបុព្វីកថាទាំង៥គឺ៖ ទានកថា១ សីលកថា១ សគ្គកថា១ ទោសនៃការប្រព្រឹត្តកាម១ និងអានិសង្សនៃការចាកកាមចេញទៅបួស១។ ព្រះអង្គក៏បានពន្យល់ នូវចតុរារិយសច្ច គឺ៖ ទុក្ខសច្ច១ សមុទយសច្ច១ និរោធសច្ច១ និងមគ្គសច្ច១ បន្ថែមទៀត ដើម្បីអោយយសបិតាយល់កាន់តែច្បាស់ឡើងទៀត។

គហបតីមានអារម្មណ៍ដូចជាស្រាលខ្លួន កាលបានស្តាប់យល់នូវពាក្យទូន្មានទាំងឡាយរបស់ព្រះពុទ្ធរួចមក។ គាត់ក៏ក្រោកឈរហើយលើកដៃប្រណម្យសំពះថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ព្រះពុទ្ធដីការបស់ព្រះអង្គ ដែលបានត្រាស់ហើយពីរោះពេកណាស់។ ព្រះអង្គជាអ្នកបានចាប់ផ្ងារឡើងរបស់ដែលគេផ្កាប់ចុះ ឬក៏បើកឡើងនូវរបស់ដែលគេបិទបាំងទុក ឬក៏ដុតបំភ្លឺនូវប្រទីបក្នុងទីងងឹត។ បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គសូមដល់នូវ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹងទីរលឹកសូមព្រះមានព្រះភាគមេត្តា



ទទួលខ្ញុំព្រះអង្គថាជាឧបាសករបស់ព្រះអង្គ ចាប់តាំងពីថ្ងៃនេះតទៅផង!"

ព្រះពុទ្ធទ្រង់គង់ស្ងៀមមួយស្របក់ ទើបមានព្រះពុទ្ធដីកាបន្តទៅទៀតថា៖

"ម្នាលគហបតី! សាវកទាំងឡាយរបស់តថាគត ព្យាយាមរស់នៅក្នុងជីវិតសាមញ្ញ និងមានស្មារតីភ្ញាក់រលឹកជានិច្ច ជាអ្នកចៀសវាងនូវការកាប់សម្លាប់ ចៀសវាងអំពើផិតក្បត់សាហាយស្មន់ និយាយតែពាក្យសច្ចៈ និងចៀសវាងការសេពនូវគ្រឿងស្រវឹងដែលនាំអោយល្អក់កករក្នុងខន្ធសន្តាន។ គហបតី! ប្រសិនបើយល់ថាលោកអាចដើរតាមមាគ៌ាបែបនេះបាន លោកនឹងទៅជាឧបាសកនៅក្នុងពេលនេះ។"

បិតារបស់យសលុតជង្គង់ចុះចំពោះព្រះភ័ក្ត្រព្រះពុទ្ធ ហើយលើកដៃសច្ចាថា៖

"បពិត្រព្រះអង្គដ៏ចំរើន! សូមទ្រង់អនុញ្ញាតអោយទូលបង្គំ ជ្រកក្រោមការប្រៀនប្រដៅរបស់ព្រះអង្គផងចុះ។ សូមបង្ហាញដល់ខ្ញុំព្រះអង្គនូវព្រះធម៌ក្នុងជីវិតនេះ។ ខ្ញុំព្រះអង្គប្តេជ្ញាគោរពចំពោះព្រះរតនត្រ័យ លុះត្រាអវសានជីវិត។"

ពេលនោះយសត្ថេរក៏ចូលមកដល់។ យសគ្រងស្បង់ចីវរដែលមានព្រហកេសកោរ និងមានឫកពារស្រគត់ស្រគំសមរម្យល្អ។ ភិក្ខុដែលទើបនឹងបួសថ្មីនេះ ញញឹមដោយក្តីសង្ឃឹម។ យសបិតាមិនដែលឃើញបុត្ររបស់ខ្លួនសប្បាយចិត្តដូចជាថ្ងៃនេះសោះរួចហើយក៏ពោលពាក្យថា៖

"យស! មាតារបស់អ្នកមានសេចក្តីខ្សឹកខ្សួលខ្លាំងណាស់ណា! សូមលោកម្ចាស់ប្រទានជីវិតដល់មាតារបស់លោកម្ចាស់ផង!"

ក្នុងគ្រានោះឯង យសត្ថេរងើបមើលព្រះភ័ក្ត្រព្រះពុទ្ធ។ ព្រះពុទ្ធទ្រង់យល់នូវអធ្យាស្រ័យ ក៏ព្រះអង្គត្រាស់នឹងយសបិតាថា៖

"ម្នាលគហបតី! លោកសំគាល់ឃើញយសដែលជាបុត្រានេះ មានអាការៈប្លែកដូចម្តេចខ្លះ? បើយសជាអ្នកបានឃើញព្រះធម៌ដោយ សេខញ្ញាណ និង សេខទស្សនៈ ហើយជាអ្នកបានពិចារណានូវ ភូមិធម៌ ដូចជាធម៌ដែលលោកបានឃើញហើយ ជាអ្នកដឹងច្បាស់ដោយចិត្តខ្លួនឯងហើយ ជាអ្នកបានរួចចាកអាសវធម៌ទាំងឡាយហើយ ដោយឥតមានជាប់ជំពាក់នឹង ឧបាទាន អ្វីបន្តិចសោះនោះ តើយសគួរនឹងវិលត្រឡប់ទៅផ្ទះវិញ ដើម្បី

ភាវៈថោកទាប និងបរិភោគកាមទាំងឡាយ ដូចកាលពីនៅ ឃរាវាស (គ្រហស្ថ)ដែរឬទេ?"

គហបតីក៏បង្គំទូលថា៖

"បពិត្រព្រះអង្គដ៏ចំរើន! សូមទ្រង់ព្រះមេត្តាប្រោស យសមិនគួរនឹងធ្វើទេ។ យសមានលាភធំហើយ យសមានអត្តភាពជាមនុស្សខ្ពង់ខ្ពស់ហើយ។ ម្យ៉ាងទៀតចិត្តរបស់យសក៏រួចចាកអំពីអាសវធម៌ទាំងឡាយអស់ហើយ ឥតមានជាប់ជំពាក់ដោយឧបាទានអ្វីទៀតឡើយ។"

យសត្ថេរបានងាកមើលមុខបិតា រួចហើយក៏មានពុទ្ធដីកាថា៖

"អាត្មានឹងទៅជួប ហើយចំរើនពរដល់អ្នកមានគុណ ដើម្បីអោយគាត់បាតទុក្ខកង្វល់។ ប៉ុន្តែអាត្មាបានប្តេជ្ញាដើរតាមព្រះពុទ្ធជាម្ចាស់ និងរស់នៅក្នុងជីវិតជាអ្នកបំរើដល់សព្វសត្វលោក រួចស្រេចទៅហើយ។"

បិតារបស់យសញញឹមទទួល ដោយគ្មានបញ្ចេញវាចាអ្វីឡើយ រួចទើបគហបតីបែរមុខទៅរកព្រះពុទ្ធវិញម្តង។ គហបតីបង្គំទូលព្រះពុទ្ធថា៖

"បពិត្រព្រះអង្គដ៏ចំរើន! សូមព្រះមានព្រះភាគទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ព្រះទាំងយសនិងភិក្ខុទាំងឡាយផង។"

ព្រះពុទ្ធទ្រង់បែរព្រះភ័ក្ត្រទៅរកយសត្ថេរ ហើយទ្រង់ងក់ព្រះសិរទទួលតាមការនិមន្តរបស់បិតាយស។

ក្នុងពេលនោះ ព្រះអរហន្ត៧អង្គ ក៏បានកើតមានឡើងក្នុងលោក។

លុះព្រឹកស្អែកឡើង ព្រះពុទ្ធនិងភិក្ខុសង្ឃទាំង៦អង្គ បានចូលទៅកាន់លំនៅរបស់គហបតី។ ពេលនិមន្តដល់ភិក្ខុសង្ឃទាំង៧អង្គត្រូវបានមាតាបិតាយសត្ថេរនិមន្តអោយគង់លើអាសនៈ ដែលបានក្រាលបំរុងទុកជាស្រេច។ មាតានិងអតីតភរិយា (បុរាណទុតិយាយិកា) របស់យសបាននាំគ្នាចូលទៅក្រាបថ្វាយបង្គំព្រះពុទ្ធនិងភិក្ខុសង្ឃទាំងឡាយ។ មាតាយសក៏យំខ្សឹកខ្សួល កាលបានឃើញនិងដឹងថាយសជាបុត្រាបានប្រកបដោយសេចក្តីសុខ។

មាតាបិតានិងអតីតភរិយារបស់ព្រះយស បានអង្គាសព្រះពុទ្ធ និងព្រះយសព្រមទាំង



ភិក្ខុសង្ឃទាំងអស់ដោយ ខាននីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ដោយដៃខ្លួនឯងដរាបណាឆ្អែតស្កប់ស្កល់ និងលែងលូកទៀត។

បន្ទាប់ពីទទួលភត្តរួចមក នៅពេលដែលគ្រួសារគហបតីអង្គុយក្នុងកន្លែង ដ៏សមគួរហើយ ព្រះពុទ្ធក៏ចាប់ផ្តើមសំដែងធម៌ដល់អ្នកទាំងឡាយនោះស្តាប់។ ព្រះអង្គសំដែងអំពីអនុបុព្វីកថាទាំង៥គឺ៖ ទានកថា១ សីលកថា១ សគ្គកថា១ ទោសនៃការប្រព្រឹត្តកាម១ និងអានិសង្សនៃការចេញបួស១។ ព្រះអង្គក៏បានសំដែងអំពីចតុរារិយសច្ចផងដែរ។ ជាពិសេស ព្រះពុទ្ធបានបង្រៀន សិក្ខាបទ៥ យ៉ាងដែលបង្កើតជាមូលដ្ឋាននៃការប្រតិបត្តិសំរាប់គ្រហស្ថ។ តើសិក្ខាបទគ្រហស្ថទាំង៥យ៉ាងនោះដូចម្តេចខ្លះ?

"ម្នាលអ្នកសប្បុរសទាំងឡាយ! មានសិក្ខាបទ៥យ៉ាងសំខាន់សំរាប់គ្រហស្ថយកទៅប្រតិបត្តិ ដើម្បីទទួលនូវសេចក្តីសុខកាយសប្បាយចិត្ត ក្នុងជីវិតរស់នៅរាល់ថ្ងៃ។ សិក្ខាបទទាំង៥ប្រការនោះគឺ៖

សិក្ខាបទទី១ គឺ បាណាតិបាត ឬហាមសម្លាប់សត្វ។ ឃើញថាសត្វលោកទាំងអស់ខ្លាចណាស់នូវសេចក្តីស្លាប់។ បើយើងបានយល់ដឹងអំពីមគ្គនៃពន្លឺត្រាស់ដឹងនិងសេចក្តីស្រឡាញ់ យើងនឹងប្រតិបត្តិតាមសិក្ខាបទនេះមិនលែងឡើយ។ យើងមិនគ្រាន់តែការពារនូវជីវិតផ្ទាល់ខ្លួនឯងជាមនុស្សប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវការពារជីវិតសព្វសត្វផងដែរ។ ប្រតិបត្តិតាមសិក្ខាបទនេះ នាំអោយយើងចំរើននូវ សេចក្តីមេត្តា និង បញ្ញា។

សិក្ខាបទទី២ គឺ អទិន្នាទាន ឬហាមលួចទ្រព្យអ្នកដទៃ។ យើងឥតមានសិទ្ធិលួចទ្រព្យអ្នកដទៃ និងមិនត្រូវលោភចង់មានដោយការកេងប្រវ័ញ្ចន៍លើកកម្លាំងគេឡើយ។ យើងគួររកមធ្យោបាយជួយអ្នកដទៃអោយចេះជួយខ្លួនឯងវិញប្រសើរជាង។

សិក្ខាបទទី៣ គឺ ការមេសុមិច្ឆាចារ ឬហាមប្រព្រឹត្តខុសនៅក្នុងផ្លូវកាម។ ហាមរំលោភលើភរិយា ស្វាមី និងកូនរបស់អ្នកដទៃ។

សិក្ខាបទទី៤ គឺ មុសាវាទ ឬហាមនិយាយកុហក។ យើងមិនត្រូវនិយាយពាក្យដែលប្រាសចាកសេចក្តីពិត ឬបង្ករអោយមានការបែកបាក់ និងស្អប់គុំគួនគ្នាឡើយ។ សូមកុំផ្សាយរឿងណាដែលអ្នកមិនបានឮផ្ទាល់នឹងត្រចៀក ឬឃើញពិតជាក់ស្តែងនឹងភ្នែករបស់អ្នកអោយសោះ។

សិក្ខាបទទី៥ គឺ សុរាមេរ័យ ឬហាមសេពសុរានិងមេរ័យ។ យើងមិនត្រូវផឹកសុរា និងគ្រឿងញៀនដែលនាំអោយខូចសុខភាពឬភ្លេចស្មារតីនិងជាហេតុនាំអោយមានទុក្ខ ឬគ្រោះថ្នាក់ដល់ខ្លួនឯងផង និងដល់អ្នកដទៃផង។

"ម្នាលអ្នកសប្បុរសទាំងឡាយ! បើលោកអ្នករស់នៅក្នុងគំនិត នៃសិក្ខាបទទាំង៥នេះ លោកអ្នកប្រាកដជាអាចចៀសផុតអំពីសេចក្តីទុក្ខ និងការរកាំរកូសសំរាប់ទាំងខ្លួនឯងផ្ទាល់ផង សំរាប់គ្រួសារផង និងសំរាប់មិត្តភក្តិទៀតផង។ ការប្រតិបត្តិតាមសិក្ខាបទទាំង៥ប្រការនេះ លោកអ្នកនឹងរកឃើញសុភមង្គល ក្នុងជីវិតកើនថែមឡើងទៀតរាប់មិនអស់។"

ពេលកំពុងស្តាប់ព្រះធម្មទេសនានេះ មាតារបស់ភិក្ខុយសចាប់អារម្មណ៍ហាក់ដូចជាមានទ្វារសុភមង្គល១ មកបើកប្រអប់បេះដូងរបស់គាត់ អោយបើកចំហឡើង។ គាត់មានចិត្តរំភើបរីករាយឥតឧបមា កាលបានដឹងថា ស្វាមីរបស់គាត់បានថ្វាយខ្លួនជាឧបាសករបស់ព្រះពុទ្ធរួចហើយ។ ភរិយារបស់យសនិងស្ត្រីបំរើបានយល់ និងជឿច្បាស់នូវអរិយសច្ចធម៌របស់ព្រះពុទ្ធ។ ស្ត្រីទាំងអស់បង្គំទូលព្រះពុទ្ធថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ព្រះពុទ្ធដីកាដែលព្រះអង្គបានត្រាស់ហើយនេះពីរោះពេកណាស់ ខ្ញុំព្រះអង្គទាំងអស់គ្នានេះ សូមដល់នូវព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃជាទីពឹងទីរលឹក សូមព្រះអង្គទ្រង់ជ្រាបនូវខ្ញុំព្រះអង្គទាំងឡាយថាជាឧបាសិការបស់ព្រះមានព្រះភាគចាប់តាំងអំពីថ្ងៃនេះតទៅ។"

ព្រះពុទ្ធទ្រង់ញញឹមទទួលដឹង យសមាតា យសភរិយា និងស្ត្រីបំរើគហបតីនោះដោយភាពកក់ក្តៅជាទីបំផុត។

ស្ត្រីទាំងអស់នោះបាននាមបញ្ញត្តិថាជា បឋមឧបាសិកា ឬ តេវាចិកាសរណគមន៍ក្នុងព្រះពុទ្ធសាសនាតាំងអំពីពេលនោះមក។

ព្រះពុទ្ធនិងភិក្ខុទាំង៦អង្គក៏ចំរើនពរលាគហបតីនិងគ្រួសារ រួចនិមន្តត្រឡប់ទៅកាន់អាស្រម នៅឯឥសិបតនមិគទាយវ័ននោះវិញ។



# សូមសមាទាន បញ្ចសីល (សីល៥)

១. បាណាតិបាតា វេរមណី សិក្ខាបទំ សមាទីយាមិ។
ប្រែថា៖ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតអោយធ្លាក់ចុះកន្លង គឺសម្លាប់សត្វ។

២. អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ។
ប្រែថា៖ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកវត្ថុដែលគេមិនបានអោយ។

៣. កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ។
ប្រែថា៖ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

៤. មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ។
ប្រែថា៖ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

៥. សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។
ប្រែថា៖ ខ្ញុំព្រះករុណា សូមដល់សិក្ខាបទគឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាថគឺផឹកនូវគ្រឿងស្រវឹងគឺសុរានិងមេរ័យ។

# ជំពូកទី ១៤
# ព្រះត្រៃសរណគមន៍

ដំណឹងស្ដីអំពីយសកុលបុត្តចូលបួសជាភិក្ខុ នៅក្នុងសំណាក់ព្រះសាស្ដាចារ្យបានឮសុះសាយយ៉ាងឆាប់រហ័សបំផុត ជាពិសេស ក្នុងបណ្ដាលមិត្តភក្ដិរបស់យសត្ថេរតែម្ដង។ មិត្តស្និទ្ធស្នាលនឹងភិក្ខុយសចំនួន៤នាក់ ដែលសុទ្ធសឹងជាបុត្រានៃត្រកូលសេដ្ឋីនិងអនុសេដ្ឋីក្នុងក្រុងពារាណសីគឺ៖ វិមល១ សុពាហុ១ បុណ្ណជិ១ និង គវម្បតិ១ កាលបានឮដំណឹងថាយសជាសំឡាញ់កោរសក់និងពុកមាត់ពុកចង្កាស្លៀកដណ្ដប់ដោយសំពត់កាសាយៈ(ចីវរ) ចេញទៅអំពីផ្ទះ និងចូលបួសក្នុងភេទនៃបុគ្គលមិនមានប្រយោជន៍ដល់ផ្ទះហើយក៏នាំគ្នាត្រិះរិះថាធម្មវិន័យដែលយសបព្វជ្ជានោះមិនមែនជាធម៌វិន័យថោកទាបឡើយ។ សំឡាញ់ទាំង៤នោះក៏សំរេចចិត្តបបួលគ្នាទៅជួបយសត្ថេរនៅឯព្រៃឥសតបនមិគទាយវ័ននោះ។

កាលបានជួបនឹងមិត្តសំឡាញ់ទាំង៤របស់លោកនៅក្នុងសួនម្រឹគរួចហើយ យសត្ថេរក៏នាំសំឡាញ់ទាំងនោះទៅថ្វាយបង្គំព្រះពុទ្ធថា៖

"បពិត្រព្រះអង្គដ៏ចំរើន! សំឡាញ់របស់ខ្ញុំព្រះអង្គ ជាគ្រហស្ថទាំង៤នាក់នេះឈ្មោះ វិមល១ សុពាហុ១ បុណ្ណជិ១ និង គវម្បតិ១ ក៏ជាបុត្រក្នុងត្រកូលសេដ្ឋីនិងអនុសេដ្ឋីក្នុងទីក្រុងពារាណសីដែរ។ មិត្រទាំង៤នៃខ្ញុំព្រះអង្គនេះសុទ្ធសឹងជាមនុស្សល្អជាទេ សូមទ្រង់ព្រះមេត្តាប្រោសជួយបើកភ្នែកដល់សំឡាញ់ នៃខ្ញុំព្រះអង្គទាំងអម្បាលនេះ អោយយល់នូវមាគ៌ានៃពន្លឺត្រាស់ដឹងផង។"

ព្រះពុទ្ធបានសំដែងនូវអនុបុព្វីកថានិងចតុរារិយសច្ចៈ ញ៉ាំងអ្នកទាំង៤នោះអោយបានមើលឃើញ បានដល់ បានត្រាស់ដឹង បានជឿស៊ប់ នូវអរិយសច្ចធម៌ឆ្លងកាត់ការមន្ទិលសង្ស័យ ឈប់ជឿបុគ្គលឯណា ក្រៅអំពីព្រះសាស្ដា ទើបនាំគ្នាក្រាបថ្វាយបង្គំព្រះពុទ្ធដោយពាក្យយ៉ាងនេះថា៖

"បពិត្រព្រះសាស្ដាដ៏ចំរើន! យើងខ្ញុំព្រះអង្គទាំង៤នាក់នេះ គួរបានបព្វជ្ជានិងឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគផង!"



ព្រះពុទ្ធទ្រង់អនុញ្ញាត ហើយទ្រង់ត្រាស់ថា៖

"ម្នាលអ្នកទាំងឡាយ! សាសនធម៌ព្រះពុទ្ធបានពោលល្អហើយ ចូរអ្នកទាំងឡាយនាំគ្នាប្រព្រឹត្តព្រហ្មចរិយធម៌ដើម្បីធ្វើនូវនិព្វានជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។"

បន្ទាប់មកព្រះពុទ្ធក៏ប្រៀនប្រដៅភិក្ខុថ្មីទាំង៤អង្គនោះ ដោយធម្មីកថា។ កាលបានស្ដាប់នូវធម្មីកថារួចហើយ ភិក្ខុថ្មីទាំង៤រូបក៏មានចិត្តចាកផុតអាសវៈទាំងពួង ឥតមានជាប់ជំពាក់ដោយឧបាទានទៀតឡើយ។

ដូច្នោះ ក្នុងកាលនោះ ព្រះអរហន្ត១១អង្គ ក៏បានកើតឡើងក្នុងលោក។

លំដាប់អំពីនោះមក មានមិត្តសំឡាញ់របស់យសត្ថេរ ចំនួន១២០នាក់ទៀតដែលជាអ្នករស់នៅក្នុងជនបទក្នុងត្រកូលផ្សេងៗក៏បានឮដំណឹងថា យសជាសំឡាញ់បានចូលបួសក្នុងសំណាក់ព្រះពុទ្ធដែរ។ អ្នកទាំង១២០នាក់នោះក៏នាំគ្នាត្រិះរិះតាមទំនងមិត្តរបស់យសទាំង៤នាក់ពីមុនដែរ រួចហើយក៏សំរេចចិត្តនឹងគ្នាថា ពួកយើងនឹងទៅជួបយសត្ថេរ ក្នុងវេលាព្រឹកស្អែកនេះតែម្ដង។

យសត្ថេរ កាលបានឮដំណឹងថាសំឡាញ់ទាំង១២០នាក់មកដល់ហើយក៏ចេញទៅចាំទទួលស្វាគមន៍នៅឯដើមផ្លូវ។ ពេលមិត្តសំឡាញ់ទាំងអស់មកដល់ យសត្ថេរក៏បានពន្យល់អំពីសេចក្ដីសំរេចចិត្តរបស់លោកក្នុងការចូលសាងផ្នួស រួចមកក៏អញ្ជើញមិត្តសំឡាញ់ទាំង១២០នាក់នោះ ទៅធ្វើសាវនាការផ្ទាល់នឹងព្រះពុទ្ធ។

ព្រះពុទ្ធទ្រង់ទទួលស្វាគមន៍ដល់អ្នកទាំងឡាយនោះ រួចហើយព្រះអង្គទ្រង់ចាប់ផ្ដើមសំដែង អំពីមាគ៌ាដែលអាចបញ្ចប់នូវសេចក្ដីទុក្ខ និងនាំទៅរកសេចក្ដីស្ងប់ និងសប្បាយរីករាយ។ ព្រះអង្គបាននិទាននូវការស្វែងរកអរិយសច្ចធម៌នេះដោយកម្រគឺតាំងអំពីព្រះអង្គនៅកុមារភាពម្ល៉េះ។ ព្រះពុទ្ធក៏បានសំដែងប្រាប់នូវអនុបុព្វីកថា និងចតុរារិយសច្ចៈ ព្រមទាំងញ៉ាំងអ្នកទាំង១២០នោះដោយធម្មីកថាប្រោសចាកនូវអាសវៈទាំងពួង ឥតមានជាប់ជំពាក់នឹងឧបាទានអ្វីទៀតឡើយ។

កាលបានយល់ច្បាស់នូវអរិយសច្ចធម៌នេះហើយ មាណពទាំង១២០នាក់ក៏មានចិត្តចង់សាងបព្វជ្ជានិងឧបសម្បទា។ ក្នុងចំណោមមាណពទាំង១២០នាក់នោះមានតែ៥០នាក់

ទេ ដែលបានសំរេចចិត្តចូលបួសតែម្តង។ ចំណែកឯ៧០នាក់ទៀតក៏មានប្រាថ្នាចង់បួសខ្លាំងណាស់ដែរ ប៉ុន្តែ មិនអាចចាកចោលការទទួលខុសត្រូវ ក្នុងបន្ទុកនៃគ្រួសារបានដោយបិតក្នុងឋានៈខ្លួនជាប្តី ជាឪពុក ឬជាបងប្រុស ជាដើម។

ឥឡូវនេះ ព្រះពុទ្ធមានព្រះអរហន្ត៦០អង្គ គង់នៅក្នុងឥសិបតនមិគទាយវ័នជាមួយនឹងព្រះអង្គហើយ។ ព្រះពុទ្ធសំរេចព្រះទ័យថានឹងគង់នៅទីនេះរវាង៣ខែទៅមុខទៀត ដើម្បីអប់រំភិក្ខុបួសថ្មីទាំងនោះអោយរឹតតែល្អប្រសើរឡើង។ ក្នុងគ្រានោះក៏មានគ្រហស្ថប្រុសស្រីជាច្រើនរយនាក់ បានចូលមកកាន់ឥសិបតនមិគទាយវ័ននេះ ដើម្បីសូមប្រគល់កាយថ្វាយខ្លួនធ្វើជាឧបាសកនិងឧបាសិកានៃព្រះមាព្រះភាគដែរ។

ព្រះពុទ្ធយល់យ៉ាងច្បាស់ នូវការទទួលខុសត្រូវក្នុងឋានៈជាព្រះសាស្តាចារ្យ។ ព្រះអង្គទទួលខុសត្រូវ និងណែនាំភិក្ខុទាំងឡាយ ទុកដូចជាបងប្អូនបង្កើត។ ព្រះអង្គរំលែកការទទួលខុសត្រូវជាមួយនឹងបញ្ចវគ្គីយភិក្ខុ។ ភិក្ខុកោណ្ឌញ្ញទទួលខុសត្រូវភិក្ខុក្មេងៗ១២០រូប។ ភិក្ខុភទ្ទិយៈ វប្បៈ មហានាម អស្សជិ ក្នុងមួយអង្គៗទទួលខុសត្រូវភិក្ខុក្មេងៗ១០រូប។ ភិក្ខុបួសថ្មីមានការរីកចំរើនយ៉ាងខ្លាំងក្នុងមាគ៌ាសិក្សាធម៌វិន័យ។

ដោយព្រះអង្គបានទតឃើញនូវការរីកដុះដាលខាងគំនិតប្រាជ្ញានៃពួកភិក្ខុទាំង៦០រូបនោះហើយ ព្រះពុទ្ធទ្រង់បើកនូវអង្គសន្និបាតមួយ ហើយទ្រង់ត្រាស់បញ្ជាក់ថា៖

"ម្នាលភិក្ខុទាំងឡាយ! យើងទាំងអស់គ្នាមានសេរីភាពបរិបូណ៌ហើយ យើងបានយល់ច្បាស់នូវមាគ៌ានៃពន្លឺត្រាស់ដឹងហើយ យើងបានរួចពីអន្ទាក់ទាំងអស់ហើយទោះជាអន្ទាក់របស់ទេវតាក្តីឬក៏មនុស្សលោកក្តី។ អ្នកទាំងឡាយ អាចត្រាច់ទៅកាន់ចារិកនៃស្រុកភូមិជនបទផ្សេងៗក្នុងឋានៈជាមនុស្សទំនេរ ហើយសំដែងនូវព្រហ្មចរិយធម៌ដែលអ្នកចេះចាំស្ទាត់នោះ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ និងដើម្បីអនុគ្រោះដល់ជនដ៏ច្រើន ដល់ទេវតានិងមនុស្សទាំងឡាយ។ ចូរអ្នកទាំងឡាយកុំទៅពីរនាក់ក្នុងផ្លូវតែមួយ (មួយផ្លូវមួយអង្គ)។ ចូរអ្នកសំដែងធម៌អោយពីរោះនូវបទខាងដើមបទកណ្តាល និង បទខាងចុង។ ចូរអ្នកទាំងឡាយប្រកាសនូវព្រហ្មចរិយធម៌ប្រកបដោយអត្ថន័យ និងព្យញ្ជនៈពេញបរិបូណ៌ ដើម្បីសត្វលោកទាំងឡាយដែលមានរាគាទិក្កិលេសតិច ឬក៏បំរុងនឹងត្រាស់ដឹងនោះ អោយបាន



ត្រាស់ដឹងផង។ ម្នាលភិក្ខុទាំងឡាយ! ចំណែកឯកតថាគតវិញដល់ពេលចេញវស្សាក៏នឹងទៅកាន់ឧរុវេលសេនានិគមដែលជាស្រុកកំណើតរបស់នាងសុជាតា ដើម្បីនឹងសំដែងធម៌ដែរ។ ប៉ុន្តែ មុននឹងទៅដល់ឧរុវេលនោះ តថាគតក៏ចង់ឆ្លៀតចូលទៅទស្សនាដើមពោធិព្រឹក្សនិងសួរសុខទុក្ខដល់ពួកកុមារនៅទីនោះផងដែរ។ លុះចេញពីឧរុវេលនោះមកវិញទើបតថាគតចូលទៅគាល់ព្រះបាទពិម្ពិសារ នៅឯក្រុងរាជគ្រឹះទៀត។"

បន្ទាប់ពីបានទទួលនូវពុទ្ធដីការបស់ព្រះសាស្តាចារ្យហើយ ភិក្ខុមួយចំនួនធំក៏គ្រងដោយស្បង់ចីវរនិងបាត្រនិមន្តចេញទៅផ្សព្វផ្សាយធម៌នៅតាមទីកន្លែងផ្សេងៗគ្នា។ ព្រះពុទ្ធនិងភិក្ខុ២០អង្គទៀត នៅគង់ចាំក្នុងឥសបតនមិគទាយវ័ននេះនៅឡើយ។

កាលបានស្តាប់នូវព្រហ្មចរិយធម៌ដែលភិក្ខុទាំងឡាយបានសំដែងហើយ មានពួកគ្រហស្ថជាច្រើនអំពីជនបទនិងទិសផ្សេងៗ ក្នុងនគរកាសីនិងមគធៈ បាននាំគ្នាសុំចូលសាងផ្នួសក្នុងសំណាក់ព្រះមានព្រភាគ។ អ្នកខ្លះសុំបួសជា សាមណេរ (បព្វជ្ជាបេក្ខបុគ្គល) និងអ្នកខ្លះសុំបួសជា ភិក្ខុ(ឧបសម្បាទាបេក្ខបុគ្គល) ហើយបុគ្គលម្នាក់ៗសុទ្ធតែគិតចង់បានទទួលការបំបួសផ្ទាល់អំពីព្រះពុទ្ធតែម្តង។ ដូច្នេះបញ្ហាលំបាកក្នុងការបំបួសក៏កើតមានឡើងដល់ព្រះអរហន្តផង ដល់បុគ្គលប្រាថ្នាបួសនោះផង។

"ម្នាលភិក្ខុទាំងឡាយ! តថាគតយល់ថា ពុំមែនជាការចាំបាច់អោយតថាគតបំបួសផ្ទាល់ នៅក្នុងឥសបតនមិគទាយវ័ននេះទេ។ ចាប់ពីពេលនេះតទៅ តថាគតអនុញ្ញាតអោយជនណា ដែលមានបំណងចង់បួសជាសាមណេរក្តី ជាភិក្ខុក្តី អាចធ្វើនៅតាមភូមិស្រុកនៃខ្លួនក៏បាន អោយតែនៅចំពោះមុខក្រុមគ្រួសារនិងញាតិមិត្ររបស់ខ្លួន។ តថាគតក៏មានចំណង់ចេញទៅផ្សាយធម៌ដូចអ្នកទាំងឡាយដែរ។ ដូច្នេះតពីនេះទៅ នៅពេលណាឬទីណាក៏ដោយ អោយតែអ្នកបានជួបនិងបុគ្គលណាដែលមានចិត្តប្រាថ្នាចង់សាងបព្វជ្ជានិងឧបសម្បាទា ចូរអ្នកទាំងឡាយបំបួសចុះ!"

កោណ្ឌញ្ញភិក្ខុក្រោកឈរឡើង ហើយបង្គំទូលសួរថា៖

"បពិត្រព្រះសាស្តាចារ្យដ៏ចំរើន! សូមព្រះអង្គបង្ហាញដល់ខ្ញុំព្រះអង្គទាំងឡាយនូវក្បួនសំរាប់រៀបចំពិធីសាងបព្វជ្ជានិងឧបសម្បទានេះផងចុះ។ អំណើះតទៅ ខ្ញុំព្រះអង្គទាំងឡាយ

នឹងប្រារព្ធពីធីបំបួសនេះដោយខ្លួនឯង។"

ព្រះពុទ្ធទ្រង់ត្រាស់បញ្ជាក់ថា៖

"ម្នាលកោណ្ឌញ្ញ! ចូរអ្នកធ្វើតាមទម្លាប់ដែលតថាគតតែងបានប្រតិបត្តិពីមុនមកនោះទៅ បានហើយ។"

អស្សជិភិក្ខុស្ទុះក្រោកឈរឡើង ហើយបង្គំទូលសួរព្រះពុទ្ធថា៖

"បពិត្រព្រះមហាសាស្តាជាទីគោរព! វត្តមានរបស់ព្រះមានព្រះភាគមានសារៈសំខាន់ណាស់ ព្រះអង្គពុំចាំបាច់ធ្វើពិធីនេះជាផ្លូវការក៏បានដែរ។ ក៏ប៉ុន្តែចំពោះពួកខ្ញុំព្រះអង្គវិញ ត្រូវតែធ្វើពិធីបព្វជ្ជានិងឧបសម្បទានេះ អោយទៅជាផ្លូវការទើបបាន។ មើល៍អាវុសោកោណ្ឌញ្ញ! បើតាមខ្ញុំយល់ អាវុសោប្រហែលជាអាចជួយផ្តល់នូវរូបមន្តនៃការបំបួសនេះបាន ទាន់ព្រះមានព្រះភាគលោកគង់នៅទីនេះជាមួយពួកយើង ព្រះអង្គនឹងជួយបន្ថែមទៅលើយោបល់របស់អាវុសោ អោយបានសមរម្យ។"

កោណ្ឌញ្ញភិក្ខុគង់នៅស្ងៀមមួយស្របក់ ទើបមានពុទ្ធដីកាថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គគិតថា ជំហានដំបូងបុគ្គលអ្នកសាងបព្វជ្ជានិងឧបសម្បទា ត្រូវកោរសក់ និងពុកមាត់ពុកចង្កា។ បន្ទាប់មក អ្នកទាំងនោះត្រូវហាត់រៀននូវរបៀបគ្រងស្បង់ចីវរ។ បន្ទាប់ពីរៀនគ្រងស្បង់ចីវររួចមក អ្នកនោះអាចបញ្ចេញស្មាខាងស្តាំក្នុងរបៀបធម្មតា ហើយលុតជង្គង់ចុះចំពោះព្រះភ័ក្ត្រគ្រូឧបជ្ឈាយ៍ដែលជាតំណាងព្រះពុទ្ធ។ អ្នកសាងផ្នួស ត្រូវលើកដៃទាំងពីរប្រណម្យសំពះដូចជាផ្កាឈូកក្រពុំ ហើយសូត្រនូវពាក្យនេះថា ៖

**"ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹក៖**

**ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹក៖**

**ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក៖"**

បន្ទាប់អំពីបានសូត្រតាមព្រះត្រៃសរណគមន៍ទាំងនេះចប់ហើយ បុគ្គលអ្នកសាងផ្នួសនោះ ក៏បានក្លាយខ្លួនជាភិក្ខុពេញលក្ខណៈក្នុងគណៈនៃភិក្ខុសង្ឃ។ បពិត្រព្រះអង្គដ៏ចំរើន! នេះគ្រាន់តែជាការថ្វាយយោបល់ដ៏ស្តួចស្តើងនៃខ្ញុំព្រះអង្គប៉ុណ្ណោះ។ សូមព្រះសាស្តាទ្រង់



ព្រះមេត្តាប្រោស ជួយកែសំរួលតាមការគួរអោយទានផង។"

ព្រះពុទ្ធក៏ត្រាស់បញ្ជាក់បន្ថែមថា៖

"យោបល់នេះប្រសើរថ្លៃថ្លាណាស់អាវុសោកោណ្ឌញ្ញ! ប៉ុន្តែ ភិក្ខុបំរុងនោះត្រូវសូត្រនូវព្រះត្រៃសរណគន៍នេះ ជាគំរប់២ដងផងនិងជាគំរប់៣ដងផងនៅពេលលុតជង្គង់ចំពោះព្រះភ័ក្ត្រគ្រូឧបជ្ឈាយ៍។ ធ្វើតែប៉ុណ្ណោះជាការគ្រប់គ្រាន់ក្នុងការក្លាយខ្លួនជាភិក្ខុពេលសិទ្ធិហើយ។ ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាតនូវបព្វជ្ជា និងឧបសម្បទា ដោយព្រះត្រៃសរណគមន៍នេះហើយ។"

ភិក្ខុសង្ឃទាំងឡាយនោះ មានសេចក្តីសប្បាយរីករាយជាខ្លាំង ចំពោះសេចក្តីអនុម័តរបស់ព្រះមានព្រះភាគនេះ។

នៅពេលចេញវស្សា ព្រះពុទ្ធទ្រង់ត្រាស់នឹងភិក្ខុសង្ឃទាំងឡាយថា៖

"ម្នាលភិក្ខុទាំងឡាយ! អរហត្តផលវិមុត្តិ ដ៏ប្រសើរតថាគតបានសំរេចហើយតថាគតបានធ្វើអោយជាក់ច្បាស់ហើយ បានធ្វើទុកក្នុងចិត្តដោយសេចក្តីព្យាយាមរួចហើយ។ ចំណែកអ្នកទាំងឡាយវិញក៏បានសំរេច ក៏បានធ្វើអោយជាក់ច្បាស់ ក៏បានធ្វើទុកក្នុងចិត្តដោយសេចក្តីព្យាយាមនូវអរហត្តផលវិមុត្តិដ៏ប្រសើរហើយដែរ។"

ព្រះពុទ្ធគង់នៅក្នុងឥសិបតនមិគទាយវ័ន នាក្រុងពារាណសីនេះ គួរសមដល់ពុទ្ធអធ្យាស្រ័យហើយ ទើបទ្រង់ប្រដាប់ដោយស្បង់ចីវរនិងបាត្រ យាងចេញទៅកាន់ឧរុវេលនិគម មុននឹងព្រះអង្គយាងទៅកាន់ក្រុងរាជគ្រឹះ។

**"ព្រះរតនត្រ័យ វិសេសថ្លៃបីប្រការ ដែលមនុស្សនិងទេព្តា តែងបូជាគ្រប់ទីឋាន។**
**ទី១ព្រះសម្ពុទ្ធ បញ្ញាមុតអនន្តញាណ ព្រះធម៌ទុកដូចយាន នាំសត្វបានជាទីពីរ។**
**ព្រះសង្ឃបរិសុទ្ធ វិសេសផុតស្ងប់ឥន្ទ្រីយ៍ ជួយអង្គព្រះមុនី គ្រប់ទិសទីជាទីបី។**
**អ្នកដល់រតនត្រ័យ ផុតទុក្ខភ័យមានសិរីចាប់តាំងពីលោកិយរៀងដរាបដល់និព្វាន។**
**កុំគប្បីប្រមាទ ត្រូវសង្វាតខំសូត្ររៀន ធម៌អាថ៌ព្រះទ្រង់ញាណ កុំបីខានគ្រប់ៗគ្នា។**
**នាំគ្នាបដិបត្តិ រៀងរាល់រត្តិទិវា ជោគជ័យសិរីសុខា ឈ្នះមារាគ្រប់គ្នាហោង។"**

**ភិក្ខុ និង ភេន ឥន្ទប្បញ្ញោ**

សូមសមាទាន **ព្រះត្រៃសរណគមន៍**

| | |
|---|---|
| ពុទ្ធំ សរណំ គច្ឆាមិ។ | ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក។ |
| ធម្មំ សរណំ គច្ឆាមិ។ | ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរលឹក។ |
| សង្ឃំ សរណំគច្ឆាមិ។ | ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក។ |

| | |
|---|---|
| ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ។ | ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹក ជាគំរប់២ដងផង។ |
| ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ។ | ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹក ជាគំរប់២ដងផង។ |
| ទុតិយម្បិ សង្ឃំ សរណំ គិច្ឆាមិ។ | ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក ជាគំរប់២ដងផង។ |
| តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ។ | ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹក ជាគំរប់៣ដងផង។ |
| តតិយម្បិ ធម្មំ សរណំ គិច្ឆាមិ។ | ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹក ជាគំរប់៣ដងផង។ |
| តតិយម្បិ សង្ឃំ សរណំ គិច្ឆាមិ។ | ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក ជាគំរប់៣ដងផង។ |



# ជំពូកទី ១៥
# មាណព៣០នាក់សាងបព្វជ្ជា

មុននឹងព្រះអង្គយាងដល់ក្រុងរាជគ្រឹះ ព្រះពុទ្ធត្រូវឆ្លងកាត់ព្រៃធំមួយនៅតាមដងផ្លូវ។ ព្រះអង្គបានជួបជាមួយយុវជនចំនួន៣០រូប (ភទ្ទវគ្គិយកុមារ) កំពុងច្រៀងរាំកំសាន្តក្នុងព្រៃធំនោះ។ បន្ទាប់អំពីបានស្តាប់ការទូន្មានរបស់ព្រះមានព្រះភាគហើយយុវជនទាំង៣០រូបក៏សំរេចចិត្តសុំបួសជាភិក្ខុ ក្នុងសំណាក់ព្រះអង្គនៅក្នុងព្រៃនោះតែម្តង។

ព្រះពុទ្ធធ្លាប់យាងតាមផ្លូវពីពារាណសីទៅកាន់មគធៈនេះពីមុនមកដែរ។ ព្រះអង្គយាងលំហែតាមដងព្រៃនិងវាលស្រែ។ ពេលនេះ ព្រះអង្គបានឈប់បិណ្ឌបាតក្នុងភូមិតូចមួយតាមដងផ្លូវ និងយកចង្ហាន់បិណ្ឌបាតនោះទៅឆាន់ដោយស្ងៀមស្ងាត់នៅក្នុងព្រៃមួយ លុះឆាន់រួចហើយក៏ទ្រង់គង់ភាវនានៅទៀបនឹងគល់ឈើមួយ។

បន្ទាប់ពីព្រះអង្គគង់ភាវនា អស់រយៈមួយសន្ទុះធំមក មានមាណពមួយក្រុមស្លៀកពាក់យ៉ាងស្រស់សង្ហារ ដើរកាត់ពីមុខព្រះភ័ក្ត្រព្រះអង្គ ហាក់បីដូចជាមានរឿងអ្វីមួយកើតឡើយ។ យុវជនភាគច្រើនបានកាន់ឧបករណ៍ភ្លេងជាប់នឹងដៃ។ កាលបានឃើញព្រះពុទ្ធគង់ទៀបគល់ឈើនោះ យុវជនទាំងអស់ក៏ចូលទៅថ្វាយបង្គំ និងសាកសួរព្រះអង្គជាពាក្យយ៉ាងនេះថា៖

"បពិត្រព្រះសមណៈ! តើព្រះអង្គបានឃើញស្រីម្នាក់រត់មកតាមនេះឬទេ?"

ព្រះពុទ្ធមិនបានឆ្លើយទេ ព្រះអង្គបែរជាត្រាស់សួរវិញថា៖

"ហេតុអ្វីក៏អ្នករាល់គ្នាត្រូវការតាមរកស្រីនោះ?"

យុវជនទាំងនោះ ក៏ថ្លែងរៀបរាប់នូវរឿងរបស់ពួកគេ ចាប់តាំងអំពីដើមទីមកដើម្បីព្រះពុទ្ធទ្រង់ព្រះសណ្តាប់។

យុវជនទាំងអស់មកពីក្រុងពារាណសី ពួកគេនាំគ្នាដើរកំសាន្តនៅក្នុងព្រៃធំនេះ តាំងពីព្រឹកព្រលឹមម្ល៉េះ។ យុវជនទាំង៣០នាក់នោះ សុទ្ធសឹងជាអ្នកមានភរិយាលើកលែងតែយុវជនម្នាក់នៅលីវ។ ដើម្បីអោយមានស្រីកំដរដូចជាខ្លួនដែរ យុវជន២៩រូបទៀតក៏បានទៅជួលស្រីផ្កាមាសម្នាក់ដែលចេះច្រៀងរាំផងនោះ អោយមកកំដរយុវជននៅលីវនោះ។ យុវជនទាំង៣០នាក់នាំគ្នាស៊ីផឹករាំរែកជាមួយភរិយានិងស្រីអញ្ជនកចម្រៀងក្មេងនោះយ៉ាង

សប្បាយ។ លុះល្មមស្កប់ស្កល់ហើយ ក៏បបួលគ្នាដេកសំរាកយកកម្លាំងនៅក្រោមម្លប់ឈើ។ ក៏ប៉ុន្តែដល់ពេលក្រោកឡើងទើបពួកគេដឹងថាស្រីរបាំនោះបានលួចយកបង្វិច ភណ្ឌៈ(គ្រឿងអលង្ការ)របស់ពួកគេនិងរត់គេចខ្លួនបាត់ទៅ។

ពួកយុវជនទាំងនោះបាននាំគ្នាស្រែកឆោឡោឡើង ហើយនាំគ្នាដេញតាមរកស្រីនោះ រហូតមកបានជួបនឹងព្រះពុទ្ធដែលកំពុងគង់ភាវនាទៀបគល់ឈើនោះឯង។

ព្រះពុទ្ធទតទៅកាន់យុវជនទាំងនោះដោយស្ងាត់ស្ងៀម ហើយទ្រង់ត្រាស់ថា៖

"ម្នាលអ្នកទាំងឡាយ! ចូរអ្នកនិយាយប្រាប់តថាគតមកមើល៍ ក្នុងពេលនេះតើអ្នកគួរតាមរកស្រីនោះ ឬក៏អ្នកគួរតាមរកខ្លួនអ្នកផ្ទាល់វិញប្រសើរជាង?"

យុវជនទាំងអស់ស្រឡាំកាំង។ អាការៈដ៏ស្រស់ប្រិមប្រិយ៍របស់ព្រះពុទ្ធ និងសំនួរមិនធម្មតារបស់ព្រះអង្គបានធ្វើអោយអ្នកទាំងនោះគិតត្រឡប់មករកខ្លួនឯងវិញ។

មានយុវជនម្នាក់ឆ្លើយឡើងថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ប្រហែលជាពួកយើងខ្ញុំត្រូវស្វែងរក ខ្លួនឯងជាមុនសិនហើយទើបប្រសើរជាង!"

ព្រះពុទ្ធទ្រង់ត្រាស់បន្តថា៖

"ម្នាលអ្នកទាំងឡាយ! បើដូច្នោះចូរអ្នកអង្គុយចុះសិនមក តថាគតនឹងសំដែងធម៌អោយស្តាប់។"

ពួកយុវជនទាំងនោះលើកដៃប្រណម្យ និងទទួលព្រះពុទ្ធដីកាថា៖

"បពិត្រព្រះអង្គ! សូមទ្រង់សំដែងមកចុះ ខ្ញុំព្រះអង្គទាំងឡាយនឹងស្តាប់។"

ព្រះពុទ្ធទ្រង់សំដែងថា៖

"ម្នាលអ្នកទាំងឡាយ! ជីវិតអាចរកឃើញតែក្នុងពេលបច្ចុប្បន្នប៉ុណ្ណោះ ប៉ុន្តែយើងក៏នៅមានគំនិតបន្តិចបន្តួចដែរ នៅក្នុងបច្ចុប្បន្ននេះ ជំនួសយើងនាំគ្នាប្រដេញតាមរកអតីតកាលឬក៏នៅរង់ចាំអនាគតកាល។ បើយើងគិតថា យើងត្រូវគិតតែអំពីខ្លួនឯងបានហើយ ប៉ុន្តែតាមពិត យើងស្ទើរមិនទាំងដែលបានគិតដល់រឿងផ្ទាល់ខ្លួនឯងតែម្តងសោះផងក៏មាន។ គំនិតរបស់យើងក៏ដូច្នោះដែរ រវល់តែប្រដេញតាមការនឹកឃើញពីម្សិលមិញ ឬការ



ស្រមៃឃើញនៅថ្ងៃស្អែកទៅវិញ។ មធ្យោបាយតែមួយគត់ ដែលយើងត្រូវគិតដល់ជីវិត គឺយើងត្រូវតែត្រឡប់មករកបច្ចុប្បន្នកាលនេះវិញ។ ពេលណាដែលអ្នកដឹងថា យ៉ាងដូចម្តេចដែលអ្នកត្រូវត្រឡប់ទៅរកបច្ចុប្បន្នកាលវិញនោះ ពេលនោះហើយដែលអ្នកបានក្លាយទៅជាមនុស្សភ្ញាក់រលឹក និង ពេលនោះហើយដែលអ្នកបានរកឃើញខ្លួនអ្នកពិត។"

ព្រះពុទ្ធក៏ចាប់ផ្តើមសំដែងនូវអនុបុព្វីកថាមានៈទានកថា សីលកថា សគ្គកថា ទោសនៃការសេពកាម និងអានិសង្សនៃការចេញសាងផ្នួស។ ដោយទ្រង់ទតឃើញយុវជនទាំង៣០នាក់(ភទ្ទវគ្គិយកុមារ) នោះមានចិត្តទន់ មានចិត្តជ្រះថ្លា ក៏ព្រះអង្គបន្តសំដែងនូវចតុរារិយសច្ចៈ និង អដ្ឋង្គមគ្គៈ អោយស្តាប់បន្ថែមទៀត។ យុវជនទាំង៣០នាក់ក៏បានឃើញ បានដល់ បានត្រាស់ដឹង បានជឿស៊ប់នូវអរិយសច្ចធម៌ ឆ្លងផុតអំពីសេចក្តីមន្ទិលសង្ស័យ ឈប់ជឿបុគ្គលឯណាក្រៅអំពីព្រះសាស្តាឡើយ ទើបនាំគ្នាថ្វាយបង្គំព្រះពុទ្ធជាពាក្យយ៉ាងនេះថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គទាំងឡាយគួរដល់នូវបព្វជ្ជានិងឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគ ក្នុងគ្រានេះឯង។"

ព្រះពុទ្ធទ្រង់ត្រាស់នឹងភទ្ទវគ្គិយកុមារនោះថា៖

"ម្នាលភទ្ទវគ្គិយកុមារទាំងឡាយ! ចូរអ្នកទាំងឡាយមកជាភិក្ខុចុះ! សាសនធម៌ព្រះពុទ្ធបានសំដែងល្អហើយ ចូរអ្នកទាំងឡាយប្រព្រឹត្តនូវព្រហ្មចរិយធម៌នេះដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខ ដោយប្រពៃចុះ។ ព្រះពុទ្ធដីកានេះហើយជាបព្វជ្ជានិងឧបសម្បទារបស់អ្នកដែលជាភទ្ទវគ្គិយភិក្ខុនេះ។"

ព្រះពុទ្ធទ្រង់បង្គាប់អោយពួកភទ្ទវគ្គិយភិក្ខុទាំងនោះ ធ្វើដំណើរតាមផ្លូវទៅកាន់ឥសិបតនមិគទាយវ័ន ដើម្បីនឹងទទួលការប្រៀនប្រដៅនូវព្រហ្មចរិយធម៌បន្ថែមទៀតពីព្រះអញ្ញាកោណ្ឌញ្ញភិក្ខុ។ ព្រះពុទ្ធទ្រង់ផ្តាំនឹងភទ្ទវគ្គិយភិក្ខុទាំងនោះថាព្រះអង្គនឹងវិលមកជួបអ្នកទាំងអស់វិញ ក្នុងពេលឆាប់ៗ។

រាត្រីនោះ ព្រះពុទ្ធសិងតែមួយព្រះអង្គឯងនៅក្នុងព្រៃនោះ។ ព្រឹកស្អែកឡើងទើបព្រះអង្គយាងឆ្លងទន្លេគង្គាឆ្ពោះទៅទិសខាងកើត។ ព្រះអង្គចង់ចូលទៅសួរសុខទុក្ខក្មេងៗទាំង

អស់នៅឯងឧរុវេលសេនានិគមសិន មុននឹងព្រះអង្គបន្តពុទ្ធដំណើរឆ្ពោះទៅកាន់ក្រុងរាជគ្រឹះ ដើម្បីចូលគាល់ព្រះបាទពិម្ពិសារមគធរាជ។

"កុំប្រព្រឹត្តអំពើបាប ចូរសាបព្រោះបណ្តុះអំពើល្អ
ចូរធ្វើចិត្តអោយបានបរិសុទ្ធ នេះគឺជាពុទ្ធោវាទ។"
ធម្មបទភាគ ១៨៣

---

# ជំពូកទី១៦
# ឧរុវេលកស្សបបព្វជ្ជា

៧ថ្ងៃក្រោយមក ព្រះពុទ្ធសព្វព្រះទ័យយ៉ាងខ្លាំង ដោយព្រះអង្គបានមកដល់ដើមពោធិព្រឹក្ស។ ពីយប់មិញព្រះពុទ្ធទ្រង់សិងនៅទីនេះ លុះដល់ព្រឹកឡើងព្រះអង្គបានវូមវាក់ជាមួយសោត្ថិយកុមារ នៅលើមាត់ស្ទឹងនេរញ្ជរា។ ព្រះពុទ្ធបានសំណេះសំណាលជាមួយសោត្ថិយកុមារអស់ពេលយ៉ាងយូរ ហើយព្រះអង្គបានជួយច្រូតស្មៅសោត្ថិហកុមារ មុននឹងទ្រង់យាងចេញទៅបិណ្ឌបាត្រ។

ស្អែកឡើងពេលរសៀល សោត្ថិយកុមារបាននាំបងប្អូននិងនាងសុជាតាក៏បាននាំមិត្តភ័ក្តិមកបង្គំគាល់ព្រះពុទ្ធ។ កុមារទាំងឡាយសប្បាយរីករាយជាខ្លាំង កាលបានជួបនឹងព្រះពុទ្ធម្តងទៀត។ កុមារទាំងនោះ បានយកចិត្តទុកដាក់ស្តាប់ព្រះពុទ្ធនិទានអំពីហេតុការណ៍ប៉ុន្មានឆ្នាំរបស់ព្រះអង្គកន្លងមកនេះ។ ព្រះពុទ្ធបានសន្យានឹងសោត្ថិយកុមារថា បើកាលណាសោត្ថិយអាយុគំរប់២១ឆ្នាំព្រះអង្គនឹងទទួលបំបួសជាភិក្ខុ។ ទំរាំដល់ពេលនោះ ប្អូនស្រីទាំងអស់និងប្អូនប្រុសម្នាក់របស់សោត្ថិយ ធំល្មមជួយខ្លួនឯងបានហើយ។

កុមារទាំងឡាយក្រាបបង្គំទូលព្រះពុទ្ធថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ក្នុងរវាងពីរបីខែកន្លងមកនេះ មានមជ្ឈមណ្ឌលសាសនាមួយដែលដឹកនាំដោយព្រាហ្មណ៍ម្នាក់ឈ្មោះ ឧរុវេលកស្សប បានកើតឡើងនៅជិតឧរុវេលនិគមនេះ។ ជដិលព្រហ្មណ៍ ជាប្រធានដឹកនាំនោះ មានបរិវារទាំងអស់ចំនួន៥០០នាក់។



ពួកជដិលទាំងនោះមិនកោរសក់ដូចភិក្ខុសង្ឃទេ គេបួងសក់មួយកណ្តុបចំពីលើក្បាល និងពួកគេនាំគ្នាគោរព អាទិទេពភ្លើង។"

ព្រឹកស្អែកឡើង ព្រះពុទ្ធយាងឆ្លងទៅកាន់ត្រើយម្ខាងនៃស្ទឹងនេរញ្ជរា រួចមកក៏ទ្រង់បានជួបនឹងអាស្រមរបស់ជដិលឧរុវេលកស្សបនោះ។ បរិស័ទទាំងអស់របស់ជដិលព្រហ្មណ៍នោះរស់នៅក្នុងខ្ទមប្រក់ស្លឹកឈើ និងស្លៀកពាក់ខោអាវដែលធ្វើអំពីសំបកឈើ។ ពួកជដិលទាំងឡាយនោះ មិនដែលចូលទៅបិណ្ឌបាតនៅក្នុងភូមិអ្នកស្រុកឬក៏ទទួលដង្វាយអំពីអ្នកស្រុកអ្នកភូមិណាឡើយ។ ពួកគេនាំគ្នាចិញ្ចឹមសត្វសំរាប់តែកាប់យកសាច់ធ្វើជាម្ហូបអាហារ និងសំរាប់បូជាយ័ញ្ញប៉ុណ្ណោះ។

លំដាប់នោះ មានសាវករបស់ឧរុវេលកស្សបម្នាក់បានជួបនឹងព្រះពុទ្ធ ហើយបានបង្គំទូលព្រះអង្គថា៖

"បពិត្រព្រះសមណៈដ៏ចំរើ! ឧរុវេលកស្សបគឺជាប្រធានដឹកនាំដ៏ឧត្តម និងជាអ្នកមានជំនឿយ៉ាងមុតមាំ ក្នុងសាសនាវេទ ហើយព្រះអង្គជាអ្នករស់នៅ ក្នុងជីវិតមានគុណធម៌ដ៏ខ្ពង់ខ្ពស់ជាទីបំផុត។"

ជដិលព្រាហ្មណ៍នោះក៏បានបញ្ជាក់ដល់ព្រះពុទ្ធថា៖

"បពិត្រព្រះសមណៈដ៏ចំរើន! លោកប្រធានឧរុវេលកស្សបមានប្អូនប្រុសពីរនាក់ទៀតដែលជាប្រធានដឹកនាំគណៈគោរពបូជាព្រះអាទិទេពដូចគ្នាដែរ។ ជដិលជាបងប្អូននឹងគ្នាទាំងបីរូបនេះមានជំនឿថាភ្លើងជា សភាវៈដើមបំផុតនៃពិភពលោក។ ជដិលឧរុវេលកស្សបស្រឡាញ់ពេញចិត្តចំពោះប្អូនប្រុសទាំងពីរនៃខ្លួនយ៉ាងខ្លាំង។ នទីកស្សប ជាប្រធានដឹកនាំជដិលជាបរិវារ ចំនួន៣០០រូប នៅតាមបណ្តោយដងស្ទឹងនេរញ្ជរា (បើដើរពីឧរុវេលនេះទៅត្រូវអស់ពេលមួយថ្ងៃ សំដៅទៅទិសខាងជើង)។ ប្អូនប្រុសម្នាក់ទៀតឈ្មោះ គយាកស្សបជាប្រធានដឹកនាំ ជដិលជាបរិវារចំនួន ២០០រូប នៅ ក្បាលកោះគយា។"

សាវករបស់ឧរុវេលកស្សប ក៏បាននិមន្តព្រះពុទ្ធចូលទៅគង់ក្នុងខ្ទមនៃគ្រូរបស់ខ្លួន ដើម្បីព្រះពុទ្ធបានធ្វើសាវនាការជាមួយ។ សូម្បីតែគាត់មានអាយុច្រើនណាស់ហើយក៏ដោយ ក៏ឧរុវេលកស្សបនៅរហ័សរហួននិងមានស្មារតីវាងវៃដែរ។ នៅពេលឃើញអាការៈ

មិនធម្មតារបស់ព្រះពុទ្ធមុនដំបូងឧរុវេលកស្សបចាប់សង្ស័យភ្លាមហើយសុខចិត្តទទួលព្រះអង្គក្នុងឋានៈជាភ្ញៀវកិត្តិយស។ ឧរុវេលកស្សបបាននិមន្តព្រះពុទ្ធគង់នៅលើអង្គត់ឈើមួយនៅខាងមុខអាស្រមហើយទាំងពីរព្រះអង្គក៏ចាប់ផ្តើមពិភាក្សានិងសំណេះសំណាលគ្នាអស់ពេលយ៉ាងយូរ។ ឧរុវេលកស្សបបានកោតស្ញប់ស្ញែងនូវការចេះដឹងយ៉ាងជ្រៅជ្រះរបស់ព្រះពុទ្ធ ផ្នែកខាងសាសនាវេទ។ ព្រះពុទ្ធបានជួយពន្យល់ដល់ឧរុវេលកស្សបនូវដំណើររឿងជ្រៅៗជាច្រើនក្នុង គម្ពីរអត្ថវេទ និង គម្ពីររាជវេទ ដែលឧរុវេលកស្សបគិតថាគាត់ចេះដឹងអស់ហើយ ក៏ប៉ុន្តែតាមពិត គាត់មិនទាន់ចាប់សេចក្តីបាននៅឡើយ។ ឧរុវេលកស្សបមានចម្ងល់ខ្លាំង ត្រង់បានឃើញព្រះសង្ឃក្មេងនេះចេះដឹងស្ទាត់ខាងទ្រឹស្តីប្រវត្តិសាស្ត្រនិងរបៀបធ្វើបុណ្យទានានារបស់ពួកព្រាហ្មណ៍។

នៅក្នុងវេលាថ្ងៃត្រង់នោះ ព្រះពុទ្ធបានទទួលសេចក្តីយាងអំពីឧរុវេលកស្សបដើម្បីទទួលភត្តជាមួយ។ ព្រះពុទ្ធទ្រង់បានបត់ស្បង់ចីវរយ៉ាងស្អាតធ្វើជាទ្រនាប់គង់ពីលើ និងទ្រង់ទទួលភត្តក្នុងសភាពពិចារណាយ៉ាងស្ងាត់ស្ងៀម។ ឧរុវេលកស្សបចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះសភាពស្ងប់ស្ងៀមរបស់ព្រះពុទ្ធក្នុងពេលព្រះអង្គសោយព្រះស្ងោយ ហើយដែលឧរុវេលកស្សបខ្លួនឯងមិនអាចធ្វើទៅកើត។

នៅពេលក្រោយភត្ត ទាំងពីរព្រះអង្គក៏បន្តការពិភាក្សាតទៅទៀត។ ព្រះពុទ្ធទ្រង់ត្រាស់សួរទៅឧរុវេលកស្សបថា៖

"ម្នាលឧរុវេលកស្សប! តើព្រះអង្គអាចពន្យល់តថាគត ថាតើការគោរពបូជា។ ភ្លើង អាចដឹងនាំមនុស្សអោយរួចផុតពីសេចក្តីទុក្ខយ៉ាងដូចម្តេចខ្លះ?"

ឧរុវេលកស្សបមិនឆ្លើយតបភ្លាមទេ។ គាត់បានដឹងយ៉ាងច្បាស់ថាការឆ្លើយសើរៗឬធម្មតា ប្រាកដជាមិនអាចគ្រប់គ្រាន់ ចំពោះព្រះសង្ឃដ៏ក្មេងចម្លែកនេះបានឡើយ។ ឧរុវេលកស្សបបែរជាព្យាយាមពន្យល់ថា ភ្លើងគឺជាសារវន្តដើមនៃពិភពលោកទៅវិញ។ ភ្លើងមានប្រភពរបស់វាចេញមកពីព្រះព្រហ្ម។ ភ្លើងទុកជាទីសក្ការបូជានិងឆេះជាប់ជានិច្ចក្នុងរោងភ្លើង។ ភ្លើងខ្លួនឯងគឺជានិមិត្តរូបនៃព្រះព្រហ្ម។ ក្នុងគម្ពីរអត្ថវេទនិយាយអំពីការបូជាភ្លើង។ ភ្លើងគឺជាជីវិត។ ទីណាគ្មានភ្លើងទីនោះក៏គ្មានជីវិត។ ភ្លើងជាពន្លឺជាកំដៅ និងជា



ប្រភពនៃព្រះអាទិត្យដែលជួយអោយរុក្ខជាតិ សត្វ និងមនុស្សរស់រានមានជីវិតបាន។ ភ្លើងកំចាត់បង់នូវភាពងងឹត ឈ្នះភាពត្រជាក់និងនាំមកនូវសេចក្តីសប្បាយ ព្រមទាំងភាពភ្លៀវក្លាដល់សព្វសត្វ។ ម្ហូបអាហារក៏ត្រូវតែចំអិនដោយសារភ្លើង។ ដោយសារភ្លើងមនុស្សនឹងបានជួបជុំគ្នាឡើងវិញជាមួយព្រះព្រហ្មគឺជាភ្លើងនេះឯងនៅពេលស្លាប់។ អាទិទេពភ្លើងឈ្មោះថា "ព្រះអគ្គី" គឺជាអាទិទេពមួយក្នុងចំណោមអាទិទេពរាប់ពាន់នៃព្រះព្រហ្ម។ នៅលើសសរក្នុងរោងភ្លើង ព្រះអគ្គីមានចម្លាក់ក្បាលពីរ។ ក្បាលមួយ គឺជាតំណាងនៃភ្លើងដែលយើងប្រើរាល់ថ្ងៃ និងក្បាលមួយទៀតគឺជាតំណាងនៃភ្លើងសំរាប់គោរពបូជា ហើយនឹងត្រូវទៅកាន់ប្រភពនៃជីវិតវិញ។ បរិស័ទម្នាក់ៗក្នុងគណៈនេះត្រូវប្រតិបត្តិតាមសិក្ខាបទហាត់រៀននូវតបកម្មនឹងសូត្រធម៌ដោយវិរិយភាពបំផុត ដើម្បីបានសំរេចការត្រាស់ដឹងនៅថ្ងៃណាមួយ។

ព្រះពុទ្ធទ្រង់ត្រាស់ថា៖

"ម្នាលឧរុវេលកស្សប! តើព្រះអង្គគិតថាយ៉ាងដូចម្តេចដែរ ចំពោះអ្នកដែលគិតថាទឹកជាសារវន្តដើមនៃជីវិត គេនិយាយថាទឹកក៏ជាអង្គធាតុដែលធ្វើមនុស្សអោយបរិសុទ្ធ និងត្រឡប់ទៅជួបជាមួយព្រះព្រហ្មដែរនោះ?"

ម្នាលឧរុវេលកស្សបបែបស្ងាក់ស្ទើរក្នុងចិត្ត។ គាត់គិតថាសព្វថ្ងៃនេះមានមនុស្សរាប់រយពាន់នាក់កំពុងតែងូតទឹកនៅក្នុងទន្លេគង្គានិងស្ទឹងដទៃទៀត ដើម្បីជំរះមន្ទិលបាប។ គាត់ក៏ទូលតបទៅព្រះពុទ្ធថា៖

"សំឡាញ់គោតម! ទឹប្រាកដជាពុំអាចជួយអ្នកណាម្នាក់ អោយរួចចាកអំពីសេចក្តីទុក្ខបានឡើយ។ ធម្មតាទឹកវាតែងហូរចុះទៅខាងក្រោម មានតែភ្លើងទេដែលអណ្តែតឡើងទៅលើ។ ពេលមនុស្សយើងស្លាប់ទៅ រូបរបស់យើងក៏ត្រូវអណ្តែតតាមផ្សែង ដោយសារភ្លើងដែរ។"

ព្រះពុទ្ធទ្រង់ត្រាស់ថា៖

"ឧរុវេលកស្សប! រឿងហ្នឹងដូចជាមិនពិតទេដឹង។ ផ្ទាំងពពកពណ៌សដែលអណ្តែតត្រសែតនៅលើមេឃក៏ជារូបរាងនៃទឹកដែរ។ ដូច្នេះទឹកក៏អាចអណ្តែតឡើងទៅលើដែរ។

ជាការពិតណាស់ផ្សែងខ្លួនឯងគឺគ្មានអ្វីក្រៅអំពីចំហាយទឹកឡើយ។ ទាំងពីរយ៉ាង គឺពពក និងផ្សែង នឹងត្រូវត្រឡប់ទៅជាវត្ថុរាវឬទឹកភ្លៀងជាចាំបាច់។ ព្រះអង្គដឹងទេថា វត្ថុទាំងអស់ក្នុងលោកវិលទៅវិលមកច្រំដែលៗមិនចេះចប់ទេណា!"

ឧរុវេលកស្សបឆ្លើយតបថា៖

"តែវត្ថុទាំងអស់ចូលរួមជាមួយសារៈដើមតែមួយគត់ ដូច្នេះវត្ថុទាំងអស់នោះត្រូវតែត្រឡប់ទៅក្នុងសារៈតែមួយនោះវិញ។"

ព្រះពុទ្ធទ្រង់បញ្ជាក់បន្ថែមថា៖

"ម្នាលឧរុវេលកស្សប! វត្ថុទាំងអស់អាស្រ័យលើវត្ថុដទៃទៀតដែរ សំរាប់វត្តមានរបស់ខ្លួន។ យកឧទាហរណ៍តាមស្លឹកឈើ ដែលនៅក្នុងដៃតថាគតនេះចុះ៖ ទឹក ដី កំដៅ គ្រាប់ពូជ ពពក ព្រះអាទិត្យ ពេលវេលា លំហរ អាកាស អង្គធាតុទាំងអស់នេះ អាចធ្វើអោយស្លឹកឈើនេះ កើតមានជារូបរាងឡើង។ បើសិនជាអង្គធាតុណាមួយនៃអង្គធាតុទាំងអស់នេះបាត់បង់ទៅ ស្លឹកឈើនេះកំពុងអាចកើតមានឡើងដែរ។ សត្វលោកទាំងអស់ ទោះមានជីវិតក្តីគ្មានជីវិតក្តី ត្រូវតែអាស្រ័យទៅលើច្បាប់បដិច្ចសមុប្បាទ។ ព្រភពនៃវត្ថុមួយគឺជាវត្ថុទាំងអស់។ សូមព្រះអង្គមេត្តាពិចារណាត្រង់ចំណុចនេះដោយប្រុងប្រយ័ត្នផងចុះ។ ឥឡូវនេះ ព្រះអង្គមិនឃើញស្លឹកឈើដែលនៅក្នុងដៃរបស់តថាគតនេះ គឺគ្រាន់តែស្ថិតនៅទីនេះ ដោយសារតែការរួមផ្សំនៃ បាតុភូតធម្មជាតិ រួមទាំងការយល់ដឹងរបស់ព្រះអង្គផងទេឬ?"

ពេលល្ងាចណាស់ទៅហើយ សន្ធិយារាត្រីក៏ធ្លាក់មកគ្របដណ្តប់លើប្រថពី។ ព្រះពុទ្ធត្រូវបានឧរុវេលកស្សបនិមន្តអោយនៅសិងក្នុងខ្ទមជាមួយព្រះអង្គ។ កស្សបមិនដែលអនុញ្ញាតអោយជនណាម្នាក់ ស្នាក់អាស្រ័យទេ នេះគឺជាលើទីមួយហើយដែលគាត់មិនដែលបានជួបមួយព្រះសង្ឃដ៏ចម្លែកបែបហ្នឹង។ ព្រះពុទ្ធក៏បានប្រកែកជាពាក្យយ៉ាងនេះថាតាំងពីប្រសូតមកព្រះអង្គមិនដែលមានទម្លាប់ផ្ទំតែម្នាក់ឯងទេ នៅពេលរាត្រី។ ក៏ប៉ុន្តែព្រះអង្គសុំអនុញ្ញាតថា ព្រះអង្គមានព្រះបំណងចង់សិងនៅឯរោងភ្លើង (អង្គើធំ) វិញ ប្រសិនបើលោកម្ចាស់ឧរុវេលកស្សបមិនយល់ទាស់ទេ។



កស្សបព្រាហ្មណ៍ទូលព្រះអង្គថា៖

"ម្នាលសមណៈជាសំឡាញ់! ជាច្រើនថ្ងៃកន្លងមកហើយ ដែលយើងសំគាល់ឃើញមានពស់ដ៏ធំមួយ (នាគរាជ) ចូលមកជ្រកនៅក្នុងរោងភ្លើងនេះ។ យើងបានប្រើគ្រប់មធ្យោបាយអស់ហើយ ក្នុងការបណ្តេញវាចេញ ក៏ពស់ដ៏ធំនេះមិនព្រមលូនចេញដែរ។ ដូច្នេះព្រះអង្គមិនត្រូវសិងនៅកន្លែងហ្នឹងទេណាសំឡាញ់គោតម! វាអាចបណ្តាលអោយមានគ្រោះថ្នាក់ដល់ព្រះអង្គ។ ជាពិសេសនៅពេលធ្វើបុណ្យទានម្តងៗយើងតែងនាំគ្នា ទៅធ្វើនៅខាងក្រៅឯណោះ ក៏ព្រោះតែយើងភ័យខ្លាច នឹងពស់ដ៏ធំចម្លែកនេះឯង។ សូមព្រះអង្គសិងនៅក្នុងខ្ទមរបស់ទូលបង្គំវិញទៅ ដើម្បីសេចក្តីសុខផ្ទាល់ព្រះអង្គ។"

ព្រះពុទ្ធទ្រង់ឆ្លើយតមវិញថា៖

"សូមកុំបារម្ភអីលោកម្ចាស់! តថាគតចង់សិងនៅក្នុងរោងភ្លើងនោះ វានឹងមិនបណ្តាលអោយមានគ្រោះថ្នាក់អ្វីឡើយ។"

ដោយឃើញព្រះពុទ្ធមិនអាចឃាត់បាន ឧរុវេលកស្សបក៏បង្គំទូលថា៖

"បើព្រះអង្គចង់សិងនៅក្នុងរោងភ្លើងនោះក៏ស្រេចតែព្រះអង្គចុះ។ ព្រះអង្គចង់សិងនៅទីហ្នឹងប៉ុន្មានថ្ងៃក៏បានដែរ អោយតែព្រះអង្គសព្វព្រះទ័យ!"

នារាត្រីនោះ ព្រះពុទ្ធក៏និមន្តចូលទៅក្នុងរោងភ្លើង។ នៅលើសសរកន្លោងមានអណ្តាតភ្លើងឆេះសន្ធៅដុតដោយទៀនជាច្រើនដើម។ នៅជ្រុងម្ខាងនៃរោងភ្លើងមានគំនរអុសដើមខ្លឹមចន្ទន៍ក្រស្នា ដែលគេគរទុកសំរាប់ដុតធ្វើបុណ្យទាននៅខាងក្រៅ។ ព្រះពុទ្ធទ្រង់ឈ្វេងយល់ថាពស់នាគដ៏ធំនោះប្រហែលជាវេននៅក្នុងគំនរអុសនោះឯង។ ពិចារណាឃើញដូច្នេះហើយព្រះអង្គក៏គង់ធ្វើសមាធិនៅជ្រុងម្ខាងទៀតដោយបត់ស្បង់ចីវរធ្វើជាកំរាល។ ព្រះអង្គគង់ធ្វើសមាធិរហូតដល់យប់ជ្រៅ។ នៅជិតពេលចុងបញ្ចប់នៃសមាធិព្រះអង្គទតឃើញពស់ដ៏ធំនោះវេនជារង្វេលនៅចំកណ្តាលរោងភ្លើងបើកភ្នែកទាំងគូសម្លឹងថ្លៃដាក់ព្រះអង្គ។ ព្រះពុទ្ធទ្រង់ត្រាស់ទៅកាន់ពស់នាគនោះ នូវព្រះវាចាដ៏ផ្អែមល្ហែមថា៖

"ម្នាលពស់នាគរាជជាសំឡាញ់! ចូរអ្នកធ្វើដំណើរទៅកាន់ទីព្រៃ ដើម្បីសេចក្តីសុខផ្ទាល់ខ្លួនអ្នកវិញចុះ!"

ព្រះពុទ្ធវាចាពោរពេញទៅដោយសេចក្តីករុណា និងយោគយល់។ ពស់នាគរាជនោះស្តាប់បាន ក៏ពន្លាខ្លួនវារសន្សឹមៗចេញតាមមាត់ទ្វារបាត់ទៅ។ ព្រះពុទ្ធទ្រង់សណ្តូកព្រះបាទរួចក៏សិងលង់លក់ទៅផងដែរ។

ពេលព្រះអង្គភ្ញាក់តើនឡើង ពន្លឺព្រះច័ន្ទភ្លឺថ្លាបានចាំងឆ្លុះចូលតាមមាត់បង្អួចទៅដល់កន្លែងព្រះអង្គសិង។ ព្រះពុទ្ធទ្រង់ព្រះចិន្តាថា ពេលនេះគួរជាទីរីករាយណាស់បើអាត្មាអញយាងយាងចង្រ្កមនៅក្រោមពន្លឺច័ន្ទថ្លាបែបនេះ។ ព្រះអង្គក៏រលាស់ធូលីចេញអំពីស្បង់ហើយទ្រង់គ្រងដណ្តប់យ៉ាងសមរម្យមុននឹងព្រះអង្គនិមន្តចេញអំពីរោងភ្លើងនេះ ទៅចង្រ្កមខាងក្រៅ ក្រោមពន្លឺព្រះចន្ទដ៏ថ្លាត្រចង់នោះ។

ពេលពន្លឺស្រាងៗរោងភ្លើងនោះត្រូវភ្លើងឆេះ។ អ្នកដែលបានឃើញភ្លើងឆេះមុនគេ ក៏ស្រែកហៅអ្នកដទៃទៀតអោយមកជួយពន្លត់។ ម្នាក់ៗកាន់ធុងរត់ទៅដងទឹកអំពីក្នុងស្ទឹងយកមកស្រោចពន្លត់ ប៉ុន្តែ ទោះបីជាពួកជដិលទាំងអស់ខំប្រឹងយ៉ាងណា ក៏នៅតែពន្លត់ភ្លើងមិនឈ្នះដែរ។ ក្នុងគ្រានោះ បរិវារទាំង៥០០នាក់របស់ឧរុវេលកស្សបគ្មានអាចធ្វើអ្វីកើតក្រៅពីនាំគ្នាឈរមើលទាល់តែរោងភ្លើងនោះឆេះធ្លាក់ចុះដល់ដី។

ឧរុវេលកស្សបក៏ឈរមើលជាមួយបរិស័ទរបស់ព្រះអង្គ ដោយសញ្ជឹងគិតថា៖

"គួរអោយអនិច្ចាដល់ព្រះសង្ឃដ៏ក្មេងនេះណាស់មិនគួរណាមកស្លាប់ក្នុងភ្លើងយ៉ាងដូច្នេះសោះ។ បើគោតមនេះយល់ព្រមទៅសិងក្នុងខ្ទមរបស់អាត្មាអញ ម្ល៉េះសមនឹងរួចរស់ព្រះជន្មពុំខាន។"

គ្រាន់តែឧរុវេលកស្សបចាប់នឹកគិតដល់រឿងនេះភ្លាម ស្រាប់តែព្រះពុទ្ធ លេចធ្លោពីក្នុងព្រៃមក។ ព្រះពុទ្ធបានទតឃើញភ្លើងដែលឆេះនោះអំពីលើភ្នំនៅពេលព្រះអង្គកំពុងតែយាងចង្រ្កមរួចមកព្រះអង្គក៏និមន្តរួតរះដើម្បីទតមើលនូវហេតុការណ៍ ក្រែងព្រះអង្គអាចជួយបាន។

ពេលឃើញព្រះពុទ្ធកាលណាឧរុវេលកស្សបស្ទុះទៅរកព្រះអង្គដោយក្តីអំណរហើយក៏ចាប់ក្តាប់ព្រហស្តព្រះអង្គយ៉ាងណែន៖

"អរណាស់លោកអើយ! ព្រះអង្គនៅគង់ព្រហជន្មសំឡាញ់គោតម! តើគ្មានអ្វីប៉ះពាល់ដល់រូបកាយព្រះអង្គទេឬ? ខ្ញុំព្រះអង្គត្រេកអរខ្លាំងណាស់!"



ព្រះពុទ្ធចាប់អង្អែលស្មាឧរុវេលកស្សបព្រាហ្មណ៍ទាំងសង្ខាង ដោយព្រះភ័ក្ត្រញញឹមទើបមានព្រះបន្ទូលថា៖

"អរគុណច្រើនហើយសំឡាញ់! តថាគតមិនអីទេ!"

ព្រះពុទ្ធទ្រង់ព្រះតំរិះថា នៅពេលថ្ងៃត្រង់នេះ ឧរុវេលកស្សបនឹងត្រូវសំដែងធម្មទេសនាដល់បរិវារទាំង៥០០រូប និងប្រហែលមានអ្នកស្រុកជិតខាងក្នុង ដែនអង្គៈ និងមគធៈចំនួន៥០០នាក់ទៀត ចូលរួមផងដែរ។ ប្រសិនបើមានវត្តមានរបស់អាត្មាអញនៅទីនេះនឹងបណ្តាលអោយជដិលឧរុវេលកស្សប មានការទើសទាល់។ កាលព្រះអង្គជ្រាបក្នុងព្រះចិន្តាដូច្នេះហើយ ព្រះពុទ្ធក៏យាងចេញទៅបិណ្ឌបាត នៅឯ ឧត្តរកុរុទ្វីប និងនាំយកចង្ហាន់បិណ្ឌបាតនោះ ទៅឆាន់នៅឯមាត់ ស្រះអនោតត្ត ជំនួសវិញ។ លុះឆាន់រួចហើយទើបទ្រង់សំរាកព្រះកាយ នៅទៀបមាត់ស្រះឈូកគួរជាទីរីករាយនោះទៅ។

រសៀលជ្រាលជ្រៅណាស់ទៅហើយ បន្ទាប់ពីសំដែងធម្មទេសនារួចមកជដិលកស្សបក៏រួតរះតាមស្វែងរកព្រះពុទ្ធ។ពេលរកឃើញព្រះអង្គនៅទៀបមាត់ស្រះឈូកនោះឧរុវេលកស្សបក៏ទូលសួរព្រះអង្គថា៖

"សំឡាញ់គោតម! កាលពីព្រឹកមិញពួកយើងនាំគ្នាទន្ទឹងរង់ចាំព្រះអង្គ ដើម្បីឆាន់តែយើងដើររកព្រះអង្គមិនឃើញសោះ។ ពួកយើងបានទាំងតម្កល់ខាទនីយាហារមួយចំណែកសំរាប់ព្រះអង្គ។ តើហេតុអ្វីក៏ព្រះអង្គមិនចូលរួមជាមួយពួកយើងអីញ្ចឹង?"

ព្រះពុទ្ធទ្រង់ឆ្លើយតបដោយញញឹមថា៖

"ម្នាលឧរុវេលកស្សបដ៏ចំរើន! តថាគត ឥតមានបំណងចង់ទៅចូលរួម ក្នុងពេលដែលព្រះអង្គសំដែងធម្មទេសនានោះទេ។"

ឧរុវេលកស្សបទូលសួរបញ្ជាក់៖

"ហេតុអ្វីក៏ព្រះអង្គមិនចង់ចូលរួមក្នុងពេលសំដែងធម្មទេសនានោះ?"

ព្រះពុទ្ធគ្រាន់តែញញឹម ដោយមិនមានបញ្ចេញព្រះពុទ្ធដីកាអ្វីឡើយ។

ឧរុវេលកស្សបសោតក៏ឈប់ដេញដោលដែរ ដោយបានដឹងយ៉ាងច្បាស់ថាសមណៈដ៏ក្មេងនេះបានដឹងអំពីគំនិតរបស់ខ្លួន ក្នុងការមិនចង់អោយព្រះអង្គទៅចូលរួមនោះ រួចអស់

ហើយ។ ទាំងពីរព្រះអង្គក៏ចាប់ផ្ដើមសំណេះសំណាលគ្នាបន្តទៅទៀតនាមាត់ស្រះនោះ។ ឧរុវេលកស្សបហបង្គំទូលសួរព្រះពុទ្ធថា៖

"បពិត្រសមណគោតម! កាលពីម្សិលមិញព្រះអង្គមានពុទ្ធដីកាថាវត្តមាននៃស្លឹកឈើ គឺជាលទ្ធផលដែលមានមកពីការ ប្រមូយផ្ដុំនៃអង្គធាតុផ្សេងគ្នាជាច្រើន។ ព្រះអង្គក៏មានពុទ្ធដីកាថា វត្តមាននៃមនុស្សក៏ដូច្នេះដែរ កើតឡើងដោយសារតែការប្រមូលផ្ដុំនៃអង្គធាតុផ្សេងៗទៀតជាច្រើន តែបើដល់ពេលអង្គធាតុទាំងអស់នោះឈប់កើតមានទៀត តើអត្តៈនឹងទៅឯណាដែរ?"

ព្រះពុទ្ធទ្រង់មានព្រះបន្ទូលថា៖

"ជាយូរយាណាស់មកហើយ មនុស្សជាប់ក្នុងអន្ទាក់នៃគំនិតអាត្ម័នគឺគំនិតនៃការបំបែកនិងគ្មានទីបញ្ចប់នៃអត្តៈ។ គេមានជំនឿថា ពេលរូបកាយមនុស្សសត្វស្លាប់ទៅអត្តៈនេះនៅតែមានបន្តហើយនឹងទៅជួបជុំជាមួយប្រភពរបស់វាដែលជាព្រះពហ្ម។ តែឧរុវេលកស្សបសំឡាញ! រឿងនេះជាប្រភពនៃការយល់ខុស ដែលបណ្ដាលអោយមនុស្សរាប់ជំនាន់មិនអស់វង្វេងវង្វាន់។ គួរតែសំឡាញ់យល់ដឹងថា វត្ថុធាតុទាំងអស់កើតមានឡើងដោយសារតែការជាប់ទាក់ទងគ្នាទៅវិញទៅមក ហើយវត្ថុទាំងអស់នោះឯង នឹងរលាយរលត់ទៅវិញក៏ដោយសារការជាប់ទាក់ទងគ្នាទៅវិញទៅមកនេះដែរ។ នេះមានពីព្រោះនោះមាន នេះគ្មានពីព្រោះនោះគ្មាន នេះកើតពីព្រោះនោះកើត នេះស្លាប់ពីព្រោះនោះស្លាប់។ នេះគឺជាទ្រឹស្ដីបដិចសមុប្បាទដ៏អស្ចារ្យ ដែលតថាគតបានពិចារណារកឃើញ។ តាមពិត គ្មានអ្វីបែកដាច់ចេញអំពីគ្នា និងមានទីបំផុតឡើយ។ គ្មានអត្តៈទេ សូម្បីតែអត្តៈនោះខ្ពស់ក៏ដោយឬទាបក៏ដោយ។ ឧរុវេលកស្សបហ! តើព្រះអង្គដែលបានគង់ភាវនាទៅលើរូបខន្ធ វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណខន្ធ របស់ព្រះអង្គដែរឬទេ? មនុស្សម្នាក់ៗសុទ្ធតែកើតឡើងដោយខ័ន្ធ៥នេះ។ ខ័ន្ធទាំង៥នៅបន្តផ្លាស់ប្ដូរស្ទើងទាំងអស់ ដែលនៅក្នុងនោះ គ្មានអ្នកណាម្នាក់អាចរកឃើញ សូម្បីតែអង្គធាតុមួយអោយនៅឋិតថេរបានឡើយ។"

ឧរុវេលកស្សបហនៅទ្រឹងស្ងៀមមិនចេញស្ដីអស់មួយស្របកធំ ទើបបង្គំទូលថា៖

"មើល៍សំឡាញ់គោតម! បើអីញ្ចឹងគេអាចនិយាយថា ព្រះអង្គជាអ្នកបង្រៀននូវទ្រឹស្ដី



ដែលមិនមែនជាអាទិទេពមែនឬទេ?"

ព្រះពុទ្ធញញឹម ហើយទ្រង់គ្រវីព្រះសិរៈ

"មិនមែនទេ! គំនិតដែលមិនមែនអាទិទេពគឺជាទស្សនៈចង្អៀតចង្អល់មួយក្នុងចំណោមទស្សនៈចង្អៀតចង្អល់ផ្សេងៗទៀតក្នុងព្រៃទាំងមូល។ គំនិតដែលមិនមែនជាអាទិទេពគ្រាន់តែខុសពីគ្នាទៅនឹងគំនិតនៃការបំបែកនិងគ្មានទីបញ្ចប់នៃអត្តៈប៉ុណ្ណោះ។ ឧរុវេលកស្សបហសូមព្រះអង្គមើលទៅផ្ទៃនៃស្រះទឹកនេះ។ តថាគតមិនចង់ថា ទឹកនិងឈូកមិនមាននោះទេ ប៉ុន្តែតថាគតចង់មានន័យថា ទឹកនិងឈូកកើតឡើងដោយសារវត្តមាន និងការប្រមូលផ្ដុំគ្នានៃវត្ថុធាតុផ្សេងៗទៀត គ្មានវត្ថុណាមួយអាចដាច់ចេញពីគេឬក៏នៅទៀងទាត់រហូតឡើយ។"

ឧរុវេលកស្សបហងើយមើលចំព្រះនេត្រព្រះពុទ្ធ ហើយបង្គំទូលថា៖

"បើសិនជាអត្តៈគ្មាន អាត្ម័នគ្មាន តើហេតុអ្វីក៏គេចាំបាច់ខំហាត់រៀនខាងផ្លូវសាសនាដើម្បីសំរេចពន្លឺត្រាស់ដឹង? មើល៍សំឡាញ់គោតម! តើអ្នកណានឹងអាចសំរេចពន្លឺត្រាស់បាន?"

ព្រះពុទ្ធទតមើលដោយព្រះនេត្រមុតថ្លាទៅកាន់ជដិលឧរុវេលកស្សបហ មុននឹងទ្រង់មានពុទ្ធដីកាទាំងព្រះភ័ក្ត្រញញឹមថា៖

"ម្នាលកស្សបដ៏ចំរើន! សូមព្រះអង្គស្វែងរកចម្លើយនេះក្នុងខ្លួនព្រះអង្គចុះ!"

ទាំងពីរព្រះអង្គក៏វិលទៅកាន់អាស្រមរបស់ឧរុវេលកស្សបហវិញ។ រាត្រីនោះឧរុវេលកស្សបនិមន្តព្រះពុទ្ធអោយសិងនៅក្នុងខ្ទមរបស់ព្រះអង្គ ហើយឧរុវេលកស្សបហខ្លួនឯងទៅសិងជាមួយសាវករបស់ព្រះអង្គផ្សេងទៀត។

មាននិទានតំណាលថា៖

"ក្នុងគ្រានោះ ឧរុវេលកស្សបហបានឃើញនូវ បាដិហារ្យ៥យ៉ាង កើតមានដល់ព្រះពុទ្ធ គឺ៖ បានឃើញព្រះពុទ្ធគ្របសង្កត់ពស់នាគរាជដោយតេជៈរបស់ព្រះអង្គ១ ឃើញទេវតា៤អង្គមានរូបល្អ និងបណ្ដាលអោយមានរស្មីភ្លឺពេញព្រៃចូលទៅបង្គំគាល់ព្រះពុទ្ធនៅក្នុងវេលាពាក់កណ្ដាលអធ្រាត្រ១ ឃើញព្រះឥន្ទគឺសក្កទេវរាជដែលធំជាងពួកទេវតា មានរូបល្អនិងបណ្ដាលអោយមានរស្មីភ្លឺពេញព្រៃចូលទៅបង្គំគាល់ព្រះពុទ្ធក្នុងវេលាពាក់កណ្ដាលអធ្រាត្រ

១ ឃើញសហម្បតីព្រហ្មមានរូបល្អនិងបណ្ដាលអោយមានរស្មីភ្លឺពេញព្រៃចូលទៅបង្គំគាល់ព្រះពុទ្ធនៅក្នុងវេលាពាក់កណ្ដាលអធ្រាត្រ១ និងឃើញព្រះពុទ្ធបានដឹងជាមុនអំពីទស្សនៈដែលខ្លួន(កស្សប) មិនចង់អោយព្រះពុទ្ធមកចូលរួមក្នុងពេលសំដែងព្រះធម៌ទេសនានោះ១។

កាលបានឃើញបាដិហារ្យទាំង៥ហើយ ឧរុវេលកស្សបក៏ចាប់ត្រិះរិះ ជាយ៉ាងនេះថា៖

"សមណគោតមនេះមានឫទ្ធិខ្លាំងណាស់តើ! មានអានុភាពធំមែនតើ! ប៉ុន្តែទោះជាយ៉ាងណា ក៏គង់គោតមនេះមិនមែនជាព្រះអរហន្តដូចជាអាត្មាអញទេ។"

---

# ជំពូកទី១៧
# ធមិទាំងអស់ជារបស់ភ្លោ

ជារៀងរាល់ព្រឹក ឧរុវេលកស្សបបានយកចង្ហាន់មកប្រគេនព្រះពុទ្ធដោយមិនចង់អោយព្រះអង្គយាងចេញបិណ្ឌបាត ដើម្បីទុកពេលសំរាប់រៀនសូត្រធម៌ពីព្រះអង្គ។ ទាំងពីរព្រះអង្គតែងតែសំណេះសំណាលគ្នានៅក្រោមម្លប់ឈើក្បែរស្រះអនោតត្តនោះ។ ពេលស្ដាប់ធម៌របស់ព្រះពុទ្ធបានច្រើនប៉ុណ្ណា ជដិលកស្សបយល់បានច្រើនប៉ុណ្ណឹង។

"រាត្រីមួយនោះ មានភ្លៀងធ្លាក់យ៉ាងខ្លាំង និងបណ្ដាលអោយមានទឹកជន់លិចមាត់ស្ទឹងនេរញ្ជរា លិចស្រែចំការនិងផ្ទះសម្បែងអ្នកស្រុកជិតខាង។ មានទូកជាច្រើនចែវចេញច្រវាត់ដើម្បីជួយស្រង់អ្នករងគ្រោះ។ បរិវារនៃឧរុវេលកស្សបរត់ឡើងគោកទាន់គ្រប់ៗគ្នា។ ឧរុវេលកស្សបក៏បានចាប់ទូកជាច្រើនអោយតាមរកព្រះពុទ្ធ។ ព្រះពុទ្ធត្រូវបានគេរកឃើញនៅលើភ្នំដ៏ឆ្ងាយដោយសុខសាន្ត។ ពេលនោះគ្មានអ្នកណាម្នាក់ទទួលរងគ្រោះដោយសារទឹកជំនន់ឡើយ។

សាវ័ករបស់ឧរុវេលកស្សបបាននាំគ្នាសង់រោងភ្លើងនិងខ្ទមទាំងអស់ឡើងវិញ។

រសៀលថ្ងៃមួយ ពេលព្រះពុទ្ធនិងឧរុវេលកស្សបកំពុងតែឈរនៅលើមាត់ស្ទឹងនេរញ្ជរា ឧរុវេលកស្សបក៏បង្គំទូលសួរព្រះអង្គថា៖



"គោតមជាសំឡាញ់! ពីថ្ងៃមុន ព្រះអង្គបាននិយាយអំពីការភាវនាលើរូបខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ និងវិញ្ញាណខន្ធ។ ខ្ញុំព្រះអង្គ ក៏បានហាត់រៀននូវ កម្មដ្ឋាន នោះហើយៗក៏បានចាប់ផ្ដើមយល់ នូវក្ខន្ធទាំង៥នោះដែរ។ ខ្ញុំព្រះអង្គក៏បានឃើញថាគ្មានអង្គធាតុអចិន្ត្រៃយ៍ណាមួយមាននៅក្នុងស្ទឹងទាំង៥នោះដែរ។ ខ្ញុំព្រះអង្គក៏មើលឃើញដែរថា ការជឿថាមានអត្តៈបែកចេញពីគ្នាគឺជាការយល់ខុសទាំងស្រុង។ ប៉ុន្តែខ្ញុំព្រះអង្គមិនទាន់យល់ច្បាស់សោះថាតើហេតុអ្វីក៏គេនាំគ្នាដើរតាមផ្លូវសាសនាបើគ្មានអត្តៈទេនោះ? តើអ្នកណាទៅហ្ន៎ជាអ្នកអាចសំរេចពន្លឺត្រាស់ដឹងបែបនោះបាន?"

ព្រះពុទ្ធទ្រង់ត្រាស់សួរបន្តថា៖

"មើល៍ឧរុវេលកស្សប តើព្រះអង្គទទួលជឿថាទុក្ខជា សេចក្ដីពិតដែរឬទេ?"

ឧរុវេលកស្សបឆ្លើយថា៖

"គោតមសំឡាញ់! ខ្ញុំព្រះអង្គជឿថាទុក្ខជាសេចក្ដីពិតហើយ!"

ព្រះពុទ្ធទ្រង់ត្រាស់សួរបន្តថា៖

"ម្នាលឧរុវេលកស្សបដ៏ចំរើន! តើព្រះអង្គយល់ថាសេចក្ដីទុក្ខមានបុព្វហេតុជាសេចក្ដីពិត ដែរឬទេ?"

កស្សបឆ្លើយថា៖

"បពិត្រគោតម ខ្ញុំព្រះអង្គជឿថាទុក្ខពិតជាមានបុព្វហេតុរបស់វា!"

ព្រះពុទ្ធទ្រង់បញ្ជាក់ថា៖

"ម្នាលកស្សបដ៏ចំរើន! ពេលបុព្វហេតុនៃទុក្ខកើតឡើង ទុក្ខក៏កើងឡើងដែរ។ ពេលបុព្វហេតុនៃទុក្ខរលត់បាត់ ទុក្ខក៏រលត់បាត់តំណាលគ្នាដែរណ៎ា!"

ឧរុវេលកស្សបឆ្លើយបន្ទរថា៖

"ខ្ញុំព្រះអង្គក៏មើលឃើញថា ពេលបុព្វហេតុនៃទុក្ខត្រូវរលត់ ទុក្ខខ្លួនឯងនោះក៏រលត់ដែរ!"

ព្រះពុទ្ធបានពន្យល់បន្តថា៖

"បុព្វហេតុនៃទុក្ខ គឺអវិជ្ជា ជាផ្លូវខុសក្នុងការស្វែងរកសេចក្ដីពិត។ ការគិតឃើញនូវអ្វីដែលមិនទៀងទាត់ថាជារបស់ទៀងទាត់ក៏ជាអវិជ្ជា។ ការគិតឃើញថាមាន មានអត្តៈ តាម

ពិតវាគ្មានក៏ជាអវិជ្ជា។ អវិជ្ជានាំអោយកើត លោភៈ ទោសៈ មោហៈ ភ័យខ្លាច ច្រណែន ប្រច័ណ្ឌ និងទុក្ខដ៏ច្រើនរាប់មិនអស់។ ផ្លូវនៃការរំលត់ទុក្ខគឺជាផ្លូវនៃការមើលជ្រៅទៅក្នុងវត្ថុ(ធម៌)ទាំងឡាយ ដើម្បីអោយដឹងរឿងពិតនៃការមិនឋិតថេរ(អនិច្ចំ)និងអវត្តមាននៃអត្តៈ(អនត្តា) ដែលដាច់ចេញពីគ្នា និងទាក់ទង់គ្នាទៅវិញទៅមកនៃវត្ថុទាំងនោះ។ ផ្លូវនេះហើយជាផ្លូវដែលច្បាំងឈ្នះអវិជ្ជា។ ពេលណាច្បាំងឈ្នះអវិជ្ជា សេចក្ដីទុក្ខក៏ត្រូវតែចុះចាញ់។ នេះហើយគឺជាការរំលត់ទុក្ខពិតប្រាកដ។ មិនបាច់ត្រូវការអត្តៈនៅទីនោះ ដើម្បីជួយរំលត់ទុក្ខទេ។"

ឱរុវេលកស្សបគង់ស្ងៀមមួយស្របក់ទើបទូលសួរថា៖

"សមណៈគោតម! ខ្ញុំព្រះអង្គដឹងថាព្រះអង្គគ្រាន់តែនិយាយតាមការពិសោធផ្ទាល់របស់ព្រះអង្គប៉ុណ្ណោះ ពាក្យទាំងឡាយរបស់ព្រះអង្គ ក៏មិនទាន់បានបញ្ជាក់អំពីគោលគំនិតអោយច្បាស់លាស់ដែរ។ ព្រះអង្គនិយាយថាការរំលត់ទុក្ខអាចសំរេចបានតែតាមការប្រឹងប្រែងក្នុងសមាធិដោយមើលធ្លុះជ្រៅក្នុងវត្ថុតែប៉ុណ្ណោះ។ តើព្រះអង្គចង់មានន័យថាការធ្វើបុណ្យទាននិងការ សូត្រមន្តជាដើមនោះ ឥតមានប្រយោជន៍សោះតែម្ដងឬ?"

ព្រះពុទ្ធទ្រង់ចង្អុលព្រះហស្តទៅកាន់ទិសម្ខាងនៃស្ទឹង ហើយទ្រង់ត្រាស់ថា៖

"ម្នាលឱរុវេលកស្សបដ៏ចំរើន! បើមនុស្សម្នាក់ ចង់ហែលឆ្លងទៅកាន់ត្រើយម្ខាងនៃស្ទឹងនេះ តើជននោះត្រូវធ្វើដូចម្ដេចខ្លះ?"

ឱរុវេលកស្សបឆ្លើយថា៖

"គោតមសំឡាញ់! បើទឹកស្ទឹងរាក់ល្មម ជននោះត្រូវតែដើរលុយឆ្លង។ តែបើទឹកស្ទឹងជ្រៅវិញជននោះត្រូវតែហែលឬក៏ចែវទូកឆ្លងទៅទើបបាន។"

ព្រះពុទ្ធត្រាស់សួរបន្តទៀតថា៖

"ចុះបើជននោះគ្រាន់តែឈរនៅលើមាត់ច្រាំនៃស្ទឹង ហើយបន់ស្រន់អោយច្រាំងម្ខាងទៀតនោះរត់ចូលមករកគាត់ តើយ៉ាងដូចម្ដេចដែរ? តើព្រះអង្គគិតដល់ជនោះថាជាមនុស្សបែបណាដែរ?"

ឱរុវេលកស្សបឆ្លើយភ្លាមថា៖



"ខ្ញុំព្រះអង្គគិតថាគាត់នោះប្រាកដជាមនុស្សឆ្កួតតែម្ដង!"

ព្រះពុទ្ធបញ្ជាក់បន្ថែមថា៖

"វាអីញ្ចឹងមែនហើយកស្សប! បើបុគ្គលណាម្នាក់មិនច្បាំងឈ្នះនូវអវិជ្ជា អ្នកនោះក៏មិនអាចឆ្លងដល់ត្រើយម្ខាងនៃស្ទឹង គឺការរំលត់ទុក្ខនោះបានឡើយ សូម្បីតែបុគ្គលនោះខំចំណាយពេលបន់ស្រន់អស់មួយជីវិតក៏ដោយ។"

រំពេចនោះ ឱរុវេលកស្សបរំជួលស្រក់ទឹកភ្នែក រួចក៏ក្រាបថ្វាយបង្គំទៀបចុងព្រះបាទព្រះពុទ្ធ ហើយបង្គំទូលថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គខាតពេលអស់ជិតពាក់កណ្ដាលអាយុទៅហើយ។ ខ្ញុំព្រះអង្គគួរបានបួសជាភិក្ខុក្នុងសំណាក់ព្រះមានព្រះភាគ នៅក្នុងពេលនេះផងចុះ។ សូមព្រះអង្គជួយផ្ដល់ឱកាសអោយខ្ញុំព្រះអង្គបានទទួលការសិក្សានូវ ព្រហ្មចរិយធម៌ ដែលជាធម៌ត្រាស់ដឹងដ៏ប្រពៃថ្លៃថ្លារបស់ព្រះអង្គនោះផង!"

ព្រះពុទ្ធយកព្រះហស្តជួយចាប់លើកឱរុវេលកស្សបអោយក្រោកឡើងវិញរួចហើយព្រះអង្គមានពុទ្ធដីកាថា៖

"ម្នាលកស្សបៈ! តថាគតទទួលព្រះអង្គជាសាវករបស់តថាគតបាន ចុះបរិវារទាំង ៥០០រូបទៀត ដែលឋិតនៅក្រោមការដឹកនាំរបស់ព្រះអង្គនោះ តើព្រះអង្គត្រូវគិតគូរយ៉ាងដូចម្ដេចដែរ? តើនរណាជាអ្នកដឹកនាំដល់អ្នកទាំងឡាយនោះ បើព្រះអង្គចាកចេញទៅ?"

ឱរុវេលកស្សបឆ្លើយទាំងរអាក់រអួលថា៖

"បពិត្រព្រះអង្គដ៏ចំរើន! សូមទ្រង់មេត្តាទុកឱកាសអោយខ្ញុំព្រះអង្គដោះស្រាយរឿងនេះជាមួយអ្នកទាំងនោះនៅវេលាព្រឹកស្អែកនេះសិនចុះ។ លុះដល់ពេលរសៀលនាថ្ងៃស្អែកនោះ ទើបខ្ញុំព្រះអង្គអោយ បានជ្រាបច្បាស់នូវ សេចក្ដីសំរេចចិត្តរបស់ខ្ញុំព្រះអង្គចំពោះរឿងនេះ។"

ព្រះពុទ្ធត្រាស់បន្តថា៖

"ម្នាលកស្សបៈ! ពួកកុមារទាំងឡាយនៅឯឱរុវេលនិគមនាំគ្នាហៅតថាគតថា"ពុទ្ធ" តែយ៉ាងនេះគ្រប់ៗគ្នា។"

ឧរុវេលកស្សបមានការភ្ញាក់ផ្អើលកាន់តែខ្លាំងឡើងថែមទាំងនឹកគិតក្នុងចិត្តថា៖

"ម្ល៉េះពាក្យនេះសមមានន័យថាបុគ្គលជាអ្នកត្រាស់ដឹងមែនឬ? អាត្មាអញត្រូវតែហៅព្រះអង្គដូចពាក្យនៃកុមារទាំងឡាយនោះដែរ។"

រសៀលស្អែកឡើង ឧរុវេលកស្សបចូលទៅបង្គំគាល់ព្រះពុទ្ធនៅឯស្រះឈូកអនោតត្តហើយបានបង្គំទូលថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គនិងជដិលទាំង៥០០ជាបរិវារដល់នូវសេចក្តីជ្រះថ្លាក្នុងសំណាក់ព្រះមហាសមណគោតមហើយ។ ខ្ញុំព្រះអង្គទាំងឡាយ សូមដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃស្មើនឹងជីវិត និងសូមប្រព្រឹត្តព្រហ្មចរិយធម៌ ដែលព្រះអង្គបានសំដែងហើយចាប់តាំងអំពីថ្ងៃនេះតទៅ។"

ព្រឹកស្អែកឡើង ឧរុវេលកស្សបនិងបរិវារទាំង៥០០រូប នាំគ្នាកោរសក់និងពុកមាត់ពុកចង្ការចោល។ គេនាំគ្នាបោះបណ្តែតចោលនូវគ្រឿងបរិក្ខារសំរាប់បូជាព្រះអគ្គីមានផ្នួងសក់(ជដា) និងអម្រែកជាដើមទៅក្នុងទឹកស្ទឹងនេរញ្ជរា។ ជដិលទាំងអស់នោះក៏នាំគ្នាទៅកាន់ទីដែលព្រះពុទ្ធគង់នៅ ឱនសិរសាចុះទៀបព្រះបាទាព្រះដ៏មានព្រះភាគ ហើយក្រាបថ្វាយបង្គំយ៉ាងនេះថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គទាំងឡាយគួរបានបួសជាភិក្ខុ ក្នុងសំណាក់ព្រះមានព្រះភាគផង។"

"ម្នាលអ្នកទាំងឡាយ! ចូរអ្នកមកជាភិក្ខុចុះ សាសនាធម៌ព្រះពុទ្ធបានពោលល្អហើយ អ្នកទាំងឡាយចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។ ព្រះពុទ្ធដីកានេះហើយជាឧបសម្បទា របស់លោកអ្នកដ៏មានអាយុទាំងឡាយ។"

បន្ទាប់មក ជដិលទាំងឡាយសូត្រធម៌បួសបីចប់តាមព្រះពុទ្ធយ៉ាងនេះថា៖

"ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាអ្នកបង្ហាញផ្លូវល្អដល់ខ្ញុំព្រះអង្គក្នុងជាតិនេះ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាផ្លូវនៃពន្លឺត្រាស់ដឹងនិងសេចក្តីបរិសុទ្ធ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាគណៈនៃការរស់នៅសុខស្រួលនិងភ្ញាក់រលឹក។"

ការសូត្រធម៌ព្រះត្រៃសរណគមន៍នេះ បានលាន់ឮសូរកងរំពង ខ្ទរអស់ព្រៃព្រឹក្សា និង



គួរអោយព្រឺព្រួច។

ពេលព្រះសាស្តាប្រទានបព្វជ្ជានិងឧបសម្បទាដល់ឧរុវេលកស្សបនិងបរិវារទាំង៥០០រូបជាឯហិភិក្ខុចប់សព្វគ្រប់ហើយ ព្រះអង្គក៏សំដែងធម្មទេសនាអំពីចតុរារិយសច្ចៈនិងបង្រៀនអោយចេះកំណត់ខ្យល់ដង្ហើមចេញចូលនិងការពិនិត្យលើរូបកាយនិងចិត្ត។ ព្រះអង្គក៏បង្រៀនអំពីការដើរបិណ្ឌបាតនិងការសង្រួមឥន្ទ្រីយ៍ក្នុងពេលទទួលភត្ត។ ជាពិសេសព្រះអង្គបានសុំអោយដោះលែងសត្វពាហណៈ ដែលជដិលទាំងនោះចិញ្ចឹមទុកសំរាប់ធ្វើម្ហូបចំណីនិងបូជាយ័ញ្ញអោយមានសេរីភាពឡើងវិញ។

ថ្ងៃបន្ទាប់មក ប្អូនប្រុសរបស់ឧរុវេលកស្សបឈ្មោះ នទីកស្សបនិងបិរវារបានឃើញផ្នួងសក់រាប់រយនិងគ្រឿងបរិក្ខារទាំងឡាយអណ្តែតសំពោងសំពាយតាមទឹកស្ទឹងនេរញ្ជរាក៏នាំគ្នាកើតមានសេចក្តីសង្ស័យថាក្រែងមានមហន្តរាយអ្វីបណ្តាលអោយប៉ះពាល់ដល់គណៈរបស់លោកកម្ចាស់ឧរុវេលកស្សបទើបនាំគ្នាមួយចំនួនធំមកសាកសួរ។ បន្ទាប់ពីបានធ្វើការពិភាក្សាអស់ពេលយ៉ាងយូរ ជាមួយឧរុវេលកស្សបនិងព្រះពុទ្ធមកនទីកស្សបអស់ការសង្ស័យ កើតមានសេចក្តីត្រេកអរ រួចហើយក៏លើកដៃប្រណម្យបង្គំទូលព្រះពុទ្ធថា "ខ្ញុំព្រះអង្គនាមនទីកស្សប នឹងនាំបរិវារចំនួន៣០០នាក់ មកសូមបព្វជ្ជានិងឧបសម្បទាក្នុងសំណាក់ព្រះអង្គ!"

បន្ទាប់មក ព្រះពុទ្ធបានប្រទានបព្វជ្ជានិងឧបសម្បទាដល់ជដិលបទីកស្សបនិងបរិវារទាំង៣០០រូបនោះជាឯហិភិក្ខុ នាពេលនោះឯង។

ឧរុវេលកស្សបនិងនទីកស្សប ទាំងពីរព្រះអង្គ បានមូលមតិគ្នាបញ្ជូនភិក្ខុមួយអង្គអោយទៅតាមប្អូនឈ្មោះគយាកស្សប នៅឯគយានោះ អោយមកកាន់សំណាក់ឧរុវេលកស្សប ដើម្បីជួបពិភាក្សា។ ៧ថ្ងៃក្រោមក គយាកស្សបនិងបរិវារ២០០រូបក៏សំរេចចិត្តប្រគល់កាយថ្វាយខ្លួនធ្វើជាសាវករបស់ព្រះពុទ្ធដូចបងៗដែរ។ ព្រះពុទ្ធទ្រង់ប្រទានបព្វជ្ជានិងឧបសម្បទាដល់គយាកស្សបនិងបរិវារ២០០រូបជាឯហិភិក្ខុដូចគ្នាដែរ។

កស្សបទាំងបីនាក់បងប្អូនធ្លាប់មានឈ្មោះល្បីថាជាអ្នកចេះស្រឡាញ់គ្នាណាស់ហើយចេះប្តូរយោបល់គ្នាទៀតផងនោះ ឥឡូវនេះ ក៏បានក្លាយទៅជាសាវកដ៏មានភក្តីភាព

បំផុតរបស់ព្រះសមណគោតមហើយ។

ព្រះពុទ្ធជ្រាបច្បាស់ថា ក្នុងការប្រោសពួកជដិលក៏មានការលំបាកណាស់ដែរព្រោះពួកជដិលទាំងនោះអាងថាខ្លួនគេជាសាស្តាធំ មានតបៈធម៌ មានប្រជាពលរដ្ឋគោរពរាប់អានច្រើន។ ហេតុដូច្នោះហើយ បានជាថ្ងៃមួយនៅពេលក្រោយភត្ត ព្រះអង្គសំរេចព្រះទ័យបើកអង្គសន្និបាតភិក្ខុសង្ឃមួយ នៅក្បាលកោះគយា ហើយទ្រង់លើកយកធម៌អាទិត្តបរិយាយសូត្រ (ធម៌ដែលសំអាងថារាងកាយជារបស់ក្តៅ) មកសំដែងប្រោសជដិល ១០០៣រូបនោះអោយបានយល់កាន់តែច្បាស់លាស់ឡើង។ ព្រះអង្គគង់នៅលើផ្ទាំងថ្មមួយដុំធំ ហើយទ្រង់ត្រាស់ទៅកាន់អង្គសន្និបាត ដែលមានភិក្ខុមួយពាន់បីអង្គនោះថា "ម្នាលភិក្ខុទាំងឡាយ! ធម្មជាតិទាំងអស់សុទ្ធសឹងជារបស់ក្តៅឬជាភ្លើង។ តើធម្មជាតិអ្វីខ្លះដែលជារបស់ក្តៅ? ធម្មជាតិឬរាងកាយទាំងនោះគឺ៖

-អាយតនៈខាងក្នុងទាំង៦គឺ៖ ភ្នែក១ ត្រចៀក១ ច្រមុះ១ អណ្តាត១ កាយ១ និងចិត្ត១ សុទ្ធសឹងជារបស់ក្តៅ។

-អាយតនៈខាងក្រៅទាំង៦គឺ៖ រូប១ សម្លេង១ ក្លិន១ រស់១ ផោដ្ឋព្វៈ១ និង ធម្មារម្មណ៍ ១ សុទ្ធសឹងជារបស់ក្តៅ។

-វិញ្ញាណទាំង៦គឺ៖ ចក្ខុវិញ្ញាណ (ការមើលឃើញដោយភ្នែត)១ សោតវិញ្ញាណ (ការស្តាប់ឮដោយត្រចៀក)១ ឃានវិញ្ញាណ(ការដឹងក្លិនដោយច្រមុះ)១ ជីវ្ហាវិញ្ញាណ(ការដឹងរសជាតិដោយអណ្តាត)១ កាយវិញ្ញាណ(ការស្ទាបប៉ះពាល់ដោយកាយ)១ និងបនោវិញ្ញាណ(ការពិចារណាដោយចិត្ត)១ សុទ្ធសឹងជារបស់ក្តៅ។

"ម្នាលភិក្ខុទាំងឡាយ! អារម្មណ៍នីមួយៗតែងតែឆាបឆេះទោះបីអារម្មណ៍នោះសុខក្តី ទុក្ខក្តី និងឧបេក្ខាក្តី។ បើសិនអារម្មណ៍ណាមួយកើតឡើងហើយ អារម្មណ៍នោះត្រូវតែជាប់ល័ក្ខខ័ណ្ឌជាមួយនឹងអាយតនៈខាងក្នុងទាំង៦ ខាងក្រៅទាំង៦ និងវិញ្ញាណទាំង៦នោះ។ អារម្មណ៍ទាំងឡាយនោះត្រូវតែឆេះឆាបដោយភ្លើងតណ្ហា(រាគៈ) សេចក្តីស្អប់(ទោសៈ)និងការភាន់ភាំងស្មារតី(មោហៈ)។ អារម្មណ៍ទាំងឡាយនោះត្រូវតែឆេះ ដោយភ្លើងនៃការ កើត(ជាតិ) ចាស់(ជរា) ឈឺ(ព្យាធិ) និងស្លាប់(មរណៈ)ព្រមទាំងត្រូវឆាបឆេះ



ដោយភ្លើងនៃការឈឺចិត្ត ការព្រួយបារម្ភ ការមិនសំរេចបំណងការសោកស្តាយតូចចិត្ត ការភ័យខ្លាច និងការអស់សង្ឃឹម។

"ម្នាលភិក្ខុទាំងឡាយ! ចូរកុំបណ្តោយខ្លួនរបស់អ្នកអោយធ្លាក់ទៅក្នុងភ្នក់ភ្លើងនៃតណ្ហា សេចក្តីស្អប់ និង ការភាន់ភាំងស្មារតីអោយសោះ។ ចូរពិនិត្យមើលអោយច្បាស់លើធម្មជាតិមិនទៀតទាត់ និងទាក់ទងគ្នាទៅវិញទៅមកនៃធម៌ទាំងឡាយ ដើម្បីកុំអោយខ្លួនអ្នកធ្លាក់ចុះក្នុងអន្លង់នៃការវិលកើតវិលស្លាប់មិនចេះចប់ ដែលបង្កើតឡើងដោយអាយតនៈខាងក្នុង៦ ខាងក្រៅ៦ និងវិញ្ញាណ៦នោះ។

"ម្នាលភិក្ខុទាំងឡាយ! អរិយសាវកជាអ្នកចេះដឹងប្រកបដោយសុតៈ (ការស្តាប់) កាលបានឃើញយ៉ាងនេះហើយរមែងនឿយណាយក្នុងការទទួលអារម្មណ៍កើតឡើងនៅក្នុងភ្នែកផង ក្នុងរូបទាំងឡាយដែលភ្នែកមើលឃើញផង ក្នុងចក្ខុវិញ្ញាណផងក្នុងចក្ខុសម្ផស្សផង ទោះបីជាអារម្មណ៍នោះ សុខក្តី ទុក្ខក្តី និង ឧបេក្ខាក្តី។ អរិយសាវកក៏រមែងនឿយណាយក្នុងការទទួលអារម្មណ៍ដែលកើតឡើង នៅក្នុងត្រចៀកផង សំឡេងដែលត្រចៀកស្តាប់ឮផង សោតវិញ្ញាណ សោតសម្ផស្សផង ទោះបីជាអារម្មណ៍នោះ សុខក្តិ ទុក្ខក្តិ និង ឧបេក្ខាក្តី។ អរិយសាវកក៏រមែងនឿយណាយក្នុងការទទួលអារម្មណ៍ដែលកើតឡើង នៅក្នុងច្រមុះផង ក្លិនដែលច្រមុះហិតផង ឃានវិញ្ញាណផង ឃានសម្ផស្សផង ទោះបីជាអារម្មណ៍នោះ សុខក្តី ទុក្ខក្តីនិងឧបេក្ខាក្តី។ អរិយសាវកក៏រមែងនឿយណាយក្នុងការទទួលអារម្មណ៍ដែលកើតឡើយ ក្នុងអណ្តាតផងរសដែលអណ្តាតភ្លក់ផង ជីវ្ហាវិញ្ញាណផង ជីវ្ហាសម្ផស្សផង ទោះបីជាអារម្មណ៍នោះ សុខក្តី ទុក្ខក្តី និង ឧបេក្ខាក្តី។ អរិយសាវកក៏រមែងនឿយណាយក្នុងអារម្មណ៍ដែលកើតឡើងនៅក្នុងកាយផង ផោដ្ឋព្វៈដែលកាយប៉ះពាល់ផង កាយវិញ្ញាណផង កាយសម្ផស្សផង ទោះបីជាអារម្មណ៍នោះ សុខក្តី ទុក្ខក្តី និង ឧបេក្ខាក្តី។ អរិយសាវកក៏រមែងនឿយណាយក្នុងអារម្មណ៍ដែលកើតឡើងនៅក្នុងចិត្តផង ធម្មារម្មណ៍ដែលចិត្តពិចារណាផង មនោវិញ្ញាណផង មនោសម្ផស្សផង ទោះបីជាអារម្មណ៍នោះ សុខក្តី ទុក្ខក្តី ឧបេក្ខាក្តី។ កាលបើនឿយណាយនឹងអារម្មណ៍ទាំងនោះហើយ អរិយសាវកក៏ប្រាសចាកតំរេកតណ្ហា និងមានចិត្តផុតស្រឡះអំពីការប្រកាន់នូវអារម្មណ៍នោះ។

កាលបើមានចិត្តផុតស្រឡះហើយ អរិយសាវកនោះក៏ដឹងយ៉ាងច្បាស់ដោយញាណថា កំណើតអាត្មាអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានបំពេញហើយ សោឡសកិច្ច (កិច្ច១៦យ៉ាង) អាត្មាអញបានបំពេញហើយ កិច្ចដទៃក្រៅពីនោះមិនមានឡើយ។"

ភិក្ខុទាំង១០០៣អង្គ ក៏បានផុតចាកអាសវៈធម៌ទាំងឡាយ នឹងឥតជាប់ជំពាក់ដោយឧបាទានអ្វីឡើយ។ ភិក្ខុទាំងអស់ក៏បានសំរេចនូវសោតាបត្តិផលនិងអរហត្តផលដ៏ប្រសើរថ្លៃថ្លានៅក្នុងពេលនោះឯង។

ព្រះពុទ្ធបានសំរេចព្រះទ័យស្នាក់នៅក្បាលកោះគយានោះ អស់ចំនួនបីខែទៅមុខទៀត ដើម្បីបង្ហាត់បង្រៀនភិក្ខុបួសថ្មីទាំង១០០៣អង្គនោះ។ កស្សបទាំងបីអង្គជាអ្នកជំនួយដ៏ឈ្លាសវៃបំផុតរបស់ព្រះពុទ្ធ ក្នុងការបង្ហាត់បង្រៀន និងជួយអប់រំណែនាំដល់សង្ឃគណៈទាំងមូល។

---

**សូមសមាទាន**

## ថ្វាយបង្គំព្រះរតនត្រ័យ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ប្រែថា៖ កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។

## ថ្វាយបង្គំព្រះពុទ្ធរតនៈ

យេ ច ពុទ្ធា អតិតា ច យេ ច ពុទ្ធា អនាគតា
បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា។

ប្រែថា៖ ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ដឹងជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណាដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណាដែលបានត្រាស់ដឹងជាព្រះពុទ្ធក្នុងភ័ទ្រកល្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះគ្រប់កាលទាំងពួង។



## ថ្វាយបង្គំព្រះធម្មរតនៈ

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា
បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា។

ប្រែថា៖ ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណាដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធនឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណាដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងសព្វថ្ងៃក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង។

## ថ្វាយបង្គំព្រះសង្ឃរតនៈ

យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា
បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា។

ប្រែថា៖ ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសំរេចមគ្គនិងផលក្នុងអតីតកាលក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះអង្ឃបានសំរេចមគ្គនិងផលក្នុងបច្ចុប្បន្នកាលក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង។

ពាក្យគួរចងចាំ៖

អាយតនៈខាងក្នុង៦គឺ៖ ភ្នែក១ ត្រចៀក១ ច្រមុះ១ អណ្តាត១ កាយ១ និង ចិត្ត១។
អាយតនៈខាងក្រៅ៦គឺ៖ រូប១ សម្លេង១ ក្លិន១ រស១ ផោដ្ឋព្វៈ១ និង ធម្មារម្មណ៍១។
វិញ្ញាណ៦គឺ៖ ចក្ខុវិញ្ញាណ១ សោតវិញ្ញាណ១ ឃានវិញ្ញាណ១ ជិវ្ហាវិញ្ញាណ១ កាយវិញ្ញាណ១ និង មនោវិញ្ញាណ១។
ភ្លើងទុក្ខធំ៤គឺ៖ ជាតិ១ ជរា១ ព្យាធិ១ និង មរណៈ១។
ភ្លើងកិលេស៣គឺ៖ លោភៈ១ ទោសៈ១ និង មោហៈ១។

# ជំពូកទី ១៨
# ព្រះពុទ្ធប្រោសព្រះបាទពិម្ពិសារ

កាលព្រះពុទ្ធគង់នៅក្បាលកោះគយាសីសៈសមគួរដល់ពុទ្ធអធ្យាស្រ័យហើយព្រះអង្គទ្រង់ពុទ្ធដំណើរទៅកាន់ក្រុងរាជគ្រឹះ ក្នុងដែនមគធៈ ជាមួយនឹងភិក្ខុសង្ឃទាំងមួយពាន់បីអង្គនោះ។ ថ្ងៃយាងព្រះដំណើរចេញ ព្រះពុទ្ធសក្យមុនីមានព្រះបំណងចង់យាងទៅតែមួយអង្គឯងប៉ុណ្ណោះ។ តែដោយមានការថ្វាយយោបល់អំពីឧរុវេលកស្សបថា នៅក្បាលកោះគយាសីសៈនេះតូចពេក ពុំមានលទ្ធភាពអាចឧបត្ថម្ភដល់ភិក្ខុទាំងមួយពាន់អង្គបាន ទើបព្រះពុទ្ធអនុញ្ញាតភិក្ខុសង្ឃទាំងនោះ និមន្តទៅកាន់ក្រុងរាជគ្រឹះជាមួយព្រះអង្គតែម្តង។

អស់រយៈ១០ថ្ងៃ ទើបព្រះពុទ្ធ និងភិក្ខុសង្ឃទាំងមួយពាន់បីអង្គ និមន្តទៅដល់និងគង់នៅក្នុង សប្បតិដ្ឋចេតិយដែលឋិននៅក្នុងចំការត្នោតព្រះរាជទ្រព្យនៃព្រះបាទពិម្ពិសារ ឈ្មោះ លដ្ឋិវនឧទ្យាន ចម្ងាយជាង៣គីឡូម៉ែត្រទៅខាងត្បូងទីក្រុងរាជគ្រឹះ។

ជារៀងរាល់ព្រឹក ភិក្ខុសង្ឃទាំងអស់ចេញទៅបិណ្ឌបាតតាមលំដាប់ផ្ទះអ្នកស្រុកនៅក្នុងក្រុងរាជគ្រឹះ។ ចំនួនពីរសប្តាហ៍ក្រោយមក ដំណឹងថាព្រះពុទ្ធនិងភិក្ខុមួយពាន់បីរូបស្នាក់នៅក្នុងចំការត្នោតលដ្ឋិវនឧទ្យានក៏បានលេចឮដល់ព្រះមហាក្សត្រពិម្ពិសារ។

ព្រះបាទពិម្ពិសារទ្រង់ព្រះសណ្តាប់នូវដំណឹងយ៉ាងនេះ ថាព្រះសមណគោតមដែលជាសក្យបុត្តចេញស្វែងរកធម៌នោះបានមកគង់ក្នុងសុប្បតិដ្ឋចេតិយនាចំការត្នោតលដ្ឋិវននៃខ្លួនហើយ។ ថាទ្រង់មានកិត្តិសព្ទពីរោះល្បីសុសសាយទៅគ្រប់ទិសានុទិស។ ថាទ្រង់ឆ្ងាយចាកកិលេស។ ថាទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ។ ទ្រង់មានដំណើរល្អ។ ទ្រង់ជ្រាបច្បាស់នូវត្រៃលោកហើយ។ ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង។ ទ្រង់ប្រសើរដោយសីលាទីគុណរកបុគ្គលណាមួយស្មើគ្មាន។ ទ្រង់ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន។ ទ្រង់ជាគ្រូនៃទេវតានិងមនុស្សលោក។ ទ្រង់បានត្រាស់ដឹងនូវអរិយសច្ចធម៌ និងទ្រង់លែងត្រឡប់មកកាន់ភពថ្មីទៀតហើយ។ ព្រះរាជាមិននៅព្រងើយបង្អង់ខាតពេលយូរឡើយ ស្តេចក៏នាំអស់ពួកអាចារ្យព្រាហ្មណ៍ ពួកអ្នកប្រាជ្ញបណ្ឌិតរាប់រយនាក់ និងពួកគហបតីផង ធ្វើដំណើរចូលទៅកាន់សំណាក់ព្រះពុទ្ធ។



ពេលយានរាជានៃយ្យបរចរទៅដល់ចុងចំការមួយ ព្រះមហាក្សត្រទ្រង់យាងចុះពីលើរាជរថ និងទ្រង់បានអមព្រះរាជដំណើរដោយព្រះអគ្គមហេសី វេទេហី និង ព្រះរាជបុត្រាអជាតសត្តុកុមារ ផងចូលទៅកាន់អាស្រមព្រះមានព្រះភាគ។

ពេលព្រះអង្គទទួលដំណឹងថាព្រះបាទពិម្ពិសារទ្រង់យាងមកដល់ ព្រះពុទ្ធនិងឧរុវេលកស្សបក៏និមន្តចេញទៅទទួលស្វាគមន៍ព្រះរាជានិងព្រះញាតិវង្សានុវង្ស ដោយសេចក្តីគួរសមរាក់ទាក់។ ភិក្ខុសង្ឃទាំងឡាយអង្គុយដំកង់យ៉ាងធំផ្ទាល់លើដី ដើម្បីរង់ចាំស្តាប់ព្រះពុទ្ធសំដែងធម្មទេសនា។ ព្រះពុទ្ធយាងព្រះរាជា ព្រះអគ្គមហេសី និងព្រះរាបុត្រា ព្រមទាំងភ្ញៀវទាំងអស់អោយគង់និងអង្គុយចុះ។ ព្រះបាទពិម្ពិសារបានធ្វើការណែនាំភ្ញៀវជាច្រើនរបស់ព្រះអង្គដែលព្រះអង្គចាំឈ្មោះបានបង្ហាញដល់ព្រះពុទ្ធ។ ប៉ុន្តែនៅពេលខ្លះ ព្រះរាជាសុំអោយពួកព្រាហ្មណ៍និងគហបតីម្នាក់ៗ ឡើងបង្ហាញខ្លួនដោយខ្លួនឯង។ ក្នុងចំណោមភ្ញៀវទាំងអស់នោះមានភ្ញៀវមួយចំនួនធំជាអ្នកប្រាជ្ញខាងសាសនាវេទ ដែលមកពីសាលាផ្សេងៗគ្នា។

ព្រាហ្មណ៍និងគហបតីភាគច្រើនធ្លាប់បានឮឈ្មោះឧរុវេលកស្សបពីដើមមក។ អ្នកខ្លះធ្លាប់បានជួបឧរុវេលកស្សបផ្ទាល់ទៀតផង។ ក៏ប៉ុន្តែ គ្មានព្រាហ្មណ៍ឬគហបតីណាម្នាក់ធ្លាប់បានឮនូវព្រះនាមព្រះពុទ្ធអង្គឡើយ។ ពួកគេនាំគ្នាភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលគេឃើញឧរុវេលកស្សបយកចិត្តទុកដាក់ក្នុងការបំរើព្រះពុទ្ធ ដែលជាអ្នកមានវ័យក្មេងជាង។ ពួកភ្ញៀវទាំងនោះខ្សិបខ្សៀវគ្នាពីម្នាក់ទៅម្នាក់ និងព្យាយាមត្រិះរិះថា តើសមណគោតមជាសាវក (ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌) ក្នុងសំណាក់សមណគោតម។

ដោយមើលឃើញថា ពួកព្រហ្មណ៍និងគហបតីទាំងនោះ មានការភាន់ច្រឡំឧរុវេលកស្សប ក៏តាំងក្រោកអំពីអាសនៈ ដើរចូលទៅជិតព្រះសាស្តាចារ្យ លើកចីវរដាក់លើស្មាស្តាំ ហើយក៏ក្រាបសិរសាទៀបព្រះបាទាព្រះពុទ្ធ រួចបង្គំទូលនូវពាក្យយ៉ាងច្បាស់ៗថា៖

"បពិត្រព្រះគោតមដ៏ចំរើន! ព្រះអង្គជាបុគ្គលត្រាស់ដឹងដ៏ឧត្តម ជាសាស្តាចារ្យដ៏មានតម្លៃបំផុតក្នុងលោក។ ព្រះអង្គជាគ្រូរបស់ខ្ញុំ។ ខ្ញុំជាសាវករបស់ព្រះអង្គ។"

ព្រះពុទ្ធទ្រង់យកព្រះហស្តចាប់លើកឧរុវេលកស្សបអោយងើបឈរឡើងវិញ។ រួចមកព្រះអង្គក៏ចង្អុលប្រាប់ឧរុវេលកស្សបអោយអង្គុយនៅក្នុងទីដ៏សមគួរជិតព្រះអង្គ។...

គ្មានឃើញអ្នកណាម្នាក់ក្នុងចំណោមភ្ញៀវព្រាហ្មណ៍និងគហបតីទាំងនោះខ្សិបខ្សៀវគ្នាទៀតទេ។ ផ្ទុយទៅវិញភ្ញៀវទាំងអស់នោះកាន់តែគោរព ដល់ព្រះពុទ្ធកើនឡើងថែមទៀត បន្ទាប់អំពីពួកគេបានសង្កេតឃើញភិក្ខុសង្ឃទាំងមួយពាន់បីអង្គគង់ចាំស្តាប់ធម្មទេសនារបស់ព្រះសាស្តាចារ្យ ដោយស្ងៀមស្ងាត់ និងប្រុងប្រយ័ត្នជាទីបំផុតនោះ។

ព្រះពុទ្ធទ្រង់ចាប់សំដែងនូវអនុបុព្វីកថាគឺ ៖ ទានកថា១ សីលកថា១ សគ្គកថា១ ទោសនៃការប្រព្រឹត្តកាម១ និងអានិសង្សនៃការចេញសាងផ្នួស១។ ព្រពុទ្ធទ្រង់ជ្រាបនូវទឹកចិត្តជ្រះថ្លានៃពួកព្រាហ្មណ៍ និងគហបតីទាំងនោះ ទើបទ្រង់បន្តសំដែងនូវអរិយសច្ចៈ៤ និងអរិយមគ្គៈប្រាកដដោយអង្គ៨ទៀត។ ព្រះពុទ្ធបញ្ជាក់ថាអរិយសច្ចធម៌នៃការត្រាស់ដឹងអាចនាំអោយឈ្នះទស្សនៈនៃការយល់ខុសនិងសេចក្តីទុក្ខទាំងឡាយ។ ព្រះអង្គក៏បានបញ្ជាក់អំពីការគោរពវិន័យ(សីល) អំពីការសង្រួមចិត្ត(សមាធិ) និងការខំរៀនអោយកើតមានគតិបណ្ឌិត(បញ្ញា) យ៉ាងច្បាស់លាស់ទៀតផង។ សម្លេងរបស់ព្រះពុទ្ធលាន់ឮស្រួយដូចសម្លេងរគាំង ដែលញ៉ាំងអោយភិក្ខុនិងភ្ញៀវទាំងឡាយ ត្រងត្រាប់ស្តាប់ដោយយកចិត្តទុកដាក់និងស្ងៀមស្ងាត់ជាទីបំផុត។

គ្រានោះ ព្រះនេត្រាទាំងគូរបស់ព្រះបាទពិម្ពិសារ មានពន្លឺចាំងភ្លឺផ្លេកដូចគ្រាប់ពេជ្រ។ ព្រះរាជាទ្រង់ទតឃើញ បានដល់និងបានត្រាស់ដឹងនូវអរិយសច្ចធម៌ហើយ។ ទ្រង់ឆ្លងផុតសេចក្តីមន្ទិលសង្ស័យ មិនជឿបុគ្គលឯណាក្រៅពីព្រះសាស្តាទៀតឡើយ។ ភាពញញឹមប្រិមប្រិយក្នុងក្តីសង្ឃឹម ក៏បានលេចឆ្លោឡើង នៅលើព្រះភ័ក្ត្រព្រះអង្គ។ ព្រះបាទពិម្ពិសារក៏ក្រាបបង្គំទូលនឹងព្រះមានព្រះភាគជាយ៉ាងនេះថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ពីដើម គឺកាលដែលខ្ញុំព្រះអង្គនៅជាកុមារនៅឡើយខ្ញុំព្រះអង្គមានបំណងតែ៥ យ៉ាងប៉ុណ្ណោះ។ ឥឡូវនេះ បំណងរបស់ខ្ញុំព្រះអង្គនោះក៏បានសំរេចរួចអស់ហើយ។

បំណងទី១ គឺចង់បានអភិសេកគ្រងរាជសម្បត្តិជាព្រះមហាក្សត្រ។ បំណងនេះ ខ្ញុំព្រះអង្គបានសំរេចរួចហើយ។

បំណងទី២ គឺចង់បានជួបជាមួយនឹងព្រះអរហន្តសម្មាសម្ពុទ្ធ ជាបុគ្គលត្រាស់ដឹងក្នុងជាត់នេះ។ បំណងនេះក៏ខ្ញុំព្រះអង្គបានសំរេចរួចហើយ។



បំណងទី៣ គឺចង់បានសេពគប់គោរពដឹងគុណ ចំពោះព្រះមហាសាស្តាចារ្យនោះ។ បំណងនេះទៀតក៏ខ្ញុំព្រះអង្គបានសំរេចរួចហើយ។

បំណងទី៤ គឺចង់អោយព្រះសាស្តាចារ្យនោះ ប្រៀនប្រដៅនូវអរិយសច្ចធម៌ដល់ខ្ញុំព្រះអង្គ។ បំណងនេះក៏ខ្ញុំព្រះអង្គបានសំរេចរួចហើយដែរ។

បំណងទី៥ គឺចង់បានយល់ដឹងច្បាស់លាស់ នូវធម៌របស់ព្រះសាស្តាចារ្យជាអ្នកត្រាស់ដឹងនោះ។

បពិត្រព្រះអង្គដ៏ចំរើន! បំណងទី៥ចុងក្រោយបង្អស់នេះ ខ្ញុំព្រះអង្គទើបតែនឹងបានសំរេចអម្បាញ់មិញនេះ។ ធម៌ដែលព្រះអង្គបានសំដែងហើយ ពីរោះក្បោះក្បាយនឹងច្បាស់លាស់ណាស់។ បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គសូមដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងទីរលឹក។ សូមទ្រង់ទទួលខ្ញុំព្រះអង្គជាឧបាសក ដល់នូវត្រៃសរណគមន៍ស្មើនឹងជីវិតចាប់តាំងអំពីថ្ងៃនេះតទៅ។ មិនតែប៉ុណ្ណោះសូមភិក្ខុសង្ឃទាំងឡាយដែលមានព្រះពុទ្ធជាប្រធានទទួលភត្តខ្ញុំព្រះអង្គក្នុងថ្ងៃពេញបូណ៌មីខាងមុខនេះ។"

ព្រះពុទ្ធទ្រង់ទទួលការយាងរបស់ព្រះរាជាដោយព្រះទ័យកក់ក្តៅបំផុត។

ភ្ញៀវទាំងអស់នាំគ្នាក្រោកឈរស្រែឡើង ដើម្បីសំដែងនូវអំណរគុណដល់ព្រះពុទ្ធ។ មានភ្ញៀវចំនួន២០នាក់បានសំដែងនូវសេចក្តីពេញចិត្តខ្លាំង រួចហើយក៏សូមខ្លួនធ្វើជាសាវករបស់ព្រះអង្គក្នុងពេលនោះតែម្តង។

នៅទីបញ្ចប់ ព្រះពុទ្ធនិងព្រះឧរុវេលកស្សប បានជូនព្រះរាជដំណើរព្រះរាជានិងព្រះញាតិវង្ស ព្រមទាំងភ្ញៀវរបស់ព្រះអង្គត្រឡប់ទៅវិញ រហូតដល់ផុតមាត់ព្រៃ។

ព្រះពុទ្ធជ្រាបថាមិនដល់មួយខែទៀតទេរដូវភ្លៀងនឹងត្រូវចាប់ផ្តើម។ ជាពេលដែលព្រះអង្គមិនអាចធ្វើពុទ្ធដំណើរទៅកាន់ភូមិកំណើតរបស់ព្រះអង្គ នៅឯនគរកបិលព័ស្តុវិញ ដូចដែលព្រះអង្គបានគិតទុកថានឹងទៅបង្គំគាល់ដល់ព្រះបិតា និងព្រះញាតិវង្សានុវង្ស។ ព្រះអង្គសំរេចព្រះហឫទ័យគង់ចាំព្រះវស្សា នៅក្នុងចំការត្នោតព្រះរាជទ្រព្យនៃព្រះបាទពិម្ពិសារនេះចំនួនបីខែទៀត។ ព្រះអង្គទ្រង់ព្រះតំរិះថា បន្ទាប់អំពីបីខែនេះទៅ សង្ឃគណៈ

នឹងមានកម្លាំងមាំមួន និង មានស្ថេរភាពគ្រប់គ្រាន់ដែលជាឱកាសអាចអោយព្រះអង្គយាងចេញទៅកាន់នគរកបិលពស្តុបាន។

ចំណែកព្រះបាទពិម្ពិសារ កាលបានយាងទៅដល់ព្រះរាជវាំងវិញកាលណាស្តេចទ្រង់បានបញ្ជាអោយប្រជាពលរដ្ឋរៀបចំតាក់តែងលំអរដងវិថីដោយភ្លើងចង្កៀងគោមនិងផ្កាភ្ញីភ្លីព្រោងព្រាត ដើម្បីរង់ចាំទទួលស្វាគមន៍ដល់ព្រះពុទ្ធ និងភិក្ខុសង្ឃទាំងឡាយរបស់ព្រះអង្គ។ ព្រះរាជាទ្រង់បានអញ្ជើញអស់អ្នកមុខអ្នកការនិងសមាជិករាជរដ្ឋាភិបាលគ្រប់តំណែងរួមតាំងក្រុមគ្រួសារនៃអ្នកទាំងឡាយនោះផងអោយចូលរួបរួម។ កុមារាកុមារីដែលមានអាយុ១២ឆ្នាំ ប្រហាក់ប្រហែលគ្នានឹងព្រះជន្មរបស់ព្រះរាជកុមារអជាតសត្តក៏ត្រូវបានអញ្ជើញអោយមកចូលរួមក្នុងពិធីនោះដែរ។ ជាពិសេសព្រះរាជាបានអោយគេតាក់តែងនូវខាទនីយភោជនីយាហារដែលធ្វើអំពីបន្លែនិងគ្រាប់ធុញ្ញជាតិសុទ្ធ ទុកអង្គាសដល់ព្រះពុទ្ធនិងភិក្ខុសង្ឃទាំងឡាយរបស់ព្រះអង្គ។

---

# ធម៌ទីពឹងឧត្តម

(ពុទ្ធគាថា ក្នុងរឿងអគ្គិទត្តបុរោហិត)

មនុស្សដ៏ច្រើន កាលណាមានភ័យ
តែងពឹងអាស្រ័យ ពំនឹងនានា
អ្នកខ្លះពឹងភ្នំ ខ្លះព្រៃព្រឹក្សា
ខ្លះពឹងវត្ថុអារ៉ាម ខ្លះពឹងចេតិយ។

ពំនឹងទាំងនោះ មិនបានក្សេមក្សាន្ត
មិនមែនជាឋាន ឧត្តមប្រពៃ
មិនរួចចាកទោស ទុក្ខគ្រប់វិស័យ



ព្រោះតែអាស្រ័យ ពំនឹងនោះឡើយ។

រីជនឯណា បានដល់ព្រះពុទ្ធ
ព្រះធម៌វិសុទ្ធ និងព្រះសង្ឃហើយ
ឃើញសច្ចៈបួន និព្វានជាត្រើយ
នេះហើយដោយសារ បញ្ញាប្រពៃ។

ឃើញទុក្ខឃើញហេតុ កើតឡើងនៃទុក្ខ
ឃើញនិរោធសុខ ឥតមានទុក្ខភ័យ
ឃើញមគ្គប្រកប ដោយអង្គប្រាំបី
នៃព្រះអរិយ៍ ថ្ងៃវិសេសផង។

ពំនឹងទាំងនោះ ជាទីក្សេមក្សាន្ត
ជាឧត្តមដ្ឋាន ប្រពៃកន្លង
រួចផុតចាកទោស ទុក្ខទាំងបួនកង
សុខក្រៃពេកហោង ព្រោះពំនឹងនោះ។

(ដកស្រង់ពីសៀវភៅ "ព្រះរតនត្រ័យ" របស់ព្រះភិក្ខុ និង ភេន ឥន្ទប្បញ្ញោ)

# ជំពូកទី១៩
# អគ្គសាវកបព្វជ្ជា

មួយអាទិត្យមុនថ្ងៃព្រះបាទពិម្ពិសារធ្វើបុណ្យ មានមនុស្សជាច្រើន(ភាគច្រើនជាយុវជន មានចំណេះវិជ្ជាក្នុងត្រកូលគហបតី) នាំគ្នាចូលទៅកាន់សំណាក់ព្រះពុទ្ធក្នុងចំការត្នោតព្រះរាជទ្រព្យនោះដើម្បីសូមបួសជាភិក្ខុ។ អ្នកស្រុកជាច្រើនរូបទៀតក៏សូមប្រគល់កាយថ្វាយខ្លួនធ្វើជាឧបាសក ឧបាសិកា ក្នុងព្រះត្រៃសរណគមន៍ដែរ។ ព្រះថេរភិក្ខុមាននាទីជាអ្នករៀបចំពិធីបំបួសនិងផ្តល់ការបង្ហាត់បង្រៀនជាលើកដំបូង។

ថ្ងៃមួយ ព្រះកោណ្ឌញ្ញបានប្រទានបព្វជ្ជាដល់គ្រហស្ថចំនួន៣០០រូប។ គ្រានោះ ព្រះអង្គបានសំដែងព្រះធម្មទេសនាស្តីពី រតនៈទាំង៣គឺ៖ ព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ប្រគេនភិក្ខុថ្មីទាំងនោះស្តាប់ជាយ៉ាងនេះថា៖

"ម្នាលភិក្ខុទាំងឡាយ! ព្រះពុទ្ធគឺជាមនុស្ស លោកមួយរូបដែលកើតមកអំពីមនុស្ស ដើម្បីមនុស្ស និងសព្វសត្វ។ ព្រះអង្គជាសត្វវិសេសឯក មិនមែនជាទេវតាមិនមែនជាមារ មិនមែនជាព្រហ្ម មិនមែនជាមនុស្សធម្មតា ប៉ុន្តែ ព្រះអង្គជាមនុស្សអស្ចារ្យ មានបញ្ញាលើសសព្វសត្វក្នុងត្រៃភពរកបុគ្គលណាមួយប្រៀបស្មើគ្មាន (ជាបញ្ញាពោធិញាណ)។ ព្រះអង្គជាអ្នកបានសំរេចពន្លឺត្រាស់ ដឹងនូវ ព្រះសម្មាសម្ពោធិញាណ។ ព្រះអង្គយកព្រះធម៌ដែលព្រះអង្គបានត្រាស់ដឹងនោះមកប្រើ ដើម្បីស្រោចស្រង់ដល់សត្វលោកនិងលោកធាតុទាំងមូល។ ហេតុដូច្នេះហើយបានជាព្រះពុទ្ធលោកមិនជាប់ជំពាក់ដោយការ លោភៈ ទោសៈ និង មោហៈឡើយ។ ព្រះពុទ្ធជាអ្នកបង្ហាញផ្លូវដល់យើងរាល់គ្នាក្នុងជីវិតបច្ចុប្បន្ននេះ ដើម្បីអោយយើងឈ្នះលើការភាន់ច្រឡំនឹងសេចក្តីទុក្ខសោកទាំងពួង។ មនុស្សគ្រប់រូបអាចទៅជាព្រះពុទ្ធបានអោយតែប្រតិបត្តិតាមពុទ្ធការកធម៌បានគ្រប់គ្រាន់។ ធម្មជាតិព្រះពុទ្ធ អាចមានសមត្ថភាពកំចាត់បង់និងពុះពារលើអវិជ្ជាទាំងអស់បាន។ បើយើងហាត់រៀនលើអរិយសច្ចធម៌នៃពន្លឺត្រាស់ដឹងធម្មជាតិនៃព្រះពុទ្ធនៅក្នុងខ្លួនរបស់យើង នឹងមានរស្មីភ្លឺចាំងចែងជារៀងរាល់ថ្ងៃ។ ថ្ងៃណាមួយ យើងនឹងបានទទួលយ៉ាងពេញលេញនូវពន្លឺត្រាស់ដឹង នូវសេចក្តីស្ងប់កាយស្ងប់ចិត្តនិងសុភមង្គល។ យើងត្រូវតែរកឃើញព្រះពុទ្ធ



នៅក្នុងចេះដូងរបស់យើង។ ដូច្នេះ ព្រះពុទ្ធគឺជារតនៈឬកែវដ៏មានតម្លៃទី១។

"ព្រះធម៌ គឺជាសេចក្តីពិត សេចក្តីល្អ ជាធម៌វិន័យ និងជាសិក្ខាបទ ដែលពន្យល់បញ្ជាក់អំពីការត្រាស់ដឹង។ ព្រះធម៌ជាផ្លូវនាំទៅរកពន្លឺត្រាស់ដឹង ជាផ្លូវដែលព្រះពុទ្ធ លោកបានទូន្មាននិងជាផ្លូវដែលអាចជួយយើងក្នុងការពុះពារលើគុកច្រវាក់នៃអវិជ្ជា លោភៈ ទោសៈ និង មោហៈ។ ផ្លូវដ៏ល្អនិងដ៏ពិតនេះនឹងនាំយើងទៅកាន់ការត្រាស់ដឹងសេចក្តីស្ងប់កាយស្ងប់ចិត្ត និង សុភមង្គល។ ព្រះធម៌ធ្វើអោយយើងកើតមានបញ្ញា និងសេចក្តីស្រឡាញ់។ បញ្ញានិងសេចក្តីស្រឡាញ់ គឺជាផលពីរដែលល្អប្រសើរ លើសគេបំផុតនៅក្នុងមាគ៌ានៃការត្រាស់ដឹង។ ដូច្នេះ ព្រះធម៌ គឺជារតនៈឬកែវដ៏មានតម្លៃទី២។

"ព្រះសង្ឃ គឺជាពួក ឬក្រុមអ្នកទ្រទ្រង់ភេទជាបព្វជិត ដែលជឿនិងប្រតិបត្តិតាមព្រះពុទ្ធនិងព្រះធម៌ឬជាអ្នកធ្វើដំណើររួមគ្នាក្នុងមាគ៌ានៃពន្លឺត្រាស់ដឹង។ សង្ឃក្នុងទីនេះសំដៅយកព្រះសង្ឃដែលជាសាវ័ករបស់ព្រះមានព្រះភាគ។ បើអ្នកទាំងឡាយចង់សិក្សានូវមាគ៌ានៃការត្រាស់ដឹង ចាំបាច់អ្នកត្រូវតែមានពួកឬក្រុមនៃភិក្ខុដែលហៅថា "សង្ឃ" នេះ។ ប្រសិនបើអ្នករស់នៅតែឯកឯង ការពិបាកទាំងឡាយអាចមកបង្អាក់ដំណើរដល់សេចក្តីសំរេចនៃការត្រាស់ដឹង។ ជាការសំខាន់ណាស់ បើអ្នកសំរេចចិត្តនាំគ្នាចូលបួសក្នុងសង្ឃគណៈឬ វត្ត ទោះបីអ្នកត្រូវបួសជា ភិក្ខុក្តី ជាភិក្ខុនីក្តី ជា ឧបាសក្តី ជា ឧបាសិកាក្តី។ ដូច្នេះ ព្រះសង្ឃគឺជារតនៈឬកែវដ៏មានតម្លៃទី៣។

"ម្នាលភិក្ខុទាំងឡាយ! ថ្ងៃនេះអ្នកទាំងឡាយបានសាងបព្វជ្ជាក្នុងម្លប់ព្រះមានព្រះភាគ ព្រះធម៌ និងព្រះសង្ឃ។ ដោយសារមានការជ្រោមជ្រែងអំពីសំណាក់រតនៈទាំងបីនេះ អ្នកនឹងមិនរវើរវាយឥតគោលដៅទៀតឡើយ តែអាចធ្វើអោយអ្នកមានការលូតលាស់ពិតប្រាកដ នៅលើមគ្គៈនៃពន្លឺត្រាស់ដឹង។ ក្នុងរយៈតែពីរឆ្នាំប៉ុណ្ណោះ អ្នកទាំងឡាយនឹងយល់ច្បាស់ក្នុងត្រៃសរណគមន៍។ រូបអាត្មាផ្ទាល់ធ្លាប់បានទទួលជោគជ័យនៅក្នុងរតនៈទាំង៣នេះរួចហើយ។ ថ្ងៃនេះអ្នកទាំងឡាយគួរតែប្តេជ្ញាដើរតាមមាគ៌ានេះជាមួយគ្នា។ អ្នកទាំងឡាយគួរតែទទួលអំណរចំពោះព្រះរតនៈទាំង៣ដែលអ្នកបានបព្វជ្ជានេះ។ ជាការពិតណាស់ ដែលកែវទាំង៣ដិតជាប់នៅក្នុងបេះដូងយើងរាល់គ្នាតាំងពីពេលដំបូងមកម្ល៉េះ។

យើងទាំងអស់គ្នាគួរហាត់រៀនមាគ៌ានៃពន្លឺត្រាស់ដឹងដើម្បីអនុញ្ញាតអោយរតនៈទាំង៣នេះបញ្ចេញរស្មីដ៏ភ្លឺថ្លាមកពីខាងក្នុងខ្លួនរបស់យើង។"

បន្ទាប់អំពីបានស្តាប់ពុទ្ធដីការបស់ព្រះកោណ្ឌញ្ញរួចមក ភិក្ខុទាំង៣០០រូប ក៏កើតមានសេចក្តីភ្ញៀវភ្លា និងចង់រស់នៅជាភិក្ខុជារៀងរហូត។

ក្នុងពេលនេះ ព្រះពុទ្ធទ្រង់បានទទួលសាវកថ្មីពិសេសពីររូបទៀតគឺ សារីបុត្រ និងមោគ្គល្លាន អោយចូលមកក្នុងសង្ឃគណៈ។ សារីបុត្រមាននាមដើមជា ឧបតិស្ស ជាកូននៃនាងសារីព្រាហ្មណី រស់នៅក្នុងស្រុកមួយឈ្មោះឧបតិស្ស។ រីឯមោគ្គល្លានមាននាមដើមថា កោលិត ជាកូននៃនាងមោគ្គល្លីរស់នៅក្នុងស្រុកមួយឈ្មោះកោលិតគ្រាម។ ភិក្ខុទាំងពីររូបនោះគឺជាអតិតសាវករបស់តាបសដ៏មានឈ្មោះល្បីល្បាញម្នាក់នាម សញ្ជ័យ នៅក្នុងទីក្រុងរាជគ្រឹះ។ បរិវាររបស់សញ្ជ័យហៅថាបរិព្វាជក។ សញ្ជ័យជាប្រធានដឹកនាំបរិព្វាជកចំនួន២៥០រូប។ បរិព្វាជកសារីបុត្រនិងមោគ្គល្លាន គឺជាមិត្តស្និតស្នាលនិងគ្នា។ អ្នកទាំងពីរបានប្តេជ្ញានឹងគ្នាទៅវិញទៅមកថា "យើងទាំងពីរនាក់បើអ្នកណាម្នាក់បានរកឃើញ អមតធម៌នៃពន្លឺត្រាស់ដឹងមុន អ្នកនោះគប្បីប្រាប់ម្នាក់ទៀតអោយដឹងដែរ។"

សម័យថ្ងៃមួយបរិព្វាជកសារីបុត្របានឃើញអស្សជិត្ថេរកំពុងត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ក៏គិតក្នុងចិត្តថា៖

"ឱអ្នកណាហ្ន៎ ក៏មានឥន្ទ្រីយ៍ស្រគត់ស្រគំសមរម្យនិង ព្រះភ័ក្ត្រផូរផង់ល្អអ្វីម្ល៉េះ! ប្រាកដជាជនបានដល់នូវអរហត្តមគ្គដ៏ឧត្តមហើយមើលទៅ។ អាត្មាអញគួរតែចូលទៅសួរភិក្ខុនេះអោយបានដឹងថា តើអ្នកណាទៅជាគ្រូអាចារ្យរបស់ភិក្ខុនោះ និងតើគ្រូរបស់លោកនោះបង្រៀនអំពីធម៌អ្វីដែរ?"

បរិព្វាជកសារីបុត្របង្កើនល្បឿនដើរអោយទាន់ភិក្ខុអស្សជិ ប៉ុន្តែស្រាប់តែឈប់ង៉ក់ដោយខ្លួនឯងវិញ ព្រោះមិនចង់រំខានដល់ការត្រាច់បិណ្ឌបាតយ៉ាងស្ងាត់ស្ងៀមពីផ្ទះមួយទៅផ្ទះមួយរបស់ភិក្ខុអង្គនោះ។ សារីបុត្រគិតថាគួរតែរង់ចាំរហូតដល់សមណៈនោះបិណ្ឌបាតរួចសិនទើបអាត្មាអញចូលទៅសាកសួរ។ សារីបុត្រដើរតាមពីក្រោយដោយមិនអោយភិក្ខុអស្សជិដឹងខ្លួន។ កាលបើព្រះអង្គបានទទួលចង្ហាន់ល្មមគ្រប់គ្រាន់ហើយ ភិក្ខុអស្សជិក៏រួតរះ



និមន្តត្រឡប់ទៅឯចំការត្នោតវិញ។ ក្សិណនោះ សារីបុត្រក៏ដើរចូលទៅជិតហើយលើកដៃទាំងគូថ្វាយបង្គំដោយគោរពនិងទូលសួរដោយទឹកចិត្តត្រេអរថា "បពិត្រសមណៈជាទីគោរព! ឥន្ទ្រីយ៍របស់ព្រះអង្គក៏ស្រគត់ស្រគំនឹងនល្អម្ល៉េះ។ គុណធម៌និងការយល់ដឹងរបស់ព្រះអង្គបង្ហាញអោយឃើញនៅក្នុងវង់ភ័ក្ត្រដ៏ផូរផង់ និងក្នុងកាយវិការដ៏ស្រគត់ស្រគំរបស់ព្រះអង្គ នាពេលព្រះអង្គត្រាច់បិណ្ឌបាត។ សូមព្រះអង្គមេត្តាអនុញ្ញាត អោយខ្ញុំព្រះអង្គសួរថាតើអ្នកណាទៅជាគ្រូអាចារ្យរបស់ព្រះអង្គ? តើវត្តណាដែលព្រះអង្គគង់នៅ? តើគ្រូនោះបង្រៀនធម៌អ្វីខ្លះ?"

ភិក្ខុអស្សជិ ក៏សម្លឹងមើលបរិព្វាជកសារីបុត្រដោយសុភាពរាបសារ អស់មួយស្របក់ធំ ទើបព្រះអង្គឆ្លើយតបថា៖

"ម្នាលអាវុសោ! មានមហាសមណៈមួយព្រះអង្គនាមគោតមជាសក្យបុត្រចេញចាកត្រកូលហើយសាងព្រះផ្នួស។ អាត្មាក៏បួសក្នុងសំណាក់ ព្រះមហាសមណៈនោះ។ ឥឡូវនេះ ព្រះមហាសមណៈកំពុងគង់ក្នុងសុប្បតិដ្ឋចេតិយនៅក្នុងចំការត្នោតព្រះរាជទ្រព្យនៃព្រះបាទពិម្ពិសារ។"

ភ្នែកទាំងគូរបស់សារីបុត្រចាំងភ្លឺថ្លា "តើគ្រូរបស់ព្រះអង្គបង្រៀនអំពីធម៌អ្វីដែរ? ព្រះអង្គអាចប្រាប់ខ្ញុំព្រះករុណាអោយដឹងផងបានដែឬទេ?"

ភិក្ខុអស្សជិក៏ឆ្លើយថា៖

"ម្នាលអាវុសោ! អាត្មាភិក្ខុទើបនឹងបួសថ្មីក្នុងធម៌វិន័យ។ ការបង្រៀនប្រដៅរបស់ព្រះពុទ្ធមានជម្រៅក្រៃណាស់និងគួរអោយគាប់ចិត្តផង។ អាត្មាមិនអាចសំដែងព្រះធម៌ដោយពិស្តារបានទេ ព្រះអង្គគួរតែអញ្ជើញទៅកាន់ទីនោះ និង សិក្សានូវព្រះធម៌នោះផ្ទាល់នឹងព្រះមហាសមណៈតែម្តងទៅ។"

ប៉ុន្តែសារីបុត្រអង្វរករភិក្ខុអស្សជិថា៖

"សូមព្រះអង្គមេត្តាសំដែងធម៌របស់សមណៈនោះ អោយខ្ញុំព្រះករុណាស្តាប់បន្តិចមកសូម្បីតែពីរបីមាត់ក៏ខ្ញុំអស់ចិត្តដែរ? ខ្ញុំព្រះករុណានឹងទៅរៀនព្រះធម៌នោះបន្ថែមខ្លួនឯង នៅថ្ងៃក្រោយទៀត!"

អស្សជិត្ថេរញញឹម រួចក៏ចាប់ផ្ដើមសូត្រនូវគាថាមួយវគ្គដ៏ខ្លីថា៖

"ធម៌ទាំងឡាយតែងកើតឡើងអំពីហេតុ ព្រះពុទ្ធបានពោលនូវហេតុនៃធម៌ទាំងឡាយនោះរួចហើយ។ ម្យ៉ាងវិញទៀត ធម៌ទាំងឡាយនៅតែងតែរលត់បាត់ទៅវិញជាធម្មតា។ ព្រះមហាសមណៈទ្រង់បានពោលនូវ ឧបាយ ជាគ្រឿងរលត់នៃធម៌ទាំងឡាយនោះជាប្រក្រតីហើយ។"

កាលបានស្ដាប់ ធម្មបរិយាយ នេះរួចហើយ បរិព្វាជកសារីបុត្រ ក៏កើតមានធម្មចក្ខុ គឺសោតាបត្តិមគ្គញ្ញាណ បានប្រាសចាកនូវការមន្ទិលសង្ស័យទាំងឡាយ។ សារីបុត្រក៏ថ្វាយបង្គំលាអស្សជិភិក្ខុ រួចដើរយ៉ាងលឿនទៅរកបរិព្វាជកមោគ្គល្លាន ជាសំឡាញ់។ ក្នុងពេលធ្វើដំណើរតាមផ្លូវ បរិព្វាជកសារីបុត្របានត្រិះរិះយ៉ាងនេះថា៖

"ធម៌ព្រះនិព្វានប្រាកដជាមានមែន។ បុគ្គលជាអ្នកត្រាស់ដឹងនូវព្រះនិព្វាននោះទោះបីច្រើនហ្មឺនកប្បទៀត ក៏អាត្មាអញមិនងាយបានឃើញនិងបានជួបឡើយ។"

ពេលមោគ្គល្លានក្រឡេកឃើញសារីបុត្រដើរចូលមកអំពីចម្ងាយ ប្រកដដោយទឹកមុខស្រស់ថ្លា ក៏ស្រែសួរថា៖

"មើល៍សំឡាញ់! ឥន្ទ្រីយ៍របស់អ្នកក៏ស្រស់បស់អ្វីម្ល៉េះ? អ្នកបានដឹងនូវអមតធម៌ហើយឬ? បើបានដឹងហើយតើអមតធម៌នោះដូចម្ដេចខ្លះទៅ? សូមសំឡាញ់ប្រាប់ខ្ញុំអោយបានដឹងផងមើល៍!"

បរិព្វាជកសារីបុត្របានរាប់រៀបអំពីការដែលខ្លួនបានជួបជាមួយអស្សជិត្ថេរនៅពេលកំពុងត្រាច់បិណ្ឌបាត និងសូត្រនូវគាថាមួយវគ្គដ៏ខ្លីដែលអស្សជិភិក្ខុសំដែងប្រាប់នោះ អោយបរិព្វាជកមោគ្គល្លានស្ដាប់។ កាលបរិព្វាជកមោគ្គល្លានបានស្ដាប់នូវធម្មបរិយាយនេះរួចហើយ ក៏កើតមានធម្មចក្ខុគឺសោតាបត្តិមគ្គញ្ញាណ ប្រាសចាកមន្ទិលសង្ស័យ និងគិតឃើញភ្លាមថាធម្មជាតិណាដំដោយ អោយតែកើតឡើយហើយ តែងតែវិនាលទៅវិញជាធម្មតា។ បរិព្វាជកមោគ្គល្លាក៏មើលឃើញដោយធម្មចក្ខុដែរថានិព្វានប្រាកដជាមាន។ បុគ្គលអ្នកត្រាស់ដឹងនូវព្រះនិព្វានកម្រនឹងបានជួប។ ពិភពលោកហាក់ដូចជាសំណាញ់ប្រទាក់ក្រឡាគ្នា។ នេះមានពីព្រោះនោះមាន នេះកើតពីព្រោះនោះកើត នេះគ្មានពីព្រោះនោះគ្មាន...



នេះរលត់ពីព្រោះនោះរលត់។ ជំនឿដែលថាអាទិទេពជាអ្នកបង្កើតវត្ថុទាំងអស់ក្នុងលោកក៏ត្រូវរលាយបាត់អស់ពីខ្លួនបរិព្វាជកទាំង២រូប ដោយសារតែបានយល់ដឹងច្បាស់នូវបដិច្ចសមុប្បាទធម៌នេះ។ ឥឡូវនេះបរិព្វាជកមោគ្គល្លានបានយល់ច្បាស់ដូចម្ដេចដែលបុគ្គលអាច់កាត់ទម្លុះនូវការវិលកើតវិលស្លាប់បាន។ ទ្វារនៃពន្លឺត្រាស់ដឹងក៏បើកចំហធ្លុងឡើយនៅចំពោះមុខអ្នកទាំងពីរ។

បរិព្វាជកមោគ្គល្លានពោលនឹងសារីបុត្រយ៉ាងនេះថា៖

"ម្នាលអាវុសោ! យើងត្រូវតែធ្វើដំណើរទៅកាន់សំណាក់ព្រះពុទ្ធក្នុងពេលនេះភ្លាម។ ព្រះអង្គពិតជាគ្រូអាចារ្យដែលយើងទន្ទឹងរង់ចាំជួបជាយូរមកហើយ ព្រះមហាសមណៈនេះពិតជាគ្រូរបស់យើងហើយ។"

បរិព្វាជកសារីបុត្របានយល់ព្រម ប៉ុន្តែលោករំលឹកមោគ្គល្លានថា៖

"នៃមោគ្គល្លានជាសំឡាញ់! ចុះបរិព្វាជក២៥០នាក់ទៀតនៅក្នុងគណៈ ដែលមានសេចក្ដីស្មោះត្រង់ និងទុកចិត្តយើងជារៀមច្បងតាំងពីយូរយាមកហើយនោះ តើយើងត្រូវគិតដូចម្ដេចដែរ? យើងមិនអាចបោះបង់ប្អូនៗទាំងអស់នោះបានទេ យើងត្រូវតែទៅជំរាបអ្នកទាំងអស់នោះ នូវសេចក្ដីសំរេចចិត្តរបស់យើងជាមុនសិន។"

បរិព្វាជកសារីបុត្រនិងមោគ្គល្លាន ក៏ចូលទៅកាន់សំណាក់បរិព្វាជកទាំង២៥០នាក់ហើយក៏ពន្យល់ថា៖

"ម្នាលបរិព្វាជកជាសំឡាញ់ទាំងឡាយ! យើងទាំងពីរនាក់នឹងចូលទៅកាន់សំណាក់ព្រះមហាសមណគោតមនិងសូមបួសជាសាវករបស់ព្រះអង្គផង។"

នៅពេលបរិព្វាជកទាំង២៥០រូបបានស្ដាប់ឮដូច្នេះ ក៏កើតមានសេចក្ដីអាឡោះអាល័យនិងត្រិះរិះថា គណៈនៃបរិព្វាជកនឹងមិនល្អប្រសើរទេ បើអត់អំពីបងប្រុសទាំងពីរនាក់នេះទៅ។ បន្ទាប់មក បរិព្វាជកទាំង២៥០រូបក៏សំរេចចិត្តទៅតាមបងប្រុសទាំងពីរនឹងសូមបួសជាសាវករបស់ព្រះពុទ្ធដែរ។

បរិព្វាជកសារីបុត្រនិងមោគ្គល្លានក៏បបួលគ្នាចូលទៅកាន់សំណាក់លោកម្ចាស់សញ្ជ័យនិងជំរាបនូវបំណងរបស់ខ្លួនថា៖

"បពិត្រលោកម្ចាស់ដ៏ចំរើន! យើងខ្ញុំទាំងឡាយនឹងចូលទៅកាន់សំណាក់ព្រះពុទ្ធ និងព្រះសមណៈនោះហើយជាគ្រូរបស់យើងខ្ញុំ។"

សញ្ជ័យបរិព្វាជកច្រឡោតខឹង ប៉ុន្តែបែរជាពោលអង្វរថា៖

"ម្នាលអាវុសោទាំងពីរ! មិនគួរទេ អ្នកកុំទៅអី ខ្ញុំនឹងប្រគល់តំណែងអោយអ្នកជួយដឹកនាំក្នុងគណៈ។ យើងទាំង៣នាក់នឹងរក្សាគ្រប់គ្រងគណៈនេះជាមួយគ្នា!"

សញ្ជ័យបរិព្វាជកបានពោលពាក្យយ៉ាងដូច្នេះអស់គំរប់៣ដងផង ក៏សារីបុត្រ និង មោគ្គល្លានមិនព្រមដែរ ពីព្រោះអ្នកទាំងពីរបានសំរេចចិត្តរួចស្រេចហើយ។

សារីបុត្រនិងមោគ្គល្លានបានពោលបញ្ជាក់នឹងសញ្ជ័យបរិព្វាជកថា៖

"បពិត្រលោកម្ចាស់ជាទីគោរព! យើងខ្ញុំទាំងពីរនាក់មានជំនឿលើសាសនាក្នុងគោលបំណងស្វែងរកពន្លឺត្រាស់ដឹង យើងខ្ញុំមិនចង់ធ្វើជាអ្នកដឹកនាំសាសនាទេ។ ប្រសិនបើជាយើងខ្ញុំមិនយល់ដឹងនូវមគ្គធម៌ពិតប្រាកដទេនោះ តើយើងខ្ញុំទៅដឹកនាំគេដូចម្តេចនឹងកើត? ដូច្នេះ យើងខ្ញុំត្រូវតែចូលទៅកាន់សំណាក់នៃព្រះសមណគោតមដែលជាអ្នកបានត្រាស់ដឹងនូវអរិយសច្ចធម៌ដ៏ប្រពៃនោះ ដើម្បីជួយបង្ហាញផ្លូវ។"

បរិព្វាជកសារីបុត្រនិងមោគ្គល្លានថ្វាយបង្គំលាសញ្ជ័យបរិព្វាជក ហើយបាននាំបរិព្វាជកទាំង២៥០រូបចូលទៅកាន់សុប្បតិដ្ឋចេតិយ ក្នុងចំការត្នោតព្រះរាជទ្រព្យ។

ចំណែកខាងសញ្ជ័យបរិព្វាជកវិញ មានការតូចចិត្ត និងក្តៅក្រហាយក្នុងចិត្តយ៉ាងខ្លាំងរហូតដល់ឈឺគ្រាំគ្រា និងក្អួតធ្លាក់ឈាមទៀតផង។

ពេលទ្រង់ទតឃើញសារីបុត្រនិងមោគ្គល្លាន ដើរនៅពីមុខគេចូលមកពីចម្ងាយព្រះពុទ្ធបែរព្រះភ័ក្ត្រទៅកាន់ភិក្ខុទាំងឡាយដែលអង្គុយជិតព្រះអង្គនោះ ហើយក៏ត្រាស់នូវពាក្យយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ! ជនជាសំឡាញ់នឹងគ្នាទាំងពីរនាក់ដើរមុខគេនោះម្នាក់ឈ្មោះឧបតិស្ស(សារីបុត្រ) និងម្នាក់ទៀតឈ្មោះ កោលិត(មោគ្គល្លាន) នឹងចូលមកដល់ទីនេះឥឡូវហើយ។ ទាំងពីរនាក់នេះនឹងក្លាយជា អគ្គសាវក ដ៏ប្រសើរនិងដ៏ឧត្តមរបស់តថាគត នៅក្នុងជាតិនេះ។"

កាលបរិព្វាជកទាំងអស់បានចូលទៅដល់សុប្បតិដ្ឋចេតិយនោះហើយ ក៏នាំគ្នាក្រាប



ថ្វាយបង្គំព្រះពុទ្ធដោយពោលពាក្យយ៉ាងនេះថា៖

"បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គទាំងឡាយ សូមបួសជាភិក្ខុក្នុងសំណាក់ព្រះដ៏មានព្រះភាគផង!"

ព្រះពុទ្ធទ្រង់ត្រាស់ថា៖

"ម្នាលអ្នកទាំងឡាយ! ចូរអ្នកមកជាភិក្ខុចុះ អរិយសច្ចធម៌ តថាគតសំដែងដោយល្អហើយ។ ចូរអ្នកប្រព្រឹត្តនូវព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ដែលជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។ ព្រះពុទ្ធដីកានេះហើយជាឧបសម្បទារបស់អ្នករាល់គ្នា។"

(មោគ្គល្លានត្ថេរកាលបួសបាន៧ថ្ងៃក៏បានសំរេចអរហន្តផលដោយបានស្តាប់នូវធាតុកម្មដ្ឋាន អំពីសំណាក់ព្រះពុទ្ធបរមគ្រូ នៅស្រុកកល្លវាឡគ្រាម ក្នុងដែនមគធៈ។ សារីបុត្រត្ថេរក៏បានសំរេចអរហន្តផលដោយបានស្តាប់ វេទនាបរិគ្គហសូត្រ ដែលព្រះសាស្តាចារ្យបានសំដែងប្រោស នីឃនខបរិព្វាជក ជាក្មួយរបស់លោកនៅក្នុងគុហា១ឈ្មោះ សុករខាតៈ ក្រោយពេលដែលលោកបួសបានកន្លះខែមកគឺបានសំរេចអរហន្តក្រោយព្រះមោគ្គល្លាន៧ថ្ងៃ។)

ឥឡូវនេះ ភិក្ខុសង្ឃនៅក្នុងសំណាក់ព្រះពុទ្ធកើនឡើងដល់១២៥០អង្គហើយ។

---

## សូមសមាទាន ថ្វាយបង្គំរំលឹកដល់ពុទ្ធគុណ(ទាំង១០)

ឥតិបិសោភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ
លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ភគវាតិ។

១- ឥតិបិ សោ ភគវា អរហំ ប្រែថា៖ ព្រះមានព្រះភាគអង្គនោះនាមអរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនាគឺកាយបយោគ និងវចីបយោគ។

២- សម្មាសម្ពុទ្ធោ ប្រែថា៖ ទ្រង់ព្រះមានថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាច្រដៅព្រះអង្គឡើយ។

៣- វិជ្ជាចរណសម្បន្នោ ប្រែថា៖ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គ

បរិបូណ៌ដោយ វិជ្ជា៣ វិជ្ជា៨ និងចរណៈ១៥។

៤- សុគតោ ប្រែថា៖ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរឋាន គឺអមតមហានិព្វាន។

៥- លោកវិទូ ប្រែថា៖ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក។

៦- អនុត្តរោ ប្រែថា៖ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន។

៧- បុរិសទម្មសារថិ ប្រែថា៖ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន។

៨- សត្ថាទេវមនុស្សានំ ប្រែថា៖ ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំព្រោះព្រះអង្គជាព្រះសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ។

៩- ពុទ្ធោ ប្រែថា៖ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃអោយត្រាស់ដឹងផង។

១០- ភគវា ប្រែថា៖ ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយគឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ។

## សូមសមាទាន ថ្វាយបង្គំរំលឹកដល់ធម្មគុណ

ស្វាក្ខាតោ ភគវាតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ។

១- ស្វាក្ខាតោ ភគវាតា ធម្មោ ប្រែថា៖ ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដកជាធម៌ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែងដោយប្រពៃហើយ(ធម្មាជាព្រះនព្វលោកុត្តរធម៌មាន៩ប្រការគឺ៖ មគ្គ៨៤ ផល៤និងនិព្វាន១)។

២- សន្ទិដ្ឋិកោ ប្រែថា៖ ជាធម៌ដែលព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិត ដោយបច្ចវេក្ខញាណ (មិនមែនដឹងដោយការស្តាប់ ឬជឿបុគ្គលដទៃគឺឃើញច្បាស់ដោយខ្លួនឯង)។



៣. អកាលិកោ ប្រែថា៖ ជាធម៌អោយនូវផលមិនរង់ចាំកាល គឺថាបើព្រះអរិយមគ្គៈកើងឡើង ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនយឺតយូរឡើយ។

៤. ឯហិបស្សិកោ ប្រែថា៖ ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសំរេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដ៏ទៃទៀតអោយចូលមក មើលបានផង។

៥. ឱបនយិយោ ប្រែថា៖ ជាធម៌ដែលព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា។

៦. បច្ចត្តំវេទិតព្វោវិញ្ញូហិ ប្រែថា៖ ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយមានឧគដិញ្ញុបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន។

## សូមសមាទាន ថ្វាយបង្គំរំលឹកដល់សង្ឃគុណ

សុបដិបន្នោ ភគវតោ សាវកសង្ឃោ
ឧជុបដិបន្នោ ភគវាតោ សាវកសង្ឃោ
ញាយបដិបន្នោ ភគវាតោ សាវកសង្ឃោ
សាមីចិបដិបន្នោ ភគវាតោ សាវកសង្ឃោ
យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា
ឯសភគវតោ សាវកសង្ឃោ អាហុនេយ្យោ
បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ
អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ។

១. សុបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថា៖ ព្រះសង្ឃជាសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌។

២. ឧជុបដិបន្នោ ភគវាតោ សាវកសង្ឃោ ប្រែថា៖ ព្រះសង្ឃជាសាវកនៃព្រះមានព្រះភាគលោកប្រតិបត្តិដោយត្រង់គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា។

៣. ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថា៖ ព្រះសង្ឃជាសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាឋានក្សេមផុតទុក្ខ។

៤. សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថា៖ ព្រះសង្ឃជាសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់ សាមីចិកម្ម គឺ៖ សីល សមាធិ និងបញ្ញា។

៥. យទិទំ ចត្តារិ បុរិសយុគានិ ប្រែថា៖ ព្រះសង្ឃឯណាបើរាប់ជាគូនៃបុរសទាំងឡាយមាន៤គូ គឺព្រះសង្ឃដែលបានសំរេចនូវសោតាបត្តិមគ្គៈ និសោតាបត្តិផលជាគូ១ សកិទាគាមិមគ្គនិងសកិទាគាមិផល ជាគូ១ អនាគាមិមគ្គនិងអនាគាមិផល ជាគូ១ អរហត្តមគ្គនិងអរហត្តផល ជាគូ១។

៦. អដ្ឋបុរិសបុគ្គលា ប្រែថា៖ បើរាប់ជាបុរសបុគ្គលមាន៨គឺ ព្រះសង្ឃបាននូវសោតាបត្តិមគ្គ១ សោតាបត្តិផល១ សកិទាគាមិមគ្គ១សកិទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ និងអរហត្តផល១។

៧. ឯសភគវតោ សាវកសង្ឃោ ប្រែថា៖ ព្រះសង្ឃទាំងនោះជាសង្ឃសាវក នៃព្រះមានព្រះភាគ។

៨. អាហុនេយ្យោ ប្រែថា៖ លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយចូលមកបូជា។

៩. បាហុនេយ្យោ ប្រែថា៖ លោកគួរទទួលនូវអាគន្តុកទាន គឺទានបុគ្គលតាក់តែងដើម្បីញាតិនិងមិត្រ ដែលមកអំពីទិសផ្សេងៗចូលមកបូជា។

១០. ទក្ខិណេយ្យោ ប្រែថា៖ លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម ហើយបូជា។

១១. អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ប្រែថា៖ លោកជាបុញ្ញក្ខេត្តគឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន។

---

**ចប់ភាគទី ១**



# វាចាអ្នករៀបរៀង

ខ្ញុំព្រះករុណាខ្ញុំបាទសូមថ្វាយបង្គំព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុតក្នុងលោក ហេតុដែលខ្ញុំព្រះករុណាខ្ញុំបានវាយអត្ថបទនេះដាក់បញ្ចូលក្នុងកុំព្យូទ័រពីព្រោះបានយល់ថាសៀវភៅព្រះសមណៈភោតមនេះមានអត្ថរសអត្ថប្រយោជន៍សំរាប់ជនរួមជាតិយើង និងយល់ឃើញថាមិនទាន់មានអ្នកណាបានវាយបញ្ចូលក្នុងកុំព្យូទ័រផងនោះទើបបានជាខ្ញុំព្រះករុណាខ្ញុំបានចំណាយពេលវាលាបណ្ដិចបន្តួចដែលមាន។

ខ្ញុំសូមដឹងគុណចំពោះអ្នកមានគុណទាំងពីរសូមឧទ្ទិសបុណ្យកុសលទាំងឡាយ ដែលខ្ញុំបានធ្វើសូមជួបដល់អ្នកទាំងពីរនឹងបងប្អូនខ្ញុំក្នុងជាតិនេះផងដែរ សូមជូនបុណ្យដល់ លោកអ្នកនិពន្ធ (ឆឹង ផាន់សុផុន) សូមលោកបានរួចផុតចាកទុក្ខទាំងពួង។

ខ្ញុំព្រះករុណាខ្ញុំបាទមិនបានវាយអស់អាថ៌នៅក្នុងខាងចុងសៀវនោះទេ គ្រាន់តែយកជំពូក ដែលមានទាំងស្រុងនោះតែប៉ុណ្ណោះ សូមអ្នកប្រាជ្ញបណ្ឌិតទាំងឡាយ ស្វែងរកក្នុងសៀវភៅនោះចុះ។

ភ្នំពេញថ្ងៃទី ៣ ខែវិច្ឆិកា ព.ស ២៥៥៦
ថៃ ប៊ុន ឆាយ